ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

## សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា

# សិក្សាសង្គម



នាយកដ្ឋានអប់រំកុមារតូច ព.ស ២៥៦៦ គ.ស ២០២២

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា

# សិក្សាសង្គម

នាយកដ្ឋានអប់រំកុមារតូច

ឆ្នាំ ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ១០៩៨ អយក.ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សព្វផ្សាយ សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ ១១១៩ អយក.ប្រក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានអប់រំ
- បានឃើញប្រកាសលេខ ៣០២ អយក.ប្រក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស
- តាមសំណើរបស់ក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យបោះពុម្ព «**សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា**» ដែលរៀបចំដោយក្រុមការងារបច្ចេកទេស និងកែសម្រួលកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាសាធារណៈ។


អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ប្រការ២ .-**

សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សានេះ មាន ៥(ប្រាំ) មុខវិជ្ជាគឺ៖

១- ចិត្តចលភាព

២- វិទ្យាសាស្ត្រ

៣- សិក្សាសង្គម

៤- បុរេគណិត

៥- ភាសាខ្មែរ

ខ្លឹមសារលម្អិតនៃសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល- និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអប់រំកុមារតូច ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានធានាគុណភាពអប់រំ និងគ្រប់ប្រធានអង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៨រោច ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០២២

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យរដ្ឋមន្ត្រី ក្រសួង អយក

  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង អយក
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ ៣

  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ នា.អកត អ.យ.ក

# សមាសភាពគណៈកម្មការ

## គណៈកម្មការដឹកនាំ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
២- លោកជំទាវ គឹម សេដ្ឋានី រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា
៣- លោកជំទាវ យុន រចនា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា
៤- ឯកឧត្តម ពុត សាមិត្ត អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ
៥- ឯកឧត្តម ឡៅ ឆវណ្ណា អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ
៦- ឯកឧត្តម ប្រាក់ កុសល ប្រធាននាយកដ្ឋានអប់រំកុមារតូច

## គណៈកម្មការនិពន្ធ និងរៀបរៀង

១- លោកស្រី ង៉ុយ គឹមចន្ទ័ដារី ជំនួយការបច្ចេកទេស ក្រសួងអប់រំ យុវជន និងកីឡា
២- លោកស្រី ម៉ៅ ណារី ប្រធានការិយាល័យ
៣- លោកស្រី ថាន ថាវី អនុប្រធានការិយាល័យផែនការ និងស្រាវជ្រាវ
៤- លោកស្រី កុយ វ៉ាទ្បែននី អនុប្រធានការិយាល័យផែនការ និងស្រាវជ្រាវ
៥- លោកស្រី មៀច ចិន្តាមុនី មន្ត្រីនាយកដ្ឋានអប់រំកុមារតូច
៦- លោកស្រី ផុង ស៊ីវអេង មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
៧- លោក រស់ ចាន់ដារា គ្រូឧទ្ទេសសាលមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម
៨- ក្រុមការងារបច្ចេកទេសមន្ទីរអេប់រំ យុវជន និងកីឡាខេត្ត សៀមរាប
៩- ក្រុមការងារបច្ចេកទេសមន្ទីរអេប់រំ យុវជន និងកីឡាខេត្ត ព្រះវិហារ
១០- ក្រុមការងារបច្ចេកទេសមន្ទីរអេប់រំ យុវជន និងកីឡាខេត្ត ពោធិ៍សាត់
១១- ក្រុមការងារបច្ចេកទេសមន្ទីរអេប់រំ យុវជន និងកីឡាខេត្ត កំពង់ស្ពឺ
១២- ក្រុមការងារបច្ចេកទេសមន្ទីរអេប់រំ យុវជន និងកីឡាខេត្ត កែប
១៣- អង្គការ Plan International

## គណៈកម្មការកុំព្យូទ័រ និងរចនាបថ

១- លោកស្រី វ័ន្ត ម៉ារិន ប្រធានការិយាល័យរដ្ឋបាល
២- លោក ណយ សុចិត្រា អនុប្រធានការិយាល័យរដ្ឋបាល
៣- លោក លី ចាន់ថុល អនុប្រធានការិយាល័យរដ្ឋបាល
៤- លោក ទៀង សុភាព អនុប្រធានការិយាល័យរដ្ឋបាល
៥- លោក យូ តុនី មន្ត្រីការិយាល័យរដ្ឋបាល
៦- លោក សៅ ដារ៉ុង មន្ត្រីជំនួយការបច្ចេកទេស

**គណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់**

| | | | |
|---|---|---|---|
| ១- លោកស្រី | ផ្លុង | មុនីកុសល | អនុប្រធាននាយកដ្ឋានអប់រំកុមារតូច |
| ២- លោក | ឈួន | ប៊ុនឈឿន | អនុប្រធាននាយកដ្ឋានអប់រំកុមារតូច |
| ៣- លោក | ឃិន | ធី | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា |
| ៤- លោកបណ្ឌិត | ឈូក | ច័ន្ទធាយា | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ៥- លោក | ប៉ាត់ | គឹមនីន | នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| ៦- លោកស្រី | សេង | សុខវណ្ណា | នាយិការរងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |

# មុខកថា

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែលម្អកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា ស្របទៅនឹងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស សំដៅពង្រឹងការកសាងធនធានមនុស្សប្រកបដោយសក្តានុពល ក្នុងគោលដៅឆ្ពោះទៅកាន់សង្គមពុទ្ធិ និងវិបុលភាព ជានាបាននូវកម្លាំងពលកម្ម ដែលមានចំណេះដឹង បំណិន ជំនាញវិជ្ជាជីវៈ មានវប្បធម៌ជ្រៅជ្រះ មានផលិតភាព និងភាពប្រកួតប្រជែងខ្ពស់ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចសកលភាវូបនីយកម្ម ឆ្លើយតបយ៉ាងសមស្រប និងទាន់ពេលវេលាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងសេចក្តីត្រូវការរបស់ប្រទេសជាតិ ជាពិសេសក្នុងពេលដែលកម្ពុជាបានកំណត់ចក្ខុវិស័យប្រែក្លាយពីប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបនាបច្ចុប្បន្ន ទៅជាប្រទេសដែលមានប្រាក់ចំណូលកម្រិតមធ្យមនៅឆ្នាំ២០៣០ និងក្លាយទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។

ផ្អែកលើមូលដ្ឋាននេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ជាយន្តការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា ពង្រឹងនិងលើកកម្ពស់ការបង្រៀននិងរៀន ដើម្បីបណ្ដុះសញ្ញាណ ឧបនិស្ស័យ បុគ្គលិកលក្ខណៈ និងបំណិនសតវត្សរ៍ទី២១ ដល់កុមារតូច ឱ្យប្រែក្លាយជាពលរដ្ឋពេញលេញនៅពេលអនាគត។

សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សានេះ ត្រូវបានបញ្ចូលខ្លឹមសារសំខាន់ៗទាក់ទងនឹងគរុកោសល្យ ដើម្បីឆ្លើយតបសមភាពយេនឌ័ររវាងកុមារីនិងកុមារ ដែលមានទិដ្ឋភាពគ្រប់ដណ្តប់ទាំងផ្នែកទ្រឹស្តីនៃការអប់រំកុមារតូច និងវិធីសាស្ត្រអនុវត្តការបង្រៀននិងរៀននៅគ្រប់កម្រិតមត្តេយ្យសិក្សា ក្នុងន័យអភិវឌ្ឍសមត្ថភាពកុមារតូចលើផ្នែករាងកាយ និងសុខភាព ផ្នែកសីលធម៌ និងវប្បធម៌ ផ្នែកចិត្តសង្គម និងអារម្មណ៍ ផ្នែកពិចារណា និងការយល់ដឹង និងផ្នែកភាសា ដែលជាមូលដ្ឋានគ្រឹះក្នុងការជួយកុមារតូច ឆ្ពោះទៅបន្តការសិក្សា ប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិត។

ក្រសួងអប់រំ យុវជន និងកីឡា មានសុទិដ្ឋិនិយមថា គ្រប់អង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នឹងចូលរួមសហការនិងគាំទ្រដល់ការអនុវត្តសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សានេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់កុមារតូចនៅកម្ពុជា ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា និងដៃគូអភិវឌ្ឍ ជាពិសេសអង្គការ **Plan International** ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួម និងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ដឹកនាំរៀបចំតាក់តែងសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សានេះឱ្យសម្រេចជាផ្លែផ្កាឡើងនាខណៈនេះ។

ថ្ងៃ ... ខែ ... ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# **អារម្ភកថា**

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើមូលដ្ឋានីយកម្មក្របខណ្ឌកម្មវិធិសិក្សាចាប់កម្រិតមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស និងបានដាក់ចេញវិធានជាយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា សំដៅជានាប្រសិទ្ធភាព និងគុណភាពលទ្ធផលសិក្សានៅគ្រប់កម្រិត។

ទន្ទឹមនឹងនេះ សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ត្រូវបានក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ដោយមានចូលរួមពីអង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសកិច្ចសហការគាំទ្រទាំងផ្នែកបច្ចេកទេស និងធនធានថវិកាពីអង្គការ **Plan International** រៀបចំឡើងក្នុងគោលដៅលើកកម្ពស់ស័ក្តិសិទ្ធភាព នៃដំណើរការសកម្មភាពបង្រៀននិងរៀន ឱ្យមានភាពកាន់តែប្រសើរឡើងនៅកម្រិតមត្តេយ្យសិក្សា។

សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា មាន ៥(ប្រាំ) មុខវិជ្ជាគឺ **មុខវិជ្ជាចិត្តចលភាព មុខវិជ្ជាវិទ្យាសាស្ត្រ មុខវិជ្ជាសិក្សាសង្គម មុខវិជ្ជាបុរេគណិត និងមុខវិជ្ជាភាសាខ្មែរ**។ ក្រុមការងារ បានសិក្សាប្រមូលដកស្រង់ខ្លឹមសារពីឯកសារពាក់ព័ន្ធចាំបាច់ក្នុងបរិបទប្រទេសកម្ពុជា ប្រៀបធៀបទៅនឹងបរិបទបណ្ដាប្រទេសមួយចំនួនក្នុងតំបន់ ធ្វើការបន្សុី និងសំយោគ ដើម្បីប្រែក្លាយពីទ្រឹស្ដីនៃការអប់រំកុមារតូច ទៅជាវិធីសាស្ត្របង្រៀននិងរៀនជាក់ស្តែងនៅកម្រិតមត្តេយ្យសិក្សា។ សៀវភៅសិក្សាគោលនេះ បានបង្ហាញនិងលើកឡើងពីទស្សនាទានទូទៅនៃសកម្មភាពបង្រៀននិងរៀននៅកម្រិតមត្តេយ្យសិក្សា គោលដៅសិក្សាតាមមុខវិជ្ជានីមួយៗ វិធីសាស្ត្របង្រៀននិងរៀន ការរៀបចំបរិស្ថាន សាលា/ថ្នាក់មត្តេយ្យសិក្សា និងវង្វាយតម្លៃលទ្ធផលសិក្សារបស់កុមារ ព្រមទាំងគរុកោសល្យបង្រៀននិងរៀន ដើម្បីឆ្លើយតបសមភាពយេនឌ័ររវាងកុមារីនិងកុមារានៅមត្តេយ្យសិក្សា។

ក្នុងនាមក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា យើងខ្ញុំ សូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅជូនចំពោះ**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលជាមគ្គុទេសក៍ដ៏ឆ្នើម ប្រកបដោយឆន្ទៈមុតស្រួចលើការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ និងដឹកនាំការអភិវឌ្ឍវិស័យអប់រំ ប្រកបដោយវឌ្ឍនភាពជាបន្តបន្ទាប់ក្នុងចក្ខុវិស័យវែងឆ្ងាយ។ ជាមួយនេះ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសអង្គការ **Plan International** ដែលបានគាំទ្រ និងសម្របសម្រួលការរៀបចំតាក់តែង និងអភិវឌ្ឍសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ដ៏មានសារសំខាន់នេះ រហូតសម្រេចបានជាស្ថាពរ។

**ក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ**
**និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា**

គីម សេដ្ឋានី

# មាតិកា


**ប្រកាស** ............ i
**សមាសភាពគណៈកម្មការ** ............ iii
**បុព្វកថា** ............ v
**អារម្ភកថា** ............ vi
**មាតិកា** ............ vii
**បញ្ជីរូបភាព** ............ xii
**សទ្ទានុក្រម** ............ xiii


## សេចក្ដីផ្ដើម

## ជំពូក១

## ទស្សនាទាននៃការបង្រៀន និងរៀនមុខវិជ្ជាសិក្សាសង្គម


**១.១.ទស្សនាទានទូទៅ** ............ 3
**១.២.ការវិវឌ្ឍន៍ខួរក្បាលកុមារ** ............ 7
១.២.១.គោលការណ៍បង្រៀនត្រូវជានានូវការរីកចម្រើន ............ 8
១.២.២. គោលការណ៍ជានានូវចរិតវិទ្យាសាស្ត្រគួបផ្សំ នឹងសកម្មភាពនានា ............ 8
១.២.២.១.ជានានូវចរិតវិទ្យាសាស្ត្រយ៉ាងពិតប្រាកដដល់ការបង្រៀនកុមារ ............ 8
១.២.៣. គោលការណ៍ជានានូវចរិតសមស្របតាមវ័យ ............ 8
១.២.៤. គោលការណ៍បង្រៀនជានាលក្ខណៈជាក់ស្ដែង ............ 8
១.២.៥.គោលការណ៍បង្រៀនជានានូវចរិតជាប្រព័ន្ធ និងរឹងមាំ ............ 9
១.២.៦. គោលការណ៍បង្រៀនជានានូវចរិតសកម្មម្ចាស់ការរបស់កុមារ ............ 9
១.២.៧. គោលការណ៍បង្រៀនចំពោះកុមារម្នាក់ៗ ............ 9
**១.៣. ទស្សនៈ និងរបកគំហើញក្នុងបរិបទថ្មី** ............ 9
**១.៤ បរិបទកម្ពុជា** ............ 10
១.៤.១. ការយល់ដឹងអំពីខ្លួនឯង និងគំនិតវិជ្ជមានរបស់ខ្លួនសម្រាប់កុមារតូច ............ 10
១.៤.២. ការគ្រប់គ្រងខ្លួនឯង ............ 10
**១.៥ អន្តរបញ្ញត្តិសិក្សាសង្គមសម្រាប់កុមារ** ............ 11
១.៥.១. ការយល់ដឹងពីសង្គម ............ 11
១.៥.២ ការគ្រប់គ្រងទំនាក់ទំនង ............ 11
១.៥.៣ .ការសម្រេចចិត្តប្រកបដោយការទទួលខុសត្រូវ ............ 12
**១.៦ អន្តរកម្មគ្រប់ជ្រុងជ្រោយសម្រាប់កុមារ** ............ 12


## ជំពូក២

## គោលដៅសិក្សា នៃមុខវិជ្ជាសិក្សាសង្គម


**២.១- ក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពរបស់កុមារ** ............ 13
២.១.១- គោលដៅសិក្សាទី១៖ ការលើកតម្កើងវប្បធម៌របស់ខ្លួន ............ 14

២.១.២- គោលដៅសិក្សាទី២៖ ស្គាល់ពីអត្តសញ្ញាណរបស់ខ្លួន ...................................14
២.១.៣. គោលដៅសិក្សាទី៣៖ ការយល់ដឹងពីតម្លៃនិងចរិតលក្ខណៈមនុស្ស...........................14
២.១.៤. គោលដៅសិក្សាទី៤៖ ការពេញចិត្តចំពោះលក្ខណៈផ្សេងគ្នារបស់បុគ្គល ..................15
២.១.៥.គោលដៅសិក្សាទី៥៖ បំណិនរស់នៅក្នុងសង្គមនិងទំនាក់ទំនងវិជ្ជមានជាមួយមនុស្សជុំវិញ...............................................................................................15
២.១.៦ គោលដៅសិក្សាទី៦៖ បំណិនក្នុងការគិត និងដោះស្រាយរាល់បញ្ហា ........................16
២.១.៧.គោលដៅសិក្សាទី៧៖ ការយល់ដឹងអំពីទង្វើ និងលទ្ធផល...........................................16
២.១.៨.គោលដៅសិក្សាទី៨៖ ការយល់ដឹងពីអារម្មណ៍ខ្លួនឯង និងអ្នកដទៃ ..........................16
២.១.៩.គោលដៅសិក្សាទី៩៖ ការចេះទប់អារម្មណ៍ និងសម្តែងអារម្មណ៍ល្អៗ .........................17
២.១.១០. គោលដៅសិក្សាទី១០៖ យល់ដឹងអំពីបរិស្ថានធម្មជាតិ និងវិធីការពារ ....................17
២.១.១១.គោលដៅសិក្សាទី១១៖យល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើនរូបភាព..................................................................................................17
២.១.១២. គោលដៅសិក្សាទី១២ .ចំណេះដឹងបច្ចេកទេស ចលនា ការច្នៃប្រឌិត និងបទពិសោធន៍ផ្នែកតន្ត្រី ..............................................................................18
**២.២.ការផ្សារភ្ជាប់ទៅនឹងបរិបទវិទ្យាសាស្ត្រ** ...................................................18
២.២.១.ជានាលក្ខណៈអប់រំ.............................................................................18
២.២.២ ជានាលក្ខណៈគរុកោសល្យ....................................................................18
**២.៣.ការបណ្តុះស្មារតីកុមារ**...........................................................................19

## ជំពូក៣
## វិធីសាស្ត្រអនុវត្តការបង្រៀន និងរៀនមុខវិជ្ជាសិក្សាសង្គម

**៣.១. ប្រធានបទ/មុខវិជ្ជាសិក្សាសង្គមនៅកម្រិតមត្តេយ្យសិក្សា** ..............................20
**៣.២.វិធីសាស្ត្របង្រៀនសិក្សាសង្គមនៅមត្តេយ្យសិក្សាមាន** ....................................20
**៣.៣.ការគ្រប់គ្រងដំណើរការបង្រៀននិងរៀន**.....................................................23
៣.៣.១. លំនាំបង្រៀនសកម្មគោលមុខវិជ្ជាសិក្សាសង្គម .............................................23
៣.៣.១.១. លំនាំបង្រៀនសកម្មភាពប្រចាំថ្ងៃ និងទម្លាប់ល្អ .............................................24
៣.៣.១.២. លំនាំបង្រៀន ល្បែង..........................................................................25
៣.៣.១.៣. លំនាំបង្រៀន ចម្រៀង តន្ត្រី របាំ.......................................................25
៣.៣.១.៤. លំនាំបង្រៀន គំនូរ ..........................................................................27
៣.៣.១.៥. លំនាំបង្រៀន សកម្មភាពកសាង..........................................................28
៣.៣.២. ការអនុវត្ត.................................................................................30
៣.៣.១.១.របៀបអនុវត្តសកម្មភាពប្រចាំថ្ងៃ..........................................................30
៣.៣.១.២. ការអនុវត្តល្បែងសិក្សា ......................................................................30
៣.៣.១.៣.ការអនុវត្តល្បែងសេរី...........................................................................31
៣.៣.១.៤. ការអនុវត្តចម្រៀង តន្ត្រី និងរបាំ.........................................................32
៣.៣.១.៥.ការហ្វឹកហាត់កុមារច្រៀងចម្រៀង...........................................................33
៣.៣.១.៦. ការអនុវត្តសកម្មភាពគំនូរ...................................................................34

៣.៣.១.៧. ការអនុវត្តសកម្មភាពកសាង ....................................................40
**៣.៤ ដំណើរការបង្រៀន** ....................................................43
៣.៤.១ ប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពប្រចាំថ្ងៃ និងទម្លាប់ល្អ ....................................................43
៣.៤.២ ប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពល្បែង ....................................................44
៣.៤.៣ ប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពតន្ត្រី ចម្រៀងនិងរបាំ ....................................................44
៣.៤.៤ ប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពកសាង ....................................................47
៣.៤.៥ ប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពគំនូរ ....................................................47

## ជំពូក៤

## ការរៀបចំបរិស្ថានសិក្សា នៃមុខវិជ្ជាសិក្សាសង្គម

**៤.១-យន្តការអនុវត្ត** ....................................................48
៤.១.១ ផ្នែកសង្គមនិងអារម្មណ៍ ....................................................48
៤.១.២.ការបង្កើតបរិយាកាសរៀនសូត្រប្រកបដោយភាពកក់ក្ដៅនិងបែបវិជ្ជមាន ....................................................48
៤.១.៣. រៀបចំបរិស្ថានដែលជួយដល់ការអភិវឌ្ឍរាងកាយ ....................................................48
**៤.២. គម្រូវការធនធានសម្ភារៈរូបវ័ន្តសិក្សា** ....................................................49
៤.២.១. ការរៀបចំ និងជ្រើសរើសធនធាន(មនុស្ស សម្ភារៈ បទពិសោធន៍) ....................................................49
៤.២.២. ការជំរុញ និងគោរពបរិស្ថាន ....................................................50
**៤.៣.ការស្វែងរកការគាំទ្រផ្សេងៗ** ....................................................50
៤.៣.១ សោភ័ណភាពនិងការបង្កើតថ្មី ....................................................50
៤.៣.២ ការរៀបចំបរិស្ថានដែលជួយដល់ការអភិវឌ្ឍរាងកាយ ....................................................50
៤.៣.៣. ការរៀបចំនិងជ្រើសរើសធនធាន ....................................................51
៤.៣.៤. ដំណាក់កាលនៃការអភិវឌ្ឍផ្នែកសិល្បៈ ....................................................51
៤.៣.៥. ជាតុផ្សំសំខាន់នៃសិល្បៈសម្រាប់កុមារ ....................................................52
៤.៣.៥.១.គំនូសមូលដ្ឋាន ....................................................53
៤.៣.៥.១.ពណ៌ ....................................................53
៤.៣.៥.៣.រាង ....................................................54
សម្ភារៈសម្រាប់គំនូរ ....................................................54
៤.៣.៦. ដំណាក់កាលនៃការអភិវឌ្ឍផ្នែកតន្ត្រី និងកាយវិការ ....................................................55
ដំណាក់កាលសកម្ម ....................................................55
ដំណាក់កាលរូបតំណាង (ផ្អែកលើរូបភាព) ....................................................55
៤.៣.៧.ធាតុសំខាន់នៃតន្ត្រីសម្រាប់កុមារតូច ....................................................56
ចង្វាក់ ....................................................57
ចំណុចរណ្ដំនៃតន្ត្រី (ចំណុចខ្ពស់ ទាប នៃតន្ត្រី) ....................................................57
៤.៣.៨ ការអភិវឌ្ឍផ្នែកសង្គមអារម្មណ៍ ....................................................58
៤.៣.៩.រៀបចំ ឥរិយាបថបែបវិជ្ជមាន ....................................................58
៤.៣.១០.អនុវត្តសកម្មភាពល្ខោន និងសម្ដែងតួ ....................................................58
៤.៣.១១.រៀបចំសកម្មភាពជាទម្លាប់ និងផ្លាស់ប្ដូរជាដំណាក់ៗ ....................................................59

៤.៣.១២.បញ្ជ្រាបសកម្មភាពសិក្សាសង្គមទៅក្នុងសកម្មភាពរៀនពេញមួយថ្ងៃ ....................59
៤.៣.១៣.រៀបចំសកម្មភាពកុមារជាក្រុមតូចៗ ....................60
៤.៣.១៤. ប្រើប្រាស់រឿងនិទាន ចង្វាក់ភ្លេង ចម្រៀង និងអាយ៉ង ....................60
៤.៣.១៥. សហការជាមួយគ្រួសារកុមារ ....................60
**៤.៤. ផ្នែកសោភ័ណភាពនិងការបង្កើតថ្មី** ....................61
៤.៤.១ យុទ្ធវិធីសម្រាប់សិល្បៈ ....................61
៤.៤.២ ការអនុវត្តគម្រោងសិក្សា ....................62
៤.៤.៣.ការប្រើរំញោច ....................62
៤.៤.៤.ការប្រើស្នាដៃសិល្បៈ ....................62
៤.៤.៥.ការផ្តល់សម្ភារៈសិល្បៈសំបូរបែប ....................62
**៤.៥ យុទ្ធវិធីបង្រៀនតន្ត្រីនិងចលនា** ....................62
៤.៥.១ ការប្រើតន្ត្រីរបាំនិងប្រភពសំឡេងផ្សេងៗគ្នា ....................63
៤.៥.២.ការប្រើចង្វាក់ស្រែកនិងចម្រៀង ....................63
៤.៥.៣. ការប្រើប្រាស់ចលនា និងលេងល្បែងជាមួយតន្ត្រី ....................64
៤.៥.៤.ការប្រើប្រាស់រាងកាយនិងឧបករណ៍តន្ត្រី ....................64
៤.៥.៥. ការប្រើល្ខោនអាយ៉ង ....................65
៤.៥.៦. ធ្វើឱ្យតន្ត្រីក្លាយជាផ្នែកសំខាន់មួយនៃទម្លាប់និងដំណើរផ្លាស់ប្តូរ ....................65
៤.៥.៧ យុទ្ធសាស្ត្រផ្សេងទៀតសម្រាប់សោភ័ណភាពនិងការបញ្ចេញមតិច្នៃប្រឌិត ....................65

**ជំពូក៥**

**ការពិនិត្យតាមដាន និងវាយតម្លៃ**

**៥.១- ចំពោះគ្រូ** ....................67
៥.១.១. វាយតម្លៃក្នុងដំណើរការសិក្សា ....................67
៥.១.២. វាយតម្លៃសរុប ....................67
**៥.២- ចំពោះកុមារ** ....................69
៥.២.១ ការវាយតម្លៃលទ្ធផលសិក្សាប្រចាំថ្ងៃ ....................69
៥.២.២ ការវាយតម្លៃលទ្ធផលសិក្សាប្រចាំត្រីមាស ....................70
៥.២.៣ ការវាយតម្លៃលទ្ធផលសិក្សាប្រចាំឆ្នាំ ....................70
**ឧបសម្ព័ន្ធទី ១ ផ្នែកខ្លឹមសារអត្ថបទ** ....................71
**ផ្នែកទី១ ការអនុវត្តសកម្មភាពគោលដែលជំនួយដល់ដំណើរការបង្រៀន និងរៀន** ....................71
១- រឿងនិទាន « បាយ១ពំនូត » ....................71
២- រឿងនិទាន ប្រវត្តិបុណ្យអុំទូក ....................72
៣- រឿងនិទាន ស្វាកាន់ខ្មៅដៃ ....................73
៤- រឿងនិទាន គ្រួសារខ្ញុំ ....................73
៥-រឿងនិទាន ការអត់ឱន ....................74
៦- រឿងនិទាន កុមារីក្លាហាន ....................75

៧-រឿងនិទាន ចូលឆ្នាំខ្មែរ....................................................................76
៨-រឿងនិទាន កូនប្អូននាក់មិនបម្រើឪពុក....................................................77
៩-រឿងនិទាន ហ្វូងដំរី ..........................................................................78
១០-រឿងនិទាន ដើរលេងតាមសួន ...........................................................78
១១-រឿងនិទាន កូនទារូបអាក្រក់ .............................................................79
១២-រឿងនិទាន បុណ្យភ្ជុំបិណ្ឌ ................................................................79
១៣-រឿងនិទាន ពិធីបុណ្យវិសាខបូជា .......................................................80
១៤.ទិវាកុមារអន្តរជាតិ ១មិថុនា ...............................................................81
១៥.ពិធីបុណ្យឯករាជ្យជាតិ .......................................................................82
១៦.សង្កេត « ទង់ជាតិកម្ពុជា »..................................................................84
១៧.សន្ទនា « ឧបករណ៍តន្ត្រីខ្មែរ »...........................................................84
១៨.ល្បែងជម្រាបសួរ...............................................................................85
១៩.កំណាព្យ...........................................................................................86
២០.ចម្រៀង............................................................................................86
**ផ្នែកទី២ ការអនុវត្តសកម្មភាពគោលសម្រាប់ដំណើរការបង្រៀន និងរៀនពេញមួយម៉ោងសិក្សា**........................................................................87
១.តារាងសកម្មភាពប្រចាំថ្ងៃ.......................................................................87
២.ការអនុវត្តល្បែងសិក្សា ..........................................................................89
៣. គំនូសមូលដ្ឋាន.................................................................................101
៤.ការបត់.............................................................................................103
៥.ការសូន្យ ..........................................................................................108
៦.ការតំរៀបស្លឹកឈើ ជារូបសត្វ ...............................................................110
**ឧបសម្ព័ន្ធទី ២ គរុកោសល្យរៀន និងបង្រៀនដើម្បីឆ្លើយតបសមភាពយេនឌ័រ រវាងកុមារី និងកុមារានៅមត្តេយ្យសិក្សា** ....................................................131
**ឯកសារពិគ្រោះ** ................................................................................143

# បញ្ជីរូបភាព


រូបភាពទី 1៖ ការអភិវឌ្ឍខួរក្បាលកុមារក្នុងកំឡុងពេល ១០០០ថ្ងៃដំបូង ....................................7
រូបភាពទី 2៖គំនូរតុបតែងលម្អ ស៊ុមរូបផ្កា ....................................37
រូបភាពទី 3៖ គំនូរតុបតែងលំអដោយពណ៌ ថ្នាក់ទាប ....................................38
រូបភាពទី 4៖ គំនូរតុបតែងលម្អដោយប្រើពណ៌សេរី....................................38
រូបភាពទី 5៖ គំនូរផ្តាម ....................................39
រូបភាពទី 6៖ ការបត់....................................41
រូបភាពទី 7៖ បត់រូបកែវ ....................................41
រូបភាពទី 8៖ សម្ភាររូបវន្តសិក្សា....................................50
រូបភាពទី 9៖ គំនូសមូលដ្ឋាន ....................................53
រូបភាពទី 10៖ ពណ៌ ....................................53
រូបភាពទី 11៖ រាង ....................................54
រូបភាពទី 12៖ សម្ភារៈសម្រាប់គំនូរ ....................................54
រូបភាពទី 13៖ ពិធីបុណ្យវិសាខបូជា ....................................81
រូបភាពទី 14៖ ទិវាកុមារអន្តរជាតិ ១មិថុនា....................................82
រូបភាពទី 15៖ ពិធីបុណ្យឯករាជ្យជាតិ....................................83
រូបភាពទី 16៖ ទង់ជាតិកម្ពុជា ....................................84
រូបភាពទី 17៖ ឧបករណ៍តន្ត្រីខ្មែរ....................................85
រូបភាពទី 18៖ តារាងថ្ងៃប្រចាំសប្តាហ៍ ....................................88
រូបភាពទី 19៖ ល្បែង ទាយអារម្មណ៍របស់ខ្ញុំ....................................91
រូបភាពទី 20៖ គំនូស  តំណក់ទឹកភ្លៀង ....................................101
រូបភាពទី 21៖ គំនូសកោង ....................................101
រូបភាពទី 22៖ គំនូស ខ្សែកោងលើក្អម....................................101
រូបភាពទី 23៖ គំនូស ខ្សែកោងលើបាល់ ....................................102
រូបភាពទី 24៖ គំនូស កាំជណ្តើរ....................................102
រូបភាពទី 25៖ ការបត់ធ្វើផ្សិត ....................................103
រូបភាពទី 26៖ បត់ធ្វើយន្តហោះ ....................................104
រូបភាពទី 27៖ បត់ធ្វើបង្កង....................................105
រូបភាពទី 28៖ បត់ធ្វើសត្វឆ្កែ ....................................106
រូបភាពទី 29៖ បត់ធ្វើដើមស្រស់....................................107
រូបភាពទី 30៖ បត់ធ្វើសត្វកណ្តូប ....................................108
រូបភាពទី 31៖ សូន្យដីធ្វើខ្យង....................................109
រូបភាពទី 32៖ សូនដីធ្វើក្តាម ....................................109
រូបភាពទី 33៖ ផ្តុំស្លឹងឈើ ធ្វើជាទន្សាយ ....................................110
រូបភាពទី 34៖ តម្រៀបគ្រាប់សណ្តែក អង្ករ ជារូបត្រី....................................111

# សទ្ទានុក្រម

១.ឥន្ទ្រីយ៍ចលករ ៖ ការសម្តែងចេញនូវចលនាជាសកម្មភាពមួយ ដែលសរីរាង្គវិញ្ញាណបានចាប់អារម្មណ៍។ ឧៈភ្នែកមើលឃើញ និងនិយាយថាអាវក្រហម។

២.បុរេប្រតិបត្តិ ៖ ការចាប់ផ្តើមអនុវត្តសកម្មភាពងាយៗដំបូង ដែលជាមូលដ្ឋានគ្រឹះឈានទៅអនុវត្តសកម្មភាពរួមមួយ ។ឧៈល្បែង«យើងធ្វើផ្លូវដើរ» កុមារប្រើមេដៃ និងចង្អុលដៃចាប់គ្រាប់ក្រួសតម្រៀបលើផ្លូវដើរដើម្បីពង្រឹងចលនាម្រាមដៃមុននឹងចាប់កាន់ ខ្មៅដៃគូសគំនូរមូលដ្ឋាន។

៣.មជ្ឈត្តនិយម ៖ ការតាំងខ្លួនជាអ្នកមានឥទ្ធិពល ដែលមនុស្សជុំវិញខ្លួនត្រូវតែបំពេញតាមតម្រូវការរបស់ខ្លួនគ្រប់បែបយ៉ាង។

៤.អន្តរសកម្មសង្គម ៖ ការតាំងខ្លួនជាកណ្តាលរវាងមនុស្សជុំវិញក្នុងការផ្តល់ ទទួលព័ត៌មាន និងឆ្លើយតបសកម្មភាពចុះឡើងដើម្បីសម្រេចគោលដៅមួយ។

៥.ប្រតិបត្តិរៀបរយ ៖ ការអនុវត្តតាមលំដាប់លំដោយនៃសកម្មភាពមួយប្រកបដោយជោគជ័យ។

៦.ភ្លោច ៖ សំដៅដល់ប្រព័ន្ធប្រសាទទាំងមូលដែលប្រតិកម្មភ្លាមទៅរកទិសនៃរំញោច។

៧.អន្តរបញ្ញត្តិ ៖ សេចក្តីដែលរៀបចំបានទ្រឹស្តីមួយពោរពេញដោយខ្លឹមសារទំនាក់ទំនងគ្នារវាងខ្លឹមសារទៅខ្លឹមសារផ្សេងៗដែលអាចជួយឱ្យសម្រេចបានគោលដៅ។

# សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡាបាននឹងកំពុងធ្វើការកំណែទម្រង់វិស័យអប់រំស៊ីជម្រៅសំដៅលើកកម្ពស់គុណភាពលទ្ធផលសិក្សារបស់សិស្សគ្រប់កម្រិត ក្នុងនោះ ក្រសួងបានធ្វើការកែលម្អកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា ដោយការផ្សារភ្ជាប់ខ្លឹមសារទៅនឹងកម្មវិធីសិក្សាចំណោះទូទៅ និងការអប់រំបច្ចេកទេស ក្នុងន័យធានាការបណ្តុះសញ្ញាណឧបនិស្ស័យបុគ្គលិកលក្ខណៈ និងបំណិន សតវត្សរ៍ទី២១ចាប់កម្រិតមត្តេយ្យសិក្សាឡើងទៅ។

ដើម្បីធានាប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្រសួងអប់រំ យុវជន និងកីឡាបានកសាងសៀវភៅសិក្សាគោលសម្រាប់មុខវិជ្ជាទាំង៥ ក្នុងនោះសៀវភៅសិក្សាគោលមុខវិជ្ជាសិក្សាសង្គមសម្រាប់មត្តេយ្យសិក្សា បានបង្ហាញនូវគោលបំណងអភិវឌ្ឍសមត្ថភាពកុមារឱ្យមាន៖

- បំណិនសង្កេត ពិនិត្យ បង្កើតរូបារម្មណ៍ ច្នៃប្រឌិត បង្កើតសិល្បៈនៃការគូរគំនូរងាយៗ និងសកម្មភាពកសាង
- ការយល់ដឹងពីហេតុនិងផល មានការគិតនិងវិភាគគ្រប់ជ្រុងជ្រោយ ការសម្តែងអារម្មណ៍ និងចេះសង្កត់ចិត្តរបស់ខ្លួន មានគោលវិធីជាវិជ្ជមាន និងមានជំហរដើម្បីដោះស្រាយបញ្ហា
- សញ្ចេតនាស្រឡាញ់ និងចូលរួមថែរក្សាសិល្បៈវប្បធម៌ ទំនៀមទម្លាប់ប្រពៃណី និងសោភ័ណ
- ការគោរពពេលវេលាបានទៀងទាត់ មានសេចក្តីអំណត់ តស៊ូព្យាយាម ម្ចាស់ការ ការទទួលខុសត្រូវ និងធ្វើកិច្ចការផ្ទាល់ខ្លួនឱ្យរួចជាស្ថាបពរចេះធ្វើការរួមគ្នាចេះផ្តល់ព័ត៌មាន មានទម្លាប់ល្អក្នុងការរស់នៅប្រចាំថ្ងៃនិងរួមរស់នៅជា សមូហភាពប្រកបដោយភាពសុខដុម។

មុខវិជ្ជាសិក្សាសង្គម មានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍអារម្មណ៍វិជ្ជមានរបស់កុមារឱ្យមានទម្លាប់រស់នៅល្អចេះសម្របខ្លួនឱ្យចុះសម្រុងក្នុងទំនាក់ទំនងជាមួយមិត្តភក្តិ ក្រុមគ្រួសារ សហគមន៍ និងសង្គមជាតិដោយចាប់ផ្តើមពីការយល់ដឹងអត្តសញ្ញាណផ្ទាល់ខ្លួន និងមានសមត្ថភាពការគ្រប់គ្រងអារម្មណ៍និងអាកប្បកិរិយាផ្ទាល់ខ្លួន ទទួលខុសត្រូវប្រាស្រ័យទាក់ទងគ្នា និងកសាងទំនាក់ទំនងជាមួយអ្នកដទៃ។ កត្តាទាំងអស់នេះ បានជួយកុមារកាន់តែល្អប្រសើរឡើងក្នុងការស្វែងយល់ពីខ្លួនឯងពីអ្នកដទៃ ហើយរៀនគោរព និងទទួលយកនូវស្ថានភាពប្លែកៗពីអ្នកដទៃដែល នឹងត្រូវកសាងទំនាក់ទំនងវិជ្ជមាន ជាមួយអ្នកដទៃ។

ដូច្នេះគ្រូមត្តេយ្យសិក្សាត្រូវផ្តល់ការគាំទ្រ និងបង្កើតបរិយាកាសឱ្យកុមារមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការស្វែងរកអ្នកដែលមានទំនុកចិត្តដើម្បីបង្ហាញនូវអារម្មណ៍មានដូចជាខឹងភ័យខ្លាចជាដើម។

ការអភិវឌ្ឍជំនាញសង្គម និងអារម្មណ៍ គឺជាដំណើរការរំពុកឡើងវិញដល់គ្រូបង្រៀនឱ្យរៀបចំសកម្មភាពបង្រៀនកុមារដោយប្រុងប្រយ័ត្ន តាមរយៈការសន្ទនាបទពិសោធន៍ប្រចាំថ្ងៃ និងការលេងរបស់កុមារនៅសាលាមត្តេយ្យសិក្សា។ គ្រូបង្រៀនត្រូវកំណត់និងប្រើពេលវេលាមកបង្រៀនកុមារឱ្យចេះគ្រប់គ្រងអារម្មណ៍ចិត្តគំនិតនិងឥរិយាបថនៅក្នុងហេតុការណ៍មួយសមស្រប។ លើសពីនេះមុខវិជ្ជាសិក្សាសង្គមបានដើរតួនាទីជួយលើកកម្ពស់ប្រសិទ្ធភាព នៃការអនុវត្តសកម្មភាពគោលផ្សេងៗដែលមានខ្លឹមសារទាក់ទងនឹងមុខវិជ្ជាផ្សេងទៀត។

ដូច្នេះអ្នកអនុវត្តការងារអប់រំកុមារតូចត្រូវឈ្លាសវៃប្រើប្រាស់បទពិសោធន៍ផ្ទាល់ខ្លួនគួបផ្សំជាមួយនឹងចំណេះដឹងក្នុងឯកសារជំនួយផ្សេងៗ មកច្នៃប្រឌិតរៀបចំបរិស្ថានសិក្សារបស់កុមារឱ្យជាទីមេត្រីធានាបានប្រសិទ្ធភាពលើការផ្តល់ចំណេះដឹងថ្មីដែលមានទំនាក់ទំនងគ្នាជាលក្ខណៈប្រព័ន្ធ និងផ្សារភ្ជាប់សមត្ថភាព

មានស្រាប់របស់កុមារ សំដៅជួយកុមារតូចឱ្យអភិវឌ្ឍបុគ្គលិកលក្ខណៈពេញបរិបូរណ៍ប្រកបដោយគុណភាព នូវចតុស្តម្ភ ដ៏រឹងមាំ លើវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងការចេះរួមរស់នៅជាមួយគ្នាដោយភាពសុខដុម និងត្រៀមខ្លួនរួចជាស្រេចក្នុងការចូលរៀនថ្នាក់ទី១ នៅសាលាបឋមសិក្សា។

មុខវិជ្ជាសិក្សាសង្គម បានពង្រីកតួនាទីអប់រំផ្តល់នូវគុណភាពជីវិតឱ្យកុមារតូចចាប់ពីមត្តេយ្យសិក្សា ហូតដល់ការត្រៀមខ្លួនចូលរៀននៅតាមភូមិសិក្សា និងការត្រៀមខ្លួនបន្តបន្ទាប់ទៅថ្ងៃអនាគតនឹងក្លាយជាធនធានមនុស្សរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ។ វិសាលភាពនេះនឹងប្រព្រឹត្តទៅមានប្រសិទ្ធភាព អាស្រ័យដោយសេវាអប់រំកុមារតូចគ្រប់រូបភាពគ្រប់ភូមិសិក្សា សហការជិតស្និទ្ធបំពេញការងារតាមតួនាទីភារកិច្ចប្រកបដោយសីល្បវិធីនិងសុខដុមរមនាដើម្បីឧត្តមប្រយោជន៍របស់កុមារ ។

## ១.គោលបំណង

សិក្សាសង្គម គឺជាបណ្តុំមុខវិជ្ជាសង្គមសាស្ត្រ និងមនុស្សសាស្ត្រ។ មុខវិជ្ជាសិក្សាសង្គមមានគោលបំណងពង្រឹង និងពង្រីកសមត្ថភាពរបស់ប្រជាពលរដ្ឋ ដោយការសិក្សាអំពីទ្រឹស្តី និងការអនុវត្តពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់វប្បធម៌ ទំនៀមទម្លាប់ សាសនា បរិស្ថានធម្មជាតិ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ច្បាប់ និងនយោបាយជាតិ ជាពិសេស ផ្នែកសិលធម៌ពលរដ្ឋវិជ្ជា គេហវិទ្យា សេដ្ឋកិច្ចវិទ្យា និងការអប់រំសិល្បៈ។

មុខវិជ្ជាសិក្សាសង្គមត្រូវបានផ្តល់ចំណេះដឹង និងបំណិនទំនាក់ទំនង ការរស់នៅប្រចាំថ្ងៃ ក្នុងតំបន់ក្នុងប្រទេសនិងក្រៅប្រទេស។ អភិវឌ្ឍបំណិនពលរដ្ឋល្អមានការទទួលខុសត្រូវតាមតួនាទី និងមានមោទនភាពចំពោះជាតិរបស់ខ្លួន និងគោរពជាតិសាសន៍ដទៃ។

## ២.សារៈប្រយោជន៍

សៀវភៅសិក្សាគោលមុខវិជ្ជាសិក្សាសង្គម ជាជំនួយស្មារតីគ្រូក្នុងការដឹកនាំសកម្មភាពបង្រៀន និងរួមចំណែកក្នុងការកសាងសមត្ថភាពរបស់កុមារសម្រាប់ការអភិវឌ្ឍន៍លើផ្នែកទាំង៥គឺ ការអភិវឌ្ឍន៍ផ្នែករាងកាយនិងសុខភាព សីលធម៌និងវប្បធម៌ ភាសាពិចារណានិងការយល់ដឹង និងផ្នែកសង្គមនិងអារម្មណ៍។ កុមារទទួលបានការរីកចម្រើន លុះត្រាតែផ្តើមចេញពីការគិតនិងការអនុវត្តជាក់ស្តែងដើម្បីអាចបំបែកចេញឱ្យឃើញកាន់តែច្បាស់ឡើងៗ តាមរយៈការធ្វើសកម្មភាពការរិះគិតបញ្ចេញមតិយោបល់ វិភាគ និងរៀបចំអនុវត្ត ។

## ៣.វិសាលភាពអនុវត្ត

សម្រាប់អនុវត្តនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ ឯកជន និងអ្នកពាក់ព័ន្ធដែលអនុវត្តកម្មវិធីអប់រំកុមារតូចទូទាំងប្រទេសកម្ពុជា ។

# ជំពូក១

# ទស្សនាទាននៃការបង្រៀន និងរៀន

# មុខវិជ្ជាសិក្សាសង្គម

## ជំពូក១ ទស្សនាទាននៃការបង្រៀន និងរៀនមុខវិជ្ជាសិក្សាសង្គម

### ១.១.ទស្សនាទានទូទៅ

នៅចុងដំណាក់កាលឥន្ទ្រីយ៍ចលករកុមារអាចប្រើប្រាស់គំនូរបំព្រួញសកម្មភាពជាច្រើន។ ក៏ប៉ុន្តែគំនូរបំព្រួញទាំងនេះ នៅដំណើរការជាមួយចលនាកុមារក៏មិនចាំបាច់រកនឹកដល់អតីតកាលចងចាំព័ត៌មាន និងរៀបចំផែនការដែរ។ នៅដំណាក់កាលបុរេប្រតិបត្តិរបស់លោក Piaget ដើម្បីឱ្យកុមារអាយុពី២ទៅ ៧ឆ្នាំ ចងចាំព័ត៌មាន និងរៀបចំផែនការកុមារត្រូវអនុវត្តតាមជំហានដែលលោក Piaget ហៅថា «ប្រតិបត្តិការ» ឬសកម្មភាពដែលត្រូវគិតក្នុងខួរក្បាលទៅមុខនិងថយក្រោយដោយមិនមានចលនា។ កុមារចាប់ផ្តើមអនុវត្តប្រតិបត្តិការខួរក្បាលតែនៅមិនទាន់ស្ទាត់ជំនាញនៅឡើយ ពោលគឺជាដំណាក់កាល «បុរេប្រតិបត្តិ» (preoperational)។ តាមមតិរបស់លោក Piaget ការគិតដែលផ្តាច់ចេញពីសកម្មភាពជាការបង្ហាញនិមិត្តរូបនៃគំនូរបំព្រួញ។

សមត្ថភាពរបស់កុមារក្នុងការបង្កើត និងប្រើប្រាស់ និមិត្តរូប ដូចជាពាក្យ ការធ្វើដៃជើង សញ្ញា និងរូបភាពជាសមិទ្ធផលដ៏ធំដែលជំរុញកុមារឱ្យមានភាពស្ទាត់ជំនាញ នៅក្នុងដំណាក់កាលប្រតិបត្តិបន្ទាប់។

នៅពេលដែលកុមារលេងលើកកែវទទេធ្វើជាផឹកទឹក ឬយកក្រាស់ទៅដាក់លើក្បាលធ្វើជាសិតសក់ សកម្មភាពនេះបង្ហាញថា គំនូរបំព្រួញរបស់ពួកគេមានលក្ខណៈទូទៅ ហើយមិនពាក់ព័ន្ធនឹងសកម្មភាពចលនាទេ។ នៅក្នុងដំណាក់កាលនេះការរៀននិយាយគឺជាការលូតលាស់ដ៏សំខាន់ហើយនៅចន្លោះអាយុ២ទៅ៤ឆ្នាំ កុមារចេះពាក្យពី ២០០ ទៅ ២០០០ពាក្យ (Wool folk, 2016) គោលការណ៍អភិរក្ស (conservation)៖ លោក Piaget បង្កើតពាក្យ «អភិរក្ស» នេះឡើងដើម្បីពិពណ៌នាអំពីការយល់ឃើញរបស់កុមារតូចនៅដំណាក់កាលបុរេប្រតិបត្តិនេះ ដែលយល់សើៗអំពីព្រឹត្តិការណ៍ទៅតាមអ្វីដែលគេមើលឃើញ ហើយមិនអាចយល់ស៊ីជម្រៅបានឡើយ(Berk,2003)។ គោលការណ៍អភិរក្សមានន័យថា៖ «បរិមាណ ឬចំនួននៃរបស់អ្វីមួយមិនផ្លាស់ប្តូរឡើយ ទោះបីជាគេយកវាទៅរៀបចំសារជាថ្មីក៏ដោយ ប្រសិនបើគេមិនបន្ថែម ឬដកចេញវត្ថុនោះ»។ លោក Piaget បានពិសោធជាមួយ Leah ដែលមានអាយុ ៥ឆ្នាំ ដោយបង្ហាញកែវធំពីរទំហំប៉ុនគ្នាតែមានកម្ពស់ខ្លីដែលមានទឹកពណ៌ស្មើគ្នា។ Leah យល់ព្រមថាទឹកក្នុងកែវទាំងពីរមានបរិមាណស្មើគ្នា។ បន្ទាប់មកអ្នកពិសោធបានយកកែវមួយចាក់ទៅក្នុងកែវមួយទៀតដែលមានទំហំតូចនិងមានកម្ពស់វែងជាងកែវមុន។ បន្ទាប់មកយកកែវវែងទៅប្រៀបធៀបជាមួយកែវចាស់ដែលធំតែខ្លី។ Leah ចង្អុលថាកែវក្រោយនេះមានទឹកច្រើនជាមុន ដោយកម្ពស់ទឹកខ្ពស់ជាងកែវមុន។ លោក Piaget ពន្យល់បាតុភូតនេះថាក្មេងតូច Leah ផ្តោតការយកចិត្តទុកដាក់លើកម្ពស់(centering) ហើយមិនអាចយល់អំពីស្ថានភាពច្រើនជាងមួយក្នុងពេលតែមួយបានឡើយ ដោយផ្តោតទាំងលើកម្ពស់និងទំហំ(decentering)។ ដូចនេះកុមារបុរេប្រតិបត្តិមិនអាចយល់ទេថា ប្រសិនបើគេកាត់បន្ថយទំហំកែវ នោះកម្ពស់នឹងកើនឡើង (Woolfolk, 2016) តាមការស្រាវជ្រាវរបស់លោក Piaget កុមារនៅក្នុងដំណាក់កាលនេះ មានចរិត «មជ្ឈត្តនិយម»(egocentrism)ដែលចាត់ទុកថា៖ (១) ខ្លួនឯងថា សំខាន់ជាងគេ(២)អ្វីៗទាំងអស់ជារបស់ខ្លួន(៣) អ្នកដែលនៅជុំវិញខ្លួនត្រូវតែយកចិត្តទុកដាក់ទៅលើខ្លួន តែម្នាក់(៤)មិនយកចិត្តទុកដាក់លើអ្នកដទៃ (៥)មិនសូវស្តាប់បង្គាប់ និងរឹងរូសប្រឆាំងនឹងមនុស្សចាស់ ដែលជាវិបត្តិ Lusi (MOEYS-TTD, 2016)។

ដូចនេះ នៅសាលាមត្តេយ្យសិក្សាគ្រូត្រូវ ( Woolfolk, 2016 )៖ ១ ) បង្រៀនសិស្សដោយប្រើប្រាស់វត្ថុ និងសម្ភារឧបទេសដែលជាក់ស្តែង និងដោយប្រើប្រាស់ពណ៌ដើម្បីឱ្យកុមារបុរេប្រតិបត្តិអាចយល់បាន ២ )និយាយខ្លីៗ និងប្រើសកម្មភាពមួយៗក្នុងពេលតែមួយដោយប្រើប្រាស់វិធីបង្រៀនជាពាក្យសម្តីផងនិងបង្ហាញសកម្មភាពផង ជាពិសេសបង្រៀនតាមរយៈល្បែងដើម្បីឱ្យក្មេងយល់។ ៣ )ដើម្បីកាត់បន្ថយចរិត «មជ្ឈត្តនិយម» គ្រូត្រូវបង្រៀនឱ្យកុមារឈ្វេងយល់អំពីអារម្មណ៍ និងមតិយោបល់អ្នកដទៃនិងបង្រៀនឱ្យចេះចែករំលែកនិងឱ្យចេះរបៀបរបបខ្លី និងឱ្យក្មេងឯទៀតខ្ចីរបស់លេង។ ៤ ) បង្រៀនកុមារឱ្យមានបំណិនជាក់ស្តែង ដើម្បីអាចរៀនបំណិន ស្មុគ្រស្មាញដូចជារៀនអានពាក្យសាមញ្ញៗ និងរៀនលេងជាមួយក្មេងឯទៀត ដើម្បីបណ្តុះបំណិនសហការ។ ៥ ) ផ្តល់ឱកាសឱ្យក្មេងមានបទពិសោធច្រើន ដើម្បីពង្រឹងមូលដ្ឋានគ្រឹះ សម្រាប់យល់ទស្សនាទានថ្មីៗ និងរៀនភាសា ដូចជានាំកុមារទៅមើលសួនសត្វ ចូលបណ្ណាគារ ស្តាប់រឿងនិទាន ស្តាប់ភ្លេង និងបង្រៀនកុមារឱ្យចេះ រៀបរាប់សកម្មភាពដែលគេបានធ្វើ បានស្តាប់បានឃើញ បានភ្លក្សរសជាតិជាដើម។

ក្នុងវ័យកុមារតូច បទពិសោធន៍របស់កុមារ ជាកត្តាសម្រួចការអភិវឌ្ឍខួរក្បាលរបស់ពួកគេ។ ការចូលរួមនៅក្នុងសកម្មភាពទាំងអស់ជួយនាំឱ្យកុមារមានការគិតត្រិះរិះ ពិចារណា វិភាគ និងការបង្កើតទំនាក់ទំនងថ្មីៗ។ ទំនាក់ទំនងកោសិកានៅក្នុងខួរក្បាលរបស់កុមារដែលត្រូវបានប្រើប្រាស់ញឹកញាប់ និងកាន់តែរឹងមាំហើយជួយឱ្យកុមារធ្វើសកម្មភាពយ៉ាងលឿន។ ទំនាក់ទំនងកោសិកាខួរក្បាលដែលមិនត្រូវប្រើនឹងស្លាប់ទៅវិញ។

ការផ្តល់ឱកាសឱ្យកុមារហ្វឹកហាត់ជំនាញថ្មីៗ ឬដោះស្រាយបញ្ហាតាមរបៀបថ្មីៗជួយពង្រឹងតំណរភ្ជាប់ទំនាក់ទំនងក្នុងខួរក្បាលដែលផ្តល់ការគាំទ្រដល់សមត្ថភាពទាំងនេះ។ លើសពីនេះ កុមារកសាងទំនុកចិត្តលើខ្លួនឯង និងមានគំនិតវិជ្ជមានពីខ្លួនឯង នៅពេលដែលពួកគេចេះស្ទាត់នូវជំនាញថ្មីៗ និងយកជំនាញថ្មីៗទាំងនេះទៅអនុវត្ត។ សកម្មភាពនានាដែលបង្ហាញក្នុងឯកសារជំនួយស្មារតីនេះ រៀបរាប់ពីសកម្មភាពនៅ "កម្រិតមូលដ្ឋាន" "កម្រិតមធ្យម" និង "កម្រិតខ្ពស់" ដោយបង្ហាញពីឧទាហរណ៍ពីរបៀប ធ្វើឱ្យសកម្មភាពនេះកាន់តែពិបាកទៅៗនៅពេលដែលកុមារកាន់តែមានភាពស្ទាត់ជំនាញ។ ការហ្វឹកហាត់មិនមែនគ្រាន់តែជាការធ្វើសកម្មភាពអ្វីមួយដដែលៗនោះទេ ក៏ប៉ុន្តែជាការធ្វើសកម្មភាព ដោយមានគោលដៅកំណត់ច្បាស់លាស់ និងត្រូវអមដោយការឆ្លុះបញ្ចាំងលើដំណើរការដែលប្រើប្រាស់ សម្រាប់ធ្វើការដោះស្រាយបញ្ហា។ដូច្នេះជានិច្ចជាកាលគ្រូត្រូវរៀបចំសកម្មភាពហ្វឹកហាត់ដោយប្រើប្រាស់ជំនាញ និងចំណេះដឹង ដែលមានស្រាប់របស់កុមារ ក្នុងគោលដៅឱ្យកុមារចេះយកចំណេះដឹងនេះទៅប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហាថ្មីៗដែលមានលក្ខណៈស្មុគស្មាញជាងមុន។ ផ្តល់ឱ្យកុមារនូវបរិយាកាសដែលជួយភ្ញោចការអភិវឌ្ឍរបស់ពួកគេ និងដែលដាក់នៅចំណោទថ្មីៗសម្រាប់ឱ្យពួកគេធ្វើការដោះស្រាយនៅក្នុងបរិយាកាសដែលភ្ញោចដល់ការអភិវឌ្ឍរបស់កុមារ និងបរិយាកាសដែលកុមារទទួលបានចំណោទកាន់តែពិបាកសម្រាប់ធ្វើការដោះស្រាយកុមារកាន់តែអាចរៀនចេះនូវបំណិនកាន់តែមានលក្ខណៈ ស្មុគស្មាញបន្ថែមទៀតបន្ទាប់ពីពួកគេទទួលបានភាពស្ទាត់ជំនាញនៅកម្រិតមូលដ្ឋានរួចហើយ។

ទ្រឹស្តីរបស់លោក Daniel Everett's៖ មនុស្សដើមចាប់ផ្តើមបញ្ចេញសំឡេង តាំងតែ២លានឆ្នាំមកម្ល៉េះ។ មនុស្សដើមរបស់មនុស្សបច្ចុប្បន្នដែល គេហៅថា « homo Erectus » ដែលមាន « homo sapiens » និង« Neander thals » មានខួរក្បាលធំៗ ដើរត្រង់ខ្លួន និងចិញ្ចឹមជីវិតដោយការប្រមូលផល និងការបរ

បាញ់។ ដើម្បីបរបាញ់ដំរីធំៗ(mammoth) បានពួកគេត្រូវការភាសាដើម្បីប្រាស្រ័យទាក់ទង និងសម្របសម្រួលការបរបាញ់ពួកគេធ្វើដំណើរឆ្លងកាត់សមុទ្រដោយជិះក្បូនជាមួយគ្នាជាក្រុម ដូចនេះត្រូវប្រើភាសាដើម្បីទាក់ទងគ្នា និងបញ្ជាដល់ក្បូនមនុស្សរួមដំណើរ។ ទ្រឹស្តីអន្តរសកម្មសង្គមរបស់លោកVygotsky តាមទ្រឹស្តីរបស់លោក LevVygotsky ភាសាកើតមកពីសង្គមមនុស្ស។ ចាប់តាំងពីកើតចេញពីផ្ទៃ**ម្តាយ**កុមារចូលរួមក្នុងអន្តរសកម្មសង្គម ដែលជួយឱ្យកុមារអភិវឌ្ឍសមត្ថភាពពុទ្ធិបញ្ញា ជាពិសេស ភាសា និងគំនិត។ តាមទ្រឹស្តីរបស់ Vygotsky ការធ្វើអន្តរសកម្មសង្គមត្រូវកើតឡើងមុនការអភិវឌ្ឍ ពុទ្ធិបញ្ញា(cognition) និងការអភិវឌ្ឍភាសា។

ទ្រឹស្តីស្ថាបនានិយមរបស់លោក Piaget តាមទ្រឹស្តីរបស់លោក Piaget ភាសាត្រូវបានស្ថាបនាបន្ទាប់ពីការអភិវឌ្ឍ ពុទ្ធិបញ្ញា។ មនុស្សអភិវឌ្ឍបំណិនភាសា និងស្ថាបនាចំណេះដឹងរួមរបស់ខ្លួន ដោយឈរលើមូលដ្ឋាននបទពិសោធរបស់ខ្លួន។ម្យ៉ាងវិញទៀត ទ្រឹស្តីរបស់លោក Piaget ផ្តោតលើសារជាតិនៃប្រាជ្ញាដោយលោកបានចែកការ អភិវឌ្ឍពុទ្ធិបញ្ញាជា ៤ ដំណាក់កាលៈ ទី១-ដំណាក់កាល «ឥន្ទ្រីយ៍ចលករ» ពី ០ ទៅ ២ ឆ្នាំ ទី២-ដំណាក់កាល «បុរេប្រតិបត្តិ» ពី ២ ទៅ ៧ ឆ្នាំ ទី៣-ដំណាក់កាល «ប្រតិបត្តិជាក់ស្តែង» ពី ៧ ទៅ ១០ ឆ្នាំ និង ទី៤-ដំណាក់កាល «ប្រតិបត្តិរៀបរយ» ពី ១២ ឆ្នាំឡើងទៅ។ ទ្រឹស្តីអាកប្បកិរិយានិយមរបស់លោក Skinner លោក Everett ចាត់ទុកការកកើតភាសាបណ្តាលមកពីតម្រូវការរបស់សង្គមដែលមនុស្សម្នាក់បង្កើតរួចប្រើប្រាស់សម្រាប់ការប្រាស្រ័យទាក់ទងគ្នាដោយមនុស្សច្រើននាក់ តាមទ្រឹស្តីនេះ គ្មានទេវេយ្យាករណ៍សាកលសម្រាប់ភាសាទាំងអស់។ ផ្ទុយទៅវិញទ្រឹស្តីអាកប្បកិរិយានិយមមានលក្ខណៈខុសពីទ្រឹស្តីទាំងពីរខាងលើ។ លោក B.F.Skinner ដែលជាចិត្តវិទូអាកប្បកិរិយានិយមបានបង្កើតទ្រឹស្តីសិក្សាភាសាតាមបែបអាកប្បកិរិយានិយម។ លោកបានសន្និដ្ឋានថាការរៀនភាសាមានលក្ខណៈដូចរៀនបំណិនឯទៀតដែរ ដែលត្រូវរៀនតាមរយៈការសង្កេត ការធ្វើត្រាប់តាម ការរំលឹក ការធ្វើខុស ការផ្តល់ការលើកទឹកចិត្ត និងការដាក់ទណ្ឌកម្ម ដែលលោក Skinner tum (Operant Conditioning)។ លោក Skinner ចាត់ទុកការអភិវឌ្ឍភាសាថាជាការរៀនអាកប្បកិរិយាថ្មី។ នៅពេលដែលកុមាររៀននិយាយដំបូងកុមារធ្វើត្រាប់តាមអាកប្បកិរិយារបស់មាតាបិតានិងមនុស្សធំជុំវិញខ្លួន។ ភាសាអភិវឌ្ឍដោយឆ្លើយតបទៅនឹងរំញោចពីបរិស្ថាន។ នៅពេលដែលមាតាបិតាឱបកូន នៅពេលឃើញកូនបញ្ចេញសំឡេងជាលើកដំបូងគឺជាការលើកទឹកចិត្តដែលជំរុញឱ្យក្មេងខំប្រឹងរៀនថែមទៀត។ ដូចនេះសិស្សសាលាអាចទទួលរង្វាន់ ឬទទួលទណ្ឌកម្មនៅក្នុងដំណើរការរៀនភាសានៅសាលារៀន។ ក៏ប៉ុន្តែទ្រឹស្តីនេះមិនត្រឹមត្រូវទាំងអស់ទេ ពីព្រោះមាតាបិតាមួយចំនួន មិនបានយកចិត្តទុកដាក់ទៅលើអ្វីដែលកូននិយាយឡើយ ដោយសារកុមារនិយាយមិនច្បាស់។ ជាការពិតណាស់ក្នុងការរៀនភាសាកុមារធ្វើត្រាប់តាមមាតាបិតារបស់គេ មនុស្សធំជុំវិញខ្លួននិងបរិស្ថានជុំវិញខ្លួនរបស់ពួកគេ។ ទ្រឹស្តីវេយ្យាករណ៍សកលរបស់លោក Chomsky ក៏ប៉ុន្តែគ្រាន់តែធ្វើត្រាប់តាមបរិស្ថានជុំវិញមិនគ្រប់គ្រាន់ទេក្នុងការអភិវឌ្ឍភាសា។ ការអភិវឌ្ឍភាសា ជាដំណើរការដ៏ស្មុគស្មាញមួយនៃមនុស្សជាតិ។

ដូចនេះហើយ លោក NoamChomsky បានបង្កើតទ្រឹស្តីទិទៀនទ្រឹស្តីអាកប្បកិរិយានិយមដោយអះអាងថា ភាសាកើតឡើងពីក្នុងខ្លួនកុមារតែម្តង ហើយកុមារមានលក្ខណៈសម្បត្តិជីវសាស្ត្រក្នុងការរៀនភាសា។ តាមទ្រឹស្តីរបស់លោក Everett ភាសា គឺជាឧបករណ៍សង្គមដែលមនុស្សបង្កើតឡើង ដើម្បីប្រាស្រ័យទាក់ទង ចែករំលែកចំណេះដឹង និងដោះស្រាយបញ្ហា។ ផ្ទុយទៅវិញ លោក Noam Chomsky

យល់ឃើញថា ភាសាកើតឡើងពីក្នុងខ្លួនមនុស្សតែម្តង។ តាមទ្រឹស្តី «វេយ្យាករណ៍សកល» របស់លោក មនុស្សកើតឡើងជាមួយនឹងសមត្ថភាពក្នុងការចេះភាសាតែម្តង។ កុមារកើតមកមានខួរក្បាលដែលមានឧបករណ៍សម្រាប់រៀនភាសាតែម្តងដែលគាត់ហៅថា «ឧបករណ៍រៀនភាសា» (Language Acquisition Device LAD)។ ដោយមានឧបករណ៍នេះកុមារអាចរៀនចេះភាសាបានយ៉ាងលឿន។ការសិក្សាស្រាវជ្រាវអំពីខួរក្បាលមិនបានបញ្ជាក់សម្មតិកម្មរបស់លោក Chomsky ឡើយ។ មនុស្សជាតិមានភាសាមួយដែលជាប្រភពនៃភាសាផ្សេងៗទៀតរបស់មនុស្សដែលមានជាតិសាសន៍ផ្សេងគ្នា។ ហើយវេយ្យាករណ៍ គឺជាប្រព័ន្ធនិង រចនាសម្ព័ន្ធនៃភាសាដែលមានៈ (១) ប្រព័ន្ធវាក្យសម្ព័ន្ធ (syntax) តាមតួនាទី ដូចជាប្រធាន កិរិយាស័ព្ទ និងកម្មវត្ថុ ឱ្យក្លាយទៅជាឈ្លះ (២) ប្រព័ន្ធសិក្សា អំពីរចនាសម្ព័ន្ធនៃពាក្យ (morphology) ដូចជាឫសនៃពាក្យ និងឈ្នាប់ (៣) វិធីបញ្ចេញសំឡេង (phonology) និង (៤) ការសិក្សាអំពីន័យរបស់ពាក្យ (semantics)។ ប្រការនេះមានន័យថាភាសារបស់មនុស្សត្រូវមានវេយ្យាករណ៍រួមស្រដៀងគ្នាដើម្បីឱ្យជាតិសាសន៍នីមួយៗអាចអភិវឌ្ឍភាសារបស់ខ្លួនបាន។ ការរៀនចេះច្បាស់ភាសារបស់ជនជាតិមួយនឹងជួយដល់ការរៀន ភាសារបស់ជនជាតិមួយទៀត ឱ្យឆាប់ចេះ ដោយសារភាសាទាំងអស់មាន វេយ្យាករណ៍សកលរួមគ្នា និងស្រដៀងគ្នា។

ទ្រឹស្តីអភិវឌ្ឍភាសារបស់លោក Arnold Gesell នៅឆ្នាំ១៩២៥ អ្នកប្រាជ្ញជនជាតិអាមេរិក លោក Arnold Gesellបានបង្កើតទ្រឹស្តីនៃការអភិវឌ្ឍភាសា ដោយបង្ហាញឥទ្ធិពលនៃសេណេទិច ក្នុងការអភិវឌ្ឍភាសា និងអាកប្បកិរិយាដទៃទៀត។ លោកជឿជាក់ថា បំណិន របស់មនុស្ស ដូចជាបំណិនបន្សំ បំណិនចលករ និងភាសា អភិវឌ្ឍ និងរីក លូតលាស់តាមធម្មជាតិទៅតាមលក្ខណៈជីវសាស្ត្ររបស់មនុស្សម្នាក់ៗ។ ប៉ុន្តែ លោកមិនបានផាត់ចោលកត្តាបរិស្ថានក្នុងការអភិវឌ្ឍកុមារឡើយ ទោះបីលោកយល់ថាបរិស្ថានមានឥទ្ធិពលតិចតួចជាសេណេទិចក្នុងការអភិវឌ្ឍ ភាសាក៏ដោយ។ ដូចនេះហើយ ទើបការសិក្សាស្រាវជ្រាវរបស់លោក Gesell ផ្តោតលើការអភិវឌ្ឍសរីរាង្គរបស់កុមារដែលជាដំណើរធំធាត់របស់កុមារ(maturation) ហើយចាត់ទុកដំណើរអភិវឌ្ឍរបស់កុមារអាស្រ័យលើការលូតលាស់នៃប្រព័ន្ធសរសៃប្រសាទ ដូចជាខួរក្បាល ខួរឆ្អឹងខ្នងជាដើម។ លោកGesell បានចាត់ទុកថាដំណាក់កាលសំខាន់នៃការអភិវឌ្ឍភាសា អាចចែកចេញជា ៥ ដំណាក់កាល ពីអាយុ ៤០ សប្តាហ៍ ដល់ ៥ ឆ្នាំៈ

- ដំណាក់កាលទី១ អាយុ 0 – ៥0 សប្តាហ៍ៈ ក្មេងចេះបន្លឺសំឡេងដែលមានន័យ។
- ដំណាក់កាលទី២ ពីអាយុ ១ គ្រង់ៗ។ ១ – ២ ឆ្នាំៈ ក្មេងចេះប្រើឈ្លះវែង និងឃ្លា
- ដំណាក់កាលទី៣ ពីអាយុ២– ៣ ឆ្នាំៈ ក្មេងចេះប្រាស្រ័យទាក់ទង ដោយនិយាយបានមួយឃ្លាទាំងស្រុង។
- ដំណាក់កាលទី៤ពីអាយុ៣–៤ឆ្នាំៈក្មេងប្រើភាសាជាឧបករណ៍ក្នុងការទទួលបានចំណេះដឹងពីពិភពលោកជុំវិញខ្លួន
- ដំណាក់កាលទី៥ ពីអាយុ ៤ – ៥ ឆ្នាំៈ ក្មេងចេះនិយាយបានយ៉ាងស្ទាត់ជំនាញ។

លោក Gesell បានចាត់ទុកថា កុមារដែលមានអាយុក្រោម១០ឆ្នាំ មាន ឧបនិស្ស័យ ក្នុងការរៀន រៀនភាសាទី២ និងទី៣ ហើយពួកគេរៀនភាសាដោយក្តីសប្បាយរីករាយ។ យើងឃើញថា ទ្រឹស្តីនៃការអភិវឌ្ឍភាសាទាំងអស់ផ្តោតលើឥទ្ធិពលបរិស្ថាន និងសេណេទិក ហើយអ្នកស្រាវជ្រាវផ្សេងៗជឿជាក់ថា

ភាសាអភិវឌ្ឍដោយសារកត្តាសេណេទិករបស់មនុស្សផង និងដោយសារការធ្វើអន្តរសកម្មផង។ ទ្រឹស្តីនៃការអភិវឌ្ឍភាសាភាគច្រើនចាត់ទុកការអភិវឌ្ឍភាសាជាការគួបផ្សំរវាងធម្មជាតិ និងការអប់រំ។

## ១.២.ការវិវឌ្ឍន៍ខួរក្បាលកុមារ

៨៥%នៃការអភិវឌ្ឍខួរក្បាល កើតមានអំឡុងរយៈពេល១០០០ថ្ងៃដំបូងនៃជីវិតកុមារហើយ ការរីកចម្រើនយ៉ាងឆាប់រហ័សនេះ បន្តមានរហូតដល់អាយុ៦ឆ្នាំ។




រូបភាពទី 1៖ ការអភិវឌ្ឍខួរក្បាលកុមារក្នុងកំឡុងពេល ១០០០ថ្ងៃដំបូង

គុណភាពនៃការថែទាំដែលកុមារទទួលបានអំឡុងពេលពីរបីឆ្នាំដំបូង រួមមានការថែទាំសុខភាព អាហារូបត្ថម្ភ ការប្រាស្រ័យទាក់ទងសង្គម ការភ្លេច ការអប់រំមុនចូលសាលារៀន ការអប់រំនៅទារកដ្ឋាន ការអប់រំនៅសាលាមត្តេយ្យសិក្សារដ្ឋ ឬមត្តេយ្យសិក្សាសហគមន៍ នឹងមានឥទ្ធិពលយូរអង្វែងដល់ខួរក្បាលកុមារ។

ការរៀនសូត្រគឺមានតាំងពីកំណើតមកម្ល៉េះ។ ការប្រាស្រ័យទាក់ទងជាមួយសង្គម និងការភ្លេចដ៏សកម្មដល់កុមារបានទាន់ពេលវេលាតាមអាយុកាល គឺជាអាហារដ៏សំខាន់សម្រាប់ការអភិវឌ្ឍខួរក្បាលកុមារ។ វាប្រៀបដូចជាការផ្តល់ចំណីអាហារដល់កុមារដូច្នោះដែរ។ ការភ្លេចគឺមានសារៈសំខាន់ខ្លាំងសម្រាប់ការអភិវឌ្ឍខួរក្បាល។

ការអភិវឌ្ឍខួរក្បាលនិងប្រព័ន្ធសរសៃប្រសាទ ក្នុងវ័យកុមារភាពក៏នៅតែបន្តកើតមានគួរឱ្យកត់សម្គាល់ដែរ។ ការលូតលាស់ខួរក្បាល និងប្រព័ន្ធប្រសាទកាន់តែប្រសើរឡើង គឺឥរិយាបថ និងការយល់ដឹងកាន់តែស្មុគស្មាញ ដែលធ្វើឱ្យកុមារកាន់តែមានសមត្ថភាព។

ខួរក្បាលមានពីរផ្នែកគឺអឌ្ឍគោលខួរខាងឆ្វេង និងអឌ្ឍគោលខួរខាងស្តាំ។ អឌ្ឍគោលខួរទាំងពីរមានការរីកចម្រើនក្នុងអត្រាផ្សេងៗគ្នា ដោយអឌ្ឍគោលខាងឆ្វេងមានការរីកចម្រើនយ៉ាងពេញលេញក្នុងវ័យកុមារភាព(អាយុ២ទៅ៦ឆ្នាំ) អឌ្ឍគោលនេះ មានផ្ទុកជាពិសេសគឺភាសា ការសរសេរ និងបំណិនគណិតវិទ្យា។ រីឯសមត្ថភាពផ្នែកច្នៃប្រឌិត ផ្នែកសិល្បៈ តន្ត្រី ឬមុខងារនៃការប្រើប្រាស់រាងកាយ ច្រើនស្ថិតនៅអឌ្ឍគោលខាងស្តាំ។ តែទោះជាអឌ្ឍគោលទាំងពីរមានមុខងារផ្សេងៗគ្នាក៏ដោយ ក៏ម៉ាស់នៃខួរក្បាលទាំងពីរតែងតែសម្របមុខងាររបស់ខ្លួនហើយធ្វើការជាមួយគ្នា។ ទិដ្ឋភាពមួយទៀតនៃការអភិវឌ្ឍខួរក្បាល គឺការប្រើដៃ ឬ

ចំណាប់ចំណូលចិត្តក្នុងការប្រើដៃម្ខាង។ ក្នុងពេលនេះ ត្រូវបង្កើនការយកចិត្តទុកដាក់ពង្រឹងសមត្ថភាពលើការប្រើដៃម្ខាងនេះ ដើម្បីឱ្យមានភាពរឹងមាំ។ ប្រជាជនទូទៅ ប្រហែល៩០% ច្រើនប្រើដៃស្តាំ។ ការបង្ខំ ឬដាក់ទណ្ឌកម្មឱ្យប្រើដៃម្ខាងណាមួយនោះ ដែលគេមិនមានចំណាប់ចំណូលចិត្ត គឺជាការបំបាក់ស្មារតីធ្វើឱ្យកុមារវង្វេងវង្វាន់ក្នុងពេលប្រើដៃ។ ជាធម្មតាការកាន់ដៃស្តាំត្រូវបានផ្សារភ្ជាប់ជា មួយឥទ្ធិពលខាងស្តាំនៃខួរក្បាល និងប្រើដៃឆ្វេង ដោយឥទ្ធិពលខួរក្បាលខាងស្តាំ។ ទោះជាខួរក្បាលមាន អឌ្ឍគោលពីរផ្សេងគ្នា ក៏ខួរក្បាលត្រូវបានបែងចែកជាផ្នែកផ្សេងៗ និងមានមុខងារផ្សេងៗគ្នាដែរ។ ក្នុងចំណោមផ្នែកផ្សេងៗនៃខួរក្បាល មានផ្នែកមួយដែលហៅថាខួរតូច ហើយមានមុខងារទទួលខុសត្រូវ ចំពោះចលនា។ ខួរតូច គឺជាផ្នែកបន្ថែមនៃខួរក្បាល ដែលមានសារៈសំខាន់សម្រាប់ចិត្តចលភាព។ ខួរតូចគ្រប់គ្រងចលករតូចក៏ដូចជាតុល្យភាពនិងការសម្របសម្រួល។

គ្រូមត្តេយ្យត្រូវក្តាប់បានពីគោលការណ៍បង្រៀនទាំង៧ដូចខាងក្រោម៖

### ១.២.១.គោលការណ៍បង្រៀនត្រូវជានានូវការរីកចម្រើន

ជួយឱ្យចំណេះដឹងកុមារលូតលាស់ហើយបង្កើតជារូបភាពម្ចាស់ការក្នុងការគិត ដោះស្រាយបញ្ហាដែលគ្រូដាក់ឱ្យ ត្រូវបង្រៀនកុមារឱ្យមានសមត្ថភាព ចំណេះដឹងច្បាស់លាស់ក្រោមការណែនាំរបស់មនុស្សធំត្រូវផ្តល់នូវសញ្ញាណថ្មីៗ ដោយផ្អែកលើសមត្ថភាពមានស្រាប់របស់កុមារ ត្រូវចេះណែនាំពីរបៀបសង្កេតមុខសញ្ញាដោយម៉ត់ចត់និងសំខាន់ជាងនេះទៀតជំរុញកុមារឱ្យមានចរិតសកម្មក្នុងការត្រិះរិះពិចារណា។

### ១.២.២. គោលការណ៍ធានានូវចរិតវិទ្យាសាស្ត្រគួបផ្សំ នឹងសកម្មភាពនានា

### ១.២.២.១.ធានានូវចរិតវិទ្យាសាស្ត្រយ៉ាងពិតប្រាកដដល់ការបង្រៀនកុមារ

ខ្លឹមសារមេរៀននីមួយៗដែលយកមកបង្រៀន ត្រូវមានភាពច្បាស់លាស់ត្រឹមត្រូវ និងត្រូវបង្រៀនកុមារឱ្យយល់ច្បាស់ចេះត្រិះរិះបែងចែកច្បាស់មិនច្រឡំ។

#### ខ.ការត្រិះរិះដាក់ស្តែងនូវសកម្មភាពផ្ទាល់ខ្លួន

ការសង្កេតការស្ទាបប៉ះពាល់លក្ខណៈខាងក្រៅនៃវត្ថុ គ្រូមត្តេយ្យសិក្សាត្រូវផ្តល់ចំណេះដឹងឱ្យកុមារធ្វើសកម្មភាពដាក់ស្តែងជាបណ្តើរៗជាមួយនឹងសង្គម អារម្មណ៍ បរិស្ថាន មនុស្ស សត្វ រុក្ខជាតិ និងមជ្ឈដ្ឋានជុំវិញ ។

### ១.២.៣. គោលការណ៍ធានានូវចរិតសមស្របតាមវ័យ

ពេលបង្រៀនសិក្សាសង្គមដំបូងដល់កុមារ គ្រូត្រូវជ្រើសរើសខ្លឹមសារមេរៀន និងវិធីបង្រៀនបានសមស្របតាមវ័យនីមួយៗរបស់កុមារដូចជា៖ ខ្លឹមសារពីងាយទៅលំបាកប្រើប្រាស់វិធីងាយយល់ ឆាប់ចាំនិងចាំបានយូរ ចេះប្រើប្រាស់សម្ភារឧបទេសបានសមស្រប បង្កលក្ខណៈឱ្យកុមារប្រើប្រាស់សម្ភារៈ និងអនុវត្តដោយផ្ទាល់ ឧទាហរណ៍៖ ពេលបង្រៀនពីគំនូរ គ្រូប្រើសម្ភារឧបទេសតាមខ្លឹមសារមេរៀន មានល្បិចពន្យល់ល្អ និងផ្តល់ឱកាសឱ្យកុមារបានអនុវត្តជាបុគ្គលនិងជាក្រុម។

### ១.២.៤. គោលការណ៍បង្រៀនធានាលក្ខណៈដាក់ស្តែង

ការយល់ដឹងរបស់កុមារ ជាការយល់ដឹងពីសកម្មភាពដាក់ស្តែង ដូចនេះគ្រូមត្តេយ្យសិក្សាត្រូវផលិតសម្ភារៈបង្រៀនធានាលក្ខណៈដាក់ស្តែងសមស្របនឹងគរុកោសល្យប្រើប្រាស់សម្ភារៈ ដាក់ស្តែងឱ្យសមស្របតាមវ័យរបស់កុមារ បង្កលក្ខណៈឱ្យកុមារប្រើប្រាស់សម្ភារៈ ដើម្បីឱ្យគេទទួលបានចំណេះដឹងថ្មី និងចម្លើយរបស់ខ្លួន។

### ១.២.៥.គោលការណ៍បង្រៀនជានានូវចរិតជាប្រព័ន្ធ និងរឹងមាំ

កម្មវិធីសិក្សាសង្គមនៅមត្តេយ្យសិក្សា ត្រូវបានរៀបចំឡើងទៅតាមលក្ខណៈប្រព័ន្ធ ជាបន្តបន្ទាប់ដែលជាក្រឹត្យក្រមរវាងចំណេះដឹងចាស់ មានទំនាក់ទំនងជាមួយចំណេះដឹងថ្មី ចំណេះដឹងដល់ផ្តល់ឱ្យកុមារត្រូវបានពង្រឹងជានិច្ច ដោយមានរូបភាពជាច្រើនឱ្យកុមារក្តាប់បានច្បាស់ពីបញ្ហាដែលបានរៀន។

ដើម្បីអនុវត្តគោលការណ៍នេះ គ្រូមត្តេយ្យសិក្សាត្រូវយកចិត្តទុកដាក់ក្តាប់ឱ្យបានច្បាស់នូវកម្មវិធីមត្តេយ្យសិក្សាទាំងបីកម្រិត។ ក្នុងលំនាំបង្រៀនថ្នាក់មត្តេយ្យសិក្សា គ្រូត្រូវដឹងពីចំណេះដឹងមានស្រាប់របស់កុមារមានដល់កម្រិតណា ត្រូវផ្តល់បន្ថែមពីបញ្ហាអ្វី ហើយរៀបចំអ្វីទៀតដល់ពួកគេ គ្រូមត្តេយ្យសិក្សាត្រូវបង្រៀនអំពីសង្គម ជាក់ស្តែង(រូបី) ។

### ១.២.៦. គោលការណ៍បង្រៀនជានានូវចរិតសកម្មម្ចាស់ការរបស់កុមារ

ក្នុងពេលបង្រៀនសញ្ញាណសិក្សាសង្គមដំបូង ត្រូវបំផុសឱ្យកុមាររិះរកដំណោះស្រាយដោយខ្លួនឯងក្រោមការណែនាំរបស់គ្រូ។ បង្កលក្ខណៈឱ្យកុមារប្រើគ្រប់ញាណដោយផ្ទាល់ដើម្បីប្រាស្រ័យទាក់ទងជាមួយបរិស្ថានមនុស្ស បរិស្ថានធម្មជាតិ និងបរិស្ថានវប្បធម៌ធ្វើឱ្យកុមារចេះវិភាគប្រៀបធៀបដោយបញ្ញាដែលគេសន្សំបានពីបទពិសោធន៍សំខាន់ៗក្នុងជីវភាពរស់នៅជាក់ស្តែងប្រចាំថ្ងៃ។

### ១.២.៧. គោលការណ៍បង្រៀនចំពោះកុមារម្នាក់ៗ

ការបង្រៀនសិក្សាសង្គម ត្រូវយកចិត្តទុកដាក់ដល់សមត្ថភាពរួមនៃវ័យរបស់កុមារ ពិសេសត្រូវយកចិត្តទុកដាក់ដល់ចរិតលក្ខណៈនិងនិស្ស័យ របស់កុមារម្នាក់ៗឱ្យបានច្បាស់លាស់ ដោយប្រើមធ្យោបាយគ្រប់រូបភាព ដើម្បីងាយស្រួលជួយកុមារឱ្យទទួលបានចំណេះដឹងប្រកបដោយប្រសិទ្ធភាព។

គ្រូមត្តេយ្យសិក្សា ត្រូវឈ្លាសវៃក្នុងការរៀបចំខ្លឹមសារចំណេះដឹងប្លែកៗគ្នាដាក់ឱ្យកុមារ ពូកែ មធ្យម ខ្សោយ ដោះស្រាយតាមសមត្ថភាពផ្ទាល់ខ្លួន ។

## ១.៣. ទស្សនៈ និងរបកគំហើញក្នុងបរិបទថ្មី

Sigmund Freud ( ទស្សនវិទូអាល្លឺម៉ង់ ) បានរកឃើញថា ផ្លូវចិត្តរបស់មនុស្សត្រូវបានបែងចែកជាបីផ្នែក ៖ ID, Ego និង Superego។

ID ជាផ្នែកមួយនៃផ្លូវចិត្ត ជាថាមពលពីកំណើត ជាសារជាតិដើមរបស់មនុស្សដែលមានតាំងពីកំណើត ជាតម្រូវការ (I want it now) (ខ្ញុំត្រូវការវា)។ លោក Freud បានលើកឧទាហរណ៍ប្រៀបធៀប ID ទៅនឹងសារជាតិបិសាច(អាក្រក់)។ ដោយបានធ្វើការសិក្សាស្រាវជ្រាវលើខួរក្បាលមនុស្សក្នុងរយៈពេលដ៏យូរលោកជឿថា យើងអាចធ្វើការបន្ធូរបន្ថយ ID បាននៅពេលដែលយើងមានវប្បធម៌នៅក្នុងខ្លួនរបស់យើង គឺការបង្កើតគំនិតប្រកបដោយ ភាពរីករាយផ្តើមចេញពីអន្តរកម្មនៃសង្គម។

Ego ជាផ្លូវចិត្តនៅមានមនសិការ និងសតិសម្បជញ្ញៈ។ Ego មានផ្នែកផ្សេងៗទៀតដូចជា ហេតុផល ការប្រកែកតវ៉ា ការរៀបចំផែនការ ការគិតទុកដោយចេតនា និងការធ្វើអ្វីដោយមានហេតុផល ដោយផ្អែកលើបTពិសោធន៍។ Ego នៅកណ្តាលរវាង ID និងពិភពខាងក្រៅ បង្កើតបានជាការយល់ពីខ្លួនឯង។ គ្រប់អន្តរកម្មជាមួយបរិស្ថានពីខាងក្រៅ Ego បង្កើតបានជាការយល់ពីខ្លួនឯង ជាផ្នែកប្រតិបត្តិនៃចរិតរបស់មនុស្ស វាត្រូវបានកំណត់ដោយបទពិសោធន៍របស់កុមារ។

Superego ជាឥទ្ធិពលនៃឪពុកម្តាយ ឬអ្នកនៅជុំវិញ ឬហៅថាមនសិការ។ Superego កើតចេញពីការរៀន ការគិត និងបទពិសោធន៍។ លោក Freud បានលើកឧទាហរណ៍ថា Superego គឺជាព្រះ ប្រៀបដូចជាព្រះនៅឋានលើ គាត់បង្កើតច្បាប់ ផ្តល់រង្វាន់ និងពិន័យ។ Superego រុញមនុស្សឱ្យពិចារណា។

ទំនាក់ទំនងរវាង ID និង Ego តាមរយៈអន្តរកម្មវិជ្ជមាន ជាការបង្កើតឱ្យមាន Superego កាន់តែច្រើនឡើងដែលអាចកម្ចាត់បិសាចអាក្រក់នៅក្នុងចិត្ត ហើយបង្កើតបានជាសម្បជញ្ញៈ ដែលអាចបង្ក្រាបបាននូវគំនិតអវិជ្ជមានធ្វើឱ្យមនុស្សចេះរួមរស់នៅជាមួយគ្នាដោយសន្តិភាព។

បទពិសោធន៍ ផ្សំផ្គុំបានជាគោលការណ៍ បញ្ញត្តិ ច្បាប់សម្រាប់ខ្លួនឯង ជាទំនាក់ទំនងរវាងខ្លួនឯង និងបរិស្ថានខាងក្រៅ។ អន្តរកម្មជាមួយអ្នកដទៃមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍការយល់ពីខ្លួនឯង និងយល់ពីអ្នកដទៃដែលឈានទៅរកការអភិវឌ្ឍចិត្តសង្គម។ លោក Carl Rogers 1983 បានរកឃើញថា ឪពុកម្តាយ និងគ្រូបង្រៀន អាចធ្វើឱ្យកុមារចេះស្រឡាញ់ខ្លួនឯង គោរពខ្លួនឯងបានច្រើនតាមរយៈការផ្តល់ក្តីស្រឡាញ់ដល់ពួកគេដោយឥតលក្ខខណ្ឌ ទោះបីកុមារនោះជោគជ័យ ឬបរាជ័យក៏ដោយ។ ការគិតគូរពីនរណាម្នាក់ដោយវិជ្ជមាន ជាការស្រឡាញ់ដោយឥតលក្ខខណ្ឌ។

## ១ ៤.បរិបទកម្ពុជា

### ១.៤.១. ការយល់ដឹងអំពីខ្លួនឯង និងគំនិតវិជ្ជមានរបស់ខ្លួនសម្រាប់កុមារតូច

កុមារដែលមានការយល់ដឹងច្បាស់អំពីភាពខ្លាំងរបស់ខ្លួននូវគំនិតបែបវិជ្ជមាន និងការឱ្យតម្លៃខ្លួនឯង។ កុមារសម្គាល់បាននូវការចូលចិត្ត និងការមិនចូលចិត្តរបស់ខ្លួន ហើយទទួលស្គាល់នូវអ្វីដែលអាច ឬមិនអាចធ្វើបាន។ កុមារអាចកំណត់អារម្មណ៍ហើយប្រាប់អ្នកផ្សេងទៀតឱ្យយល់ពីអារម្មណ៍របស់ខ្លួន។

ឧទាហរណ៍៖ និយាយអំពីអាហារ ឬរបស់លេងដែលចូលចិត្ត ឬមិនចូលចិត្តក្នុងអំឡុងពេលសម្តែង ឬសន្ទនាគ្នា និងណែនាំល្បែងដែលខ្លួនពូកែលេងជាមួយមិត្តភក្តិ(Ministry of Education, Copies right 2013, p.6)។

### ១.៤.២. ការគ្រប់គ្រងខ្លួនឯង

ជាសមត្ថភាពមួយដែលបានធ្វើចំណាត់ថ្នាក់នៅក្នុងផ្នែកអភិវឌ្ឍន៍ចំណេះដឹង ដែលកុមារអាចចេះគ្រប់គ្រងអារម្មណ៍ និងឥរិយាបថនៅពេលធ្វើសកម្មភាពក្នុងពេលសិក្សា និងសង្គមរបស់ពួកគេ។ កុមារអាចឆ្លើយតបចំពោះតម្រូវការនៅក្នុងស្ថានភាពអ្វីមួយ ដោយប្រើប្រាស់អារម្មណ៍ដែលមានលក្ខណៈសមស្របសម្រាប់សង្គម អាចពិនិត្យតាមដានវាយតម្លៃ និងផ្លាស់ប្តូរប្រតិកម្មផ្នែកអារម្មណ៍របស់ពួកគេចំពោះស្ថានភាពអ្វីមួយបាន (ក្រសួងអប់រំ យុវជន និងកីឡា, ២០២០, ទំព័រ ១៥)។ កុមារមានទំនោរមើលឃើញអ្វីៗតាមទស្សនៈផ្ទាល់ខ្លួន ដូច្នេះកុមារអាចបង្ហាញគំនិត និងអារម្មណ៍របស់ខ្លួនជាមួយនឹងការពិចារណាតិចតួចសម្រាប់អារម្មណ៍របស់អ្នកដទៃ និងប្រហែលជាមិនដឹងថា សកម្មភាពរបស់ខ្លួនអាចប៉ះពាល់ដល់អ្នកដទៃឡើយ។

កុមារត្រូវមានទម្លាប់ទទួលជំនាញគ្រប់គ្រងអារម្មណ៍ជាមូលដ្ឋាន ដែលរួមមានការយល់ដឹងពីអារម្មណ៍ខុសគ្នានៃអារម្មណ៍វិជ្ជមានដូចជាសុភមង្គលភាពស្និទ្ធស្នាលសេចក្តីស្រឡាញ់ និងអាចចែករំលែកដល់អ្នកដទៃជាដើម។ ទន្ទឹមនេះ កុមារនឹងអាចរៀនពីអារម្មណ៍អវិជ្ជមាន ដូចជាកំហឹងច្រណែនការមិនសប្បាយចិត្ត និងការភ័យខ្លាច ជាដើម ដែលតម្រូវកុមារឱ្យខិតខំគ្រប់គ្រងអារម្មណ៍របស់ខ្លួនក្នុងលក្ខណៈអាចទទួលយកបានក្នុងសង្គម។ ឧទាហរណ៍៖ នៅពេលកុមារខឹងកុមារនឹងចេះទប់អារម្មណ៍ចរចាពីការមិន

ចុះសម្រុងជាមួយមិត្តភក្តិ ជំនួសឱ្យការវាយគ្នាឬស្រែកដាក់គ្នា។ ជាមួយនឹងជំនាញគ្រប់គ្រងអារម្មណ៍ជាមូលដ្ឋានទាំងនេះកុមារនឹងអាចអនុវត្តវិន័យដោយខ្លួនឯង និងទទួលយកនូវទំនួលខុសត្រូវផ្ទាល់ខ្លួន ដែលបានបង្ហាញពីអារម្មណ៍អវិជ្ជមានរបស់ខ្លួន។ តើកុមារអនុវត្តការគ្រប់គ្រងកំហឹង និងការខកចិត្តលើអាកប្បកិរិយាដែលមិនចេះអត់ធ្មត់ដែរឬទេ ? ( Ministry of Education, Copies right 2013, p. 6 )។

## ១.៥ អន្តរបញ្ញត្តិសិក្សាសង្គមសម្រាប់កុមារ

### ១.៥.១. ការយល់ដឹងពីសង្គម

ការអភិវឌ្ឍផ្នែកសង្គមគឺជាដំណើរការដែលបុគ្គលម្នាក់ៗ អភិវឌ្ឍសមត្ថភាពកសាងទំនាក់ទំនងប្រកបដោយភាពសុខដុមរមនាជាមួយអ្នកដទៃទៀត។ សមត្ថភាពរៀនសូត្រផ្នែកសង្គមនៅកម្រិតកុមារតូចមានដូចជា៖

- ការអនុវត្តតាមច្បាប់ទម្លាប់សង្គម(វិជានសង្គម)៖ ការចែករំលែក ការគោរព ជម្រាបសួរ អរគុណ វេងចាំវេន ប្តូរវេន និងសុំអភ័យទោស
- ការយល់ចិត្តអ្នកដទៃ៖ ការយល់ពីអារម្មណ៍អ្នកដទៃការឆ្លើយតបដោយការគិតពីអ្នកដទៃ ការពន្យល់ពីអារម្មណ៍ ឆ្លុះបញ្ចាំងការយកចិត្តទុកដាក់ ការសម្តែងសេចក្តីអាណិតអាសូរនិងការយល់ដឹងពីផ្នត់គំនិតងាយៗ
- ការដោះស្រាយជម្លោះ៖ ឈប់ គិត សាកល្បងដោះស្រាយ
- ការគោរពលក្ខណៈផ្សេងៗគ្នារបស់អ្នកដទៃ៖ស្គាល់គ្នាទៅវិញទៅមក ចេះឱ្យតម្លៃដល់លក្ខណៈខុសគ្នារបស់អ្នកដទៃចុះសម្រុងជាមួយអ្នកដទៃដែលមាលក្ខណៈខុសពីខ្លួន
- ការស្វែងយល់ពីលក្ខណៈដូចគ្នា គោរពលក្ខណៈខុសៗគ្នារបស់មនុស្ស
- ការចេះរស់នៅជាមួយធម្មជាតិ៖ យកចិត្តទុកដាក់ចំពោះរាល់ទម្រង់ផ្សេងៗរបស់ជីវិត ស្វែងយល់ គោរព គិតគូរពីបរិស្ថានធម្មជាតិ យល់ដឹងពីបញ្ហាបរិស្ថាន សន្សំសំចៃអគ្គិសនី និងសន្សំសំចៃទឹក។ ( ក្រសួងអប់រំយុវជននិងកីឡា២០២០, ទំព័រ ១៤ )

កុមារដែលមានការយល់ ដឹងផ្នែកសង្គមបានគឺកុមារអាចស្គាល់ពីអារម្មណ៍ និងទស្សនៈរបស់អ្នកដទៃដែលមានភាពចម្រុះគ្នាដោយការពេញចិត្តស្តាប់ និងបង្ហាញពីការគោរពចំពោះអ្នកផ្សេងទៀតដោយមិនគិតពីភាពខុសគ្នា។ ការរៀបចំសកម្មភាពឬព្រឹត្តិការណ៍ពិសេសៗដោយការផ្តល់ឱកាសឱ្យ កុមារ និងក្រុមគ្រួសារ ឬអ្នកតំណាងស្លៀកសម្លៀកបំពាក់ប្រពៃណី ដើម្បីចែករំលែកចំណេះដឹងអំពីម្ហូបអាហាររបស់ជាតិសាសន៍នីមួយៗ និងអបអរសាទរមហោស្រព។ គ្រូជួយលើកកម្ពស់ការយល់ដឹងរបស់កុមារអំពីការអនុវត្ត និងការឱ្យតម្លៃពិសេសដល់កុមារដែលមានវប្បធម៌ខុសគ្នា ( Ministry of Education, Copies right 2013, p.7 )។

### ១.៥.២ ការគ្រប់គ្រងទំនាក់ទំនង

កុមារត្រូវរៀនសូត្រពីលទ្ធផលជាច្រើនដែលនឹងអាចកើតមាននៅក្នុងស្ថានភាពលំបាក និងតម្រូវឱ្យកុមាររៀនពីការគ្រប់គ្រងលទ្ធផលនោះឱ្យបានក្នុងអំឡុងពេលកំពុងធ្វើការជាមួយអ្នកដទៃ។

ដូច្នេះ គ្រូត្រូវផ្តល់ឱកាសឱ្យកុមាររៀនដោះស្រាយបញ្ហាដូចជាការដោះស្រាយទំនាស់ ការកំណត់វិន័យថ្នាក់រៀនការកំណត់លក្ខខណ្ឌល្បែងជាដើម។ ក្នុងន័យនេះ កុមារនឹងទទួលបានការរៀនសូត្រពីឥរិយាបថក្នុងសង្គម ដូចជាការសហការជួយគ្នា ការប្តូរវេនគ្នា និងបង្ហាញនូវការគោរព ស្តាប់ទស្សនៈរបស់អ្នកដទៃ តាមរយៈការអនុវត្តសកម្មភាពផ្សេងៗឬការលេងល្បែង។

### ១.៥.៣ .ការសម្រេចចិត្តប្រកបដោយការទទួលខុសត្រូវ

កុមារត្រូវរៀនចេះទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន។ គ្រូបង្រៀនគប្បីជួយកុមារឱ្យធ្វើអ្វីៗសម្រាប់ខ្លួនឯង ជាជាងគ្រូធ្វើសកម្មភាពសម្រាប់កុមារ។ នៅពេលកុមារកាន់តែមានភាពម្ចាស់ការ កាន់តែមានភាពឯករាជ្យកុមារនឹងមានការសម្រេចចិត្តកាន់តែខ្ពស់ឡើង ដែលធ្វើឱ្យកុមារកាន់តែមានការទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន និងជួយកុមារឱ្យមានសមត្ថភាពដោះស្រាយបញ្ហាតាមរបៀបនៃការគិតពិចារណាដោយការពេញចិត្ត។

ដូច្នេះកុមារត្រូវការឱកាសនិងការលើកទឹកចិត្តឱ្យមានការរែកញែកមានការពិចារណា និងមានការពន្យល់រកហេតុផលនៃការប៉ះពាល់ ផលវិបាកនិងការស្វែងរកជម្រើសផ្សេងៗ។

កុមារកាន់តែមានកម្លាំងចិត្តរៀននៅពេលបានយល់ពីការគ្រប់គ្រងអារម្មណ៍របស់ខ្លួនបានល្អ និងអាចធ្វើអន្តរកម្មជាមួយអ្នកដទៃ ព្រមទាំងធ្វើការសម្រេចចិត្តប្រកបដោយទំនួលខុសត្រូវ។ នៅពេលកុមារទទួលបានជោគជ័យក្នុងការបំពេញភារកិច្ចជាមួយអ្នកដទៃ កុមារនឹងរីករាយជាមួយនឹងការពេញចិត្តបែបវិជ្ជមានព្រមទាំងមានឆន្ទៈក្នុងការសហការជាមួយអ្នកដទៃ។

## ១.៦ អន្តរកម្មគ្រប់ជ្រុងជ្រោយសម្រាប់កុមារ

អន្តរកម្មនៃការសិក្សាប្រកបដោយគុណភាពកុមារនឹងទទួលបានចំណេះដឹងបំណិន និងឥរិយាបថថ្មីៗបន្ថែមទៀតពីបរិយាកាសសិក្សារបស់ខ្លួន។ កុមារធ្វើអន្តរកម្មជាមួយពិភពលោក កុមារត្រូវប្រឈមមុខនឹងបញ្ហាសង្គម និងបុគ្គលដែលបញ្ហាទាំងអស់នោះត្រូវបានភ្ជាប់កុមារឱ្យចេះប្រើប្រាស់នូវបញ្ញារបស់ពួកគេដើម្បីដោះស្រាយបញ្ហាទាំងនោះ។ កុមារត្រូវការចង់ចេះចង់ដឹងនិងស្វែងយល់ពីហេតុនិងផលហេតុនេះជាកត្តាចាំបាច់ដែលត្រូវឱ្យកុមារចូលរៀននៅថ្នាក់មត្តេយ្យសិក្សា ដើម្បីភ្ញោចបញ្ញារបស់ពួកគេឱ្យមានការលូតលាស់ព្រមទាំងត្រូវសិក្សាពីមុខវិជ្ជាជាច្រើនជាបុរេមុខវិជ្ជា ដើម្បីជាគ្រឹះទៅសិក្សានៅមុខវិជ្ជាផ្សេងៗទៀតនៅកម្រិតបឋមសិក្សា មធ្យមសិក្សា និងកម្រិតឧត្តមសិក្សាដែលចាំបាច់ត្រូវមានការគាំទ្រពីគ្រូឱ្យមានការអនុវត្តជាក់ស្តែងនិងប្រកបដោយប្រសិទ្ធភាព។ ដើម្បីឱ្យកុមារមានសមត្ថភាពពេញលេញ និងគ្រប់ជ្រុងជ្រោយលើការអភិវឌ្ឍលើផ្នែកទាំង៥គឺការអភិវឌ្ឍលើផ្នែករាងកាយនិងសុខភាព ការអភិវឌ្ឍផ្នែកវប្បធម៌និងសីលធម៌ ការអភិវឌ្ឍផ្នែកសង្គមនិងអារម្មណ៍ ការអភិវឌ្ឍផ្នែកពិចារណានិងការយល់ដឹង និងការអភិវឌ្ឍផ្នែកភាសាដែលត្រូវការអន្តរាគមន៍ពីក្រុមគ្រួសារ សាលារៀន គ្រូមត្តេយ្យសិក្សា សហគមន៍ និងរដ្ឋអំណាចដើម្បីធានាគុណភាព និងប្រសិទ្ធភាព។

# ជំពូក២
# គោលដៅសិក្សា នៃមុខវិជ្ជា
# សិក្សាសង្គម

## ជំពូក២ គោលដៅសិក្សា នៃមុខវិជ្ជាសិក្សាសង្គម

### ២.១- ក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពរបស់កុមារ

មុខវិជ្ជាសិក្សាសង្គម បានផ្តល់ឧត្តមប្រយោជន៍ជាច្រើន ដ៏មានប្រសិទ្ធភាពដល់កុមារតូចទាំងផ្នែកចំណេះដឹង បំណិន និងឥរិយាបថសម្រាប់ការត្រៀមខ្លួនជាស្រេចដើម្បីចូលរៀននៅសាលាបឋមសិក្សាឱ្យមាននគុណភាព។ ប្រការនេះតម្រូវឱ្យគ្រូមត្តេយ្យសិក្សាតាំងខ្លួនជាមាតាទី២ ប្រកាន់ខ្ជាប់នូវមនសិការវិជ្ជាជីវៈខ្ពស់ យកអស់ពីកម្លាំងកាយចិត្តណែនាំអប់រំ និងបង្ហាត់បង្រៀនហ្វឹកហាត់កុមារឱ្យមានការរីកចម្រើនលើគ្រប់ផ្នែក ទាំងសមត្ថភាព និងចរិយាសម្បត្តិ ឈានឡើងជាបន្តបន្ទាប់រហូតដល់សម្រេចបាននូវការអភិវឌ្ឍតាមគោលដៅសិក្សា ដូចខាងក្រោម៖

- អភិវឌ្ឍបាននូវសមត្ថភាពសង្កេតពិនិត្យបង្កើតរូបារម្មណ៍ច្នៃប្រឌិត និងបង្កើតសិល្បៈនៃការគូរគំនូរងាយៗ និងសកម្មភាពកសាងប្រកបដោយប្រសិទ្ធភាព
- អភិវឌ្ឍបាននូវការយល់ដឹងពីហេតុ និងផល មានការគិត និងវិភាគគ្រប់ជ្រុងជ្រោយការសម្តែងអារម្មណ៍និងចេះសង្កត់ចិត្តរបស់ខ្លួន មានគោលវិធីជាវិជ្ជមាន និងមានជំហដើម្បីដោះស្រាយបញ្ហា
- អភិវឌ្ឍបាននូវសេចក្តីនាស្រឡាញ់ និងចូលរួមថែរក្សាសិល្បៈវប្បធម៌ ទំនៀមទម្លាប់ប្រពៃណីនិងសោភ័ណ
- គោរពពេលវេលាបានទៀងទាត់មានសេចក្តីអំណត់តស៊ូព្យាយាមមានការទទួលខុសត្រូវធ្វើកិច្ចការផ្ទាល់ខ្លួនឱ្យរួចជាស្ថាបពរ ចេះធ្វើការរួមគ្នា ចេះផ្តល់ព័ត៌មាន មានទម្លាប់ល្អក្នុងការរស់នៅប្រចាំថ្ងៃ និងរួមរស់នៅជាសមូហភាពប្រកបដោយភាពសុខដុម។

គោលដៅសិក្សារួមទទួលបានប្រសិទ្ធភាព ចាំបាច់គ្រូត្រូវផ្សារភ្ជាប់ទៅនឹងកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាដែលក្នុងនោះ ការសិក្សារៀនសូត្ររបស់កុមារបានចាប់ផ្តើមឡើងពីការប្រើប្រាស់ញាណតាមរយៈ ការលេង ការគិត ពិចារណា និងសកម្មភាពអនុវត្តដោយផ្ទាល់របស់កុមារ។ ការផ្សារភ្ជាប់ការលេងរបស់កុមារទៅនឹងការច្នៃប្រឌិតតាមរយៈវិធីសាស្ត្រខុសៗគ្នាវានឹងផ្តល់នូវមូលដ្ឋានចំណេះដឹង និងជំនាញមួយចំនួនដូចជា សមត្ថភាពគិតពិចារណា វិនិច្ឆ័យ ម្ចាស់ការ ការចូលរួមនិងសហការ។សញ្ញាណនៃមុខវិជ្ជាមួយចំនួនត្រូវបានដាក់បញ្ចូលក្នុងគោលដៅសិក្សានៅមត្តេយ្យសិក្សាដើម្បីផ្សារភ្ជាប់ចំណេះដឹង និងបំណិនទៅបឋមសិក្សា។ នៅពេលបញ្ចប់មត្តេយ្យសិក្សា កុមារនឹងមានសមត្ថភាពផ្នែក៖

- ការលើកតម្កើនវប្បធម៌របស់ខ្លួន
- ការស្គាល់អត្តសញ្ញាណរបស់ខ្លួន
- ការយល់ដឹងពីតម្លៃ និងចរិតលក្ខណៈមនុស្ស
- ការពេញចិត្តចំពោះលក្ខណៈផ្សេងៗគ្នារបស់អ្នកដទៃ
- បំណិនរស់នៅក្នុងសង្គម និងទំនាក់ទំនងល្អជាមួយមនុស្សជុំវិញ
- បំណិនក្នុងការគិត និងដោះស្រាយរាល់បញ្ហា
- ការយល់ដឹងពីទង្វើ និងលទ្ធផល
- ការយល់ដឹងពីអារម្មណ៍ខ្លួនឯង និងអ្នកដទៃ
- ការចេះទប់អារម្មណ៍ និងសម្តែងអារម្មណ៍ល្អៗ
- យល់ដឹងអំពីបរិស្ថានធម្មជាតិ និងវិធីការពារ

- យល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើនរូបភាព
- ចំណេះដឹងបច្ចេកទេស ចលនា ការច្នៃប្រឌិត និងបទពិសោធន៍ផ្នែកតន្ត្រី។

### ២.១.១- គោលដៅសិក្សាទី១៖ ការលើកតម្កើងវប្បធម៌របស់ខ្លួន

ឧទាហរណ៍ទី ២ សង្កេត « ទង់ជាតិកម្ពុជា »

- លទ្ធផលរំពឹងទុក៖
  - ប្រាប់បានពីសម្មភាពខ្លះៗរបស់បុណ្យប្រពៃណីជាតិខ្មែរ
  - ស្គាល់ទីកន្លែងសំខាន់ៗមួយចំនួនដូចជា៖ អង្គរវត្ត វត្តអារាម ព្រះបរមរាជវាំង(ឬទីកន្លែងតាមតំបន់)
  - ទង់ជាតិរបស់ប្រទេសកម្ពុជា និងទង់សាសនា
  - ច្រៀងបទគោរពទង់ជាតិ (បទនគររាជ) បានត្រឹមត្រូវ តាមទំនុកបទបានចំនួន៣វគ្គ។
- សកម្មភាព៖

ចែករូបទង់ជាតិកម្ពុជាឱ្យកុមារជាក្រុមតូចៗ នាំគ្នាសង្កេត

- សមាជិកក្រុមស្មគ្រចិត្តឡើងបង្ហាញពីគំនិតផ្ទាល់ខ្លួន
- សម្របសម្រួល និងបញ្ជាក់នូវអត្តសញ្ញាណនៃទង់ជាតិកម្ពុជា ( ទីតាំងរូប និងពណ៌នៃប្រាសាទ ទីតាំងពណ៌ក្រហម ពណ៌ខៀវ និងបញ្ជាក់អត្ថន័យ គឺអនុវត្តសម្រាប់កុមារថ្នាក់កម្រិតខ្ពស់)
- បំផុសកុមារឱ្យប្រាប់ចំណងជើង
- ណែនាំពីរបៀបឈរគោរព និងថែរក្សាទង់ជាតិកម្ពុជា។

### ២.១.២- គោលដៅសិក្សាទី២៖ ស្គាល់ពីអត្តសញ្ញាណរបស់ខ្លួន

ឧទាហរណ៍៖ ល្បែង ណែនាំខ្លួន

- លទ្ធផលរំពឹងទុក៖
  - ស្គាល់នាមត្រកូល នាមខ្លួន ចំនួនសមាជិកក្នុងគ្រួសារនិងជាកូនទី ប៉ុន្មាន
  - រាប់ចំនួនសមាជិកក្នុងគ្រួសារ និងប្រាប់ពីបងប្អូន
  - ណែនាំខ្លួន ចំនួនសមាជិកក្នុងគ្រួសារដល់អ្នកដទៃ
- សកម្មភាព
  - ឱ្យកុមារចាប់ដៃគូពីរៗនាក់
  - ឱ្យកុមារប្រាប់ឈ្មោះនិងព័ត៌មានផ្ទាល់ខ្លួនដល់គ្នាទៅវិញទៅមក(ឧ៖ កូនទី? ឈ្មោះ? មានបងប្អូន?នាក់..។)
  - ឱ្យកុមារអនុវត្តដូចខាងលើដោយផ្លាស់ប្តូរដៃគូ(២ឬ៣គូ)
  - ហៅកុមារឡើងមកនិយាយប្រាប់ព័ត៌មានរបស់មិត្តភក្តិឱ្យបានច្រើននាក់។

### ២.១.៣. គោលដៅសិក្សាទី៣៖ ការយល់ដឹងពីតម្លៃនិងចរិតលក្ខណៈមនុស្ស

ឧទាហរណ៍៖ ល្បែង « ជម្រាបសួរ »

- លទ្ធផលរំពឹងទុក៖
  - ការគោរពចាស់ទុំ និងឱ្យតម្លៃចំពោះអ្នកដទៃ

- សម្តែងអាកប្បកិរិយាគោរពអ្នកដទៃបានត្រឹមត្រូវ
- មិនបង្កទំនាស់ មានសាមគ្គីភាព និងជួយដោះស្រាយបញ្ហាគ្នា។

- សកម្មភាព
  - ផ្គាប់បណ្ណរូបភាពកុមារ មនុស្សចាស់ ព្រះសង្ឃ និងព្រះពុទ្ធរូប នៅលើតុគ្រូ ឱ្យកុមារម្នាក់មកបើក បណ្ណ១
  - រួចលើកបង្ហាញឱ្យមិត្តរួមថ្នាក់សំពះតបទៅរូបភាពតាមវ័យដែលនៅក្នុងបណ្ណនោះ
  - កុមារដែលសំពះជម្រាបសួរមិនទាន់ត្រឹមត្រូវ គ្រូជួយកែលម្អ និងបង្ហាញពីរបៀបជម្រាបសួរតាមវ័យនៅក្នុងបណ្ណរូបភាពនោះ។
  - បន្ទាប់មកគ្រូឱ្យកុមារជម្រាបសួរគ្នា ទៅវិញទៅមកឱ្យបានត្រឹមត្រូវ ។

### ២.១.៤. គោលដៅសិក្សាទី៤៖ ការពេញចិត្តចំពោះលក្ខណៈផ្សេងគ្នារបស់បុគ្គល

ឧទាហរណ៍៖ ល្បែង «ខ្ញុំអាចស្តាប់បាន» (ដកស្រង់ចេញពីឯកសាររៀនសូត្រចិត្តសង្គមនៅមត្តេយ្យសិក្សា ទំព័រទី ២៦)

- លទ្ធផលរំពឹងទុក
  - ប្រាប់បានពីលក្ខណៈសម្បត្តិរបស់មិត្តភក្តិដែលលេងជាមួយ
  - ប្រាប់បានពីសមត្ថភាពដែលខ្លួនស្រឡាញ់ចូលចិត្ត។
  - មិនប្រកាន់ពូសាសន៍ ពណ៌សម្បុរ រូបរាង ពិការ អ្នកមាន អ្នកក្រ

- សកម្មភាព
  - ឱ្យកុមារចាប់ដៃគូ ពីរនាក់ និងម្នាក់ទៀតជាអ្នកត្រូវបានគេគូរ(៣នាក់)
  - អ្នកគូររូបត្រូវស្តាប់ហើយសង្កេតពីការសន្ទនារបស់មិត្តភិក្ក និងគូរពីសកម្មភាពរបស់អ្នកឆ្លើយ (ឧ តើឯងប្រើអ្វីដើម្បីស្តាប់? អ្នកឆ្លើយ៖ ត្រចៀក ដូច្នេះអ្នកគូរត្រូវគូររូបត្រចៀក..)
  - អ្នកសួរត្រូវសួរបន្តទៀត...
  - អ្នកឆ្លើយក៏បន្តឆ្លើយ...
  - អ្នកគូរក៏បន្តគូរតាមចម្លើយ
  - អ្នកគូរឡើងបកស្រាយពីគំនូររបស់ខ្លួនបានគូរ ពីឥរិយាបថរបស់មិត្តភិក្ក

  (ឧ នេះជាមាត់ទុកសម្រាប់ហូបបាយ...)និយាយបណ្តើរចង្អុលរូបគំនូរបណ្តើរ។

### ២.១.៥.គោលដៅសិក្សាទី៥៖ បំណិនរស់នៅក្នុងសង្គមនិងទំនាក់ទំនងវិជ្ជមានជាមួយមនុស្សជុំវិញ

ឧទាហរណ៍៖ កំណាព្យ « អូនវង្វេងផ្លូវតែក្លាហាន »

- លទ្ធផលរំពឹងទុក
  - ប្រាប់បានពីឈ្មោះមនុស្សជុំវិញនិងអាសយដ្ឋានរបស់ខ្លួន ឱ្យជួយនៅពេលមានបញ្ហា
  - រៀបរាប់ឈ្មោះមនុស្សជុំវិញឱ្យជួយនៅពេលដែលខ្លួនមានបញ្ហា
  - ក្លាហានក្នុងការទាក់ទងជាមួយមនុស្សធំនៅពេលមានបញ្ហា

- សកម្មភាព
  - ប្រាប់ចំណងជើងកំណាព្យ
  - សូត្រកំណាព្យឱ្យកុមារស្តាប់

- នាំកុមារសូត្រកំណាព្យរហូតដល់ចប់មួយបទ
- បំផុសសំណួរអំពីដំណោះស្រាយនៅពេលវង្វេងផ្លូវតាមអត្ថន័យកំណាព្យ
- បូកសរុប និងសង្ខេបមេរៀនត្រង់ចំណុចសំខាន់ៗ។

### ២.១.៦ គោលដៅសិក្សាទី៦៖ បំណិនក្នុងការគិត និងដោះស្រាយរាល់បញ្ហា

ឧទាហរណ៍៖សន្ទនា«ផ្ទាំងរូបភាពកុមារឈ្លោះគ្នា»

- លទ្ធផលរំពឹងទុក
  - ប្រាប់ពីវិធីដោះស្រាយក្នុងក្រុម
  - ចេះបង្ហាញពីវិធីផ្សេងៗដើម្បីដោះស្រាយបញ្ហាលើសម្មភាព
  - សហការគ្នាល្អក្នុងការធ្វើការងារជាក្រុម ឬដៃគូ
- សកម្មភាព
  - ចែកកុមារក្នុងថ្នាក់ជាពីរក្រុម និងផ្តល់ផ្ទាំងរូបភាពឱ្យកុមារសង្កេត និងសន្ទនាតាមក្រុម
  - តំណាងក្រុមនីមួយៗឡើងមកបង្ហាញពីយោបល់របស់ក្រុម និងហេតុផលដែលត្រូវរក
  - ដំណោះស្រាយទំនាស់
  - សំយោគចម្លើយកុមារទាំង២ក្រុម។

### ២.១.៧.គោលដៅសិក្សាទី៧៖ ការយល់ដឹងអំពីទង្វើ និងលទ្ធផល

ឧទាហរណ៍៖ រឿងនិទាន បងប្អូន៤នាក់មិនបម្រើឪពុក

- លទ្ធផលរំពឹងទុក
  - ប្រាប់បានពីអំពើល្អ និងមិនល្អ
  - ទម្លាប់ធ្វើអំពើល្អ និងគោរពទឹកចិត្តអ្នកដទៃ។
- សកម្មភាព
  - និទានរឿងឱ្យកុមារស្តាប់
  - បំផុសកុមារឱ្យប្រាប់ចំណងជើងរឿង
  - បំផុសសំណួរពីអំពើ និងលទ្ធផលរបស់បងប្អូន៤នាក់
  - អប់រំណែនាំកុមារឱ្យប្រព្រឹត្តតែអំពើល្អ និងចៀសវាងអំពើណាមួយដែលប៉ះពាល់ដល់អារម្មណ៍ និងរូបរាងកាយរបស់អ្នកនៅជុំវិញខ្លួន។

### ២.១.៨.គោលដៅសិក្សាទី៨៖ ការយល់ដឹងពីអារម្មណ៍ខ្លួនឯង និងអ្នកដទៃ

ឧទាហរណ៍៖ ល្បែង « តាថាសម្តែងអារម្មណ៍ »

- លទ្ធផលរំពឹងទុក
  - ដឹងពីមូលហេតុដែលធ្វើឱ្យខ្លួនសប្បាយត្រេកអរ ភ័យ ខ្លាចនៅពេលជួបព្រឹត្តិការណ៍ណាមួយ។
  - ទំនាក់ទំនងល្អជាមួយមនុស្សដែលនៅជុំវិញខ្លួន។
- សកម្មភាព
  - កុមារសម្តែងអារម្មណ៍នៅពេលឮពាក្យថាតាថាសើច/យំ/ខឹង/ភ័យ/ព្រួយ... (គ្រូអាចប្រើពាក្យសម្តី ឬរូបភាព)

- បើមិនបានឮពាក្យតាថានៅខាងដើមពាក្យសើច/យំ/ខឹង/ភ័យ/ព្រួយកុមារមិនធ្វើត្រាប់តាម ឡើយបើកុមារធ្វើខុសលក្ខខណ្ឌល្បែងនឹងទទួលបានពិន័យរាំតាមបទចម្រៀងរបស់អ្នកឈ្នះ។

### ២.១.៩.គោលដៅសិក្សាទី៩៖ ការចេះទប់អារម្មណ៍ និងសម្តែងអារម្មណ៍ល្អៗ

ឧទាហរណ៍ ៖ រឿងនិទាន «បាយពំនូត»

- លទ្ធផលរំពឹងទុក
  - ប្រាប់បានពីអំពើល្អដែលជួយទុកធុរៈដល់មនុស្សចាស់និងមនុស្សជុំវិញខ្លួន
  - គោរពពេលវេលាទៀងទាត់ និងមានទម្លាប់ល្អ
  - ចែករំលែក យោគយល់ និងបង្ហាញឥរិយាបថគាំទ្រអំពើល្អរបស់មិត្តភក្តិ។
- សកម្មភាព
  - និទានរឿងឱ្យកុមារស្តាប់
  - បំផុសកុមារឱ្យប្រាប់ចំណងជើងរឿង
  - បំផុសសំណួកុមារឱ្យរៀបរាប់ពីអំពើល្អនិងលទ្ធផលរបស់កុមារក្នុងសាច់រឿង
  - អប់រំណែនាំកុមារឱ្យប្រព្រឹត្តតែអំពើល្អ និងចៀសវាងទង្វើណាមួយដែលប៉ះពាល់ដល់អារម្មណ៍ និងរូបរាងកាយរបស់អ្នកនៅជុំវិញខ្លួន។

### ២.១.១០. គោលដៅសិក្សាទី១០៖ យល់ដឹងអំពីបរិស្ថានធម្មជាតិ និងវិធីការពារ

ឧទាហរណ៍ ៖ សន្ទនា « ការចោលសំរាម »

- លទ្ធផលរំពឹងទុក
  - ប្រាប់ពីការចោលសម្រាមឱ្យត្រូវតាមប្រភេទនិងទីកន្លែងកំណត់
  - ទម្លាប់ចោលសម្រាមតាមកន្លែងកំណត់និងមានអនាម័យ
- សកម្មភាព
  - ដាក់ពាក្យបណ្តៅឱ្យកុមាររក ឈ្មោះនាងផ្តើមសួរ«ច»ផ្លែធ្លាញ់បរញ្ញាំបានទាំងខ្ញីទុំ។ ចម្លើយ គឺផ្លែចេក
  - បំផុសសំណួរពីការចោលសំបកចេក សំរាមផ្សេងៗ ( ខ្ចប់យកទៅចោលនៅផ្ទះ ឬការចោលសំរាមតាមប្រភេទ តាមកន្លែងកំណត់ )
  - កុមារអនុវត្តពីរបៀបចោលសំរាម និងការធ្វើអនាម័យ
  - បំផុសកុមារឱ្យប្រាប់ចំណងជើង។

### ២.១.១១.គោលដៅសិក្សាទី១១៖យល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព

ឧទាហរណ៍ ៖សកម្មភាពកសាង « បិទរូបផ្ទះ »

- លទ្ធផលរំពឹងទុក
  - ប្រាប់បានពីររបៀប បិទរូបផ្ទះ
  - ប្រុងប្រយ័ត្នក្នុងការចាប់កាន់
- សកម្មភាព

កុមារម្នាក់ៗត្រូវ៖

- មានក្រដាស២សន្លឹក គឺ ១សន្លឹកសម្រាប់ជាទ្រនាប់បិទរូបផ្ទះនិងក្រដាស១សន្លឹកទៀត គ្របពីលើរូបភាព កាវ និងក្រដាសរាងត្រីកោណ១សន្លឹក រាងចតុកោណកែងសម្រាប់ធ្វើជាតួផ្ទះ១សន្លឹក និងទ្វារ១សន្លឹកនិងក្រដាសរាងការេធ្វើជាបង្អួច១សន្លឹក
- បិទតួផ្ទះលើក្រដាសទ្រនាប់ដោយគ្របក្រដាសពីលើរូបភាពរឹតឱ្យស្អាតមិនជ្រួញរូបភាព។កុមារបន្តបិទទ្វារ បិទបង្អួច បិទដំបូលផ្ទះដោយជំណាក់កាលនីមួយៗអនុវត្តការបិទតាមតួផ្ទះ។

### ២.១.១២. គោលដៅសិក្សាទី១២ .ចំណេះដឹងបច្ចេកទេស ចលនា ការច្នៃប្រឌិត និងបទពិសោធន៍ផ្នែកតន្ត្រី

ឧទាហរណ៍ ៖ ល្បែង « ទាយសំឡេង »

- លទ្ធផលរំពឹងទុក
  - ប្រាប់ពីសូរសំឡេងផ្សេងៗក្នុងបរិស្ថាន
  - ញែកសូរសំឡេងក្នុងធម្មជាតិ និងសំឡេងដែលបង្កើតឡើងដោយមនុស្ស
  - យកចិត្តទុកដាក់ស្តាប់និងគាំទ្រគំនិតត្រឹមត្រូវរបស់មិត្តភក្តិ។
- សកម្មភាព

បង្កើតសំឡេងតាមរយៈការគោះតុ កែវទឹក... និងការស្តាប់សំឡេងម៉ូតូ ឡាន រថភ្លើង រទេះគោ សត្វ សំឡេងខ្យល់បក់ សំឡេងភ្លៀងធ្លាក់ ទឹកហូរតាមរយៈម៉ាញ៉េ ឬទូរស័ព្ទ ឬការអនុវត្តផ្ទាល់។ កុមារឈរបែរខ្នង ស្តាប់ហើយទាយថាជាសំឡេងគ្រូធ្វើអ្វីឬសំឡេងអ្វីចេញពីម៉ាញ៉េ ឬទូរស័ព្ទ គ្រូហៅកុមារណាម្នាក់ដែលលើកដៃឱ្យឆ្លើយដោយត្រឡប់ក្រោយបែរទាំងអស់គ្នា។ បើចម្លើយត្រឹមត្រូវ កុមារទាំងអស់ត្រូវទះដៃ។ ប៉ុន្តែបើចម្លើយមិនត្រឹមត្រូវកុមារនៅស្ងៀមហើយលើកដៃដើម្បីឡើងឆ្លើយចម្លើយដែលពេញចិត្ត។

## ២.២.ការផ្សារភ្ជាប់ទៅនឹងបរិបទវិទ្យាសាស្ត្រ

កុមារមិនអាចអភិវឌ្ឍចិត្តសង្គមតាមបែបធម្មជាតិដោយគ្មានការសម្របសម្រួលពីមនុស្សនៅជុំវិញខ្លួនបាន ទេដូច្នេះគ្រូត្រូវរៀបចំសកម្មភាពឆ្លើយតប ទៅនឹងការបង្រៀន និងរៀនដោយផ្តល់នូវឱកាស ដើម្បីលើកកម្ពស់ ការអភិវឌ្ឍ សមត្ថភាពសង្គមនិងអារម្មណ៍( Ministry of Education, Copies right 2013 )។

### ២.២.១.ធានាលក្ខណៈអប់រំ

- ទម្លាប់កុមារឱ្យគិតបែបវិជ្ជមាន
- កុមារសម្តែងចេញនូវសមត្ថភាពផ្ទាល់ខ្លួននូវចរិតលក្ខណៈសង្គមដូចជាសហការគ្នាគោរពលក្ខណៈផ្សេងគ្នារបស់បុគ្គល និងជួយទុក្ខធុរៈគ្នាទៅវិញទៅមកចូលរួមនិងសហការរបស់សាលារៀនសហគមន៍ និងរដ្ឋអំណាចមូលដ្ឋានអាជ្ញាធរដែនដីនិងអ្នកពាក់ព័ន្ធ

ឧទាហរណ៍៖ ការរៀបចំកម្មវិធីបើកបវេសនកាល កម្មវិធីថ្ងៃកីឡាកុមារ កម្មវិធីទិវាកុមារអន្តរជាតិ ថ្ងៃ១មិថុនា... ដែលនៅក្នុងកម្មវិធីទាំងនេះគ្រូគប្បីរៀបចំដាក់បញ្ចូលឱ្យមានសកម្មភាពកុមារបង្ហាញពីសមត្ថភាពផ្ទាល់ខ្លួនដូចជា សមត្ថភាពសិល្បៈសមត្ថភាពល្បែងចលនា ដោយមានការចូលរួមពីមាតាបិតា និងអាណាព្យាបាលផងដែរ។

### ២.២.២ ធានាលក្ខណៈគរុកោសល្យ

- សម្ភារឧបទេសសំបូរបែបមានលក្ខណៈជាក់ស្តែង មានសោភ័ណ មានសុវត្ថិភាព និងសមស្របតាមវ័យ
- ឥរិយាបថវិជ្ជមានរបស់គ្រូក្នុងសកម្មភាពបង្រៀន និងរៀន

- រៀបចំបរិស្ថានសិក្សាឱ្យជាទីមេត្រី សមស្របតាមខ្លឹមសារសកម្មភាពគោល ស្របតាមវ័យជាទីពេញចិត្តរបស់កុមារ ងាយស្រួលកុមារធ្វើសកម្មភាព និងធានាសុខសុវត្ថិភាព
- ការរៀបចំខ្លឹមសារមេរៀននីមួយៗ និងដំណើរការបង្រៀនត្រូវផ្សារភ្ជាប់សមត្ថភាពមានស្រាប់ និងគំនិតផ្តួចផ្តើមរបស់កុមារ ផ្សារភ្ជាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់កុមារតាមវ័យ សមស្របនឹង សមត្ថភាពទទួលចំណេះដឹង ឆ្លើយតបនិងបំណិនសតវត្សរ៍ទី២១។

## ២.៣.ការបណ្តុះស្មារតីកុមារ

ការបណ្តុះស្មារតីកុមារឱ្យមានភាពជាឯករាជ្យសម្រាប់ខ្លួនឯង និងមានចរិតសង្គម ចាំបាច់ត្រូវយកចិត្តទុកដាក់ជាពិសេសដល់ការអប់រំបុគ្គលិកលក្ខណៈកុមារនៅក្នុងដំណើរការបង្រៀននិងរៀនដែលគ្រូបានរៀបចំ នៅក្នុងចរិយាសម្បទានៃវត្ថុបំណងរបស់កិច្ចតែងការបង្រៀន។

# ជំពូក៣

# វិធីសាស្ត្រអនុវត្តការបង្រៀន និងរៀន មុខវិជ្ជាសិក្សាសង្គម

## ជំពូក៣ វិធីសាស្ត្រអនុវត្តការបង្រៀន និងរៀនមុខវិជ្ជាសិក្សាសង្គម

### ៣.១. ប្រធានបទ/មុខវិជ្ជាសិក្សាសង្គមនៅកម្រិតមត្តេយ្យសិក្សា

ប្រធានបទមុខវិជ្ជាសិក្សាសង្គមមាន៖

- ការយល់ដឹងពីតម្លៃមនុស្ស
- ការលើកតម្កើនវប្បធម៌
- បំណិនទំនាក់ទំនង
- ការយល់ដឹងអំពីខ្លួនឯង
- បំណិនពិចារណា
- បំណិនក្នុងសង្គម
- គំនូរ និងសកម្មភាពកសាង
- ចម្រៀង និងតន្ត្រី

### ៣.២.វិធីសាស្ត្របង្រៀនសិក្សាសង្គមនៅមត្តេយ្យសិក្សាមាន

ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងដំណើរការបង្រៀននិងរៀន តម្រូវឱ្យគ្រូផ្តោតលើសកម្មភាពកុមារជាមូលដ្ឋាន និងផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយសកម្មភាពគ្រូរហូតដល់ចប់ម៉ោងសិក្សាមួយ។ កត្តានេះ គ្រូគប្បីរៀបចំសកម្មភាពឱ្យកុមាររីករាយនឹងការសិក្សាស្វែងយល់ជាបុគ្គលជាដៃគូជាក្រុមតូច និងក្រុមធំដោយគ្រូត្រូវយកចិត្តទុកដាក់គិតគូរពីវ័យពីសមត្ថភាព និងបរិយាបន្នរបស់កុមារក្នុងការរៀបចំក្រុមផងដែរ។

ទន្ទឹមនេះ គ្រូក៏ត្រូវលើកទឹកចិត្តកុមារឱ្យក្លាហានបញ្ចេញមតិយោបល់ចេះស្តាប់យោបល់គ្នាទៅវិញទៅមកចេះសម្របគំនិតឱ្យឯកភាពគ្នាក្នុងក្រុម និងក្លាហានធ្វើជាតំណាងក្រុមដោយមិនមើលបំណាំគ្នាឬប្រណែនគ្នាជាពិសេសចេះសហការយោគយល់គ្នា និងចេះចែករំលែកឱ្យគ្នាទៅវិញទៅមក។

➢ គោលវិធីសិស្សមជ្ឈមណ្ឌល វិធីផ្តល់ឱ្យ៖

- កុមារមានការអភិវឌ្ឍពីមួយថ្ងៃទៅមួយថ្ងៃ ឈានទៅរកការរីកចម្រើនពេញលេញលើគ្រប់ផ្នែកដើម្បីប្រែក្លាយជាមនុស្សដែលសង្គមចង់បាន
- ថ្នាក់រៀនមានភាពរស់រវើកពោរពេញដោយបរិយាកាសរីករាយក្នុងការស្រាវជ្រាវស្វែងយល់
- កុមារបំពេញការងារយ៉ាងសកម្មក្នុងការសិក្សាប្រើអស់លទ្ធភាពដែលគេមាន មានគំនិតច្នៃប្រឌិតតាមលទ្ធភាពរបស់គេ
- កុមារស្គាល់តម្លៃរបស់ខ្លួនដែលជាសមាជិកម្នាក់របស់ក្រុម និងសង្គមទៅអនាគត
- កុមារយល់ដឹងពីសិទ្ធិទទួលខុសត្រូវរបស់ខ្លួន និងចេះគោរពសិទ្ធិអ្នកឯទៀត (ការអប់រំសិទ្ធិមនុស្ស)
- កុមារយល់ដឹងពីអត្ថន័យនៃតម្លៃសោភ័ណ សិល្បៈ តន្ត្រី អក្សរសិល្ប៍...
- កុមារចេះរស់នៅនិងសហការជាមួយអ្នកឯទៀតប្រកបដោយការយោគយល់គ្នានិងគ្មានហិង្សា (បណ្តុះគំនិតសាមគ្គី ភាតរភាព សន្តិភាព ចេះរស់នៅរួមគ្នា...)
- កុមាររៀនប្រើប្រាស់ពេលទំនេររបស់គេឱ្យមានប្រយោជន៍
- កុមារយល់ដឹងពីបរិស្ថាន (បរិស្ថានសាលារៀន សង្គម និងធម្មជាតិ)

**តារាងសង្ខេបសម្រាប់ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល**

| សកម្មភាពគ្រូ | សកម្មភាពសិស្ស |
| --- | --- |
| - ដាក់បញ្ហា( សំណួរផ្ទាល់មាត់ ពិសោធន៍ ល្បែងសិក្សា )<br>- ណែនាំរបៀបរបបការងារ (លក្ខខណ្ឌនៃការអនុវត្តសញ្ញាចាប់ផ្ដើម និងបញ្ចប់ការងារ ឬល្បែង)<br>- តាមដាន និងសម្របសម្រួល(ជួយបំភ្លឺសិស្សនៅពេលមានចម្ងល់និងមានបញ្ហា ជំរុញសរសើរលើកទឹកចិត្តសិស្ស)<br>- សំយោគខ្លឹមសារ ( សង្ខេប បូកសរុប វាយតម្លៃក្រុម ) | - ដោះស្រាយបញ្ហាជាបុគ្គល ដៃគូ ក្រុមតូច ក្រុមធំ<br>- ធ្វើពិសោធន៍ ពិភាក្សាផ្លាស់ប្ដូរយោបល់ សូមឱ្យគ្រូជួយនៅពេលមានចម្ងល់<br>- បង្ហាញលទ្ធផល (ឆ្លើយជាបុគ្គល តំណាងក្រុមរាយការណ៍ ជួយបំពេញបន្ថែមឱ្យក្រុមផ្សេង) |

➢ គោលវិធីចម្រុះ៖ មានវិធីរូបី វិធីសន្ទនា វិធីអធិប្បាយ វិធីអនុវត្ត និងវិធីប្រើល្បែង។

តម្រូវឱ្យគ្រូប្រើវិធីរ៉ាយរ៉ាប់ផង វិធីសន្ទនាផងនៅពេលជាមួយគ្នា។ វិធីនេះតម្រូវឱ្យគ្រូអធិប្បាយពន្យល់មេរៀនផងចោទសួរឱ្យកុមារឆ្លើយផងបើជាការចាំបាច់។ មេរៀនមានលក្ខណៈជាការសន្ទនាមួយរវាងគ្រូនិងកុមាររវាងកុមារនិងកុមារគួបផ្សំនឹងការរ៉ាយរ៉ាប់របស់គ្រូ។វិធីនេះងាយស្រួល និងអនុវត្តសម្រាប់ការបង្រៀនគ្រប់ថ្នាក់វិធីចម្រុះមានចំណុចល្អជាច្រើនដូចជា៖

- ពង្រីកបញ្ញា និងការត្រិះរិះរបស់កុមារ
- ជំរុញកុមារឱ្យចូលរួមក្នុងមេរៀនប្រកបដោយការសប្បាយរីករាយ
- ទម្លាប់កុមារឱ្យស្គាល់ ត្រិះរិះពិចារណា និងឆ្លើយបានភ្លាមៗ។ វិធីនេះអាចបណ្ដុះគំនិតឯករាជ្យម្ចាស់ការ និងពង្រីកបុគ្គលិកលក្ខណៈរបស់កុមារ
- អាចឱ្យគ្រូចៀសវាងបាននូវការអនុវត្តតាមទម្លាប់ដដែលៗដូចម៉ាស៊ីន
- អាចទម្លាប់កុមារជួបផ្ទាល់ជាមួយតថភាព និងបានបញ្ចេញសកម្មភាពដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនគេផង ដល់គ្រួសារផង និងមជ្ឈដ្ឋានសង្គមផង។ គ្រូមត្តេយ្យសិក្សាគប្បីអនុវត្តគោលវិធីចម្រុះក្នុងកម្រិតមួយសមស្របប្រកបដោយសិល្បវិធីគួបផ្សំ នឹងបំណិនប្រើប្រាស់សម្ភារឧបទេស ទើបអាចលើកកម្ពស់ប្រសិទ្ធភាពបង្រៀន និងរៀនបានល្អប្រសើរនៅក្នុងម៉ោងសិក្សាមួយ។

➢ វិធីរូបី ឬវិធីជាក់ស្ដែង៖

គឺជាវិធីជួយកុមារឱ្យមានបំណិនសង្កេតបានគ្រប់ជ្រុងជ្រោយមានភាពជឿជាក់ ក្លាហានក្នុងការនិយាយរៀបរាប់បានត្រឹមត្រូវនូវអ្វីដែលបានឃើញ បានស្ដាប់ បានហិត បានប៉ះពាល់ តាមរយៈការបង្ហាញវត្ថុពិត ឬរូបភាព ឬរូបតំណាង ឬកាយវិការ ទឹកមុខ ឬនាំកុមារទៅពិនិត្យផ្ទាល់។

➢ វិធីសន្ទនា៖

គឺជាប្រព័ន្ធសំណួរចម្លើយរវាងគ្រូនិងកុមារ។ក្នុងដំណើរការបង្រៀន គ្រូបំផុសកុមារឱ្យឆ្លើយគ្រប់បញ្ហា ឯកុមារក៏អាចចោទសួរទៅគ្រូឱ្យឆ្លើយបំភ្លឺពល់ចម្ងល់របស់ខ្លួនវិញដែរ។

ដើម្បីអនុវត្តវិធីនេះឱ្យមានប្រសិទ្ធភាព គ្រូគប្បីយកចិត្តទុកដាក់លើ៖

**១.ការរៀបចំសន្ទនារវាងកុមារ និងកុមារឱ្យបានច្រើន**

**២.ការប្រើប្រាស់សំណួរ**

- ប្រើសំណួរឱ្យចំបញ្ហា ពាក្យសម្ដីសាមញ្ញ ខ្លី ងាយយល់ និងមានទំនាក់ទំនងគ្នាតាមលំដាប់លំដោយ

- ប្រើសំណួរសមស្របតាមវ័យ តាមកម្រិតយល់ដឹងរបស់សិស្ស
- ប្រើសំណួរដែលបង្កប់ចម្លើយខ្លះដើម្បីលើកទឹកចិត្តកុមារឱ្យឆ្លើយបានល្អ។

**ពារបៀបចោទសំណួរទៅកាន់កុមារដែលលំបាកក្នុងការឆ្លើយសំណួរ.**

- ចោទសំណួរទៅកាន់កុមារទាំងអស់ ដើម្បីត្រិះរិះពិចារណា
- ហៅកុមារមានសមត្ថភាពម្នាក់ឱ្យឆ្លើយសំណួរ ដើម្បីឱ្យកុមារឯទៀតតាមដានចម្លើយ និង ជួយកែតម្រូវឬលើកដៃឡើងផ្តល់ចម្លើយថ្មីដែលប្រសើរជាង
- ជំរុញ និងលើកទឹកចិត្តកុមារដែលមិនសូវនិយាយស្តីឱ្យឡើងឆ្លើយ
- មិនបន្ទះបង្អាប់កុមារណាដែលឆ្លើយមិនត្រូវ គ្រូគប្បីប្រើរូបភាពនិងផ្លាស់ប្តូរសំណួរឱ្យបាន ទាន់ពេលដោយរក្សាខ្លឹមសារដដែល។បើនៅតែឆ្លើយមិនបានទៀត គ្រូហៅកុមារពូកែឱ្យ ឡើងឆ្លើយជំនួស
- អំណត់ព្យាយាមរង់ចាំស្តាប់ចម្លើយកុមារ ចៀសវាងការឆ្លើយកាត់សម្តីភ្លាមៗ ព្រោះកុមារខ្លះ មានស្មារតីយឺត ។

- ចុងបញ្ចប់ គ្រូសំយោគចម្លើយត្រឹមត្រូវសំខាន់ៗរបស់កុមារ ចងក្រងជាចំណេះដឹងថ្មីសម្រាប់កុមារ សិក្សា។

➢ **វិធីអធិប្បាយ៖** គឺជាវិធីពន្យល់ បកស្រាយ អធិប្បាយចំណុចសំខាន់ៗនៃមេរៀន និងចម្ងល់របស់ កុមារដោយប្រើពាក្យសម្តីច្បាស់លាស់ សាមញ្ញ ខ្លី ងាយស្តាប់ ងាយយល់ មានទំនាក់ទំនងជា ប្រព័ន្ធ និងត្រឹមត្រូវទៅតាមលំដាប់លំដោយនៃខ្លឹមសារមេរៀន។

វិធីនេះ ទាមទារឱ្យគ្រូមត្តេយ្យសិក្សាអនុវត្តតាមសំណូមពរដូចខាងក្រោម៖

- ប្រើពេលវេលាខ្លីបំផុតសម្រាប់ការពន្យល់ បកស្រាយ អធិប្បាយមេរៀន ចៀសវាងកុមារស្មុគ ស្មាញធុញថប់
- យកចិត្តទុកដាក់ដល់ចំណាប់អារម្មណ៍របស់កុមារដោយលើកទឹកចិត្ត និងបង្កលក្ខណៈឱ្យ កុមារបានបញ្ចេញមតិយោបល់ រួចពន្យល់បកស្រាយឱ្យកុមារបានយល់អស់ចម្ងល់
- យកចិត្តទុកដាក់ដល់ប្រតិកម្មតបតាមរយៈការបញ្ចេញសកម្មភាព និងទឹកមុខរបស់កុមារ ដើម្បីវាយតម្លៃលើការបង្រៀន និងរៀន និងចាត់វិធានការកែលម្អបានទាន់ពេលវេលា។

➢ **វិធីអនុវត្ត៖** គឺជាវិធីហ្វឹកហាត់ ពង្រឹងចំណេះដឹងរបស់កុមារ ដើម្បីឈានទៅសម្រេចវត្ថុបំណង នៃមេរៀន។ វិធីអនុវត្តមាន ការហ្វឹកហាត់ និងការដកបទពិសោធន៍។

➢ **ការហ្វឹកហាត់៖** កុមារអនុវត្តលំហាត់ច្រើនបែប ច្រើនវិធីបញ្ជាក់លើខ្លឹមសារសំខាន់ក្នុងមេរៀនតែ មួយ ដើម្បីពង្រឹងចំណេះដឹងឱ្យកុមារទទួលបាននូវគុណភាពសិក្សា។

ឧទាហរណ៍៖ បន្ទាប់ពីសន្ទនា « ការចោលសំរាម »កុមារហ្វឹកហាត់ពីរបៀបចោលសំរាមតាមភេទ និងរបៀបវេចខ្ចប់សំរាមយកទៅចោលនៅផ្ទះ។ជាបណ្តើរៗ កុមារនឹងមានទម្លាប់ក្នុងការចោលសំរាម និង គ្រប់គ្រងសំរាមបានល្អ។

➢ **ការដកបទពិសោធន៍ ៖**

ការដកបទពិសោធន៍ គឺជាសកម្មភាពត្រូវនឹងចំណង់ចំណូលចិត្តរបស់កុមារដែលមាននិស្ស័យ ចង់ចេះ ចង់ដឹងចង់ស្រាវជ្រាវរុករក ចង់ដកពិសោធន៍នូវអ្វីជាចម្ងល់ចាំបាច់របស់ខ្លួន។ ស្របតាមនិស្ស័យ នេះ គ្រូគប្បីរៀបចំសកម្មភាពឱ្យកុមារដកបទពិសោធន៍ ដើម្បីងាយស្រួលទទួលបាននូវគុណភាពផ្ទេរ ចំណេះដឹងឱ្យកុមារ។

ឧទាហរណ៍៖ បន្ទាប់ពីស្តាប់រឿងនិទាន«នារីកូនល្អ» គ្រូឱ្យកុមារសាកល្បងធ្វើអំពើល្អមួយដាក់នរណាម្នាក់ក្នុងគ្រួសារស្នែកឡើង គ្រូយកព័ត៌មានពីកុមារនូវផលតបស្នងអំពើល្អរបស់ខ្លួន។ (កិច្ចការនេះត្រូវសហការជាមួយគ្រួសារ)។

➢ **វិធីប្រើល្បែង៖** គឺជាវិធីនាំកុមារលេងដើម្បីផ្តល់និងពង្រឹងចំណេះដឹងដល់កុមារ។ វិធីនេះមានអត្ថប្រយោជន៍ណាស់ចំពោះកុមារ ព្រោះការលេងជាចំណង់ចំណូលចិត្តរបស់កុមារក្នុងការសិក្សាស្រាវជ្រាវ រុករក ស្វែងយល់ដកបទពិសោធន៍និងបង្ហាញពីសមត្ថភាពរបស់ខ្លួនថាអាចធ្វើបាន។ ក្រៅពីវិធីសាស្ត្រផ្សេងៗដែលបានអនុវត្តក្នុងដំណើរការបង្រៀនសម្រាប់ម៉ោងសិក្សាមួយ គ្រូមត្តេយ្យសិក្សាអាចរៀបចំសកម្មភាពល្បែងតាមការច្នៃប្រឌិត និងបំណិនប្រសប់ទៅក្នុង៖

- ជំហានទី២ ត្រួតពិនិត្យមេរៀនចាស់រយៈពេល២នាទីទៅ៣នាទី ដើម្បីរំឭកមេរៀនចាស់
- ជំហានទី៣ មេរៀនថ្មីសម្រាប់ការផ្តល់ និងបញ្ជាក់ការយល់ដឹងរបស់កុមារ
- ជំហានទី៤ ពង្រឹងចំណេះដឹង ដើម្បីបញ្ជាក់លើការយល់ដឹងរបស់កុមារ។

#### ៤.ការផលិត និងប្រើប្រាស់សម្ភារឧបទេស៖

សម្ភារឧបទេសសម្បូរបែបទៅបាន គឺអាស្រ័យដោយគ្រូមត្តេយ្យសិក្សាមានបំណិនស្រាវជ្រាវពោរពេញដោយគំនិតផ្តួចផ្តើមសន្សំសំចៃច្នៃប្រឌិតផលិត និងប្រើប្រាស់សម្ភារឧបទេសឱ្យមានលក្ខណៈវិទ្យាសាស្ត្រ មានសោភ័ណ សមស្របតាមលក្ខណៈគរុកោសល្យ ។ ទន្ទឹមនឹងការងារនេះ គ្រូត្រូវបណ្តុះនិស្ស័យល្អៗដល់កុមារឱ្យមានចិត្តស្មោះត្រង់ជួយទុក្ខធុរៈមនុស្សជុំវិញខ្លួន និងបំណិនច្នៃប្រឌិតតាមរយៈការនាំកុមារសន្សំសម្ភារៈបោះចោលនិងសម្អាតកំចាត់មេរោគរួចច្នៃប្រឌិតផលិតជាសម្ភារល្បែងងាយៗ ឬសម្ភារៈតុបតែងលម្អងាយៗ ឬជាសម្ភារឧបទេសងាយៗជាដើម។ចំពោះរបៀបនៃការប្រើប្រាស់សម្ភារឧបទេស គ្រូគប្បីយកចិត្តទុកដាក់ដល់៖

- ការរៀបចំសម្ភារៈសម្រាប់គ្រូ និងសម្រាប់កុមារឱ្យបានគ្រប់គ្នា ឬគ្រប់ក្រុម
- ការដាក់សម្ភារៈកំបាំងភ្នែកកុមារ និងងាយលើកយកមកបង្ហាញកុមារម្តងមួយៗឱ្យត្រូវតាមលំដាប់លំដោយ
- កាន់សម្ភារៈបង្ហាញកុមារឱ្យមានលំនឹង មិនបាំងរូបភាព និងមិនចាំបាច់ចង្អុលក្នុងផ្ទាំងរូបភាព ដើម្បីទុកពេលឱ្យកុមារសង្កេត និងតាមដានការពន្យល់របស់គ្រូ
- ការរៀបសម្ភារៈដែលរៀនរួចនិងទុកដាក់សម្ភារៈសម្រាប់កុមារឱ្យងាយស្រួលយកមកលេង ឬប្រើប្រាស់
- ការផ្លាស់ប្តូរសម្ភារៈដែលព្យួរ និងសម្ភារល្បែងឱ្យបានញឹកញាប់ទៅតាមខ្លឹមសារមេរៀន។

## ៣.៣.ការគ្រប់គ្រងដំណើរការបង្រៀននិងរៀន

### ៣.៣.១. លំនាំបង្រៀនសកម្មគោលមុខវិជ្ជាសិក្សាសង្គម

ដើម្បីជាជំនួយក្នុងការរៀបចំសកម្មភាពបង្រៀន ឱ្យមានប្រសិទ្ធភាព គ្រូគប្បីអនុវត្តតាមលំនាំនៃការបង្រៀន។ ទាំងនេះគឺជាឧទាហរណ៍ សម្រាប់ជំនួយស្មារតីគ្រូមត្តេយ្យសិក្សាងាយស្រួលដល់ការរៀបចំដំណើរការបង្រៀន និងរៀនទៅតាមបទពិសោធន៍ និងការច្នៃប្រឌិតឱ្យមានប្រសិទ្ធភាព។មានន័យថាគ្រូអាចម្ចាស់ការរៀបចំលំនាំបង្រៀនបាន។

### ៣.៣.១.១. លំនាំបង្រៀនសកម្មភាពប្រចាំថ្ងៃ និងទម្លាប់ល្អ

ការអនុវត្តសកម្មភាពប្រចាំថ្ងៃ ទទួលបានប្រសិទ្ធភាព គឺតម្រូវឱ្យគ្រូមត្តេយ្យសិក្សាគប្បីត្រូវៈ

- ប្រកាន់ខ្ជាប់នូវទឹកមុខរីករាយសម្ដែងការគួរសមរវាងគ្រូនិងកុមារឱ្យបានជិតស្និទ្ធជារៀងរាល់ព្រឹក
- សំណេះសំណាលខ្លះៗអំពីការសាកសួរសុខទុក្ខកុមារ ដោយផ្សារភ្ជាប់ទៅនឹងការប្រើប្រាស់តារាងវត្តមាន
- តារាងថ្ងៃប្រចាំសប្ដាហ៍ និងតារាងប្រតិទិនប្រចាំខែ និងតារាងផ្សេងៗទៀតតាមការច្នៃប្រឌិត
- ទម្លាប់កុមារឱ្យទុកដាក់សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនមានសណ្ដាប់ធ្នាប់
- បង្កបរិយាកាសរីករាយតាមការច្នៃប្រឌិត និងអនុវត្តសកម្មភាពប្រចាំថ្ងៃឱ្យបានទៀងទាត់

❖ ចំពោះការប្រើតារាងឆ្នាំខ្មែរទាំង១២ ខែទាំង១២ និងតារាងផ្សេងៗ គ្រូមត្តេយ្យសិក្សាច្នៃប្រឌិតសកម្មភាពទៅតាមពេលវេលាអំណោយផល។

**ឧទាហរណ៍៖ សកម្មភាពប្រចាំថ្ងៃ និងទម្លាប់ល្អ**

មានសារសំខាន់ណាស់ មិនអាចខ្វះបាន និងតម្រូវឱ្យគ្រូអនុវត្តជារៀងរាល់ថ្ងៃមុននឹងដំណើរការបង្រៀន និងរៀនពីព្រោះសកម្មភាពប្រចាំថ្ងៃនេះ ជាជំនួយដល់មុខវិជ្ជាទាំង ៥ ឱ្យសម្រេចបាននូវលទ្ធផលរំពឹងទុកក្នុងកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា។ ដូចនេះ មុខវិជ្ជាសិក្សាសង្គមបានជួយកុមារឱ្យៈ

- ទទួលបានការអប់រំចិត្តសង្គមដូចជាទម្លាប់ល្អក្នុងការទុកដាក់សម្ភារៈឱ្យមានសណ្ដាប់ធ្នាប់ ទម្លាប់ល្អក្នុងការសម្ដែងការគួរសម បង្ហាញអារម្មណ៍ស្មោះត្រង់ ការចែករំលែក ការយោគយល់ ការមិនបង្កជម្លោះ ការសារភាពកំហុស ការគាំទ្រការអបអរសាទរស្នាដៃរបស់មិត្តភក្ដិ ជាដើម
- អភិវឌ្ឍបំណិនចលនា នៃរាងកាយទាំងមូលបានទន់ភ្លន់រហ័សរហួនស្វាហាប់ នៅក្នុងមុខវិជ្ជាចិត្តចលភាព
- មានទម្លាប់ធ្វើអនាម័យខ្លួនប្រាណអនាម័យបរិស្ថាន និងយល់ដឹងពីធាតុអាកាសនៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ
- ពង្រីកពាក្យបានច្រើនសម្រាប់ការសន្ទនានៅក្នុងមុខវិជ្ជាភាសាខ្មែរ
- ស្គាល់ឈ្មោះថ្ងៃ ពេលវេលា កាលបរិច្ឆេទ និងមករៀនទៀងទាត់នៅក្នុងមុខវិជ្ជាសិក្សាសង្គម
- ចូលរួមរៀបចំថ្នាក់រៀនឱ្យជាទីមេត្រី និងបង្កើនទំនាក់ទំនងជិតស្និទ្ធជាមួយមាតាបិតាអាណាព្យាបាលឱ្យចូលរួមសហការអប់រំកូនបន្ថែម។

➕ នៅរៀងរាល់ព្រឹកមុននឹងអនុវត្តសកម្មភាពបង្រៀននិងរៀន គ្រូមត្តេយ្យសិក្សានាំកុមារអនុវត្តសកម្មភាពប្រចាំថ្ងៃ៖

- ការគួរសម (ទម្លាប់កុមារជម្រាបសួរគ្រូ និងមិត្តភក្ដិជារៀងរាល់ព្រឹក)
- ការពិនិត្យវត្តមាននិងអវត្តមានកុមារ ហៅឈ្មោះកុមារ ឬនាំកុមារដាក់បណ្ណឈ្មោះក្នុងតារាងវត្តមានកុមារ
- ការប្រើប្រាស់តារាងសកម្មភាពប្រចាំថ្ងៃតារាងវត្តមានកុមារតោរាងប្រតិទិនប្រចាំខែ តារាងថ្ងៃប្រចាំសប្ដាហ៍ ...
- ទម្លាប់ល្អសម្អាតថ្នាក់រៀនការបោចសំរាមបង្កុយកុមារតាមក្រុម ការទុកដាក់សម្ភារៈឱ្យមានសណ្ដាប់ធ្នាប់ ...។

- ក្នុងដំណើរការសកម្មភាពប្រចាំថ្ងៃនេះ គ្រូត្រូវព្យាយាមតាមដានការប្រព្រឹត្តរបស់កុមារម្នាក់ៗ និងកែលម្អកុមារភ្លាមៗប្រកបដោយភាពសប្បាយរីករាយទើបល្អប្រសើរ។

### ៣.៣.១.២. លំនាំបង្រៀន ល្បែង

មគ្គុទ្ទេសក៍ជាអាចនាំកុមារលេងល្បែងមួយតាមលំនាំបង្រៀនដែលជាឧទាហរណ៍ដូចខាងក្រោម៖

- ប្រាប់ចំណងជើងល្បែង
- បង្ហាញសម្ភារល្បែងឱ្យកុមាររៀបរាប់
- ណែនាំរបៀបលេង និងលក្ខខណ្ឌល្បែង
- កុមាររៀបរាប់ឡើងវិញពីរបៀបលេង និងលក្ខខណ្ឌល្បែង
- កុមារអនុវត្ត
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលល្បែង។

❖ **ឧទាហរណ៍៖ សកម្មភាពល្បែង**

- **ល្បែងសិក្សា៖** គឺជាប្រភេទល្បែងសម្រាប់ការលើកកម្ពស់គុណភាពសិក្សារបស់កុមារក្នុងការផ្តល់ និងពង្រឹងចំណេះដឹងដែលមាននៅតាមមុខវិជ្ជាផ្សេងៗទៀត។
- **ល្បែងចលនា ៖**គឺជាប្រភេទល្បែងជួយកុមារឱ្យរីកចម្រើនរាងកាយនិងចលនា មានន័យថាកុមារបានបង្កើនកម្លាំងកាយ ចិត្តបញ្ញាប្រឈមទប់ទល់នឹងឧបសគ្គដោយសន្តិវិធីក្នុងពេលលេង។
  **ឧទាហរណ៍៖** ល្បែងផ្ទាត់កៅស៊ូ ល្បែងឆ្មាចាប់កណ្តុរ ល្បែងស្វាដណ្តើមទី ល្បែងរាំដណ្តើមកៅអី ...
- **ល្បែងច្នៃប្រឌិត៖** គឺជាប្រភេទល្បែងដែលបង្កើតឡើងដោយគំនិតច្នៃប្រឌិត( ការបង្កើតថ្មី )របស់កុមារដែលកុមារចូលចិត្តលេងសាងសង់គ្រាប់តាមសកម្មភាព ឬមុខរបររបស់មនុស្សធំក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។
  **ឧទាហរណ៍៖**ល្បែងសាងសង់ ល្បែងបាយឡុកបាយឡ ល្បែងគ្រាប់តាមគ្រូពេទ្យ។...
- **ល្បែងសេរី ៖** គឺជាប្រភេទល្បែងដែលកុមារជ្រើសរើសយកមកលេងតាមចំណង់ចំណូលចិត្តមានក្នុងចំណោមល្បែងផ្សេងៗដូចជា ល្បែងប្រជាប្រិយ ល្បែងតាមជ្រុងថ្នាក់រៀនក្នុងនោះ មានល្បែងសិក្សា ល្បែងចលនា និងល្បែងច្នៃប្រឌិតជាដើម។

### ៣.៣.១.៣. លំនាំបង្រៀន ចម្រៀង តន្ត្រី របាំ

ចំពោះគ្រូដែលមានភាពជឿជាក់លើសមត្ថភាពផ្ទាល់ខ្លួន គ្រូអាចម្ចាស់ការច្នៃប្រឌិតរៀបចំលំនាំបង្រៀននិងដំណើរការបង្រៀនទៅតាមបទពិសោធន៍ឱ្យមានលក្ខណៈគរុកោសល្យ។លំនាំបង្រៀនខាងក្រោមនេះគឺជា៖

ឧទាហរណ៍៖មួយបែបត្រូវបានរៀបចំឡើងក្នុងគោលបំណងជួយសម្រួលដល់គ្រូងាយយកទៅរៀបចំដំណើរការបង្រៀនកុមារឱ្យមានប្រសិទ្ធភាព។

❖ **លំនាំបង្រៀនចម្រៀង (ពេលទី១)**

- ច្រៀង និងធ្វើកាយវិការឱ្យកុមារស្តាប់ និងសង្កេត១ចប់
- ប្រាប់ឈ្មោះអ្នកនិពន្ធ
- បំផុសរកចំណងជើងបទចម្រៀងនិងលំនាំបទចម្រៀង
- ពន្យល់ពាក្យលំបាក និងអត្ថន័យចម្រៀង

- កុមារអានខ្លឹមសារចម្រៀងម្តង១ឃ្លាៗរហូតដល់ចប់
- នាំកុមារកំដៅសំឡេង
- នាំកុមារហ្វឹកហាត់ច្រៀងឃ្លាទី១ ឃ្លាទី២ រួចច្រៀងឃ្លាទី១ និងទី២កុមារហ្វឹកហាត់របៀប
- នេះរហូតដល់ចប់ចម្រៀង
- ច្រៀងបំបាត់ពាក្យ កុមារច្រៀងតាមខ្លឹមសារបទចម្រៀងរហូតដល់ចប់ច្រៀងបន្ថយសំឡេង
- ម្តងបន្តិចៗ កុមារច្រៀងឮ។

❖ **លំនាំបង្រៀនចម្រៀង(ពេលទី២)**

- បំផុសកុមារឱ្យប្រាប់ចំណងជើង និងលំនាំបទចម្រៀងនាំ
- កុមារកំដៅសំឡេងនាំកុមារហ្វឹកហាត់
- ច្រៀង និងធ្វើកាយវិការ(គ្រូច្រៀងបន្ថយសំឡេងរហូតកុមារម្ចាស់ការបាន)
- កុមារច្រៀង និងធ្វើកាយវិការជាបុគ្គល ក្រុមតូច ក្រុមធំ។

❖ **ឧទាហរណ៍៖ សកម្មភាពចម្រៀង របាំ និងតន្ត្រី**

សកម្មភាពចម្រៀង របាំ និងតន្ត្រីគឺបំបាត់ភាពធុញថប់ មានមនោសញ្ចេតនាជ្រាលជ្រៅ មានសីលធម៌រស់នៅល្អ ចូលចិត្តភាពស្រស់ស្អាត និងសប្បាយរីករាយក្នុងការសិក្សាមុខវិជ្ជាផ្សេងៗទៀតប្រកបដោយប្រសិទ្ធភាពដូចជា៖

- ស្រឡាញ់ ចូលចិត្ត ស្តាប់តន្ត្រី និងច្រៀងចម្រៀង
- មានរាងកាយលូតលាស់សមស្របមាំមួន មានតុល្យភាពមានបំណិនធ្វើសកម្មភាពនិងធ្វើពលកម្មស្រាលៗនិងធ្វើឱ្យសាច់ដុំត្រចៀកភ្នែកនិងដៃ ធ្វើចលនាបានស្របគ្នាបានយ៉ាងឆាប់រហ័សតាមរយៈកាយវិការបទចម្រៀង។

➢ **ចម្រៀង** គឺជាបណ្តុំពាក្យចាប់ចុងជួន ចងក្រងជាឃ្លា ជាប្រយោគឱ្យមានអត្ថន័យពិរោះរណ្តំផ្សារភ្ជាប់ទៅនឹងជីវិតរស់នៅប្រចាំថ្ងៃ និងតថភាពរបស់សង្គម។

➢ **របាំ** គឺជាក្បាច់រាំតាមបែបបទចម្រៀង និងចង្វាក់ភ្លេង។របាំបង្ហាញនូវអត្តសញ្ញាណជាតិ និងវប្បធម៌ប្រពៃណីរបស់ប្រទេសនីមួយៗ។ របាំមាន៣ប្រភេទគឺ៖

- របាំបុរាណខ្មែរមានដូចជា របាំជូនពរ របាំកូនមាន់តឿ ជាដើម។
- របាំប្រពៃណីខ្មែរមានដូចជា របាំត្រុដិ របាំក្ងោកប៉ៃលិន ជាដើម។
- របាំប្រជាប្រិយមានដូចជា រាំវង់ រាំក្បាច់ រាំសារ៉ាវ៉ាន់ជាដើម។

➢ **តន្ត្រី** គឺជាឧបករណ៍ភ្លេងដែលមានប្រភេទផ្លុំ(ខ្លុយ ប៉ី ផ្លុំស្លឹក...) គោះ ដំ វាយ (រនាត ស្គរ...) ដេញកេះ( ឃឹមត្រលោក ទ្រ ឃឹមប្រអប់ដែក)។

នៅមត្តេយ្យសិក្សា គ្រូអាចច្នៃប្រឌិតបង្កើតឧបករណ៍ភ្លេងសម្រាប់កុមារលេង និងប្រគំតន្ត្រីមានដូចជា ផ្លុំស្លឹកចេកស្លឹកដូង គោះឫស្សី គោះស្គរ ធុងទឹក គោះដបភ្លេង គំរបដបសំរាប់គោះ កងគោះ ស្គរបង្ហិលឫស្សីគ្រវី ឫស្សីគ្រលុកកាសបន្លឺសំឡេង ដងសំឡេង កណ្តឹងត្រលោក កាសត្រលោកភ្លោះជាដើម។

### ៣.៣.១.៤. លំនាំបង្រៀន គំនូរ

- បង្ហាញរូបគំនូរគំរូ (គំនូសមូលដ្ឋាន គំនូសអក្សរ គំនូរតាមវត្ថុគំរូគំនូរផាត់ពណ៌គំនូរផ្គុំមគំនូរផ្តិតនិងគំនូរតុបតែងលម្អ)

- ណែនាំអំពីរបៀបគូសគំនូស ឬគូររូបនៅលើក្ដារខៀន
- កុមារគូសសាកល្បងលើក្ដារខៀន ១ ឬ ២ នាក់ អាស្រ័យតាមពេលវេលា
- ចែកសម្ភារៈ និងឱ្យកុមារអនុវត្ត
- សម្របសម្រួល និងជំរុញលើកទឹកចិត្តកុមារ
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផល និងវាយតម្លៃស្នាដៃកុមារ។

**កំណត់សម្គាល់៖**

- ចំពោះចំណងជើងមេរៀន គ្រូអាចបំផុសសំណួរឱ្យកុមារប្រាប់ចំណងជើងគំនូរ មុនឬក្រោយការបង្ហាញរូបគំរូ ឬមុន ឬក្រោយដំណើរការបង្រៀន ឬនៅត្រង់ចំណុចណាមួយក្នុងលំនាំបង្រៀនគំនូរទៅតាមខ្លឹមសារមេរៀន
- ចំពោះគំនូរតាមប្រធានបទ គំនូរបែបសហការ និងគំនូរសេរី គ្រូមិនចាំបាច់បង្ហាញរូបគំរូ ប៉ុន្តែគ្រូត្រូវតែបំផុសសំណួរកុមារឱ្យរំឭកពីអ្វីដែលធ្លាប់ស្គាល់ ធ្លាប់ឃើញ និងប្រាប់ចំណងជើងមេរៀន។

**❖ ឧទាហរណ៍៖ សកម្មភាពគំនូរ**

គំនូរនៅមត្តេយ្យសិក្សា មានគោលបំណងជួយកុមារឱ្យរីកចម្រើនសាច់ដុំម្រាមដៃពង្រឹងចលនាម្រាមដៃក្នុងការកាន់ទប់លំនឹងខ្មៅដៃ កំណត់ព្រំដែននៃសំណេរបានត្រឹមត្រូវ ធ្វើឱ្យកុមារស្រឡាញ់សោភ័ណ និងមានគំនិតច្នៃប្រឌិត។ គំនូរមានលក្ខណៈជាសិល្បៈ ដែលតម្រូវឱ្យគ្រូមត្តេយ្យសិក្សាយកចិត្តទុកដាក់រៀបចំខ្លឹមសារបង្រៀនកុមារគូរគំនូរដោយរីករាយ មានលំនឹកល្អ ពោរពេញដោយរូបបារម្មណ៍ច្នៃប្រឌិតផ្សារភ្ជាប់ចំណេះដឹងទៅនឹងជីវភាពប្រចាំថ្ងៃទៅនឹងបាតុភូតធម្មជាតិ និងការរៀនគូរគំនូរដោយការចាប់ផ្ដើមពីងាយទៅលំបាក និងកាន់តែលំបាកឡើង។ សកម្មភាពគំនូរនៅមត្តេយ្យសិក្សាមាន៨៖

➢ **គំនូស ៖**

**១. គំនូសមូលដ្ឋាន ៖** គឺជាគំនូសដើម ឬគំនូសដំបូងដែលមានគំនូសចំនួន៩ ក្នុងនោះមានគំនូសត្រង់បញ្ឈរត្រង់ដេក គំនូសត្រង់ទ្រេតឆ្វេង គំនូសត្រង់ទ្រេតស្ដាំ គំនូសកោងផ្កាប់ និងកោងផ្ងារ កោងឆ្វេង និងកោងស្ដាំនិងគំនូសរង្វង់។ ក្នុងចំណោមគំនូសមូលដ្ឋានទាំងអស់នេះ គ្រូអាចផ្សំបញ្ចូលគ្នាបង្កើតជាគំនូសអក្សរតួអក្សរ និងរូបភាពងាយៗទៅតាមការច្នៃប្រឌិត។

**២. គំនូសអក្សរ ៖** គឺជាការផ្សំគំនូសមូលដ្ឋានបញ្ចូលគ្នាបង្កើតជារាងតួអក្សរដែលមានលក្ខណៈ មិនពេញលេញកុមារគូសគំនូសអក្សរមិនដកដៃដោយចាប់ផ្ដើមពីគំនូសកោងផ្កាប់ ឬគំនូសកោងផ្ងារបន្តជាប់គ្នា ឬគំនូសមូលដ្ឋានផ្សេងៗដែលបន្តជាប់គ្នាតាមការច្នៃប្រឌិតរបស់គ្រូ។

➢ **គំនូរ ៖.**

- គំនូរតាមរូបគំរូ៖ គឺជាការគូរតាមវត្ថុពិត តាមរូបគំនូរ ឬរូបភាពគំរូដែលគ្រូបានបិទបង្ហាញនៅលើក្ដារខៀន។
- គំនូរតុបតែងលំអ៖ គឺជាការគូរតុបតែងលម្អបន្ថែមលើរូបគំនូរ ឬរូបភាពមួយដែលគ្រូបានត្រៀមទុកជាមុន។
- គំនូរតាមប្រធានបទ៖ គឺជាគំនូរដែលគ្រូបានកំណត់គោលដៅរួមឱ្យកុមារគូរដោយគ្មានរូបគំរូ។

**ឧទាហរណ៍ ១៖** គំនូរផ្លែស្វាយ៖ គឺកុមារអាចគូរផ្លែស្វាយខ្ចី ឬស្វាយទុំមានទង ឬផ្លែស្វាយ២ផ្លែ ឬផ្លែស្វាយ ១ ចង្កោម។

**ឧទាហរណ៍ ២៖** គំនូរសត្វជើងពីរ: គឺកុមារអាចគូរសត្វទា ឬកូនមាន់។

**៤. គំនូរសេរី៖** គឺជាការគូរតាមចំណង់ចំណូលចិត្តរបស់កុមារ គូរតាមការស្រមើស្រម៉ៃ ។

**៥. គំនូរផាត់ពណ៌៖** គឺជាការផាត់ពណ៌លើរូបគំនូរដែលមានស្រាប់( គំនូរម៉ោងសិក្សាមុនឬគំនូរត្រៀមរបស់គ្រូ )

**៦. គំនូរផ្តាម៖** គឺជាការគូរផ្តាមតាមទម្រង់វត្ថុ ឬសម្ភារប្រើប្រាស់ងាយៗ ឬរូបភាព ឬរូបគំនូរងាយៗ។

**ឧទាហរណ៍ ១៖** គំនូរផ្តាមប្រអប់ដៃ ប្រអប់ជើង គំនូរផ្តាមរង្វង់មាត់ចាន គំនូរផ្តាមរាងទន្សាយ។

**ឧទាហរណ៍ ២៖** គំនូរផ្តាម រូបទន្សាយ (ដាក់ក្រដាសស្តើងពីលើរូបទន្សាយឱ្យកុមារគូរតាម)។

**៧. គំនូរផ្តិត៖** គឺជាសិល្បៈគំនូរមួយប្រភេទដែលគ្រូអនុវត្តបានតាមការច្នៃប្រឌិតដូចខាងក្រោម៖ ការជ្រលក់ពណ៌ផ្តិតយករូបរាងដើមនៃវត្ថុ ៖ ប្រៀបដូចជាការបោះពុម្ពឱ្យចេញរូបភាពផ្សេងៗ ដោយប្រើជាងចេកឬត្រារូបភាព ឬផ្តិតម្រាមដៃ ម្រាមជើង ឬប្រអប់ដៃ ប្រអប់ជើងជាដើម

- ការផ្តិតយកពណ៌ចេញជារូបភាពផ្សេងៗ៖ បត់ក្រដាសស្តើង រួចជ្រលក់ពណ៌នៅផ្នែកខាងចុងផ្ទត់បន្ទាប់មកលាក្រដាសចេញ ហើយហាលថ្ងៃឱ្យស្ងួត ឬចងក្រណាត់ជាដុំតូចៗ រួចជ្រលក់ពណ៌នៅផ្នែកខាងចុងចំណង បន្ទាប់មកស្រាយចំណងកៅស៊ូហើយហាលថ្ងៃឱ្យស្ងួត
- ការផ្តិតយករូបរាងដើមរបស់វត្ថុ៖ តាមរយៈការផាត់ពណ៌ស្រាលៗដោយខ្មៅដៃ ឬខ្មៅដៃពណ៌នៅលើក្រដាសដែលដាក់ពីលើស្លឹកឈើ លើរូបភាព លើវត្ថុដែលលាន ឬលឹប វានឹងបង្ហាញនូវរូបស្លឹកឈើ ឬរូបភាពដើមនោះ ។

**៨. គំនូរបែបសហការ៖** គឺជាការងារដៃគូ ឬក្រុមតូចដែលតម្រូវឱ្យកុមារពិភាក្សាគ្នា សហការគ្នាគូររូបវី ឬគូរតាមប្រធានបទ ឬគូរតុបតែងលម្អទៅតាមការកំណត់របស់គ្រូ។

### ៣.៣.១.៥. លំនាំបង្រៀន សកម្មភាពកសាង

- បង្ហាញរូបភាពគំរូ
- ណែនាំអំពីរបៀបហែក បិទ បត់ កាត់ ដោត ដេរ រោយ សូន
- កុមារអនុវត្តសាកល្បង
- បំផុសរកចំណងជើងមេរៀន
- ចែកសម្ភារៈ និងឱ្យកុមារអនុវត្ត ( ជាបុគ្គល ឬជាក្រុម )
- សម្របសម្រួលនិងជំរុញលើកទឹកចិត្តកុមារ
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផល និងវាយតម្លៃស្នាដៃកុមារ។
- ការបង្កើតបរិយាកាសរៀនសូត្រប្រកបដោយភាពកក់ក្តៅនិងវិជ្ជមាន
- ការរៀបចំបរិស្ថានដែលជួយឱ្យអភិវឌ្ឍរាងកាយ

❖ **ឧទាហរណ៍៖ សកម្មភាពកសាង**

**១. ការហែក៖** សកម្មភាពនេះ គ្រូបង្វឹកកុមារឱ្យចាប់ផ្តើមហែកក្រដាសជាចម្រៀកតូចៗ បន្ទាប់មកឱ្យកុមាររៀនហែកក្រដាសពីលើចុះក្រោមជាចម្រៀកវែងៗ បន្ទាប់មកឱ្យកុមារហែករូបភាពតាមស្នាមចុច បន្ទាប់មកកុមាររៀនហែកតាមទម្រង់រូបភាព។

**២. ការបិទ៖** ជាចំណុចចាប់ផ្តើម កុមារត្រូវរៀនបិទរូបភាពតូចៗ ឬរូបភាពដែលបានពីស្នាដៃហែកផ្ទាល់ខ្លួនមកបិទឱ្យបានស្អាត មិនជ្រួញមិនប្រឡាក់ការ បន្ទាប់មកកុមារអាចបិទផ្គុំជារូបភាពងាយៗ (មនុស្ស ផ្ទះ... )។ទន្ទឹមនឹងការងារនេះ កុមាររៀនបិទតុបតែងលម្អដោយកំទេចវត្ថុ ឬគ្រាប់ធញ្ញជាតិលើរូបភាពមួយ។

**៣. ការហែកបិទ៖** សកម្មភាពនេះ គឺកុមារអនុវត្តព្រមគ្នាតែមួយម៉ោងសិក្សា។ ផ្តល់ឱកាសឱ្យកុមារហែកយករូប សត្វ វត្ថុ ផ្លែឈើ រាងធរណីមាត្រ រួចយកទៅបិទលើក្រដាស់សដែលគ្រូបានរៀបចំទុករួច ជាស្រេច។

៤. ការបត់៖ ដំបូងកុមាររៀនបត់ក្រដាសឱ្យបាន២ផ្នត់ ៣ផ្នត់ ទៅ៤ផ្នត់ និងអាចលើសពីនេះ ដើម្បីជាមូលដ្ឋាននៃការបត់រូបភាពងាយៗ ដូចជាបត់កែវ បត់ត្រីបាឡែន បត់មួក ជាដើម។

៥. ការកាត់៖ បន្ទាប់ពីកុមារមានបំណិនហែក គ្រូអាចបង្វឹកកុមារឱ្យកាន់កន្ត្រៃមុខទាលកាត់ក្រដាសតាមលំដាប់លំដោយដូចដំណាក់កាលហែកដែរ។

៦. ការកាត់បិទ៖ នៅពេលកុមារមានបំណិនកាត់ គឺកុមារអនុវត្តកាត់បិទព្រមគ្នាក្នុងមួយម៉ោងសិក្សា។

៧. ការសូនរូប៖ សកម្មភាពនេះ កុមារទទួលបានការហ្វឹកហាត់ដោយចាប់ផ្តើមដាក់ដីឥដ្ឋទៅក្នុងពុម្ពចេញជារូបផ្សេងៗ បន្ទាប់មកកុមារសូនរាងមូល រាងមូលទ្រវែងដោយដៃម្ខាង ដោយដៃទាំង២ បន្ទាប់មកកុមារសូនរូបផ្សេងៗបានតាមគំនិតច្នៃប្រឌិត។

៨. ការដោត៖ កុមារហ្វឹកហាត់ដោតដោយចាប់ផ្តើមពីការដោតអង្កាំរន្ធធំៗបន្តគ្នា ដោតអង្កាំរន្ធតូចៗបន្តគ្នាដោតអង្កាំតូចធំ តាមពណ៌ តាមរាងទៅតាមចំណូលចិត្ត ដោតអង្កាំតាមគំរូ ដោតអង្កាំច្នៃប្រឌិតជាគ្រឿងតុបតែងលម្អកាយ លម្អថ្នាក់រៀន និងជាបន្តបន្ទាប់កុមារកោច់ព្រលិត ជាងល្ហុងធ្វើជាខ្សែក ខ្សែដៃតាមការរៀបចំរបស់គ្រូ។គ្រូអាចជំនួសគ្រាប់អង្កាំដោយវត្ថុផ្សេងបានទៅតាមលទ្ធភាពរបស់មូលដ្ឋាន។

៩. ការដេរ ៖ គឺជាការដេរតាមទម្រង់រូបភាពដែលបានចោះមានលក្ខណៈរង្វើលញឹក និងខ្វែងចុះឡើងឱ្យកាន់តែលំបាក ជាបន្តបន្ទាប់កុមារដេរភ្ជាប់ស្លឹកឈើ ឬក្រដាស ដើម្បីអភិវឌ្ឍបំណិនចលនាម្រាមដៃ បំណិនគិត និងបំណិនច្នៃប្រឌិតឱ្យមានលក្ខណៈសោភ័ណ។

១០. ការពោយ ៖ កុមារហ្វឹកហាត់ចលនាម្រាមដៃពោយកំទេចវត្ថុផ្សេងៗ លើរូបភាពដែលបានលាបការរួច។

១១. ការស្នាច់ ៖ សកម្មភាពស្នាច់នេះ គ្រូនាំកុមារយកក្រដាសស្តើង ឬក្រដាសកាសែតដែលបានកាត់ ឬហែកជាចម្រៀកវែងៗមកបិទលើវត្ថុមួយ( បាល់ ផ្លែននោង...)ឱ្យបានក្រាស់ល្មមពី៤ទៅ៥ជាន់ ឬលើសពីនេះ រួចយកទៅហាលថ្ងៃឱ្យស្ងួត ទើបគ្រូយកកាំបិតមុតមកវះពុះយកបាល់ចេញ។ បន្ទាប់មក គ្រូនាំកុមារបិទស្នាមវះនោះនិងតុបតែងលម្អឱ្យបានជាបាល់ក្រដាសដ៏ល្អមួយ។ គ្រូគប្បីហ្វឹកហាត់កុមារថ្នាក់កម្រិតខ្ពស់នៅឆមាសទី២។

១២. តម្បាញ ៖ សកម្មភាពតម្បាញនេះ តម្រូវឱ្យគ្រូហ្វឹកហាត់ចលនាម្រាមដៃកុមារឱ្យមានបំណិនខ្ទាស់ ចងប្រទាក់ ឬក្រង។ដូចនេះគ្រូគប្បីរៀបចំសកម្មភាពបង្រៀនតម្បាញងាយសប្បាយៗឱ្យសមស្របតាមសមត្ថភាពរបស់កុមារមាន៖

- **តម្បាញ** គឺជាការនាំកុមារត្បាញខ្ទាស់បន្ទះក្រដាស បន្ទះស្លឹកដូង ស្លឹកត្នោត ស្លឹកចេកធ្វើ... ជាកន្ទេល កម្រាលថូផ្កាខ្សែក នាឡិកា ចិញ្ចៀន វ៉ែនតាជាដើម
- **ចងប្រទាក់គ្នា ឬក្រង** គ្រូនាំកុមារចងប្រទាក់ ឬក្រងកៅស៊ូ ខ្សែ ស្លឹកដូង ស្លឹកត្នោត ឬស្លឹកចេក វល្លិ សក់ធ្វើជាសម្ភារល្បែង សម្ភារៈតុបតែងលម្អ។ ...

### ៣.៣.២. ការអនុវត្ត

សកម្មភាពប្រចាំថ្ងៃ ត្រូវបានគ្រូ.មត្តេយ្យសិក្សានាំកុមារអនុវត្តជារៀងរាល់ថ្ងៃឱ្យទៅជាទម្លាប់ល្អ។ សកម្មភាពប្រចាំថ្ងៃរួមមាន៖

- ការពិនិត្យវត្តមាន
- ការបង្ហាញកាលបរិច្ឆេទ
- ការអនុវត្តទម្លាប់ល្អ

### ៣.៣.១.១.របៀបអនុវត្តសកម្មភាពប្រចាំថ្ងៃ

- សម្តែងការគួរសមរវាងគ្រូ និងសិស្សឱ្យបានជិតស្និទ្ធជារៀងរាល់ព្រឹក
- ពិនិត្យវត្តមាន និងអវត្តមានកុមារតាមរយៈ

• ការហៅឈ្មោះកុមារតាមសៀវភៅបញ្ជីហៅឈ្មោះកុមារ។ ការអនុវត្តបែបនេះ នឹងត្រូវចំណាយពេលវេលាច្រើន ឬនាំកុមារឱ្យមានទម្លាប់ល្អក្នុងការដាក់បណ្ណឈ្មោះទៅក្នុងតារាងវត្តមានកុមារ ដោយទម្លាប់កុមារឱ្យចេះឆ្លើយបាទចាសចេះរាយការណ៍ពីមូលហេតុនៃអវត្តមានរបស់មិត្តភក្តិ។ ចំពោះករណីនេះ គ្រូគប្បីបង្កលក្ខណៈឱ្យគ្រួសារកុមារនាំកូនដាក់ ឬត្រឡប់បណ្ណឈ្មោះមកខាងវត្តមានទៅក្នុងតារាងវត្តមាន និងទុកដាក់សម្ភារៈផ្ទាល់ខ្លួនរបស់កូនឱ្យចំណាំកន្លែងនៅមុនម៉ោងសិក្សាដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការយល់ដឹងពីសារសំខាន់នៃការអប់រំកូន និងការចូលរួម។

✚ នៅចុងម៉ោងរៀបចំទៅផ្ទះគ្រូគប្បីទម្លាប់កុមារឱ្យជួយកិច្ចការគ្រូ ដោយត្រឡប់បណ្ណឈ្មោះខាងអវត្តមានចេញមកក្រៅវិញដើម្បីព្រឹកឡើងកុមារត្រឡប់បណ្ណឈ្មោះមកខាងវត្តមានវិញ ក្នុងគោលណងងាយស្រួលគ្រូត្រួតពិនិត្យវត្តមាន និងអវត្តមានកុមារ និងសម្រង់ដាក់ទៅក្នុងសៀវភៅបញ្ជីហៅឈ្មោះកុមារ។

• ទម្លាប់កុមារឱ្យចេះប្រើតារាងថ្ងៃប្រចាំសប្តាហ៍ តារាងប្រតិទិនប្រចាំខែ តារាងថ្ងៃប្រចាំសប្តាហ៍ គឺបំផុសកុមារឱ្យរៀបរាប់សកម្មភាពក្នុងពេលវេលាសមស្របអំពីថ្ងៃទាំងប្រាំពីរ ថ្ងៃរៀនថ្ងៃឈប់សម្រាកថ្ងៃនេះ ថ្ងៃម្សិល ថ្ងៃស្អែក ថ្ងៃខានស្អែក អាកាសធាតុ ពេលព្រឹក ពេលថ្ងៃ ពេលយប់តារាងប្រតិទិនប្រចាំខែ ... គឺនាំកុមារដាក់បណ្ណលេខថ្ងៃទីឱ្យបានរាល់ថ្ងៃ ដោយបញ្ជាក់ពីកាលបរិច្ឆេទថ្ងៃនេះ ថ្ងៃម្សិល ថ្ងៃស្អែក ថ្ងៃឈប់សម្រាក និងថ្ងៃរៀន

• នាំកុមារសង្កេតបរិស្ថានថ្នាក់រៀន ការចោលសំរាម ការទុកដាក់សម្ភារឱ្យមានសណ្តាប់ធ្នាប់ ដោយនាំកុមារកែលម្អ និងបំពេញបន្ថែមចំណុចខ្វះខាត។

### ៣.៣.១.២. ការអនុវត្តល្បែងសិក្សា

- *ការអនុវត្តល្បែងសិក្សារយៈពេល២ទៅ៣នាទី ដើម្បីរំឭកមេរៀនចាស់ក្នុងជំហានទី២*

ឧទាហរណ៍៖ ល្បែង « អ្នកលេងភ្លេង » (គ្រូបង្កើតល្បែងសិក្សាទាក់ទងនឹងការរំឭកមេរៀនចាស់តាមការច្នៃប្រឌិត)

• កុមារ១នាក់ ឡើងមកយករូបភាពដែលផ្កាប់នៅលើតុបង្ហាញម្តងមួយៗដល់មិត្តរួមថ្នាក់ (ចំនួន២/៣សន្លឹក)

• កុមារទាំងអស់ ធ្វើកាយវិការវាយស្គរ កូដទ្រ វាយរនាត ព្រមជាមួយនឹងការបញ្ចេញសំឡេង ស្គរ កូដទ្រ រនាត

• បំផុសកុមារឱ្យរៀបរាប់ឈ្មោះឧបករណ៍ភ្លេងដែលបានស្គាល់ និងភាគច្រើនលេងភ្លេងនៅពេលណាខ្លះ?

- *ការអនុវត្តល្បែងសិក្សានេះ គ្រូអាចច្នៃប្រឌិត ឬដកស្រង់ពីឯកសារផ្សេងៗ ដើម្បីផ្តល់ចំណេះដឹងថ្មី ក្នុងជំហានទី៣*

**ឧទាហរណ៍៖** ល្បែង «សប្បាយនិងមិនសប្បាយចិត្ត» (គ្រូច្នៃប្រឌិតល្បែងតម្រូវតាមប្រធានបទការយល់ដឹងអំពីខ្លួនឯង )

• ចែកកុមារជា២ក្រុម

- ក្រុមនីមួយៗពិភាក្សាអំពីកាយវិការសប្បាយចិត្តនិងមិនសប្បាយចិត្តនិងចាត់តំណាងក្រុម
- ផ្លាស់ប្តូរវេនគ្នាឡើងបង្ហាញកាយវិការឱ្យក្រុមផ្សេងទាយ
- ក្រុមនីមួយៗទាយ និងផ្តល់ចម្លើយត្រឹមត្រូវប្រាប់គ្នាទៅវិញទៅមក
- សម្របសម្រួលលើកទឹកចិត្តកុមារដោយបំផុសសំណួរបញ្ជាក់ពីប្រការដែលនាំឱ្យកុមារសប្បាយ ចិត្តនិងមិនសប្បាយចិត្ត និងក្លាហានក្នុងការប្រាប់ពីអារម្មណ៍របស់ខ្លួនដល់មនុស្សធំ។ ជាពិសេសអ្នកស្តាប់ត្រូវសម្តែងអារម្មណ៍ស្មោះត្រង់ គាំទ្រ អបអរសាទរចំពោះទឹកចិត្តរបស់មិត្តភក្តិ។

- *ការអនុវត្តល្បែងសិក្សារយៈពេល៥ទៅ៧នាទី ដើម្បីពង្រឹងចំណេះដឹងកុមារក្នុងជំហានទី៤*

ការអនុវត្តល្បែងពង្រឹងចំណេះដឹងនេះ សំណូមពរឱ្យគ្រូរៀបចំខ្លឹមសារល្បែងផ្សារភ្ជាប់នឹងមេរៀនថ្មីដែលបានអនុវត្តសកម្មភាពគោលផ្សេងៗខុសពីល្បែង។

ឧទាហរណ៍៖ ល្បែង « តាថាសម្តែងអារម្មណ៍ » (ប្រធានបទ ការយល់ដឹងអំពីខ្លួនឯង)

- កុមារសម្តែងអារម្មណ៍នៅពេលឮពាក្យថា តាថាសើច/យំ/ខឹង/ភ័យ/ព្រួយ... (ម្តងដោយនិយាយម្តងលើករូបមុខបង្ហាញ) បើមិនបានឮពាក្យតាថានៅខាងដើមពាក្យ សើច/ខឹង/យំ/ព្រួយ/ភ័យ... កុមារមិនធ្វើត្រាប់តាមឡើយ បើកុមារធ្វើខុសលក្ខខណ្ឌល្បែង នឹងទទួលបានពិន័យរាំ តាមបទចម្រៀងរបស់អ្នកឈ្នះ។

### ៣.៣.១.៣.ការអនុវត្តល្បែងសេរី

- *ការអនុវត្តល្បែងសេរីក្នុងគោលបំណងផ្តល់ និងពង្រឹងចំណេះដឹងកុមារ*

- រៀបចំល្បែងថ្មីដែលមានរបៀបលេងតាមទម្រង់ប្រហាក់ប្រហែល នឹងល្បែងចាស់ដែលកុមារធ្លាប់លេង និងល្បែងមួយមានរបៀបលេងថ្មីដែលកុមារពុំធ្លាប់លេងសោះ តម្រូវឱ្យគ្រូណែនាំកុមារលេងឱ្យបានច្បាស់លាស់។ ល្បែងទាំងអស់នេះគ្រូអាចរៀបចំដាក់តាមខ្លឹមសារជ្រុងថ្នាក់រៀនដោយដកល្បែងចាស់ចេញ ឬដាក់តាមកន្លែងសមស្របងាយស្រួលកុមារលេងក្នុងគោលបំណងផ្លាស់ប្តូរបរិយាកាសសិក្សានិងកសាងជំនឿចិត្តឱ្យកុមារអាចម្ចាស់ការលេងល្បែងដោយសប្បាយរីករាយ៖
- បំផុសកុមារឱ្យជ្រើសរើសល្បែង និងអនុវត្តតាមចំណូលចិត្ត
- តាមដាន សម្របសម្រួលព្រមជាមួយនឹងការផ្តល់ និងពង្រឹងចំណេះដឹងកុមារ

**ឧទាហរណ៍៖** ល្បែងផ្ទាត់កៅស៊ូដាក់នៅជ្រុងល្បែង ល្បែងបំពេញចន្លោះលេខនៅជ្រុងសិក្សា ល្បែងដោត អង្កាំនៅជ្រុងសិល្បៈ ល្បែងលាយពណ៌ដែលមានរបៀបលេងថ្មីនៅជ្រុងវិទ្យាសាស្ត្រ

- បូកសរុបការលេងសេរីរបស់កុមារឱ្យទាក់ទងនឹងចំណេះដឹង និងលទ្ធផលរំពឹងទុកក្នុងកម្មវិធីសិក្សា។

- *ការអនុវត្តល្បែងសេរីក្នុងគោលបំណងបង្កបរិយាកាសសប្បាយរីករាយ និងអប់រំចិត្តសង្គម*

- អប់រំវិន័យតាមជ្រុងថ្នាក់រៀន (ភាពសុខដុមក្នុងពេលលេង ការទុកដាក់ល្បែងតាមកន្លែងដើម)
- កុមារជ្រើសរើសល្បែង និងអនុវត្តតាមចំណូលចិត្ត

- តាមដានសម្របសម្រួលដំណើរការលេងរបស់កុមារដោយនាំកុមារកែលម្អ និងបំពេញចំណុចខ្វះខាត
- បូកសរុបការលេងសេរីរបស់កុមារ ។

### ៣.៣.១.៤. ការអនុវត្តចម្រៀង តន្ត្រី និងរបាំ

#### ឧទាហរណ៍១ ៖ ល្បែង « ទាយសំឡេង »

➢ **របៀបលេង**

គ្រូបង្កើតសំឡេងតាមរយៈការគោះតុ កែវទឹក... និងការស្តាប់សំឡេងម៉ូតូ ឡាន រថភ្លើង រទេះគោ សត្វ សំឡេងខ្យល់បក់ សំឡេងភ្លៀងធ្លាក់ ទឹកហូរតាមរយៈម៉ាញេ ឬទូរស័ព្ទ ឬការអនុវត្តផ្ទាល់។ កុមារឈរបែរខ្នងស្តាប់ហើយទាយថាជាសំឡេងគ្រូធ្វើអ្វីឬសំឡេងអ្វីចេញពីម៉ាញេឬទូរស័ព្ទ គ្រូហៅកុមារណាម្នាក់ដែលលើកដៃឱ្យឆ្លើយដោយត្រឡប់ក្រោយបែរទាំងអស់គ្នា។ បើចម្លើយត្រឹមត្រូវកុមារទាំងអស់ត្រូវទះដៃ។ ប៉ុន្តែបើចម្លើយមិនត្រឹមត្រូវ កុមារនៅស្ងៀមហើយលើកដៃដើម្បីឡើងឆ្លើយចម្លើយដែលពេញចិត្ត។

#### ឧទាហរណ៍២ ៖ ល្បែង « គោះចង្វាក់តាមសញ្ញាតាង »

➢ **របៀបលេង**



គ្រូបង្ហាញសញ្ញាតាងនៃចង្វាក់ភ្លេង

សញ្ញា ○ ទះដៃ ឬគោះ២ដងជាប់ៗគ្នា || សញ្ញា ទះដៃ ឬគោះ២ដងតែយឺតៗ

សញ្ញា ● ទះដៃ ឬគោះ៤ដងជាប់ៗគ្នា សញ្ញា ✥ សម្រាក

សម្ភារៈតារាងសញ្ញាតាង ដបគ្រលុកគ្រាប់សណ្តែក ប្រអប់ដែក ឬដបសម្រាប់គោះ និងចង្កឹះ។

#### ឧទាហរណ៍៣ ៖ ល្បែង « ចម្រៀងហៅភ្លៀង

➢ **របៀបលេង**

គ្រូបំផុសកុមារឱ្យធ្វើសំឡេងកង្កែបអ៊ូបៗសំឡេងហ៊ីងហ៊ីងហាងសំឡេងក្អាត់ ក្អាក់ៗដោយបញ្ចេញសំឡេងថ្នមក្នុងន័យអង្វរសំឡេងខ្លាំងៗក្នុងន័យសប្បាយចិត្ត សំឡេងខ្លាំងល្មមក្នុងន័យអរគុណមេឃដែលបានបង្អុរទឹកភ្លៀង។គ្រូធ្វើសញ្ញាដោយដៃស្តាំដើម្បីឱ្យកុមារសង្កេតសញ្ញាសំឡេងទាប( សំឡេងថ្នម) សំឡេងខ្ពស់( សំឡេងខ្លាំង )សំឡេងស្មើ(រក្សាសំឡេងថ្នមដដែល ឬរក្សាសំឡេងខ្លាំងដដែល) ។

#### ឧទាហរណ៍៤ ៖ ល្បែង « ប្រាប់ឈ្មោះអ្នកច្រៀងបទ.... »

➢ **របៀបលេង**

គ្រូចែកកុមារជា២ក្រុមឈរទល់មុខគ្នាចម្ងាយ៣ម៉ែត្រសមាជិកក្រុមម្នាក់ៗ ត្រូវប្រាប់ឈ្មោះខ្លួនឯងចំណាងជើងបទចម្រៀង និងច្រៀងឱ្យក្រុមម្ខាងទៀតស្តាប់ចំនួន២ឃ្លាយ៉ាងច្រើន២វិនាទី។ បន្ទាប់ពីសមាជិកក្រុមម្នាក់ៗច្រៀងឱ្យក្រុមស្តាប់ស្គាល់សំឡេងរួចហើយ គ្រូឱ្យក្រុមទាំង២បែរខ្នងដាក់គ្នាដោយមេក្រុមជាអ្នកចាត់បញ្ជាសំងាត់ឱ្យសមាជិករបស់ខ្លួនណាម្នាក់ច្រៀងនិងសម្រេចចម្លើយត្រូវឬខុស។ អ្នកទាយខុសត្រូវដកខ្លួនមកខាងក្រុមឈ្នះ។ ក្រុមដែលទាយត្រូវឈ្មោះអ្នកច្រៀងមានសិទ្ធិនាំខ្លួនអ្នកនោះ មកកាន់ក្រុមរបស់ខ្លួន។

#### ឧទាហរណ៍៥ ៖ ល្បែង « ប្រគំតន្ត្រី »

➢ **របៀបលេង**

គ្រូនាំកុមារទាំងអស់ច្រៀងបទ«ស្អាតជានិច្ច»ឬបទណាមួយដែលងាយគោះចង្វាក់២ចប់។ រួចចែកកុមារជា ៣ ក្រុម ១ក្រុមជាអ្នកច្រៀង ១ក្រុមទះដៃជាចង្វាក់ និង១ក្រុមទៀតគោះតុ ឬគ្រលុកគ្រឿងដោយគ្រាប់គ្រួសតូចៗ ក្នុងដបទឹកសុទ្ធ។បន្ទាប់មកគ្រូឱ្យក្រុមនីមួយៗ គោះចង្វាក់តាមសញ្ញាម្រាមដៃរបស់គ្រូដែលលើកបង្ហាញហើយចង្អុលទៅរកក្រុមនោះ។

### ឧទាហរណ៍៦ ៖ ល្បែង « ចម្រៀងហៅភ្លៀង

➢ **របៀបលេង**

គ្រូបំផុសកុមារឱ្យធ្វើសំឡេងកង្កែបអ៊ូបៗសំឡេងហ៊ឹងហ៊ឹងហាងសំឡេងក្អាត់ក្អាក់ៗដោយបញ្ចេញសំឡេងថ្នមក្នុងន័យអង្វរសំឡេងខ្លាំងៗក្នុងន័យសប្បាយចិត្ត សំឡេងខ្លាំងល្មមក្នុងន័យអរគុណមេឃដែលបានបង្អុរទឹកភ្លៀង។គ្រូធ្វើសញ្ញាដោយដៃស្ដាំដើម្បីឱ្យកុមារសង្កេតសញ្ញាសំឡេងទាប( សំឡេងថ្នម) សំឡេងខ្ពស់( សំឡេងខ្លាំង )សំឡេងស្មើ(រក្សាសំឡេងថ្នមដដែល ឬរក្សាសំឡេងខ្លាំងដដែល) ។

### ឧទាហរណ៍៧ ៖ ល្បែង « សូមច្រៀងតាមខ្ញុំ »

➢ **របៀបលេង**

គ្រូជ្រើសរើសចម្រៀងដែលមានទំនុកបទងាយៗនិងកុមារធ្លាប់ច្រៀងឱ្យបានចំនួន៤បទ។ កុមារទាំងអស់ច្រៀងចម្រៀងដែលគ្រូបានកំណត់។ រួចឱ្យកុមារច្រៀងចម្រៀងផ្សេងទៀតដែលកុមារចេះ អាចច្រៀងរួមគ្នាបាន។ បន្ទាប់មកចែកកុមារជា២ក្រុម។ ក្រុមនីមួយៗជ្រើសរើសយកចម្រៀង២បទដែលគ្រូបានកំណត់និងពិភាក្សាគ្នា ជ្រើសយកសំឡេងសត្វ ឬវត្ថុមួយមកធ្វើតាមលំនាំបទតាមបែបកំដៅសំឡេងឱ្យក្រុមផ្សេងទៀតធ្វើតាម។ ក្រុមអនុវត្តបែបនេះ ឆ្លាស់គ្នាម្ដង១បទ។ នៅពេលកុមារលេងស្ទាត់ហើយ គ្រូឱ្យក្រុមកុមារម្ចាស់ការជ្រើសរើសយកចម្រៀងផ្សេងៗមកឱ្យក្រុមដទៃច្រៀងតាមលំនាំខាងលើដូចជា៖ ក្រុមទី១ជ្រើសយកបទ «**ស្អាតជានិច្ច**» និងយកសំឡេងឆ្មាមកហ្វឹកហាត់។ រួចឱ្យក្រុមទី២ ច្រៀងតាម២ចប់ «**ម៉េវៗ ម៉េវៗៗ ម៉េវៗៗៗ ម៉េវៗៗៗ ម៉េវៗៗ ម៉េវៗៗ ម៉េវៗៗៗៗៗៗ**» ។

ឯក្រុមទី២ជ្រើសយកបទ «**ឆ្មាមួយ**» និងយកសំឡេងតុកៗមកហ្វឹកហាត់។ រួចឱ្យក្រុមទី១ ច្រៀងតាម ២ចប់វិញម្ដង «**តុកៗៗៗ តុកៗៗៗៗៗៗ**»។ ចំពោះលក្ខខណ្ឌល្បែង គ្រូអាចពិភាក្សាជាមួយកុមារ។

## ៣.៣.១.៥.ការហ្វឹកហាត់កុមារច្រៀងចម្រៀង

ដើម្បីទាក់ទាញកុមារឱ្យមានចិត្តរំភើបចូលចិត្តច្រៀងចម្រៀង និងឆាប់ចាំ គ្រូអាចដំណើរការបង្រៀនចម្រៀងតាមវិធី ផ្សេងៗដូចខាងក្រោម៖

- គ្រូចម្លងខ្លឹមសារបទចម្រៀង និងបិទរូបភាពដាក់លើក្រដាសផ្ទាំងធំ រួចជាស្រេច
- ឬគ្រូច្រៀងបណ្ដើរបិទរូបភាពលើក្ដារខៀនបណ្ដើរពុំមានខ្លឹមសារអត្ថបទចម្រៀង
- ឬគ្រូចម្លងតែខ្លឹមសារបទចម្រៀង ដោយទុកចន្លោះបិទរូបភាពមានន័យថា គ្រូច្រៀងបណ្ដើរបិទរូបភាពបណ្ដើរ
- ឬគ្រូនាំកុមារច្រៀងបណ្ដើរ បិទរូបភាពបណ្ដើរ និងបិទខ្លឹមសារចម្រៀងបណ្ដើរ។ វិធីនេះងាយស្រួលនៅពេលច្រៀងបំបាត់ពាក្យ គ្រូអាចដករូបភាពម្ដងមួយៗចេញ ឬលុបពាក្យម្ដងមួយៗចេញ។

✚ គ្រូអាចអនុវត្តសិល្បវិធីផ្សេងៗតាមបទពិសោធន៍ទៅក្នុងដំណើរការបង្រៀន ។

## ៣.៣.១.៦. ការអនុវត្តសកម្មភាពគំនូរ

➢ **គំនូសមូលដ្ឋាន**

ដើម្បីទាក់ទាញកុមារឱ្យពេញចិត្តគូសគំនូសមូលដ្ឋាន គ្រូមត្តេយ្យសិក្សាគប្បីរៀបចំកិច្ចការឱ្យសមស្របនឹងកម្រិតអាយុកុមារដោយចាប់ផ្ដើមពីងាយទៅលំបាកនិងកាន់តែលំបាកដែលស្ថិតក្នុងកម្រិតសមត្ថភាពកុមារអាចធ្វើបាន មិនធ្វើឱ្យកុមារបាត់បង់ជំនឿលើខ្លួនឯងនិងមិនធ្វើឱ្យកុមារធុញថប់មិនចង់បញ្ចប់កិច្ចការរបស់ខ្លួននៅពាក់កណ្ដាលទី។

- ថ្នាក់ម្រិតទាប៖ គ្រូគប្បីឱ្យកុមារគូសគំនូសងាយៗច្រើនបំផុត៣គំនូស គឺ២/៥ ទៅ ៣/៥ នៃរូបភាព១
- ថ្នាក់ម្រិតមធ្យម៖ គ្រូគប្បីឱ្យកុមារគូសគំនូសងាយៗច្រើនបំផុត៣គំនូស គឺ២៥ នៃរូបភាព១/៥ទៅ ៣/
- ថ្នាក់ម្រិតខ្ពស់៖ គ្រូគប្បីឱ្យកុមារគូសគំនូសងាយៗច្រើនបំផុត៤គំនូស គឺ៣៥ នៃរូបភាព១ /៥ ទៅ ៤/ និងកុមារអាចគូសគំនូសទាំងស្រុងតាមរូបគំរូ។

### ឧទាហរណ៍១៖ គំនូស « សំណាញ់ទ្រុងទន្សាយ »



➢ **បង្ហាញរូបគំរូ**

១. ទន្សាយ១នៅក្នុងទ្រុងមានសំណាញ់ការពារខ្លួនជុំវិញ

- **ណែនាំពីរបៀបគូសបន្ទាត់ត្រង់ឈរ បន្ទាត់ដេកតាមស្នាមចុច**



២. ទន្សាយ១ទៀតបានសុំកូនៗឱ្យជួយគូសសំណាញ់បន្ថែមឱ្យដូចទន្សាយទី១ដែរ( បំផុសកុមារឱ្យគូសតាមស្នាមចុចពីលើចុះក្រោមរួចពីឆ្វេងទៅស្ដាំ )

- **ចែកកិច្ចការឱ្យកុមារគូស**



៣. ឥឡូវនេះ ទន្សាយ១ទៀតបានសុំកូនៗឱ្យជួយគូសសំណាញ់បន្ថែមឱ្យដូចទន្សាយមុនៗដែរ។(ចែកកិច្ចការឱ្យកុមារម្នាក់១រូបភាព )

**បញ្ជាក់៖** ការនាំកុមារគូសសំណាញ់លើទ្រុងតាមស្នាមចុច គឺគ្រូអនុវត្តសម្រាប់កុមារថ្នាក់ទាប ថ្នាក់មធ្យម និងចំពោះកុមារអាយុ៥ឆ្នាំដែលពុំធ្លាប់កាន់ខ្មៅដៃទាល់តែសោះ។ ជាបន្តបន្ទាប់គ្រូបង្កើនការលំបាកបន្តិចម្ដងៗឱ្យសមស្របនឹងសមត្ថភាពកុមារ ដើម្បីអភិវឌ្ឍបំណិនសង្កេតបំណិនរិះគិត ការអត់ធ្មត់ និងការសម្រេចចិត្ត។ ទន្ទឹមនេះ គ្រូមិនគប្បីកាន់ដៃកុមារឱ្យគូសគំនូសឡើយ ដោយគ្រូជំរុញលើកទឹកចិត្តកុមារឱ្យខិតខំគូសតាមការចង្អុលបង្ហាញរបស់គ្រូ។

### ឧទាហរណ៍២ ៖ គំនូស «តំណក់ទឹកភ្លៀង»



➢ **បង្ហាញរូបគំរូ**

១. ពពកខ្មៅ និងពពកសរសោត់តាមខ្យល់ពេញផ្ទៃមេឃ

- **ណែនាំពីរបៀបគូសបន្ទាត់ត្រង់ឈរ បន្ទាត់ដេកតាមស្នាមចុច**

២. រួចក៏ប៉ះគ្នា ខ្យល់ក៏ស្ងប់ តំណក់ទឹកភ្លៀងវែងៗ បានធ្លាក់មក និទានបណ្ដើរគូសបន្ទាត់ត្រង់ខ្លីៗឱ្យកុមារសង្កេតបណ្ដើរ រួចបំផុសកុមារ) ២ ឬ៣នាក់ឱ្យគូសបន្តពីគ្រូ



- **ចែកកិច្ចការឱ្យកុមារគូស**

៣. កុមារអនុវត្តកិច្ចការជាបុគ្គល



**បញ្ជាក់៖** ឧទាហរណ៍ខាងលើ គឺជាវិធីដែលទាក់ទាញចិត្តរំភើបកុមារឱ្យចូលចិត្តគូសគំនូស ដោយមានការតាំងចិត្តគូសឱ្យបានស្អាត និងព្យាយាមគូសគំនូសតាមការណែនាំនិងឱ្យរួចជាស្ថាពរ។ ដូចនេះ គ្រូមត្តេយ្យសិក្សាគប្បីបង្កើតនូវគំនិតថ្មីៗដែលមានឥទ្ធិពលទៅលើចំណូលចិត្តរបស់កុមារទៅតាមបទពិសោធន៍ ទៅតាមស្ថានភាពជាក់ស្ដែងស្របតាមសមត្ថភាពកុមារ និងជីវភាពរស់នៅរបស់កុមារ។ ចំពោះការវាយតម្លៃស្នាដៃរបស់កុមារ គ្រូមិនគប្បីគិតដល់រូបល្អប្រណិតនោះទេសំខាន់កុមារគូសដោយគោរពតាមការណែនាំរបស់គ្រូ មានគ្រប់លក្ខណៈតាមទម្រង់ប្រហាក់ប្រហែល នឹងរូបភាព គំរូ។

➢ **គំនូសអក្សរ**

ចំពោះគំនូសអក្សរ គ្រូអាចដំណើរការបង្រៀនដូចគំនូសមូលដ្ឋានបាន និងអាចច្នៃប្រឌិត តាមទៅបទពិសោធន៍ផ្សេងៗដែលគ្រូមាន។គំនូសអក្សរនេះ ទាមទារកុមារឱ្យគូសអក្សរដោយមិនដកដៃ។បន្ទាប់ពីឱ្យកុមារគូសគំនូសអក្សរក្នុងឧទាហរណ៍ទី១ នេះហើយ ម៉ោងសិក្សាក្រោយគ្រូអាចឱ្យកុមារដាក់សក់បានជា « **ក** » បន្ទាប់មកគួចខាងក្នុងជា« **គ** » ជា « **ត** » តាមការច្នៃប្រឌិត។

**ឧទាហរណ៍១ ៖ គំនូសអក្សរ**



កិច្ចការកុមារ



**ឧទាហរណ៍២៖ តុបតែងគំនូសអក្សរ (កិច្ចការកុមារដែលបានអនុវត្តនៅម៉ោងសិក្សាទី១)**

**កុមារដាក់សក់ឱ្យបានជា« ក »**



នៅម៉ោងសិក្សាក្រោយ កុមារកាត់ឱ្យដាច់ពីគ្នា យកទៅលេងតម្រៀបបន្តគ្នានៅក្នុង« ក » ល្បែងបុរសំណេរ។

**ឧទាហរណ៍៣ ៖ គំនូសអក្សរ**



**កិច្ចការកុមារ**



ឧទាហរណ៍៤ ៖ គំនូសអក្សរ



កិច្ចការកុមារ



➢ គំនូរតាមរូបគំរូ

ឧទាហរណ៍១ ៖ គំនូរ « កូនទា »

- បំផុសកុមារឱ្យសង្កេតពីរបៀបគូរដោយគ្រូច្រៀងតាមលំនាំបទស្មាតជានិច្ចបណ្ដើរគូរបណ្ដើរ

១. ផ្លែធំធ្លាក់  ២. ផ្លែតូចធ្លាក់  យើង២នាក់នាំគ្នារត់លេង

៣. ស្លឹកតូចធំ រត់ប្រឡែង  ៤. មែកស្រែកថា ខ្ញុំសុំលេងផង 

៥. កេបៗ គ្មានចំពុះ  ខ្ញុំគ្មានឈ្មោះ សូមជួយដាក់ផង

៦. កេបៗ សូមបងៗ ទាយថាខ្ញុំ គឺជាសត្វអ្វី ? (សត្វទា)

- **បំផុស**សំណួរបញ្ជាក់៖ តើគ្រូគូរសត្វអ្វី ?
- តើគ្រូគូរកូនទាចាប់ពីរាងអ្វីមុន ?បន្ទាប់មកទៀតគូររាងអ្វីទើបបានជាកូនទា? បន្ទាប់មកគូររាងអ្វី?
- បញ្ជាក់ពីរបៀបគូរ
- បំផុសកុមារឱ្យប្រាប់ចំណងជើងគំនូរ
- បំផុសកុមារឱ្យឡើងគូរសាកល្បង១ឬ២នាក់ និងឱ្យកុមារគូររូបកូនទាទាំងអស់គ្នា។

➢ **គំនូរគូរតាមរឿងនិទាន**

ឧទាហរណ៍២ ៖គំនូររឿងនិទាន « អ្នកគ្រូគូររូបអ្វី ?

- **បំផុសកុមារឱ្យសង្កេតពីរបៀបគូរដោយគ្រូគូរបណ្ដើរ និទានបណ្ដើរ**

| | |
|---|---|
| ១មានសត្វមួយនោះណា ខ្លួនទន់អស្ចារ្យវារ. រកផ្ទះនៅ |  |
| ២. វារទៅៗ ទាក់នឹងមែកឈើ |  |
| ៣. វើចុះវើឡើង វើសបានត្បូង៣ សត្វនោះស្រដីថាភ្នែកខ្ញុំភ្លឺ ទោះខ្ញុំមិនឮ ទ្រមុះ២ពូកែស្រង់ក្លិន |  |

| | |
|---|---|
| ៤. ហិតចុះ ហិតឡើង ជុំមូលវិលៗអិលធ្លាក់ លើខ្លួនខ្ញុំ អូហ៍!នេះហើយជាផ្ទះខ្ញុំ។ |  |

**បំផុសសំណួរបញ្ជាក់៖ តើគ្រូគូររូបសត្វអ្វី ?**

- តើគ្រូគូររូបខ្យងនេះចាប់ពីអ្វីមុន ? បន្ទាប់មកគូររាងអ្វី ?បន្ទាប់មកគូរអ្វីទៀត ?បន្ទាប់មកគូរអ្វីទៀត ទើបបានជាខ្យង ?
- បញ្ជាក់ពីរបៀបគូរ
- បំផុសកុមារឱ្យប្រាប់ចំណងជើងគំនូរ
- បំផុសកុមារឱ្យឡើងគូរសាកល្បង១ឬ២នាក់
- កុមារអនុវត្តទាំងអស់គ្នា គ្រូសម្របសម្រួល
- បូកសរុប និងវាយតម្លៃស្នាដៃកុមារ។

➢ **គំនូរតុបតែងលម្អ ដោយគំនូសមូលដ្ឋាន ឬគំនូរតូចៗ**

គំនូរតុបតែងលម្អចែកចេញជាគំនូរតុបតែងលម្អដោយគំនូសមូលដ្ឋាន ដោយគំនូរផ្សេងៗ និងដោយផាត់ពណ៌។គ្រូគប្បីដាក់កិច្ចការសមស្របតាមកម្រិតនៃការយល់ដឹង កម្រិតថ្នាក់និងអាយុរបស់កុមារ។

**ឧទាហរណ៍១៖ គំនូរតុបតែងលម្អ «ស៊ុមរូបផ្កា»** ( សម្រាប់កុមារថ្នាក់ទាប )

- កុមារទីតាសម្លឹងមើលជញ្ជាំងឃើញស៊ុមរូបផ្កាដូចជាចាស់បន្តិច ទីតាក៏បានយកស៊ុមនោះ មកជូត និងគូរតុបតែងលម្អ( និទានបណ្តើរ បិទរូបស៊ុមនៅលើក្តារខៀនបណ្តើរ )
- បំផុសកុមារ២ទៅ៣នាក់ឡើងមកជួយតុបតែងលម្អជុំវិញស៊ុមរូបផ្កាដោយគំនូសត្រង់ឈរត្រង់ដេក ក្នុងគោលបំណងពង្រឹងការគូសគំនូសមូលដ្ឋានត្រង់ឈរ ត្រង់ដេក
- ជាបន្តបន្ទាប់ កុមារតុបតែងលម្អកាន់តែលំបាកដោយការជ្រើសរើសវិធីតុបតែងតាមចំណូលចិត្ត។



បិទរូបភាពលើក្តារខៀន



កុមារអនុវត្តសាកល្បងលើរូបភាព



កិច្ចការ

រូបភាពទី 2៖គំនូរតុបតែងលម្អ ស៊ុមរូបផ្កា

- **គំនូរតុបតែងលំអដោយពណ៌**

*ថ្នាក់ទាប ៖*




រូបភាពទី 3៖ គំនូរតុបតែងលំអដោយពណ៌ ថ្នាក់ទាប

- **គំនូរតុបតែងលម្អដោយប្រើពណ៌សេរី**



រូបភាពទី 4៖ គំនូរតុបតែងលម្អដោយប្រើពណ៌សេរី

- **គំនូរផ្តាម**

**ឧទាហរណ៍១៖ គំនូរផ្តាម «ផ្តាមស្លឹកឈើ»**

កុមារដាក់ស្លឹកឈើ១សន្លឹកពីលើក្រដាសស ដោយដៃឆ្វេងទប់សង្កត់ស្លឹកឈើឱ្យមានលំនឹង ដៃស្តាំកាន់ខ្មៅដៃគូរផ្តាមតាមទម្រង់ស្លឹកឈើ រួចគូរទ្រនង់ស្លឹកឈើនោះ។

ក្នុងករណីកុមារមានបំណិនគូរផ្តាម និងកាត់បិទ គ្រូអាចបន្តសកម្មភាពកុមារកាត់បិទតាមទម្រង់ស្លឹកឈើក្នុងម៉ោងសិក្សាតែមួយ។

**ឧទាហរណ៍២៖ គំនូរផ្តាម«ផ្តាមកូនទា»**

- កុមារដាក់ក្រដាសសស្តើងលើរូបភាពកូនទា ដៃឆ្វេងទប់ក្រដាស ដៃស្តាំគូរតាមទម្រង់រូបភាពកូនទានោះ
- សកម្មភាពនេះ គ្រូអាចនាំកុមារចូលក្នុងបណ្ណាល័យ ស្រាវជ្រាវរូបភាពងាយៗដែលកុមារពេញចិត្តគូរផ្តាម
- នៅម៉ោងសិក្សាក្រោយ កុមារផាត់ពណ៌តុបតែងលម្អរូបកូនទានោះ។

**ឧទាហរណ៍៣៖ គំនូរផ្តាម «ផ្តាមមាត់ចាន»**

កុមារផ្តាប់មាត់ចានលើក្រដាសស ដោយដៃឆ្វេងទប់ចាដៃស្តាំកាន់ខ្មៅដៃគូរព័ទ្ធជុំវិញមាត់ចាននោះឱ្យបានយ៉ាងតិច៥ ទៅ៦រង្វង់មាត់ចាន ។ គ្រូអាចនាំកុមារតុបតែងច្នៃប្រឌិតជាសត្វដង្កូវ ឬជាសត្វស្រមោច ឬជាសត្វផ្សេងទៀតបាន ទៅតាមសមត្ថភាពរបស់កុមារ។



រូបភាពទី 5៖ គំនូរផ្គាម

✚ គ្រូនាំកុមារគូរផ្គាមតាមរង្វង់គម្របដប គម្របម្សៅធ្វើជាសត្វអណ្ដើកមាស ស្រមោច អង្រ្កង។ល។

➢ **គំនូរផ្តិត**

- ការជ្រលក់ពណ៌ផ្តិតយករូបរាងដើមនៃវត្ថុ។

**ឧទាហរណ៍១៖ គំនូរផ្តិត « បោះពុម្ពផ្កា »**

កុមារយកជាងចេកដែលសាប់មុខកាត់ទៅជ្រលក់ក្នុងពណ៌ទឹកខាប់បន្តិច រួចបោះពុម្ពលើក្រដាសដែលគ្រូបានគូរទេង និងស្លឹកត្រៀមទុកជាមុន។

**ឧទាហរណ៍២៖ គំនូរផ្តិត « បោះពុម្ពរូបភាព »**

- បង្ហាញត្រារូបភាពផ្សេងៗឱ្យកុមាររៀបរាប់
- កុមារជ្រើសរើសត្រា និងធ្វើការបោះពុម្ពរូបផ្កា រូបសត្វ រូបវត្ថុផ្សេងៗតាមចំណូលចិត្ត រួចកុមាររៀបរាប់ ពីរូបភាពនោះ។

**ឧទាហរណ៍៣៖ គំនូរផ្តិត « ផ្តិតប្រអប់ដៃ »**

កុមារផ្តិតប្រអប់ដៃ ស្រាលៗទៅក្នុងពណ៌ដែលពេញចិត្តដាក់ទៅលើ(ឬប្រអប់ជើង) ក្រដាសផ្ទាំងធំដោយចំណាំរៀងៗខ្លួន។

✚ នៅពេលកុមារមានបំណិនផ្តិតប្រអប់ដៃ គ្រូនាំកុមារផ្តិតម្រាមដៃឬម្រាមជើងនិងច្នៃប្រឌិតជារូបភាពផ្សេងៗ។

- **ការផ្តិតយកពណ៌ចេញជារូបភាពផ្សេងៗ**

**ឧទាហរណ៍១៖ គំនូរផ្តិត « ផ្តិតក្រដាសយកពណ៌ »**

កុមារបត់ក្រដាសស្តើង ជក់ទឹក តាមគំនិតផ្ទាល់ខ្លួន រួចជ្រលក់ពណ៌តាមផ្នែក នៃចុង ក្រដាស។ បន្ទាប់មកកុមារលាក្រដាស នោះនឹងឃើញរូបភាពតាមការបត់ និងកម្លាំងដៃកាន់ក្រដាសជ្រលក់ រួចយកទៅហាលថ្ងៃ។

**ឧទាហរណ៍២៖ គំនូរផ្តិត « ជ្រលក់ពណ៌កំណាត់ »**

កុមារដាក់គ្រាប់គ្រួសក្នុងក្រណាត់ រួចចងកៅស៊ូ ជាដុំៗ តាមគំនិតផ្ទាល់ខ្លួន។ បន្ទាប់មកយកទៅជ្រលក់ពណ៌ហើយស្រាយកៅស៊ូ យកដុំថ្មចេញ នោះនឹងឃើញមានរូបភាពលេចចេញឡើង។

- **ការផ្តិតយករូបរាងដើមរបស់វត្ថុ**

**ឧទាហរណ៍១៖ គំនូរផ្តិត « ផ្តិតយកស្លឹកឈើ»**

កុមារដាក់ក្រដាសស១សន្លឹកពីលើស្លឹកឈើ១សន្លឹក ដោយដៃឆ្វេងទប់ក្រដាស ដៃស្តាំកាន់ខ្មៅដៃផាត់ផ្តេកពីលើក្រដាសសនោះ នឹងឃើញរូបស្លឹកឈើលេចឡើង។ នៅម៉ោងសិក្សាក្រោយ គ្រូនាំកុមារកាត់តាមទម្រង់ស្លឹកឈើនោះ រួចយកទៅបិទលើក្រដាស១សន្លឹកផ្សេងទៀត។

- ក្រៅពីស្លឹកឈើ កុមារអាចផាត់ផ្តិតលើប្រាក់កាក់ដែលមានកម្រាស់ស្តើង លើវត្ថុដែលមានប្រហោងតិចឬច្រើន...។ និងជាបន្ត គ្រូនាំកុមារច្នៃប្រឌិតកាត់ឆ្មៀលតាមទម្រង់រូបដែលបានផ្តិតបង្កើតជារូបផ្សេងៗ។

### ៣.៣.១.៧. ការអនុវត្តសកម្មភាពកសាង

ការអនុវត្តសកម្មភាពកសាងនៅមត្តេយ្យសិក្សា តម្រូវឱ្យគ្រូបង្ហាញនូវឆន្ទៈមោះមុតឧស្សាហ៍ព្យាយាមតស៊ូអត់ធ្មត់ចូលចិត្តស្រាវជ្រាវរកអ្វីដែលថ្មី សមស្របនឹងសមត្ថភាពកុមារបង្កើតគំនិតផ្តួចផ្តើមច្នៃប្រឌិតផ្សារភ្ជាប់ជាមួយសិល្បៈគំនូរដើម្បីឱ្យស្នាដៃកុមារកាន់តែមានអត្ថន័យមានសោភ័ណនិងទាក់ទាញចំណាប់អារម្មណ៍កុមារឱ្យរំភើបចិត្ត ចង់គូរចង់អនុវត្តសកម្មភាពកសាងដោយសប្បាយរីករាយ។

➢ **ការហែក**

ការហែកក្រដាសនេះ តម្រូវឱ្យកុមារប្រើម្រាមមេដៃ និងចង្អុលដៃឆ្វេងទប់ក្រដាសនិងម្រាមមេដៃនិងចង្អុលដៃស្តាំចាប់ហែកក្រដាសពីលើចុះក្រោម និងហែកបង្វិលតាមទម្រង់រូបភាព។

**ឧទាហរណ៍១.៖ សកម្មភាពកសាង «ហែកក្រដាសចម្រៀកតូចៗ»**

កុមារម្នាក់ៗហែកក្រដាសជាចម្រៀកតូចៗឱ្យបានច្រើនកាន់តែល្អដើម្បីសន្សំទុកនៅក្នុងថង់មួយសម្រាប់បាចផ្កា ថ្ងៃខួបកំណើត ឬបិទតុបតែងលម្អគំនូរផ្សេងៗជាដើម។

**ឧទាហរណ៍២.៖ សកម្មភាពកសាង « ហែកក្រដាសចម្រៀកតូចវែងៗ »**

កុមារម្នាក់ៗ ហែកក្រដាសជាចម្រៀកតូចវែងៗ ពីលើចុះក្រោមដោយមិនចាំបាច់ឱ្យត្រង់ពេកទេ ហែកបានច្រើនកាន់តែល្អដើម្បីសន្សំទុកនៅក្នុងថង់មួយ សម្រាប់បិទធ្វើជារំយោលតុបតែងលម្អថ្នាក់រៀន។

- ក្រដាសសម្រាប់ហែកមិនត្រូវជាក្រដាសស្វិត និងមានទំហំ A4 ចែកជា៤ ចំពោះកុមារថ្នាក់ទាប និងមធ្យម
- សម្រាប់កុមារថ្នាក់ខ្ពស់ក្រដាស A4 ចែកជា២ ។បន្ទាប់មក គ្រូអាចហ្វឹកហាត់កុមារហែករូបភាពតាមស្នាមនិងជាបន្តបន្ទាប់កុមាររៀនហែកតាមទម្រង់រូបភាពដោយផ្អែកលើសមត្ថភាពរបស់កុមារតាមវ័យ។

➢ **ការបិទ**

**ឧទាហរណ៍១ ៖ សកម្មភាពកសាង « បិទរូបផ្លែក្រូច »**

កុមារត្រូវមានក្រដាស២សន្លឹក គឺ១សន្លឹកសម្រាប់ជាទ្រនាប់បិទផ្លែក្រូច និង១សន្លឹកទៀត គ្របពីលើរូបភាពដែលបិទការួចលើក្រដាសទ្រនាប់នោះ ដោយយកដៃរីតបង្អួសថ្នមៗ ដើម្បីឱ្យការរត់ស្មើ មិនជ្រួញរូបភាពនោះ។

**ឧទាហរណ៍២៖ សកម្មភាពកសាង « បិទរូបផ្ទះ »**

កុមារម្នាក់ៗត្រូវ៖

- មានក្រដាស២សន្លឹក គឺ១សន្លឹកសម្រាប់ជាទ្រនាប់បិទរូបផ្ទះ និងក្រដាស១សន្លឹកទៀតគ្របពីលើរូបភាព
- មានកាវ និងក្រដាសរាងត្រីកោណ១សន្លឹក រាងចតុកោណកែងសម្រាប់ធ្វើជាតួផ្ទះ១សន្លឹក និងទ្វារ១សន្លឹកនិងក្រដាសរាងការេធ្វើជាបង្អួច១សន្លឹក
- បិទតួផ្ទះលើក្រដាសទ្រនាប់ដោយគ្របក្រដាសពីលើរូបភាពរីតឱ្យស្អាតមិនជ្រួញរូបភាពរួចបិទទ្វារបន្ទាប់មកបង្អួច ចុងក្រោយបិទដំបូលផ្ទះ ដោយដំណាក់កាលនៃការបិទនីមួយៗ អនុវត្តដូចបិទតួផ្ទះ។

**ឧទាហរណ៍៣៖ សកម្មភាពកសាង « យើងបិទស្រកាឱ្យត្រី »**

- បំផុសកុមារឱ្យសង្កេតរូបគំរូ រួចប្រាប់ពីការបិទស្រកាត្រីចាប់ពីណាទៅមុន

- នាំកុមារបិទតាមចម្លើយត្រូវ១ ខុស១រួចផ្ទៀងផ្ទាត់តាមរូបគំរូ (បិទ២ឬ៣ជួរ)
- ចែកសម្ភារៈ និងឱ្យកុមារអនុវត្តជាបុគ្គលតាមចម្លើយត្រឹមត្រូវ គឺបិទពីកន្ទុយទៅមុខ។

➢ **ការហែកបិទ**

**ឧទាហរណ៍១៖ សកម្មភាពកសាង «ហែកបិទរូបផ្លែក្រូច»**

- កុមារហែកបិទតាមស្នាមចុចនៃទម្រង់រាងរាងផ្លែក្រូច
- បិទផ្លែក្រូចដែលបានហែករួច នៅលើក្រដាស១ផ្ទាំងតាមបែបបទនៃរបៀបបិទរូបភាពឱ្យស្អាត។

➢ **ការបត់**

**ឧទាហរណ៍១៖ សកម្មភាពកសាង** « បត់១ផ្នត់ »( អនុវត្តសម្រាប់កុមារថ្នាក់ទាប)

កុមារម្នាក់ៗបត់រង្វង់តាមស្នាមចុច១ផ្នត់ខាងផ្នែកមុខកាត់របស់រង្វង់ឱ្យបានចំនួន៥រង្វង់។



រូបភាពទី 6៖ ការបត់

គ្រូកាត់ត្រឹមចំណុចកណ្ដាលនៃអង្កត់ផ្ចិត គ្រូបត់ឱ្យមានស្នាមរួចលាវិញ កុមារបត់តាមស្នាមផ្នត់ឱ្យត្រួតស៊ីគ្នា

- នៅម៉ោងសិក្សាក្រោយ គ្រូនាំកុមារបិទរង្វង់ដែលមានផ្នត់ជាស្លាប នៅលើក្រដាស១សន្លឹក តុបតែងដោយបំផុសកុមារឱ្យគូរភ្នែក ចំពុះ និងជើង ធ្វើជាកូនមាន់។
- គ្រូអាចនាំកុមារបត់រង្វង់តែមួយផ្នត់ដូចគ្នាឱ្យបានជាពាក់កណ្ដាលរង្វង់ឱ្យបានច្រើនមានតូច មានធំដើម្បីផ្គុំបញ្ចូលគ្នាច្នៃប្រឌិតជារូបកូនទា រូបផ្កា។...

**ឧទាហរណ៍១៖ សកម្មភាពកសាង** «បត់រូបកែវ»

កុមារបត់ក្រដាសរាងការេឱ្យបានជារូបកែវមួយ។



រូបភាពទី 7៖ បត់រូបកែវ

- គ្រូអាចនាំកុមារបត់រូបងាយៗមានដូចជារូបយន្តហោះ ក្បាលសត្វ ផ្កាជាដើម។

➢ **ការកាត់**

**ឧទាហរណ៍១៖ សកម្មភាពកសាង « កាត់តាមរាងការ៉េ »**

- កុមារកាន់រូបការ៉ុតនៅដៃឆ្វេង ដៃស្តាំកាន់កន្ត្រៃដោយមេដៃស្តាំស៊កចូលផ្នែកលើត្រង់កន្លែងកាន់ ឯចង្អុលដៃទប់លំនឹងតួកន្ត្រៃផ្នែកខាងក្រោម និងម្រាម៣ទៀតស៊កចូលផ្នែកខាងក្រោមត្រង់កន្លែងកាន់កន្ត្រៃ។
- នៅពេលកាត់កុមារកាន់កន្ត្រៃនៅដៃស្តាំកាត់ធៀលតាមស្នាមគំនូសរូបភាពដែលដៃឆ្វេងបង្វិលរូបភាពការ៉ុត ។

✚ ការបង្វឹកកុមារកាន់កន្ត្រៃ គ្រូត្រូវចាប់ផ្តើមនាំកុមារកាត់ចាប់ពីកំទេចក្រដាសដូចដំណាក់កាលហែកដែរ។

➢ **ការកាត់បិទ**

**ឧទាហរណ៍១៖ សកម្មភាពកសាង « កាត់បិទរូបបាល់ »**

- កុមារកាត់ធៀលរូបបាល់ រួចបិទនៅលើក្រដាស១សន្លឹកឱ្យមានសោភ័ណ។

✚ គ្រូអាចនាំកុមារកាត់បិទរាងធរណីមាត្រតូចធំ រួចយកទៅបិទផ្គុំជារូបភាពផ្សេងៗតាមការច្នៃប្រឌិត។

➢ **ការសូនរូប**

**ឧទាហរណ៍១៖ សកម្មភាពកសាង « សូនរូបផ្លែក្រូច »**

គ្រូនាំកុមារបេះដីឥដ្ឋពណ៌ទឹកក្រូច ឬពណ៌បៃតងដាក់ចំកណ្តាលបាតដៃឆ្វេង រួចដាក់បាតដៃស្តាំពីលើដីឥដ្ឋហើយសូនបានជារាងមូល។ បន្ទាប់មកកុមារសូនដីឥដ្ឋពណ៌សូកូឡាជារាងមូលទ្រវែងប្រវែង ២ស.ម រួចយកទៅភ្ជាប់ពីលើរាងមូល។បន្ទាប់មកទៀត គ្រូនាំកុមារសូនពណ៌បៃតងជារាងមូលទ្រវែងហើយឱ្យកុមារដាក់ពុម្ពស្លឹកក្រូចពីលើ រួចសង្កត់ឱ្យចេញជាស្លឹកក្រូច ដោយយកបន្ទះឈើចិតតាមទម្រង់ស្លឹកក្រូចឱ្យបានស្អាត ទើបដកពុម្ពនោះចេញ រួចយកទៅបិទភ្ជាប់ពីគល់ទង បានជាផ្លែក្រូចមួយ។

**ឧទាហរណ៍២ ៖ សកម្មភាពកសាង « រូបចម្លាក់តាមពុម្ព »**

គ្រូនាំកុមារបេះដីឥដ្ឋពណ៌ដាក់ចូលក្នុងពុម្ពដែលពេញចិត្ត រួចដកពុម្ពចេញ នោះនឹងលេចចេញឡើងនូវរូបរាងចម្លាក់តាមពុម្ពនីមួយៗ។គ្រូលើកសរសើរកុមារជាបុគ្គល និងបំផុសកុមារឱ្យរៀបចំរូបចម្លាក់ដាក់តាមគំនិតរបស់ក្រុម។បន្ទាប់មក គ្រូបំផុសក្រុមនីមួយៗឱ្យពណ៌នាប្រាប់គ្នាទៅវិញទៅមកអំពីអត្ថន័យនៃការរៀបចំរបស់ក្រុម។

✚ គ្រូឱ្យកុមារអនុវត្តសកម្មភាពនេះ សម្រាប់កុមារថ្នាក់ខ្ពស់។

➢ **ការដោត**

**ឧទាហរណ៍១៖ សកម្មភាពកសាង « ផលិតខ្សែក »**

- កុមារដោតអង្កាំតាមគំរូ គឺបំពង់បឺត២កង់ អង្កាំស៣គ្រាប់។ចំពោះប្រវែងតាមការស្រឡាញ់ចូលចិត្ត
- កុមារដោតរួច គ្រូជួយចង និងឱ្យកុមារលើកខ្សែកពាក់ដោយខ្លួនឯង កុមារដទៃទៀតជួយវាយតម្លៃ។

**ឧទាហរណ៍២៖ សកម្មភាពកសាង « ផលិតខ្សែតុបតែងលម្អ»**

គ្រូនាំកុមារកាច់ព្រលិត ឬដោតជាងល្ពង ឬជាងជំឡូងមី ជាខ្សែក ខ្សែដៃ ខ្សែលម្អព័ទ្ធជុំវិញក្បាល សម្រាប់ជូនជាវត្ថុអនុស្សាវរីយ៍ដល់មនុស្សជាទីស្រឡាញ់។

➢ **ការដេរ**

**ឧទាហរណ៍១ ៖ សកម្មភាពកសាង « ដេរអាវ »**

កុមារម្នាក់ៗដេរតាមរាងអាវ ដែលគ្រូបានចោះរន្ធជាស្រេច។

➢ ការពោយ

ឧទាហរណ៍១ ៖ សកម្មភាពកសាង « ពោយពណ៌លើមេអំបៅ »

កុមារពោយកំទេចក្រដាសពណ៌លើស្លាប និងខ្លួនមេអំបៅដែលបានលាបកាវ រួចលើករូបមេអំបៅបញ្ឈរឱ្យជ្រុះកំទេចក្រដាសដែលមិនជាប់កាវ។កំទេចក្រដាសនេះ បានមកពីកុមារដែលហែក និងកាត់សន្សំទុកកន្លងមក។

➢ ការស្នាច់

ឧទាហរណ៍១ ៖ សកម្មភាពកសាង « ស្នាច់ផ្លែននោង »

កុមារយកក្រដាសដែលបានហែកវែងៗសន្សំទុកកន្លងមក មកបិទពីលើផ្លែននោងពិតឱ្យ បានច្រើនជាន់(៥ ទៅ៦ជាន់) រួចយកទៅហាលឱ្យស្ងួត។គ្រូវះយកផ្លែននោងពិតចេញ រួចឱ្យកុមារបិទភ្ជិតស្នាមវះឱ្យស្អាត។ ម៉ោងសិក្សាក្រោយគ្រូនាំកុមារលាបពណ៌ទឹកលើផ្លែននោង ហើយយកទៅហាលឱ្យស្ងួត នោះនឹងបានផ្លែននោងដ៏ស្អាត១។

➢ តម្បាញ

ឧទាហរណ៍១ ៖ សកម្មភាពកសាង « ត្បាញកន្ទេលតូច »

កុមារត្បាញកន្ទេលតូចដោយការខ្វាស់បន្ទះក្រដាសលើក្រោមឆ្លាស់គ្នា២ពណ៌ ប្រវែង ១៥ស.ម ចំនួន ៦បន្ទះ ស្មើគ្នាដែលបន្ទះនីមួយៗ មានទំហំ២ស.ម។ ហេតុតែ កុមារមិនទាន់មានបំណិនទប់បន្ទះក្រដាស ដូចនេះបន្ទះទ្រនាប់ក្រោមចំនួន៦បន្ទះមិនត្រូវកាត់ផ្ដាច់ចេញពីគ្នាដោយទុកឱ្យនៅជាយកន្ទេលខាងដើមដែលត្រូវចាប់ផ្ដើមមុនគេ។

ឧទាហរណ៍២ ៖ សកម្មភាពកសាង « ក្រងកៅស៊ូ »

កុមារម្នាក់ៗអង្គុយសណ្ដូកជើងទៅមុខ យកកៅស៊ូ១មកទាក់នឹងមេជើង បន្ទាប់មកយកកៅស៊ូ១មកស៊កបន្តនឹងកៅស៊ូដែលចេញពីមេជើងដោយបត់ជា២បញ្ចូលគ្នា រួចយកកៅស៊ូ១ទៀតមកស៊កបន្តដោយបត់ជា២បញ្ចូលគ្នា កុមារអនុវត្តបែបនេះ រហូតនៅសល់កៅស៊ូ១ចុងក្រោយសម្រាប់យកមកស៊កបញ្ចូលគ្នាដោយទាក់ចងធ្វាក់ភ្ជិតមុខមិនឱ្យរបូត។

## ៣.៤ ដំណើរការបង្រៀន

គឺជាឧទាហរណ៍សម្រាប់ជំនួយស្មារតីគ្រូមត្តេយ្យសិក្សា ងាយស្រួលដល់ការរៀបចំដំណើរការបង្រៀន និងរៀនទៅតាមបទពិសោធន៍និងការច្នៃប្រឌិតឱ្យមានប្រសិទ្ធភាព។ មានន័យថា គ្រូអាចម្ចាស់ការរៀបចំលំនាំបង្រៀនបាន។

### ៣.៤.១ ប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពប្រចាំថ្ងៃ និងទម្លាប់ល្អ

អនុវត្តសកម្មភាពប្រចាំថ្ងៃទទួលបានប្រសិទ្ធភាព គឺតម្រូវឱ្យគ្រូមត្តេយ្យសិក្សាគប្បីត្រូវ៖

- ប្រកាន់ខ្ជាប់នូវទឹកមុខរីករាយសម្ដែងការគួរសមរវាងគ្រូ និងកុមារឱ្យបានជិតស្និទ្ធជារៀងរាល់ព្រឹក
- សំណេះសំណាលខ្លះៗអំពីការសាកសួរសុខទុក្ខកុមារ ដោយផ្សារភ្ជាប់ទៅនឹងការប្រើប្រាស់តារាងវត្តមាន
- តារាងថ្ងៃប្រចាំសប្ដាហ៍និងតារាងប្រតិទិនប្រចាំខែនិងតារាងផ្សេងៗទៀតតាមការច្នៃប្រឌិត
- ទម្លាប់កុមារឱ្យទុកដាក់សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនមានសណ្ដាប់ធ្នាប់
- បង្កបរិយាកាសរីករាយតាមការច្នៃប្រឌិត និងអនុវត្តសកម្មភាពប្រចាំថ្ងៃឱ្យបានទៀងទាត់

- ចំពោះការប្រើតារាងឆ្នាំខ្មែរទាំង១២ ខែទាំង១២ និងតារាងផ្សេងៗ គ្រូមត្តេយ្យសិក្សាច្នៃប្រឌិតសកម្មភាពទៅតាមពេលវេលាអំណោយផល។

### ៣.៤.២ ប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពល្បែង

- ជ្រើសរើសល្បែងសមស្របតាមវ័យ តាមចំណូលចិត្ត និងកំណត់ពេលវេលាលេងសមល្មមនឹងកម្លាំងកុមារ
- រៀបចំទីកន្លែង និងសម្ភារៈល្បែងគ្រប់គ្រាន់ ធានាលក្ខណៈគរុកោសល្យ និងសុវត្ថិភាព
- ផ្ដល់ការណែនាំឱ្យបានច្បាស់លាស់
- ចូលរួមលេងជាមួយកុមារ
- ជំរុញ លើកទឹកចិត្តកុមារលេងឱ្យសប្បាយរីករាយ និងគោរពលក្ខខណ្ឌល្បែង។
- ដើម្បីឱ្យការលេងល្បែងសេរីតាមជ្រុងថ្នាក់រៀនផ្ដល់នូវលទ្ធផលល្អដល់កុមារទាំងផ្នែកចំណេះដឹង និងការអប់រំចិត្តសង្គមប្រកបដោយគុណភាព គ្រូមត្តេយ្យសិក្សាគប្បី៖
  - ពិភាក្សាអំពីវិន័យតាមជ្រុងថ្នាក់រៀនភាពសុខដុមក្នុងពេលលេងការទុកដាក់ល្បែងតាមកន្លែងដើម
  - តាមដាន និងសម្របសម្រួលកុមារលេងតាមជ្រុងថ្នាក់រៀន
  - បូកសរុបការលេងសេរីរបស់កុមារទាក់ទងនឹងចំណេះដឹងឬ លទ្ធផលរំពឹងទុកក្នុងកម្មវិធីសិក្សា។

- ប្រសិនបើគ្រូមានគោលបំណងឱ្យលទ្ធផលល្បែងសេរីជួយដល់ការផ្ដល់ និងពង្រឹងចំណេះដឹងថ្មី គ្រូគប្បី៖
  - ដកល្បែងចាស់ចេញ ដើម្បីឱ្យកុមារចាប់អារម្មណ៍យកតែល្បែងថ្មីមកលេង
  - រៀបចំខ្លឹមសារល្បែងថ្មីទាក់ទងនឹងការពង្រឹងចំណេះដឹងស្របតាមកម្មវិធីសិក្សា តាមបទពិសោធន៍ និងសិល្បវិធីរបស់ខ្លួនដាក់តាមជ្រុងថ្នាក់រៀន។

### ៣.៤.៣ ប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពតន្ត្រី ចម្រៀងនិងរបាំ

ប្រភេទនៃការបង្រៀនចម្រៀងនៅមត្តេយ្យសិក្សាមានបីគឺចម្រៀងការស្ដាប់ភ្លេង និងការធ្វើចលនាបទភ្លេង។ការបង្រៀនចម្រៀងកុមារតូចជានាបាននូវប្រសិទ្ធភាពគ្រូគប្បីហ្វឹកហាត់កុមារឱ្យមានការអភិវឌ្ឍសមត្ថភាពតាមរយៈ

➢ **ការហ្វឹកហាត់កុមារច្រៀងចម្រៀង**

- ជ្រើសរើសចម្រៀងដែលមានខ្លឹមសារអប់រំ ពាក្យពេចន៍សាមញ្ញ ងាយយល់ ទំនុកបទងាយច្រៀង និងសមស្របតាមវ័យដោយគ្រូអាចឱ្យកុមារថ្នាក់ទាបច្រៀងតែមួយវគ្គ ថ្នាក់មធ្យម១អាចច្រៀងបានត្រឹម១ ឬ២វគ្គថ្នាក់ខ្ពស់អាចលើសពី២វគ្គទៅតាមសមត្ថភាពជាក់ស្ដែង
- ឱ្យកុមារមានអារម្មណ៍ប្រមូលផ្ដុំល្អក្នុងឥរិយាបថក្រោកឈរ ឬអង្គុយត្រង់ខ្លួន មិនឱន ឬផ្អែកខ្លួននៅលើតុ
- ឱ្យកុមារស្វែងយល់ពីលទ្ធភាពនៃការប្រើប្រាស់សំឡេងផ្ទាល់ខ្លួន ដោយការចេះប្រើខ្យល់ដង្ហើម និងចេះស្រូបខ្យល់ចេញចូលបានរហ័សក្នុងរលកនៃទំហំសំឡេងធម្មតា មិនតឹងពេក មិនធូរពេក មិនប្រឹងពេក និងមិនធ្វើឱ្យកុមារហត់ពេកសំឡេងខ្លាំងល្មម មិនស្រែកឱ្យភ្លាត់សំឡេង មិនលឿនពេក

មិនញាប់ពេក ចេះធ្វើសំឡេងគ្រលួច សំឡេងស្អក ចេះតម្រូវសំឡេងដោយការលើកដាក់សំឡេងឡើងចុះឱ្យត្រូវតាមចង្វាក់ និងអ្នកច្រៀងក្នុងក្រុម

- ឱ្យកុមារយល់ដឹងពីភាពត្រឹមត្រូវនៃការច្រៀងពិរោះដោយការប្រើប្រដាប់បំពងសំឡេងនិងការបញ្ចេញសូរឱ្យត្រូវតាមវាក្យស័ព្ទក្នុងបទចម្រៀង ច្រៀងត្រូវតាមចង្វាក់ ច្រៀង និងធ្វើកាយវិការឱ្យស្រុះគ្នា។

➢ **ការហ្វឹកហាត់កុមារស្តាប់**

ដើម្បីហ្វឹកហាត់កុមារឱ្យមានបំណិនស្តាប់ គ្រូគប្បីរៀបចំសកម្មភាពសមស្របនឹងវ័យ តាមរយៈការនាំកុមារៈ

- អនុវត្តសលាកបត្រក្នុងសៀវភៅតន្ត្រី និងចម្រៀងផ្នែកមត្តេយ្យសិក្សា
- ស្តាប់សូរតន្ត្រីធម្មជាតិ (សំឡេងខ្យល់បក់ ស្លឹកឈើ បោកបក់សំឡេងចាបយំ ទឹកហូរសត្វត្រសេកចោះដើមឈើផ្គរលាន់សូរភ្លៀងធ្លាក់លើដំបូលផ្ទះជាដើមនាំកុមារស្តាប់សំឡេងមិនធម្មជាតិ) ដូចជាសំឡេងគោះតុ សំឡេងឡាន ម៉ូតូ ដំដែកគោល កាប់ឱសជាដើម...។ជាបន្តបន្ទាប់នាំកុមារស្តាប់សាច់ភ្លេងសុទ្ធ នៃបទចម្រៀងដែលបានច្រៀងរួចមកហើយ។
- ស្តាប់ និងហ្វឹកហាត់កុមារគោះចង្វាក់ភ្លេង
- ហ្វឹកហាត់សំឡេង និងការលេងល្បែងទាក់ទងនឹងសំឡេងដូចជាសំឡេងស្មើ គ្រលួច តូចធ្មារ គ្រលរ គ្រហឹម ខ្លាំងៗ តិចៗ ថ្នមៗ ត្រាប់តាមសំឡេងសត្វ ត្រាប់តាមសំឡេងវត្ថុផ្សេងៗ ជាដើម
- ស្តាប់ចម្រៀងអាចប្រាប់ចំណងជើងបាន
- ស្តាប់ និងចំណាំសំឡេងរបស់អ្នកច្រៀង។

➢ **ការហ្វឹកហាត់ ចលនាតាមបទភ្លេង**

ចលនា និងបទភ្លេងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ។ ត្រចៀកមានសញ្ញាណពីរដែលផ្គោបជាប់គ្នាគឺសោតវិញ្ញាណ និងប្រព័ន្ធឥន្ទ្រីយាម្មរណ៍(ប្រត្យក្សារម្មណ៍) ដូចនេះហើយ បានជានៅពេលឮសូរភ្លេងយើងមានអារម្មណ៍រំភើបព្រមជាមួយនឹងការបញ្ចេញកាយវិការទៅតាមបទភ្លេងនោះ និងឱ្យយើងដឹងពីប្រភពសំឡេង។ការធ្វើចលនាតាមបទភ្លេង (ធ្វើកាយវិការតាមបទចម្រៀង តាមបទភ្លេង តាមសលាកបត្រ) ការស្តាប់ខ្លុយឬហ្គីតា ឬចាប៉ី ឬស្តាប់ការប្រគំតន្ត្រីខ្មែរ បរទេស មានឥទ្ធិពលអង្រួនអារម្មណ៍ស្រូបយកបេះដូង អ្នកស្តាប់ អ្នកទស្សនាឱ្យរំភើបញាប់ញ័រដាក់អារម្មណ៍ទៅក្នុងបទភ្លេង ច្រៀងតាម ធ្វើកាយវិការតាម ឬបង្ហាញកាយវិការគាំទ្រហូតដល់ងប់ងល់លះបង់ដើម្បីតារាដែលខ្លួនពេញចិត្ត។ ចំពោះមត្តេយ្យសិក្សាបទភ្លេងដែលកំសត់លន្លង់លន្លោចមិនសក្តិសមនឹងវ័យកុមារឡើយ។ បទភ្លេងដែលត្រូវ នឹង វ័យកុមារ គឺជាបទភ្លេងដែលមានចង្វាក់ផ្លាស់ប្តូរម្តងលឿន ម្តងយឺតបែបកន្ត្រាក់ បែបស្វាហាប់ទើបមានឥទ្ធិពលធ្វើឱ្យអារម្មណ៍កុមារ រំភើបសម្តែងចេញនូវចលនាសមស្រប ជាមួយបទភ្លេងតាមចង្វាក់ដោយសប្បាយរីករាយ និងមោទកៈ។

ដោយហេតុនេះគ្រូមត្តេយ្យសិក្សា ត្រូវបណ្តុះនិស្ស័យសិល្បៈរបស់ខ្លួនឱ្យយល់ដឹងពីទំនាក់ទំនងរវាងបទភ្លេង និងចលនាដែលមានលក្ខណៈសមស្របនឹងវ័យកុមារ ទាក់ទាញកុមារឱ្យមានចិត្តរំភើបពេញចិត្តស្តាប់ និងធ្វើកាយវិការតាមបទភ្លេង ។

- ការធ្វើចលនាតាមបទភ្លេងនឹងមានការរៀបចំផ្លាស់ប្តូរតាមខ្លឹមសារបទចម្រៀង តាមកម្រិតវ័យរបស់កុមារ។

➢ **ការហ្វឹកហាត់លំនឹករបស់កុមារ**

ទន្ទឹមនឹងការហ្វឹកហាត់កុមារច្រៀង ស្ដាប់ និងធ្វើកាយវិការ គ្រូគប្បីហ្វឹកហាត់លំនឹកបន្ថែមទៀត តាមរយៈការគ្រាប់តាម ឬរំឭកចម្រៀង ឬធ្វើសកម្មភាពឡើងវិញនូវ៖

- ភាពបន្តគ្នានៃសូរសំឡេង
- ចង្វាក់
- ល្បឿនភ្លេង
- ចម្រៀង

## តារាងបង្ហាញពីសំណួមពរក្នុងដំណើរការបង្រៀន និងរៀនចម្រៀង

| សំណូមពរ | ថ្នាក់ទាប | ថ្នាក់មធ្យម | ថ្នាក់ខ្ពស់ |
|---|---|---|---|
| - ធ្វើឱ្យកុមាររំភើបចិត្ត | - ស្ដាប់ និងចូលរួមច្រៀងរហូតដល់ចប់រយៈពេល១-២នាទី<br>- គ្រូប្រែប្រួលវិធីបង្រៀនឱ្យមានលក្ខណៈទាក់ទាញ និងបំផុសសំណួរប្រដេញឱ្យកុមារយល់អត្ថន័យបទចម្រៀង | - ស្ដាប់និងចូលរួមច្រៀងរហូតដល់ចប់រយៈពេល៣-៥នាទី និងយល់អត្ថន័យខ្លះៗ<br>- គ្រូប្រែប្រួលវិធីបង្រៀនឱ្យមានលក្ខណៈទាក់ទាញនិងបំផុសសំណួរប្រដេញឱ្យកុមារយល់អត្ថន័យបទចម្រៀង | - កុមារស្ដាប់ដោយប្រុងប្រយ័ត្ន បង្ហាញនូវឥរិយាបថជំនក់ចិត្ត និងចូលរួមច្រៀងរហូតដល់ចប់រយៈពេល៥នាទី និងយល់អត្ថន័យបចម្រៀងអាចឆ្លើយតបសំណួរគ្រូបានច្រើននាក់<br>- គ្រូប្រែប្រួលវិធីបង្រៀនឱ្យមានលក្ខណៈទាក់ទាញនិងបំផុសសំណួរសរុប |
| - ជួយកុមារឱ្យអភិវឌ្ឍប្រត្យក្សារម្មណ៍ | - ស្ដាប់ចម្រៀងកុមារប្រាប់ចំណាងជើងចម្រៀងបានចំពោះចម្រៀងដែលធ្លាប់ស្ដាប់និងបានហាត់ច្រៀង | - ស្ដាប់ចម្រៀង កុមារប្រាប់ចំណាងជើងចម្រៀង និងលំនាំបទបានចំពោះចម្រៀងដែលធ្លាប់ស្ដាប់និងបានហាត់ច្រៀង | - ដូចសកម្មភាពថ្នាក់មធ្យមស្ដាប់បទភ្លេងកុមារប្រាប់ចំណាងជើងចម្រៀង និងលំនាំបទបានចំពោះចម្រៀងថ្មីដែលមានសាច់ភ្លេងដូចគ្នា |
| - ជួយកុមារឱ្យបង្ហាញពីចំណូលចិត្តបទចម្រៀង | - ប្រាប់ពីចំណាងជើងបទចម្រៀងនិងច្រៀងធ្វើកាយវិការបាន១ឬ២បទ | - ដូចថ្នាក់ទាប និងប្រាប់បានខ្លះៗពីហេតុផលចូលចិត្តបទចម្រៀងនោះ | - ដូចថ្នាក់មធ្យម |
| - ជួយកុមារឱ្យយល់ដឹងពីសញ្ញាតាង | - ចំណាំបានពីសញ្ញាតាង និងកាយវិការដែលបញ្ជាក់ពីចំនួនព្យាង្គក្នុងពាក្យ | - ដូចថ្នាក់ទាបនិងអនុវត្តលំហាត់កាន់តែលំបាក | - ដូចថ្នាក់មធ្យម<br>- ហ្វឹកហាត់ជាអ្នកបញ្ជាភ្លេង |

| | | | |
|---|---|---|---|
| | | - ប្រាប់ពីសញ្ញាបញ្ជាភ្លេងរបស់គ្រូដូចជាសំឡេងស្មើ ឡើងចុះលឿន យឺតជាដើម | |

### ៣.៤.៤ ប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពកសាង

ការបង្រៀនសកម្មភាពកសាងកុមារតូចជានាបាននូវប្រសិទ្ធភាព គ្រូគប្បីហ្វឹកហាត់កុមារឱ្យមានការអភិវឌ្ឍសមត្ថភាព ការយល់ដឹង ការពេញចិត្តចំពោះសិល្បៈ ការបង្កើតរូបភាពតាមរយៈ ៖

- ការហ្វឹកហាត់របៀប បត់ រោយ ដេរ ត្បាញ ហែកបិត កាត់បិត សូន ស្នាច់ ដោត បង្កើតបានជារូប ឬល្បែងលេងដែលចេញពីការច្នៃប្រឌិតសម្រាប់ការសិក្សារបស់កុមារតូច និង តុបតែងលម្អ ជាពិសេសរីកចម្រើន ផ្នែកចលករតូចឱ្យបានស្ទាត់ជំនាញក្នុងការចាប់កាន់ខ្មៅដៃសរសេរត្រៀមចូលបឋមសិក្សា។

### ៣.៤.៥ ប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពគំនូរ

ការបង្រៀនសកម្មភាពគំនូរ កុមារតូចជានាបាននូវប្រសិទ្ធភាព គ្រូគប្បីហ្វឹកហាត់កុមារឱ្យមានការអភិវឌ្ឍសមត្ថភាព ការយល់ដឹង ការពេញចិត្តចំពោះសិល្បៈគំនូរ តាមរយៈ ៖

- ការហ្វឹកហាត់របៀបគូរតាមវត្ថុគម្រូ គូរតាមប្រធានបទ គំនូរផាត់ពណ៌ គំនូរផ្គុំម គូរលម្អជរជាយ គូរដោយសេរី គឺធ្វើឱ្យកុមារអភិវឌ្ឍផ្នែកសង្គមនិងអារម្មណ៍ សិលធម៌ វប្បធម៌ កុមារចូលចិត្តសោភ័ណ្ឌ ជាពិសេសរីកចម្រើនផ្នែកចលករតូចឱ្យបានស្ទាត់ជំនាញក្នុងការចាប់កាន់ខ្មៅដៃសរសេរត្រៀមចូលបឋមសិក្សា ។

# ជំពូក ៤

# ការរៀបចំបរិស្ថានសិក្សា នៃមុខវិជ្ជាសិក្សាសង្គម

# ជំពូក៤ ការរៀបចំបរិស្ថានសិក្សា នៃមុខវិជ្ជាសិក្សាសង្គម

## ៤.១-យន្តការអនុវត្ត

បរិស្ថានសិក្សាជាទីមេត្រីរបស់កុមារសំដៅលើការរៀបចំថ្នាក់រៀនបែបគរុកោសល្យ ឱ្យមានភាពទាក់ទាញ ជាទីស្រឡាញ់ចូលចិត្តរៀនសូត្រ និងធានាបាននូវគុណភាពនិងប្រសិទ្ធភាពនៃដំណើរការបង្រៀន និងរៀន ។

### ៤.១.១ ផ្នែកសង្គមនិងអារម្មណ៍

ការផ្តល់ភាពកក់ក្តៅ និងមានសុវត្ថិភាពធ្វើឱ្យកុមារកាន់តែមានភាពងាយស្រួលក្នុងការរុករកអ្វីៗដែលថ្មី។ បទពិសោធន៍ទាំងអស់ត្រូវមានការពាក់ព័ន្ធរវាងសម្ភារៈនិងមនុស្ស។ការចិញ្ចឹមបីបាច់ការអភិវឌ្ឍសុខភាពផ្លូវចិត្ត អាកប្បកិរិយាសង្គមអារម្មណ៍ឱ្យសមស្របទៅនឹងបរិយាកាសដែលជាទីមេត្រីរបស់កុមារ។ គ្រូត្រូវជួយសម្រួលដល់ការរៀនសូត្ររបស់កុមារនៅក្នុងផ្នែកផ្សេងទៀត។ ក្នុងការកំណត់បរិស្ថានសិក្សារាប់បញ្ចូលទាំងទីកន្លែង ពេលវេលា បទពិសោធនសម្ភារៈរូបវន្ត និងសម្ភារៈសិក្សា។

### ៤.១.២.ការបង្កើតបរិយាកាសរៀនសូត្រប្រកបដោយភាពកក់ក្តៅនិងបែបវិជ្ជមាន

គ្រូជួយកុមារឱ្យចេះអត់ធ្មត់ នឹងបញ្ហាប្រឈមដែលពួកគេជួបប្រទះរាល់ថ្ងៃផ្តល់នូវបរិយាកាសគាំទ្រដែលអនុញ្ញាតឱ្យកុមារអភិវឌ្ឍទំនុកចិត្ត និងមានអារម្មណ៍សុវត្ថិភាព អំពីការរកឃើញពួកគេជានរណាបង្ហាញអារម្មណ៍របស់ពួកគេរួមទាំងអារម្មណ៍ដូចជាកំហឹង និងការភ័យខ្លាចធ្វើឱ្យគេស្គាល់គំនិត និងទស្សនៈរបស់ពួកគេទោះបីការយល់ឃើញខុសៗគ្នាក៏ដោយ។ ម៉្យាងទៀតការបង្កើតអារម្មណ៍បែបវិជ្ជមានរបស់កុមារទាក់ទងទៅនឹងមិត្តភក្តិគ្រួសារ និងសហគមន៍លើសពីនេះទៀតគ្រូគួរតែបង្ហាញពីការយកចិត្តទុកដាក់និងសុវត្ថិភាពនៅពេលមានការទំនាក់ទំនងគ្នាជាមួយកុមារ និងគ្រប់គ្រងអាកប្បកិរិយារបស់ពួកគេ។

**ឧទាហរណ៍៖** កាន់ដៃកុមារនៅពេលនិយាយជាមួយគាត់អំពីអាកប្បកិរិយាសមរម្យដែលគាត់គួរបង្ហាញជួយកុមារឱ្យមានអារម្មណ៍សុវត្ថិភាព។ អាកប្បកិរិយារបស់គ្រូបែបនេះជំរុញឱ្យមានអារម្មណ៍សុវត្ថិភាពនិងសុខភាពផ្លូវចិត្ត និងជួយកុមារឱ្យរៀនបង្ហាញពីអារម្មណ៍របស់ពួកគេចំពោះមិត្តភក្តិ និងមនុស្សពេញវ័យដែលគួរឱ្យទុកចិត្ត។

គ្រូបង្រៀន ត្រូវចូលរួមក្នុងការលេងរបស់កុមារដោយគាំទ្រចំណាប់អារម្មណ៍របស់ពួកគេការសន្ទនាជាមួយពួកគេទទួលស្គាល់ការខិតខំរបស់ពួកគេតាមរយៈការសរសើរ និងលើកទឹកចិត្ត។បរិយាកាសក្នុងថ្នាក់បែបវិជ្ជមានកុមារនឹងមានអារម្មណ៍ថាមានសុវត្ថិភាពការគាំទ្រមានឆន្ទៈ ដើម្បីពិសោធសាកល្បងអ្វីដែលថ្មី និងបង្ហាញគំនិតរបស់ពួកគេ។

### ៤.១.៣. រៀបចំបរិស្ថានដែលជួយដល់ការអភិវឌ្ឍរាងកាយ

គ្រូបង្រៀនត្រូវរៀបចំសម្ភារៈរូបវន្តឧបករណ៍និងការលេង។ នៅពេលរៀបចំផែនការគ្រូត្រូវគិតពីបទពិសោធន៍ សម្ភារៈការរៀនសូត្រសម្រាប់កុមារព្រោះកត្តាទាំងវានេះជះឥទ្ធិពលលើផ្លូវចិត្តកុមារតាមរយៈការធ្វើសកម្មភាពនិងការឆ្លើយតប។ ថ្នាក់រៀនដែលមានបរិស្ថានសិក្សាល្អត្រូវរៀបចំគ្រឿងសង្ហារឹមឱ្យសមស្របនិងមានដែនកំណត់ទៅតាមស្ថានភាពជាក់ស្តែងនៃតំបន់និមួយៗគ្រូត្រូវរៀបចំទីកន្លែង ដើម្បីឱ្យកុមារលេងធ្វើការជាក្រុមនិងស្វែងយល់។ ការរៀបចំប្រកបដោយប្រសិទ្ធភាពនៃឯកសារបរិស្ថាននឹងកាត់បន្ថយចំនួនជម្លោះដែលអាចកើតមានក្នុងចំណោមកុមារ។

ខាងក្រោមនេះគឺជាសំនួរមួយចំនួនដែលគ្រូអាចសួរខ្លួនឯងនៅពេលពួកគេជួបបរិយាកាសគាំពារសង្គមនិងអារម្មណ៍ដែលក្មេងៗមាន អារម្មណ៍នៃកម្មសិទ្ធិនិងសុវត្ថិភាព៖

- តើការបង្ហាញសម្ភារៈនិងធនធានត្រូវបានដាក់ រៀបចំឱ្យមានភាពទាក់ទាញទេ?

- តើស្នាដៃរបស់កុមារត្រូវបានបង្ហាញដើម្បីទាក់ទាញការកោតសរសើរពីឪពុក**ម្ដាយ**គ្រូនិងកូនខ្លួនឯង
- តើកន្លែងទំនេរធ្វើឱ្យកុមារមានអារម្មណ៍ស្រួលទេ? materials
- តើសម្ភារៈរបស់កុមារត្រូវបានដាក់ជាក្រុមដោយផ្អែកលើរបៀបដែលពួកគេត្រូវបានប្រើឬទេ?
- តើមជ្ឈមណ្ឌលសិក្សាត្រូវបានកំណត់យ៉ាងច្បាស់ដូច្នេះកុមារអាចស្គាល់ពីអ្វីដែលពួកគេអាចធ្វើបានធ្វើនៅក្នុងចន្លោះនោះ?
- តើមានទីធ្លាសម្រាប់សកម្មភាពផ្សេងៗគ្នា ស្ងាត់ សកម្ម និងធំឬតូចក្រុម?

## ៤.២. តម្រូវការធនធានសម្ភារៈរូបវ័ន្តសិក្សា

### ៤.២.១. ការរៀបចំ និងជ្រើសរើសធនធាន(មនុស្ស សម្ភារៈ បទពិសោធន៍)

ការរៀបចំធនធានដោយគិតគូរនៅក្នុងបរិយាកាសល្អ ដែលមានភាពស្អាតស្អំស្រស់ស្អាតលើកទឹកចិត្តឱ្យកុមារគោរពបរិស្ថានរបស់ពួកគេ។ កុមារមានគំនិតអភិវឌ្ឍខ្លួនឯងបែបវិជ្ជមាននៅពេលដែលពួកគេអាចទទួល បានសម្ភារៈដោយខ្លួនឯង។ មាតាបិតាអ្នកអាណាព្យាបាលត្រូវទម្លាប់ឱ្យកុមារទទួលខុសត្រូវក្នុងការរៀបចំទុកដាក់សម្ភារៈឱ្យត្រូវតាមទីកន្លែង។ បរិយាកាសល្អប្រសើរដែលមានបទប្បញ្ញត្តិគ្រប់គ្រាន់សម្រាប់កុមារលើកទឹកចិត្តពួកគេសម្រេចថាត្រូវនិងអ្វីដែលពួកគេចង់ស្វែងយល់និងពិសោធន៍ធនធាន។

ដើម្បីលើកកម្ពស់ការអភិវឌ្ឍសង្គម និងអារម្មណ៍គ្រូអាចជ្រើសរើសសម្ភារៈទាំងនោះផ្ដល់ឱកាសឱ្យកុមារធ្វើអន្តរកម្មជាមួយគ្នា។

**ឧទាហរណ៍៖**

- គ្រូមានគម្រោងអោយក្មេងៗចូលរួមលេងល្បែងដែលធ្លាប់ស្គាល់លេងជាក្រុមតូចដោយផ្ដល់
- សម្ភារៈលើកទឹកចិត្តកុមារឱ្យពិភាក្សាគ្នាប្ដូរវេន និងធ្វើការសម្រេចចិត្តប្រកបដោយទំនួលខុសត្រូវដើម្បីជួយកុមារឱ្យដឹងពីចំណុចខ្លាំងរបស់ពួកគេនៅពេលលេងតែម្នាក់ឯង។
- ការផ្ដល់សំភារៈសមស្របមជ្ឈដ្ឋានរស់នៅរបស់កុមារនិងការអភិវឌ្ឍអារម្មណ៍។
- មានសៀវភៅរូបភាពនិងសៀវភៅព័ត៌មានជាច្រើនអំពីគំនិតខ្លួនឯងគ្រប់គ្រងអារម្មណ៍ ការភ័យខ្លាចការយល់ពីតម្លៃខ្លួនឯង និងធ្វើការរួមគ្នាជាក្រុមដោះស្រាយជម្លោះពួកគេគឺជាមធ្យោបាយដ៏ល្អបំផុតបង្កឱ្យមានការពិភាក្សាលើបញ្ហាដែលនឹងជួយកុមារ។ កំណត់បញ្ហានៃជម្លោះនិងមធ្យោបាយដែលអាចទទួលយកបានដើម្បីដោះស្រាយស្វែងយល់ពីការធ្វើខុសនិងអាកប្បកិរិយាសមរម្យទទួលស្គាល់អារម្មណ៍បែបអវិជ្ជមាន។



រូបភាពទី ៨៖ សម្ភាររូបវន្តសិក្សា

### ៤.២.២. ការជំរុញ និងគោរពបរិស្ថាន

បរិយាកាសអារម្មណ៍សង្គមសមស្របគោរពលក្ខណៈបុគ្គលរបស់កុមារ និងត្រូវការភាពឯកជន។ នេះមានន័យថាកុមារម្នាក់ៗមានកន្លែងប្រមូល និងរក្សាទុករឿង"មានតម្លៃ" និង"ប្លែក" (វាគួរតែមានកន្លែងទំនេ សម្រាប់រូបភាពនិងការងាររបស់ពួកគេត្រូវបានបង្ហាញយ៉ាងទាក់ទាញនៅក្នុងថ្នាក់រៀន) ពួកគេគួរតែត្រូវបានអនុញ្ញាតពេលវេលាដើម្បីធ្វើអ្វីដែលពួកគេចង់ធ្វើ បើមិនដូច្នេះទេការលេងអាចនឹងក្លាយជាការខកចិត្តមួយបទពិសោធន៍សម្រាប់ពួកគេ។

**សង្ខេប**

បរិយាកាសរៀនសូត្រប្រកបដោយភាពកក់ក្ដៅ និងមានសុវត្ថិភាពរួមជាមួយទំនាក់ទំនងល្អរបស់គ្រូក្នុងការជួយកុមារឱ្យមានអារម្មណ៍និងសុវត្ថិភាព។ ដូច្នេះការបង្កើនទំនុកចិត្តរបស់កុមារការលើកទឹកចិត្តពួកគេឱ្យស្វែងរកអ្វីថ្មីនិងអាចបង្កើតដោយខ្លួនឯងបានគឺជាកត្តាសំខាន់បំផុតសម្រាប់ឱ្យកុមារមានការអភិវឌ្ឍន៍។

កុមារអាចរៀននិងស្វែងយល់ពីអ្វីដែលពួកគេអាចធ្វើបាន។ ការជ្រើសរើសនេះត្រូវគិតពីធនធានដែលមាននៅក្នុងបរិយាកាសរៀនសូត្ររបស់កុមារ និងដែលមានការរៀបចំល្អនឹងផ្ដល់ជូនឱកាសសម្រាប់កុមារធ្វើនិងបង្កើតទំនាក់ទំនងជាមួយគ្នាហើយឱ្យកុមារធ្វើការសម្រេចចិត្តប្រកបដោយភាពទទួលខុសត្រូវ។

## ៤.៣.ការស្វែងរកការគាំទ្រផ្សេងៗ

### ៤.៣.១ សោភ័ណភាពនិងការបង្កើតថ្មី

សិល្បៈ តន្ត្រី និងសកម្មភាពចលនា អាចត្រូវបានធ្វើឡើងក្រៅពីថ្នាក់រៀន និងមិនគួរត្រូវបានកំណត់ទៅកន្លែងធ្វើការដូចគ្នា។ គ្រូបង្រៀនគួរតែប្រើសម្ភារៈធនធានទីធ្លាខាងក្នុងនិងខាងក្រៅនៃថ្នាក់រៀន។

គ្រូអាចពិចារណាដូចតទៅនេះនៅពេលរៀបចំបរិយាកាសដែលលើកកម្ពស់សោភ័ណភាពនិងការបញ្ចេញមតិច្នៃប្រឌិត៖

- បង្ហាញសៀវភៅរូបភាពដែលមានភាពស្រស់ស្អាតដែលមានបោះពុម្ពរូបភាពសិល្បៈនិងវត្ថុបុរាណគួរឱ្យចាប់អារម្មណ៍ និងទាក់ទាញភ្នែករបស់កុមារ
- ផ្ដល់កន្លែងទំនេរសម្រាប់ចលនាច្នៃប្រឌិតនិងសកម្មភាពក្រុម
- ផ្ដល់កន្លែងទំនេរសម្រាប់សកម្មភាពច្នៃប្រឌិតដូចជាការធ្វើគំរូជីឥដ្ឋនិងការធ្វើឱ្យ Collage
- ផ្ដល់កន្លែងសម្រាប់សកម្មភាពសើមនិងរញ៉េរញ៉ៃ
- រៀបចំឱ្យមានធនធាន និងសម្ភារៈដែលធ្លាប់ស្គាល់ និងរឿងនិទានសម្រាប់កុមារពិសោធន៍ស្វែងយល់និងប្រើដើម្បីបង្ហាញគំនិត និងអារម្មណ៍របស់ពួកគេផ្ដល់សំភារៈដែលអាចទាក់ទាញចំណាប់អារម្មណ៍របស់កុមារនិងអាចប្រើប្រាស់បានដោយសំបូរបែប។

### ៤.៣.២ ការរៀបចំបរិស្ថានដែលជួយដល់ការអភិវឌ្ឍរាងកាយ

- សិល្បៈតន្ត្រីនិងសកម្មភាពចលនាអាចត្រូវបានធ្វើឡើងជាក្រុមធំតូចឬសកម្មភាពបុគ្គល
- រៀបចំការផ្លាស់ទី ជ្រុងសិក្សាគ្រឿងសង្ហារឹម ដើម្បីឱ្យកុមារធ្វើការជាក្រុមធំដូចជាការគូរគំនូរ លើជញ្ជាំង
- ទីកន្លែងធ្វើសកម្មភាពសិល្បៈប្រកបដោយផាសុកភាពជាក្រុមតូចឬជាបុគ្គលគួរតែត្រូវបានដាក់ឱ្យឆ្ងាយពីផ្លូវចេញចូល។

- សកម្មភាពគូរគំនូរអាចត្រូវបានធ្វើឡើងនៅខាងក្រៅកន្លែងដែលកុមារអាចសង្កេតនិងបង្កើតស្នាដៃសិល្បៈទាក់ទងនឹងបរិស្ថានធម្មជាតិបាន
- ភាពរញ៉េរញ៉ៃនិងការកំពប់ជាផ្នែកមួយនៃការរៀនសូត្ររបស់កុមារ។ដើម្បីកាត់បន្ថយភាពរញ៉េរញ៉ៃអប្បរមាគ្រូអាចពិចារណាដូចខាងក្រោម៖
  - រៀបចំកុមារឱ្យទៅធ្វើសកម្មភាពនៅខាងក្រៅថ្នាក់ សមស្របតាមប្រធានបទ និងបរិស្ថាន
  - ឱ្យកុមារអនុវត្តទម្លាប់នៃការសម្អាតបន្ទាប់ពីធ្វើសកម្មភាព
  - វត្ថុដែលមុតស្រួចហើយត្រូវការការត្រួតពិនិត្យពីមនុស្សពេញវ័យ

### ៤.៣.៣. ការរៀបចំនិងជ្រើសរើសធនធាន

**សិល្បៈ** ៖ប្រភេទមូលដ្ឋាននៃធនធានសិល្បៈរួមមាន៖

- ឧបករណ៍សម្រាប់ធ្វើសញ្ញាសម្គាល់ )ឧទាហរណ៍៖សញ្ញាសម្គាល់ខ្មៅដៃ ដីសក្រដាសមានទំហំរាង និង
- កំណាត់ផ្សេងៗគ្នារូបគំរូ ដីឥដ្ឋ កន្ត្រៃការ កាសែត ស្លុត ខ្សែ អំបោះ ...
- តន្ត្រីនិងចលនាឧបករណ៍ភ្លេងដែលសមស្របសម្រាប់ថ្នាក់រៀនរួមមាន៖ (កំប៉ុងដែលបំពេញដោយធញ្ញជាតិគ្រាប់គ្រួស បន្ទះឬស្សី ត្រឡោក ដុំឈើ...)
- សំលៀកបំពាក់ សម្រាប់ របាំប្រជាប្រិយ និង របាំជនជាតិ

### ៤.៣.៤. ដំណាក់កាលនៃការអភិវឌ្ឍផ្នែកសិល្បៈ

ការអភិវឌ្ឍផ្នែកសិល្បៈសម្រាប់កុមារអាស្រ័យលើកុមារទទួលបានឱកាស៖

- រីករាយក្នុងការរុករក និងពិសោធជាមួយសម្ភារៈផ្សេងៗ និងឧបករណ៍សិល្បៈ
- ភ្ញោចឱ្យមើលឃើញនូវបរិយាកាស និងការងារសិល្បៈ
- បង្ហាញទស្សនៈផ្ទាល់ខ្លួនអំពីពិភពលោកជុំវិញសកម្មភាពសិល្បៈគួរតែត្រូវបានរៀបចំទៅ
- តាមលំដាប់លំដោយនៃសកម្មភាព ដើម្បីបង្ហាញពីការលូតលាស់នៃភាពស្មុគស្មាញរបស់កុមារ និងកសាងបទពិសោធន៍សម្រាប់ជំនាញទុនរបស់កុមារ។

ខាងក្រោមនេះគឺជាឧទាហរណ៍របៀបរៀបចំសកម្មភាពសិល្បៈអាចត្រូវបានដាក់ជាបន្តបន្ទាប់៖

| ជំហាន | គំនូរ | គំនូរផាត់ពណ៌ | ការផ្គុំ ឬបោះពុម្ព | រូបគំរូ |
| --- | --- | --- | --- | --- |
| ១ | គូរលើក្រដាសជាមួយហ្វឺតធំឬគូល័រទៀន | ផាត់ព័ណលើរូបភាព... | បោះពុម្ពជាមួយអរយរៈឬវត្ថុផ្សេងៗ | គូររូបគំរូ វត្ថុពិត គូរតាមស្រមោលរូបភាព... |
| ២ | គូរលើក្រដាសជាមួយដីស និងដំបងធ្យូង | លាបជាមួយនឹងជក់ធំលើក្រដាសដែលនៅលើជើងទម្រប៉ាណូ | បោះពុម្ពដោយប្រើក្រដាស ជូតលើកំណាត់ដែលមានសម្ភារៈដូចជាផ្នែកម្ខាងនៃកន្ត្រកកម្រាលថ្មជញ្ជាំង សំបកឈើ កាក់ និងស្លឹក | |
| ៣ | ពិសោធន៍ជាមួយធ្យូងលើផ្ទាំងកំណាត់ | គូរជាមួយវត្ថុផ្សេងទៀតដូចជា ស្លឹកគ្រាប់ ដុំឈើជាដើម | បោះពុម្ពជាមួយវត្ថុមានទំហំកណ្តាលដូចជាគម្របដប ថ្មម៉ាបជាដើម | |

ការស្វែងយល់អំពីដំណាក់កាល នៃការអភិវឌ្ឍផ្នែកសិល្បៈអាចជួយគ្រូសម្រួលដល់កុមារឱ្យទទួលបាននូវចំណេះដឹង ជំនាញ សោភ័ណភាព និងការច្នៃប្រឌិត គ្រូត្រូវដឹងថាកុមាររីកចម្រើនឆ្លងតាមដំណាក់កាលដូចតទៅ៖

- ដំណាក់កាលនៃការគូសវាស
- ដំណាក់កាលទម្រង់មូលដ្ឋាន ( ការច្នៃប្រឌិតគំនូសមូលដ្ឋាន)
- ដំណាក់កាលរូបភាព (គំនូរដំបូងគំនូរតាម គំនូរសេរី... )
- ដំណាក់កាលរូបភាពពេញលេញ

ក្នុងចំណោមដំណាក់កាលទាំងបួននេះ មានដំណាក់បីដំបូងដែលបង្ហាញនូវសកម្មភាពប្លែកៗជាច្រើននៅកម្រិតមត្តេយ្យសិក្សាក្នុងការស្វែងយល់ពីសិល្បៈ។ ដំណាក់កាលទាំងនេះគឺជាដំណាក់រៀបតាមលំដាប់លំដោយ ដើម្បីឱ្យកុមាររីកចម្រើនជាបន្តបន្ទាប់ចាប់ពីការពិសោធន៍ និងការរុករក (ដំណាក់កាលនៃការគូសវាស) រហូត ដល់ការបង្កើតទម្រង់មូលដ្ឋានមុនពេលបង្កើតរូបតំណាង ឬនិមិត្តរូប (Ministry of Education, Aesthetic and creative expression, Copyright 2013)។

### ៤.៣.៥. ធាតុផ្សំសំខាន់នៃសិល្បៈសម្រាប់កុមារ

ដើម្បីប្រែក្លាយសកម្មភាពសិល្បៈ ប្រកបដោយប្រសិទ្ធភាពឱ្យទៅជាបទពិសោធន៍នៃការសិក្សាដ៏មានតម្លៃគ្រូគប្បីយល់ពីធាតុផ្សំនៃសិល្បៈក្នុងការជួយកុមារឱ្យអភិវឌ្ឍការយល់ដឹងអំពីសិល្បៈបានល្អប្រសើរ ដើម្បីឱ្យកុមាររកពាក្យឆ្លើយតបឬបកស្រាយនូវអ្វីដែលកុមារបានមើលឃើញនិងសម្រួលដល់ការបង្កើនបទពិសោធន៍ សិល្បៈរបស់ កុមារ។

ធាតុផ្សំមូលដ្ឋានសំខាន់ៗនៃសិល្បៈមានដូចខាងក្រោម៖

- គំនូសមូលដ្ឋាន

- ពណ៌ ( ស្គាល់ពណ៌ និងការលាយពណ៌ )
- រាង (រាងធរណីមាត្រ)
- សម្ភារៈសម្រាប់គំនូរ
- ទម្រង់រូបភាព ( ការច្នៃទម្រង់ )
- លំហ( ការរៀបចំប្លង់រូបភាព )
- តម្លៃ ( ខ្លឹមសាររូបភាព )

### ៤.៣.៥.១.គំនូសមូលដ្ឋាន

ជាបន្ទាត់ដែលត្រូវបន្តពីចំណុចមួយទៅចំណុចមួយ ឬសញ្ញាបន្តដែលបង្ហាញនូវទិសដៅជាក់លាក់ បង្កប់នៃចលនា និងបង្ហាញពីកម្លាំងសង្កត់ (ឧទាហរណ៍៖បន្ទាត់ស្តើង បន្ទាត់ក្រាស) ត្រូវបានធ្វើឡើងបានដោយប្រើឧបករណ៍ ដូចជាខ្មៅដៃ ហ្វឺត គូល័រទៀន ឬដំបង...។

តាមរយៈគំនូសមូលដ្ឋាន គ្រូណែនាំកុមារឱ្យស្គាល់ពាក្យពេចន៍ និងអារម្មណ៍ ដើម្បីពិពណ៌នាដូចជា វែងខ្លីក្រាស់ស្តើងផ្តេក បញ្ឈរ ទ្រេតឆ្វេង ទ្រេតស្តាំ...ដោយរលូនជាដើម ។



*រូបភាពទី ៩៖ គំនូសមូលដ្ឋាន*

### ៤.៣.៥.១.ពណ៌

ពណ៌ត្រូវបានកើតឡើងដោយកាំរស្មីនៃពន្លឺព្រះអាទិត្យដែលសំយោគជាមួយចំហាយទឹក។ ដូច្នេះ យើងមើលឃើញពណ៌តាមចំណាំងផ្លាតនៃពន្លឺ ឆ្លងកាត់តាមរយៈភ្នែក បានបង្ហាញពណ៌៖

- ទាក់ទាញចំណាប់អារម្មណ៍
- ធ្វើឱ្យយើងមានអារម្មណ៍ធូរស្បើយឬរំភើប
- ជួយឱ្យមានពន្លឺ សោភ័ណ ឆ្លុះបញ្ចាំងពីអត្តចរិតរបស់មនុស្ស ។

ពណ៌ខាងក្រោមនេះបានបង្ហាញពីពណ៌ដើម/មេពណ៌ដែលបង្កើតបានជាពណ៌ផ្សេងៗនិងពណ៌បំពេញបន្ថែមជួយឱ្យយើងយល់ពីការប្រើប្រាស់ពណ៌នៅក្នុងសិល្បៈ៖




រូបភាពទី 10៖ ពណ៌

## ពណ៌ដើមឬពណ៌មេពណ៌បន្ទាប់ ឬពណ៌ទី ២

ពណ៌ចម្បងទាំងបីគឺក្រហមខៀវនិងលឿងពណ៌ទាំងនេះត្រូវបានប្រើដើម្បីផលិតពណ៌ផ្សេងទៀត។

លាយពណ៌ចម្បងពីរក្នុងបរិមាណស្មើគ្នានឹងមានពណ៌បន្ទាប់ឬពណ៌ទី២។

ឧទាហរណ៍៖

- លឿង + ក្រហម = ទឹកក្រូច
- លឿង + ខៀវ = បៃតង
- ខៀវ + ក្រហម = ស្វាយ

ពណ៌ទាំងអស់មានការប្រែប្រួល អាស្រ័យលើភាគរយនៃការលាយពណ៌។

ឧទាហរណ៍៖

- ក្រហម + ទឹកក្រូច = ( ខ្ចី ចាស់ )ទឹកក្រូច
- លឿង + បៃតង = ( ខ្ចី ចាស់) បៃតង
- ខៀវ + ស្វាយ = ស្វាយ (ចាស់)



### ៤.៣.៥.៣.រាង

គ្រូប្រើប្រាស់រាងដើម្បីឱ្យកុមារស្គាល់ពាក្យនិងពណ៌នាអំពីរាង (ឧទាហរណ៍៖ រាងមូល ត្រីកោណ ការេ ចតុកោណកែង ពងក្រពើ កន្លះរង្វង់) ដើម្បីជាមូលដ្ឋាននៃការគូរគំនូរ និងការអនុវត្តសកម្មភាពកសាង។



រូបភាពទី 11៖ រាង

### សម្ភារៈសម្រាប់គំនូរ

តាមរយៈកំណាត់ ឬចម្រៀកកំណាត់កុមារប្រើវត្ថុផ្សេងៗគ្នាដើម្បីបង្កើតរូបភាពតាមការស្រមើស្រមៃ និងពិពណ៌នាអំពីការងារដែលបានអនុវត្ត និងសង្កេត ដោយប្រើពាក្យដូចជា ស្អាត ភ្លឺ គ្រើម ឬរលោង។



*រូបភាពទី 12៖ សម្ភារៈសម្រាប់គំនូរ*

### ៤.៣.៦. ដំណាក់កាលនៃការអភិវឌ្ឍផ្នែកតន្ត្រី និងកាយវិការ

នៅឆ្នាំដំបូងរបស់កុមារតន្ត្រី និងកាយវិការគឺជាសកម្មភាពសង្គមយ៉ាងសំខាន់សម្រាប់ក្មេងកុមារឱ្យមានការអភិវឌ្ឍដើម្បីរៀបចំផែនការអនុវត្តសកម្មភាពតន្ត្រីនិងចលនាឱ្យសមស្របសម្រាប់កុមារ។ ដូច្នេះគ្រូត្រូវមានការយល់ដឹងអំពីការអភិវឌ្ឍផ្នែកតន្ត្រី និងរូបរាងកាយនិងយល់ដឹងពីរបៀបដែលកុមារឆ្លើយតបនឹងតន្ត្រី និងចលនា។ ផ្អែកតាមឯកសារឆ្លោះទៅរកទ្រឹស្តីនៃការណែនាំBruner,J.(1966) បានលើកឡើងនូវរបៀប ចំនួនបី ជួយដល់ការអភិវឌ្ឍការយល់ដឹងរបស់កុមារដែលមានប្រយោជន៍សម្រាប់គ្រូប្រើជាឯកសារយោង ក្នុងការស្វែងយល់ពីកុមារឱ្យកាន់តែប្រសើរ។ការអភិវឌ្ឍតន្ត្រីដែលមានទម្រង់តំណាងទាំងបីគឺ៖

- សកម្ម (ផ្អែកលើសកម្មភាព)
- រូបតំណាង (ផ្អែកលើរូបភាព)
- និមិត្តសញ្ញា (ផ្អែកលើភាសា)

ក្នុងចំណោមរបៀបទាំងបីនេះ មានវិធីចំនួនពីរដំបូង ត្រូវបានកើតឡើងញឹកញាប់បំផុតចំពោះកុមារ។

#### ដំណាក់កាលសកម្ម

ក្នុងដំណាក់កាលសកម្មចាំបាច់ត្រូវអនុវត្តសកម្មភាព**តន្ត្រីផ្សារភ្ជាប់ជាមួយនឹងសកម្មភាពរាងកាយជានិច្ច** មិនអាចកាត់ផ្តាច់ពីគ្នាបានឡើយ។

ឧទាហរណ៍៖

- កុមារអាចលោតចេញ ឬភ្ញាក់នៅពេលបានឮចង្វាក់និងសំឡេងតន្ត្រី
- កុមារដែលទើបចេះដើរតេះតះអាចធ្វើចលនាឆ្លើយតបតន្ត្រីដោយការប្រើដៃ និងជើងរបស់គេ
- កុមារមត្តេយ្យសិក្សាដែលមានការគ្រប់គ្រងកាន់តែច្រើនលើចលនារាងកាយសំឡេងចង្វាក់ និងសក្តានុពលនៃតន្ត្រី នឹងធ្វើឱ្យកុមារបង្កើននូវទំនុកចិត្តកាន់តែខ្ពស់ឡើង។

#### ដំណាក់កាលរូបតំណាង (ផ្អែកលើរូបភាព)

នៅដំណាក់កាលប្រើប្រាស់រូបតំណាង កុមារមានការស្រមើស្រមៃខ្ពស់និងចាប់ផ្តើមប្រើវត្ថុនិងរូបភាពក្នុងពេលកុមារមានការជក់ចិត្តស្តាប់តន្ត្រីកុមារស្រមើស្រមៃ តំណាងគំនិតក៏បានកើតឡើងអណ្តែតអណ្តូង ដូចជាសត្វបក្សាបក្សីកំពុងហោះហើរផ្លាស់ពីទីមួយទៅទីមួយ។ គ្រូជួយកុមារឱ្យអភិវឌ្ឍលើចលករចាប់សញ្ញា និងការហ្វឹកហាត់ច្រៀងចម្រៀងធ្វើឱ្យកុមារមានបទពិសោធន៍និងកាន់តែក្លាហានក្នុងការបង្ហាញសមត្ថភាពសម្តែង។

ចរិតលក្ខណៈខ្លះៗរបស់កុមារក្នុងដំណាក់កាលនៃការអភិវឌ្ឍតន្ត្រី និងរាងកាយមានដូចខាងក្រោម៖

| កម្រិត/ជំនាញ | ស្តាប់ | ច្រៀង | ធ្វើកាយវិការ | លេងឧបករណ៍តន្ត្រី |
|---|---|---|---|---|
| ធ្វើសកម្មភាព សកម្ម | - កំណត់អត្តសញ្ញាណដែលធ្លាប់ស្គាល់ចង្វាក់និងបទភ្លេងនៅក្នុងតន្ត្រីតាមរយៈការលេង សើចច្រៀងស្តាប់ទៅ | - រុករកសំលេងនិងសមត្ថភាពកម្លាំងរបស់វា<br>- ភាពខុសគ្នារវាង | - រុករកនិងរីករាយក្នុង ការផ្លាស់ប្តូរកាយវិកាដោយសេរីតាមប្រភេទនៃតន្ត្រី<br>- បង្ហាញការយល់ដឹងនៃការវាយកា | - រុករក និងអាចចងចាំសំលេងនៃភាពខុសគ្នារវាងឧបករណ៍តន្ត្រីមួយទៅមួយ ឬវត្ថុដែលបង្កើតតន្ត្រីពីមួយទៅមួយទៀត (គ្រួស ឈើ ដែក ឬជ័រផ្លាស្ទិក) |

| | | | | |
|---|---|---|---|---|
| | ឧបករណ៍និងការថតសំឡេង<br>- ប្រើចលនារាងកាយឧទាហរណ៍៖ដើរកំពុងរត់ការដើរក្បួនបង្ហាញពីអារម្មណ៍នៃតន្ត្រី | សំលេងច្រៀងនិងសំលេងនិយាយ<br>- ចូលចិត្តច្រៀងចង្វាក់កុមារនិងចង្វាក់ល្បែង<br>- ច្រៀងសាមញ្ញនិងចម្រៀងខ្លីៗពីការចងចាំ | ដង់ងាយៗជាមួយចង្វាក់នៃតន្ត្រី<br>- សម្តែងចេញនូវចម្រៀងសាមញ្ញៗនិងចម្រៀងរបៀបល្បែង | - រៀចបំលេងឧបករណ៍សាមញ្ញដើម្បីបង្កើតតន្ត្រី (ឈើ ត្រឡុក ដែក)<br>- បង្ហាញការយល់ដឹងនៃការវាយកាដង់ងាយៗជាមួយចង្វាក់នៃតន្ត្រីតាមរយៈការលេងឧបករណ៍<br>- បង្ហាញគំនិតឬអារម្មណ៍ដោយប្រើឧបករណ៍ឬសម្ភារៈផ្សេងទៀតដើម្បីធ្វើសំឡេង |
| រូបតំណាង (រូបភាព) | - ប្រើពាក្យសាមញ្ញរៀបរាប់ពីតន្ត្រីលឿន យឺត ខ្លាំងខ្សោយ ខ្ពស់ ទាប<br>- បង្ហាញនូតន្ត្រីដែលគេចូលចិត្ត | - ច្រៀងជាសំណៀង<br>- បង្ហាញការយល់ដឹងពីចង្វាក់និងអារម្មណ៍ពេលកំពុងច្រៀង<br>- តែងចម្រៀងសាមញ្ញក្នុងពេលលេង | - ធ្វើតាមកាយវិការសាមញ្ញនៃការរាំ<br>- ធ្វើកាយវិការជាមួយចង្វាក់តន្ត្រី<br>- ពិសោធន៍ជាមួយរាងកាយខុសគ្នាទៅនឹងចលនាដើម្បីបង្ហាញគំនិតនិអារម្មណ៍<br>- អនុវត្តជំហាននៃការរាំសាមញ្ញៗទៅនឹងផ្នែកខ្លះនៃតន្ត្រី | - មានរាងកាយល្អជាងមុនក្នុងការលេងឧបករណ៍ភ្លេង<br>- ប្រើរាងកាយគោះចង្វាក់ភ្លេងក្នុងពេលច្រៀងនិងស្រែក<br>- ស្វែងរកចង្វាក់ភ្លេងតាមឧបករណ៍ភ្លេង |

### ៤.៣.៧.ធាតុសំខាន់នៃតន្ត្រីសម្រាប់កុមារតូច

ការយល់ដឹងអំពីតន្ត្រីរបស់កុមារនឹងអភិវឌ្ឍន៍ជាមួយនឹងបទពិសោធន៍ និងការអនុវត្តធាតុផ្សំនៃតន្ត្រី។ ធាតុផ្សំសំខាន់ៗនៃតន្ត្រីដែលគ្រូគប្បីបញ្ចូលទៅក្នុងបទពិសោធន៍រៀនសូត្ររបស់កុមារមាន៖

- ចង្វាក់
- ចំណុចរណ្តំខ្ពស់ ទាបនៃតន្ត្រី
- ថាមពល ( កម្រិតនៃសូរសំឡេង)
- គុណភាពនៃសូរសំឡេង (ច្រៀងពិរោះ)
- ទំនុកបទបទពិសោធន៍តន្ត្រីនិងចលនានៅមត្តេយ្យសិក្សាភាគច្រើនទាក់ទងនឹងបួនចំណុចដំបូងគឺចង្វាក់ចង្វាក់តេមប៉ូ ចំណុចខ្ពស់ទាបនៃសំឡេង ថាមពលនៃសំឡេង។

## ចង្វាក់

ការវាយ/គោះចង្វាក់គឺជាមូលដ្ឋានគ្រឹះក្នុងការសិក្សាតន្ត្រី វាយគោះតាមលំនាំសាមញ្ញៗ គឺវាស្រដៀងគ្នានិងការដើររបស់ទ្រនិចនាឡិកាដៃឬចង្វាក់បេះដូងដែរ។ចង្វាក់នៃបទចម្រៀងឬបំណែកនៃតន្ត្រីអាចមិនទៀងទាត់និងមានសំឡេងវែង ខ្លី ឬស្ងាត់ក៏មាន។

ឧទាហរណ៍៖

| | | | | |
|---|---|---|---|---|
| | ស្អាតជានិច្ច | ស្អាតជានិច្ច | យើងកុំភ្លេច | ត្រូវសម្អាតកាយ |
| ការគោះ | X | X X | X X | X X X |
| | ស្អាតជានិច្ច | ស្អាតជានិច្ច | យើងកុំភ្លេច | ត្រូវសម្អាតកាយ |
| ចង្វាក់ | X X X | X X X | X X X | X X X X |

កុមារអាចរៀនគោះចង្វាក់ភ្លេងដោយប្រើវត្ថុសាមញ្ញ ដើម្បីបង្កើតសំឡេងនៅទីណាដែលគេនឹកឃើញចង់ សម្តែងដូចនេះគ្រូ និងអាណាព្យាបាលត្រូវសម្របសម្រួលនៅពេលដែលគេត្រូវការលេង ដើម្បីជួយ អភិវឌ្ឍន៍ ទេពកោសល្យ របស់ពួកគេឱ្យកាន់តែប្រសើរឡើង។

## ចំណុចរណ្តំនៃតន្ត្រី (ចំណុចខ្ពស់ ទាប នៃតន្ត្រី)

ចំណុចរណ្តំនៃតន្ត្រី(ចំណុចខ្ពស់ទាបនៃតន្ត្រី) សំដៅទៅលើសំឡេងខ្ពស់ និងទាបដែលបង្កើតជាចម្រៀង ផ្នែកតន្ត្រីស៊េរី រណ្តំផ្សេងៗគ្នាជាបន្តបន្ទាប់បង្កើតជាបទភ្លេង។ ពេលណារណ្តំផ្សេងគ្នាត្រូវបានផលិតក្នុងពេលតែមួយអាកមូនី(ភាពសុខដុម)ត្រូវបានបង្កើតឡើងមានវិធីផ្សេងគ្នា នៃការដាក់ឈ្មោះឬកត់សំគាល់នូវ ភាពខុសគ្នានៃសំឡេងរណ្តំគ្រូអាចប្រើវាបានសម្រាប់ណែនាំកុមារជាពិសេសនៅពេលសម្តែងលើឧបករណ៍តន្ត្រី។

ខាងក្រោមនេះជាឧទាហរណ៍:



| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ជាអក្សរ | D | E | F | G | A | B | C | D |
| | do | re | me | fa | so | la | si | do |
| ជាលេខ | | | | | | | | |

ជាសូលុយស្យុងសំឡេង

សំដៅទៅលើការបញ្ចេញសំឡេងខ្លាំង ឬខ្សោយ និងជាធម្មតាត្រូវបានផ្សារភ្ជាប់ជាមួយនឹងការគិតអារម្មណ៍និងរូបភាព។កុមាររៀនសូត្រ និងឆ្លើយតបបានត្រឹមត្រូវជាងមុននៅពេលកុមារទទួលបទពិសោធន៍ពីផ្នែកមួយនៃថាមពលតន្ត្រី ។

ជាទូទៅការអភិវឌ្ឍរបស់កុមារតូចនៅក្នុងសិល្បៈ តន្ត្រី និងកាយវិការតែងតែពឹងផ្អែកលើការអភិវឌ្ឍសមត្ថភាពរាងកាយរបស់កុមារ ដូចជាសមត្ថភាពកាន់ឧបករណ៍តន្ត្រី និងការសម្តែង។ ការយល់ដឹងនៃការអភិវឌ្ឍផ្នែកសិល្បៈ និងតន្ត្រីនេះតម្រូវឱ្យគ្រូបង្រៀនរៀបចំផែនការ និងបទពិសោធន៍រៀនសូត្រសមស្របសម្រាប់កុមារ ដើម្បីឱ្យកុមារបានរៀនសូត្រទៅតាមទេពកោសល្យពីកំណើត។

### ៤.៣.៨ ការអភិវឌ្ឍផ្នែកសង្គមអារម្មណ៍

ទម្លាប់ល្អរបស់កុមារមានការរីកចម្រើនលើការប្រាស្រ័យទាក់ទងរវាងកុមារ ឪពុកម្តាយ គ្រូបង្រៀន មនុស្សពេញវ័យនៅក្នុងសហគមន៍។គ្រូបង្រៀនដែលបានផ្តល់ភាពកក់ក្តៅតាមរយៈការលើកទឹកចិត្តឱ្យកុមារមានការវិវត្តន៍នូវ ជំនាញសង្គមនិងអារម្មណ៍នេះបានយ៉ាងល្អប្រសើរ។

មានយុទ្ធវិធីជាច្រើនដែលគ្រូត្រូវយកមកប្រើប្រាស់ក្នុងថ្នាក់រៀនផ្សេងៗគ្នា ដើម្បីលើកកម្ពស់ការអភិវឌ្ឍផ្នែកសង្គមអារម្មណ៍ និងឱ្យជួយពួកគេឱ្យរីកចម្រើនលើការសិក្សាប្រកបដោយប្រសិទ្ធភាព។

យុទ្ធវិធីទាំងនេះរួមមាន៖

- រៀបចំឥរិយាបថបែបវិជ្ជមាន
- អនុវត្តសកម្មភាពល្ខោន និងសម្តែងតួ
- រៀបចំសកម្មភាពជាទម្លាប់ និងផ្លាស់ប្តូរជាដំណាក់ៗ
- បញ្ច្រៀបសកម្មភាពសិក្សាសង្គមទៅក្នុងសកម្មភាពរៀនពេញមួយថ្ងៃ
- រៀបចំសកម្មភាពកុមារជាក្រុមតូចៗ
- ប្រើប្រាស់រឿងនិទាន ចង្វាក់ភ្លេង ចម្រៀង និងអាយ៉ង
- សហការជាមួយគ្រួសារកុមារ ។

### ៤.៣.៩.រៀបចំ ឥរិយាបថបែបវិជ្ជមាន

មធ្យោបាយជាក់ស្តែងសម្រាប់កុមាររៀនសូត្រពីគំនិតឬជំនាញដោយមើលឃើញ និងអនុវត្តជាក់ស្តែង។ គ្រូបង្រៀនធ្វើជាគំរូល្អដូចជាចេះយល់ចិត្តទទួលស្គាល់កំហុសនិងទទួលខុសត្រូវលើសកម្មភាពរបស់ពួកគេ។ គ្រូអាចលើកឡើងនូវជំនាញសង្គមឬឥរិយាបថដោយបង្ហាញឱ្យច្បាស់នូវអ្វីដែលពួកគេកំពុងធ្វើក្នុងពេលកំពុងបង្រៀន។

ឧទាហរណ៍៖ លើកឡើងពីរបៀបដែលគ្រូបង្ហាញការយល់ចិត្តឬការនិយាយនៅពេលគ្រូហុចរបស់អ្វីមួយទៅកុមារ«អ្នកគ្រូគិតថាកូនត្រូវការដុំឈើមួយទៀតតើអ្នកគ្រូអាចចែករំលែករបស់អ្នកគ្រូទៅកូនបានទេ?»។

### ៤.៣.១០.អនុវត្តសកម្មភាពល្ខោន និងសម្តែងតួ

ការសម្តែងតួបានផ្តល់នូវឱកាសសម្រាប់កុមារក្នុងការដើរតួនាទីជាក់លាក់របស់មនុស្សម្នាក់ទៀតនៅក្នុងរឿងល្ខោនដ៏ខ្លីនេះគឺបានអនុញ្ញាតកុមារស្វែងរកនូវបញ្ហាឥរិយាបថអាកប្បកិរិយានិងគុណតម្លៃនៃមនុស្សម្នាក់ដែលគេបានសម្តែងជាតួខាងលើនេះ។

តាមរយៈការសម្តែងល្ខោននិងដើរតួដែលពួកគេអាចធ្វើបានកុមារអាចរៀនសូត្រពី៖

- ប្រកាន់យកទស្សនៈរបស់អ្នកដទៃ
- ចូលរួមការសន្ទនាក្នុងន័យស្ថាបនាជាមួយអ្នកដទៃ
- បញ្ចេញអារម្មណ៍គំនិតនិងទស្សនៈរបស់ខ្លួន
- ឆ្លុះបញ្ចាំងពីទស្សនៈនិងឥរិយាបថរបស់មនុស្សដទៃទៀត

ការសម្តែងតួក៏អនុញ្ញាតឱ្យកុមារបង្ហាញការអាណិតអាសូរដល់អ្នកដទៃដែរពីព្រោះពួកគេបានព្យាយាមធ្វើជាមនុស្សម្នាក់ទៀតអស់មួយរយៈ។

ឧទាហរណ៍៖ ឱ្យកុមារអនុវត្តសកម្មភាពកុមារនៅពេលពួកគេសម្តែងជាតួអ្នកជំងឺវេជ្ជបណ្ឌិត «នៅក្នុង គ្លីនិក វេជ្ជសាស្ត្រ» ជាអតិថិជនអ្នកគ្រប់គ្រងហាងអ្នកគិតលុយ«នៅក្នុងផ្សារទំនើបមួយ»។ កុមារនឹងចាប់យក ទស្សនៈនូវតួដែលគេបានសម្តែងដូចជាវេជ្ជបណ្ឌិតគិលានុបដ្ឋាយិកា អ្នកពន្លត់អគ្គីភ័យហើយនឹកគិតរៀបចំសកម្មភាពថាតើពួកគេត្រូវសម្តែងរបៀបយ៉ាងណា នៅកន្លែងសម្តែង។

### ៤.៣.១១.រៀបចំសកម្មភាពជាទម្លាប់ និងផ្លាស់ប្តូរជាដំណាក់ៗ

ទម្លាប់និងការផ្លាស់ប្តូរផ្តល់ឱ្យគ្រូនូវឱកាសធម្មជាតិក្នុងការបណ្តុះបណ្តាលនូវជំនាញសង្គម និងសណ្តាប់ធ្នាប់របស់ខ្លួនដល់កុមារ។ ឧទាហរណ៍៖ គ្រូអាចសង្កត់ធ្ងន់ទៅលើវេន ខណៈពេលកំពុងរង់ចាំការប្រើបង្គន់ ឬពេលទទួលបានអាហារសម្រន់។ដំណើរផ្លាស់ប្តូរនឹងផ្តល់ឱកាសសម្រាប់កុមារអនុវត្តនិងអភិវឌ្ឍចំណេះដឹងនិងជំនាញ សង្គមនិងការអភិវឌ្ឍផ្នែកអារម្មណ៍ក្នុងបរិបទជាក់ស្តែង ព្រមទាំងជួយឱ្យពួកគេយល់ដឹងភាពពាក់ព័ន្ធគ្នានៃជំនាញទាំងអស់នេះ។

កុមាររៀនចេះគ្រប់គ្រងសណ្តាប់ធ្នាប់របស់ខ្លួនឯងនៅពេលពួកគេត្រូវរង់ចាំវេនទទួលអាហារសម្រន់របស់គេលើសពីនេះទៀតកុមារនឹងរីកចម្រើនក្នុងទំនុកចិត្តនៅពេលពួកគេអាចធ្វើសម្រាប់ខ្លួនគេបាន។

វិធានការអាចត្រូវបានកំណត់ដើម្បីសម្រួលដល់ការគ្រប់គ្រងថ្នាក់រៀនហើយកុមារអាចចូលរួមបាននៅក្នុងការកំណត់នៃច្បាប់ទាំងនេះបាន។ នៅក្នុងដំណើរការនៃការបង្កើតច្បាប់កុមាររៀនស្តាប់ទស្សនៈរបស់អ្នកដទៃមុនពេលធ្វើការសំរេចចិត្ត និងអភិវឌ្ឍការទទួលខុសត្រូវរួមគ្នាសម្រាប់អ្វីដែលកើតឡើងនៅក្នុងថ្នាក់។ ការមានភាពជាម្ចាស់នៃច្បាប់ទាំងនេះកុមារមានឆន្ទៈកាន់តែច្រើន និងសហការគ្នាបង្ហាញការគោរពគ្នា និងអនុវត្តសណ្តាប់ធ្នាប់ ការគ្រប់គ្រងខ្លួនឯងបានល្អ។ ច្បាប់គួរតែត្រូវបានប្រើដើម្បីជួយការពារកុមារនិងថែរក្សាសុខុមាលភាពរបស់ពួកគេ។

សំណូមពរខ្លះៗសម្រាប់ណែនាំកុមារក្នុងដំណើរការបង្កើតច្បាប់ក្នុងថ្នាក់រៀន៖

- ដឹកនាំការពិភាក្សាបង្កើតច្បាប់ជាការឆ្លើយតបទៅនឹងតម្រូវការជាក់លាក់ឬបញ្ហាដែលមាននៅក្នុងថ្នាក់រៀន។បង្ហាញស្ថានភាពដល់កុមារហើយសួរពួកគេពីអ្វីដែលអាចដោះស្រាយវាបាន
- សង្កត់ធ្ងន់លើហេតុផល នៃវិធានពន្យល់ថាគោលបំណង នៃច្បាប់គឺត្រូវបង្កើតដើម្បីឱ្យថ្នាក់រៀនជាកន្លែងដែលមានសុវត្ថិភាពនិងរីករាយសម្រាប់អ្នករាល់គ្នា។នៅពេលកុមារណែនាំច្បាប់សួរថាហេតុអ្វីបានជាយើងត្រូវការច្បាប់នោះ? ឬ "ហេតុអ្វីច្បាប់នេះល្អ?"
- កុមារអាចមានទំនោរក្នុងការគិតអំពីវិន័យជាការរឹតត្បិត និងអវិជ្ជមានដូច្នេះត្រូវដឹកនាំពួកគេគិតដោយស្ថាបនានូវអ្វីដែលពួកគេអាចធ្វើបាននិងកំណត់វិធី ឬឃ្លាជាវិជ្ជមាន ។ឧទាហរណ៍ជំនួសឱ្យ" កុំហែកក្រដាសចេញពីសៀវភៅ" ចូរនិយាយថា" កូនត្រូវសុភាពរាបសាជាមួយសៀវភៅ"។
- កត់ត្រានូវវិធាន និងការមើលឃើញតាមរបៀបសាមញ្ញហើយបង្ហាញវានៅលើគំនូសតាងជាអក្សរទុកជាការរំលឹករហូតទៅ។

### ៤.៣.១២.បញ្ជ្រាបសកម្មភាពសិក្សាសង្គមទៅក្នុងសកម្មភាពរៀនពេញមួយថ្ងៃ

ការបង្រៀនអាចកើតឡើងគ្រប់ពេលវេលាពេញមួយថ្ងៃនៅក្នុងសាលាមត្តេយ្យសិក្សា ព្រោះវាជាស្ថានភាពជាក់ស្តែងសម្រាប់កុមារ ដើម្បីអភិវឌ្ឍនិងអនុវត្តចំណេះដឹង និងជំនាញសម្រាប់ការអភិវឌ្ឍសង្គម និងអារម្មណ៍។

គ្រូបង្រៀនអាចអោយកុមារគិតពីវិធីដែលមានលក្ខណៈស្ថាបនា ដើម្បីដោះស្រាយជាមួយ និងផ្តល់យោបល់លើគំនិតរបស់ពួកគេដោយយោបល់លើកទឹកចិត្តពួកគេក្នុងការសាកល្បងជម្រើសល្អបំផុត។

ឧទាហរណ៍៖គ្រូអាចពិពណ៌នាអំពីអ្វីដែលកុមារបានធ្វើ និងប្រតិកម្មនូវអ្វីដែលពួកគេបានឃើញដោយនិយាយថា «អ្នកគ្រូបានឃើញកូននិងនារី ចង់លេងដុំឈើក្នុងពេលតែមួយហើយកូនបានស្នើឱ្យមានវេននោះជាគំនិតល្អពីព្រោះតាមវិធីនេះអ្នកទាំងពីរមានឱកាសលេងជាមួយដុំឈើដូចគ្នា» ក្នុងនាមជាកុមារដឹងខ្លួនថាពួកគេអាចប្រឈមមុខ នឹងស្ថានភាពលំបាកដោយគ្មានជំនួយផ្ទាល់ពីមនុស្សពេញវ័យពួកគេទទួលបានអារម្មណ៍ថាពួកគេជាមនុស្សពូកែម្នាក់ក្នុងសង្គម។

### ៤.៣.១៣.រៀបចំសកម្មភាពកុមារជាក្រុមតូចៗ

នៅពេលកុមារធ្វើការនិងលេងជាក្រុមឬក្រុមតូចៗពួកគេនឹងអភិវឌ្ឍជំនាញសង្គមសំខាន់ៗ ពួកគេនឹងរៀនពីរបៀបការគួរសមក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃធ្វើការដោយសហការស្តាប់ចរចាឬដោះស្រាយជម្លោះដែលទំនងជានឹងកើតឡើង។ ខ្សាច់និងការលេងទឹកគឺជាឧទាហរណ៍នៃសកម្មភាពដែលឱ្យពួកគេជំរុញកុមារស្វែងយល់ពីសម្ភារដោះស្រាយបញ្ហានិងសាកល្បងគំនិតជាមួយគ្នា។ នៅពេលកុមារចូលរួមនៅក្នុងសកម្មភាពក្រុមតូចគ្រូអាចលើកទឹកចិត្តឱ្យមានអន្តរកម្ម និងទទួលស្គាល់អាកប្បកិរិយា និងឥរិយាបថវិជ្ជមានរបស់ពួកគេ។

### ៤.៣.១៤. ប្រើប្រាស់រឿងនិទាន ចង្វាក់ភ្លេង ចម្រៀង និងអាយ៉ង

រឿងនិទានចង្វាក់ភ្លេងនិងចម្រៀងអាចត្រូវបានប្រើដើម្បីគាំទ្រដល់ការអភិវឌ្ឍសង្គម និងអារម្មណ៍របស់កុមារពួកគេអាចត្រូវបានប្រើជាវេទិកា សម្រាប់និយាយអំពីបញ្ហានៃអារម្មណ៍របស់គេដោយឆ្លើយតបទៅនឹងរឿងរ៉ាវកុមារអាចទទួលបានអារម្មណ៍ដែលអាចជាទម្រង់នៃការពិភាក្សាគំនូរការសរសេរដោយឯកឯងឬការសម្តែងជាតួ។

នៅពេលដែលកុមារចាប់ផ្តើមស្វែងយល់ពីពិភពលោករបស់ពួកគេ កុមារច្រើនតែមានអារម្មណ៍មិនច្បាស់ហើយពេលខ្លះខ្លាចស្ថានភាពថ្មីៗ ការប្រើប្រាស់អាយ៉ងជួយបង្កើតបរិយាកាសសុវត្ថិភាពសម្រាប់ពួកគេ ដើម្បីបង្ហាញ និងនិយាយអំពីអារម្មណ៍ទាំងនេះ។

គ្រូអាចរៀបចំអាយ៉ងនៅក្នុង"ជ្រុងសុវត្ថិភាព"នៅក្នុងថ្នាក់រៀន ដើម្បីលើកទឹកចិត្តឱ្យកុមារចែកចាយ និងបង្ហាញអារម្មណ៍នៅពេលពួកគេមានអារម្មណ៍ថាត្រូវការនិយាយរឿង។

អាយ៉ងអាចត្រូវបានប្រើក្នុងការពិភាក្សាទៅ៖

- ពន្យល់ពីស្ថានភាពឬបញ្ហា
- ផ្តោតទៅលើច្បាប់និងអាកប្បកិរិយាសំខាន់ៗ
- ផ្តល់ជូននូវវិធីជាក់លាក់ដើម្បីដោះស្រាយបញ្ហា
- ផ្តល់នូវជម្រើសគួរឱ្យចាប់អារម្មណ៍ដើម្បីគ្រប់គ្រងជម្លោះ
- ស្នើជាគំរូគួរឱ្យកត់សម្គាល់នៃសកម្មភាពមួយ ។

### ៤.៣.១៥. សហការជាមួយគ្រួសារកុមារ

ក្រុមគ្រួសារដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងការអភិវឌ្ឍសង្គមនិងអារម្មណ៍របស់កុមារ។ពួកគេមានឱកាសច្រើនក្នុងអន្តរកម្មប្រចាំថ្ងៃរបស់កុមារដូចជា៖

- ណែនាំកុមារក្នុងការសម្រេចចិត្តនិងដោះស្រាយបញ្ហា

- ជួយកុមារក្នុងការគ្រប់គ្រងកំហឹងរបស់ពួកគេ
- ជួយកុមារឱ្យមានមោទនភាពចំពោះវប្បធម៌របស់ពួកគេ ។

គ្រូបង្រៀនត្រូវធ្វើការជាមួយគ្រួសារដើម្បីឱ្យការរំពឹងទុករបស់កុមារមានភាពទៀងទាត់ទាំងនៅផ្ទះ និងនៅសាលាមត្តេយ្យសិក្សា។គ្រូគួរតែចែករំលែកដល់គ្រួសារនូវយុទ្ធសាស្ត្រដែលត្រូវបានប្រើនៅក្នុងសាលា ដូច្នេះ គ្រួសារអាចប្រើយុទ្ធសាស្ត្រដូចគ្នានៅផ្ទះ។ព័ត៌មានសម្រាប់គ្រួសារអាចត្រូវបានផ្សព្វផ្សាយតាមរយៈព្រឹត្តិប័ត្រព័ត៌មាន កំណត់ហេតុជួបមាតាបិតាសិក្ខាសាលាអប់រំមាតាបិតា។ ល។

សមាជិកគ្រួសារ( ឧទាហរណ៍បងប្អូនបង្កើតពូមីង។ល។) និងអ្នកជិតខាងគឺជាមនុស្សដ៏ល្អបំផុតដែល អ្នកទាំង នេះអាចត្រូវបានអញ្ជើញឱ្យចែករំលែកចំណាប់អារម្មណ៍ចំណូលចិត្តជំនាញនិងការងារជាមួយកុមារ។ ការចូលរួមបែបនេះពង្រឹងដល់ការចងក្រងឯកសារស្តីពីកិច្ចសហការរវាងសាលាមត្តេយ្យសិក្សានិងអ្នកផ្ទះដែលជួយ កុមារឱ្យមានទំនាក់ទំនងជាវិជ្ជមានជាមួយអ្នកដទៃនៅក្នុងបរិយាកាសដំបូងរបស់ពួកគេ។

កុមារនឹងរៀនទំនាក់ទំនងល្អជាមួយមនុស្សក្នុងសហគមន៍ដូចឪពុក**ម្តាយ**ដែរជាគំរូត្រូវបានអញ្ជើញឱ្យចូលរួមនៅសាលាមត្តេយ្យសិក្សាដើម្បីចែករំលែកបទពិសោធន៍ថែរក្សាកូននិងចំណាប់អារម្មណ៍របស់ពួកគេក្នុងការចិញ្ចឹមកូន។

សរុបរួមការអភិវឌ្ឍសង្គមអារម្មណ៍ និងទម្លាប់ល្អរបស់កុមារកំពុងត្រូវបានអភិវឌ្ឍនៅពេលដែលពួកគេមានឱកាសធ្វើអន្តរកម្មជាវិជ្ជមានជាមួយអ្នកដទៃ។ គ្រូបង្រៀនដើរតួយ៉ាងសំខាន់ ក្នុងតួនាទីជាអ្នកធានាឱកាសទាំងនេះកើតឡើងនៅក្នុងថ្នាក់រៀន។ ក្រៅពីនេះគ្រូគួរតែផ្តល់សម្ភារៈសមស្រប ដែលជាយុទ្ធសាស្ត្រដើម្បីលើកកម្ពស់ការអភិវឌ្ឍសង្គមនិងអារម្មណ៍នេះដែរ។ ការអនុវត្តយុទ្ធសាស្ត្រទាំងនេះធានាថាជួយកុមារនូវ ឱកាសឱ្យក្លាយជាអ្នករៀនសូត្រអនុវត្ត និងអភិវឌ្ឍជំនាញដែលមានទំនុកចិត្តនិងបុគ្គលដែលទទួលខុសត្រូវក្នុង សង្គម។

## ៤.៤. ផ្នែកសោភ័ណភាពនិងការបង្កើតថ្មី

សិល្បៈនិងតន្ត្រី និងចលនាគួរតែត្រូវបានបង្រៀនតាមរបៀបដែលធ្វើឱ្យវារីករាយសម្រាប់កុមារនិងជួយពួកគេទទួលបានចំណេះដឹង និងជំនាញក្នុងវិធីជំរុញ។យុទ្ធសាស្ត្រដែលបានជ្រើសរើសនេះគួរតែអនុញ្ញាតឱ្យកុមារមាន ឯករាជ្យភាពខ្លះៗក្នុងការសម្រេចចិត្ត។

គ្រូអាចប្រើស្បែក( សត្វ )រំញោចស្នាដៃសិល្បៈនិងសម្ភារៈសិល្បៈដើម្បីផ្តល់ដល់កុមារការផ្តោតអារម្មណ៍និងលើកទឹកចិត្តការច្នៃប្រឌិតរបស់ពួកគេនៅក្នុងសិល្បៈ។សម្រាប់តន្ត្រីគ្រូអាចប្រើភាពខុសគ្នានៃតន្ត្រីរបាំប្រភពសំឡេងចង្វាក់ច្រៀងនិងចម្រៀងសម្រាប់កុមារស្តាប់និងអនុវត្តគ្រូក៏អាចលេងល្បែងនិងលេងភ្លេងជាមួយក្មេងៗផងដែរ។

អនុញ្ញាតឱ្យពួកគេត្រូវបានចូលរួមនៅក្នុងការធ្វើឱ្យតន្ត្រីតាមរូបរាងកាយនិងតន្ត្រីឧបករណ៍និងបង្កើតតន្ត្រីជាផ្នែកមួយនៃទម្លាប់ប្រចាំថ្ងៃរបស់កុមារ។

### ៤.៤.១ យុទ្ធវិធីសម្រាប់សិល្បៈ

មានយុទ្ធវិធីជាច្រើនសម្រាប់បង្រៀនសិល្បៈដល់កុមារ យុទ្ធវិធីសំខាន់ៗដើម្បីអភិវឌ្ឍន៍ជំនាញក្នុងការអនុវត្តសកម្មភាពសិល្បៈរបស់កុមាររួមមាន៖

- ការប្រើគម្រោងសិក្សា

- ការប្រើរំញោច
- ការប្រើស្នាដៃសិល្បៈ
- ការផ្តល់សម្ភារៈសិល្បៈជាច្រើនប្រភេទ។

### ៤.៤.២ ការអនុវត្តគម្រោងសិក្សា

មានប្រយោជន៍ក្នុងការណែនាំ និងការបញ្ចេញគំនិតច្នៃប្រឌិតរបស់កុមារ ជាពិសេសនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ ដើម្បីផ្តល់ការផ្តោតអារម្មណ៍សម្រាប់ការគិត និងការស្រមើស្រមៃរបស់កុមារ។ នៅដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍ ប្រធានបទត្រូវបានប្រើដើម្បីពង្រឹងជំនាញសិល្បៈ និងបច្ចេកទេសដែលកុមារបានស្វែង យល់នៅក្នុងបទពិសោធន៍នៃការរៀនសូត្រ ។

ឧទាហរណ៍៖គម្រោងសិក្សា សត្វ សមុទ្រ រុក្ខជាតិ បន្លែ ផ្លែឈើ មុខរបរ ឬរឿងរ៉ាវផ្សេងៗ...។

### ៤.៤.៣.ការប្រើរំញោច

ជាសកម្មភាពមានច្រើនទម្រង់វត្ថុរូបភាព និងរូបថតដែលមានពណ៌ទាក់ទាញយ៉ាងខ្លាំងចំពោះកុមារនិង ត្រូវបានប្រើ ដើម្បីលើកទឹកចិត្តដល់ការសង្កេតមើលព័ត៌មានលម្អិតតន្ត្រីនិងរឿងរ៉ាវក៏អាចត្រូវបានប្រើដើម្បីបង្កឱ្យមានការស្រមើលស្រមៃនិងគំនិតថ្មីៗ។ ការរំញោចទាំងនេះអាចជំរុញកុមារឱ្យគិតហួសពីមជ្ឈដ្ឋានជុំវិញខ្លួននៅពេលដែលគេបង្កើតស្នាដៃសិល្បៈរបស់កុមារ។

ឧទាហរណ៍៖ សម្ភារៈសម្រាប់កុមារលេងត្រូវមាន សំឡេង រូបរាង ក្លិន ពណ៌ច្បាស់ជិតហើយចម្រុះ។

### ៤.៤.៤.ការប្រើស្នាដៃសិល្បៈ

ផ្ទាំងគំនូររបស់វិចិត្រករល្បីឈ្មោះអាចពង្រីកទស្សនៈរបស់កុមារមើលទៅលើវិស័យសិល្បៈ និងពិភពលោក។ វាជួយឱ្យកុមារដឹងអំពីសោភ័ណភាពនៃសិល្បៈហើយនឹងជម្រុញពួកគេធ្វើពិសោធន៍ជាមួយប្រព័ន្ធផ្សព្វផ្សាយផ្សេងៗគ្នា ដើម្បីសាកល្បង និងធ្វើត្រាប់តាមដែលបង្កើតជាស្នាដៃរបស់គេដោយផ្អែកលើស្នាដៃសិល្បករល្បីទាំងនេះ។

### ៤.៤.៥.ការផ្តល់សម្ភារៈសិល្បៈសំបូរបែប

ការបង្កើតថ្មីរបស់កុមារជារឿយៗត្រូវបានដឹកនាំដោយសម្ភារៈ ដែលមានសម្រាប់ពួកគេប្រើប្រាស់ក្នុងការអនុវត្តសម្ភារៈសិល្បៈ អាចបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ការបង្កើតស្នាដៃសិល្បៈណាមួយរបស់កុមារ។ ផ្តល់ឱ្យកុមារជាមួយសម្ភារៈជាច្រើនអាចអោយកុមារធ្វើការពិសោធ និងស្គាល់ការប្រើប្រាស់តាមប្រភេទផ្សេងគ្នានៃសម្ភារៈដើម្បីបង្កើតសិល្បៈ។ កុមារគួរមានភាពងាយស្រួលក្នុងការរកសម្ភារៈ និងត្រូវបានទទួលនូវភាពបត់បែនក្នុងការជ្រើសរើសអ្វីដែលពួកគេចង់បង្កើតថ្មី របៀបពួកគេចង់បង្កើតហើយគិតបានទុកជាមុនថាអ្វីដែលនឹងបង្កើតវានឹងមានរូបរាងយ៉ាងណា។

ភាពងាយស្រួលក្នុងការរកមើលសម្ភារៈសិល្បៈ បានច្រើនប្រភេទអនុញ្ញាតឱ្យកុមារមានភាពបត់បែនជ្រើសរើសនិងសម្រេចចិត្តថាតើពួកគេចង់បង្កើតស្នាដៃសិល្បៈរបស់ពួកគេយ៉ាងដូចម្តេច។

## ៤.៥ យុទ្ធវិធីបង្រៀនតន្ត្រីនិងចលនា

មានយុទ្ធសាស្ត្រជាច្រើនសម្រាប់បង្រៀនតន្ត្រី និងចលនាសម្រាប់កុមារចំណុចគន្លឹះមួយចំនួនដែលជាយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍជំនាញក្នុងការស្តាប់ការសម្តែងនិងការបង្កើតថ្មីរួមមាន៖

- ការប្រើតន្ត្រីរបាំនិងប្រភពសំឡេងផ្សេងៗគ្នា
- ការប្រើចង្វាក់ស្រែកនិងចម្រៀង

- ការប្រើប្រាស់ចលនានិងល្បែងតន្ត្រី
- ការប្រើប្រាស់អវយវៈលើដងខ្លួននិងឧបករណ៍តន្ត្រី
- ការប្រើល្ពោននិយាយ
- ធ្វើឱ្យតន្ត្រីក្លាយជាផ្នែកសំខាន់មួយនៃទម្លាប់និងដំណើរផ្លាស់ប្តូរ ។

### ៤.៥.១ ការប្រើតន្ត្រីរបាំនិងប្រភពសំឡេងផ្សេងៗគ្នា

កុមារភាគច្រើនអាចបង្កើតឬធ្វើត្រាប់តាមសំឡេងដែលពួកគេបានស្តាប់ឬបានឮពួកគេត្រូវការស្តាប់សំឡេង និងតន្ត្រីមុនពេលបង្កើតសំឡេងផ្ទាល់របស់ពួកគេឬឆ្លើយតបតន្ត្រីដែលពួកគេកំពុងស្តាប់។ សារៈសំខាន់ នៃការស្តាប់ត្រូវបានគូសបញ្ជាក់ដោយ លោក ZoltánKodály ដែលជឿជាក់ថាកុមារគួរតែអាចសម្តែងតន្ត្រីបានយ៉ាងល្អដូចជា តន្ត្រីប្រជាប្រិយ ដែលរៀបចំដោយអ្នកនិពន្ធល្បីៗ។ ជំហានដំបូងដើម្បីជួយកុមារពង្រីកចំណេះដឹង និងការយល់ដឹងអំពីការបញ្ចូលសំឡេងឡើងវិញគឺ ដើម្បីធ្វើឱ្យជំនាញស្តាប់របស់ពួកគេកាន់តែច្បាស់។ ធ្វើដូចនេះគ្រូគួរតែណែនាំពីភាពខុសគ្នានៃរចនាបថប្រភេទនៃតន្ត្រីនិងបទចម្រៀង (ដូចជាឧបករណ៍តន្ត្រីគោរពភ្លេងជាតិ រាំវង់ រាំក្បាច់ សារ៉ាវ៉ាន់ ឡាំឡាវ តន្ត្រី និងរបាំជនជាតិដល់កុមារ)។ ពេលកុមារស្តាប់ ហើយប្រមូលផ្តុំតាមរបៀបដែលមានលក្ខណៈសោភ័ណភាពសំឡេងតន្ត្រីនៅក្នុងបរិយាកាសពួកគេចាប់ផ្តើមរៀនត្រាប់តាមសំនៀង និងលំនាំចង្វាក់ជាមួយនឹងភាពជាក់លាក់បានកាន់តែល្អប្រសើរ។

### ៤.៥.២.ការប្រើចង្វាក់ស្រែកនិងចម្រៀង

យោងទៅតាមលោក ZoltánKodály បទពិសោធន៍នៃការច្រៀងអាចបង្កើតបានជាមូលដ្ឋានគ្រឹះតន្ត្រីករ។ ការច្រៀងគឺជាមធ្យោបាយធម្មជាតិ នៃការបញ្ចេញមតិរបស់កុមារតាមសំឡេងឧបករណ៍ភ្លេងដែលពួកគេអាចចូលបានយ៉ាងងាយស្រួល។ ចាប់ពីដំបូងដែលកុមារឆ្លើយតបយ៉ាងឆាប់រហ័សចំពោះចង្វាក់ស្រែកច្រៀងបទចំរៀងគ្រូអាចប្រើវាសម្រាប់បង្រៀន និងពង្រឹងគំនិតបែបតន្ត្រីបាន។ អាចផ្តល់ឱកាសសម្រាប់កុមារដើម្បីដកស្រង់បទចំរៀងនិងច្រៀង។

ចំរៀងដោយមានអារម្មណ៍ខុសគ្នានូវបរិបទវប្បធម៌និងភាសាគ្រូច្រៀងរួមជាមួយកុមារនឹងជួយពួកគេឱ្យចូលចិត្តច្រៀង ឬប្រើសំឡេងរបស់ពួកគេតាមរបៀបសំដែងកាន់តែច្រើន។

គ្រូបង្រៀនអាចពិចារណាលើការរីកចម្រើន ដូចខាងក្រោមនៅពេលជួយកុមារឱ្យរៀនចម្រៀងថ្មី ៖

- ជ្រើសរើសបទចំរៀង/ចង្វាក់សាមញ្ញៗ ដែលកុមារអាចច្រៀងបានយ៉ាងងាយស្រួលមុនពេល រីកចម្រើនដើម្បីច្រៀងបានវែងជាងជាមួយបទភ្លេងស្មុគស្មាញជាងនេះ
- ចាក់សំឡេងបទចំរៀងថ្មី/ចង្វាក់ភ្លេងក្នុងកំឡុងពេលអាហារសម្រន់ ឬក្នុងពេលការផ្លាស់ប្តូរសកម្មភាពបង្រៀនពីមួយទៅមួយ
- ឱ្យកុមារស្តាប់បទចម្រៀង(ដោយគ្មានអ្នកច្រៀងអប) ដើម្បីស្តាប់ចង្វាក់ភ្លេង និងបទភ្លេងបានច្បាស់
- ធ្វើជាគំរូល្អក្នុងការច្រៀង តាមសំនៀងនិងរក្សាចង្វាក់ភ្លេងពេញមួយបទចម្រៀង
- ច្រៀងចម្រៀងទាំងមូលពីរបីដង
- ឱ្យកុមារច្រៀងដោយការបន្លឺសម្លេងនិងច្រៀងតាមសំឡេង ឱ្យនិយាយឃ្លាដែលបានស្តាប់ឡើងវិញម្តងទៀត ឬចូលរួមនិយាយឃ្លាឡើងវិញទាំងអស់គ្នា

- ឱ្យកុមារច្រៀងចម្រៀងទាំងមូលដោយខ្លួនឯងបន្ទាប់ពីពួកគេបានចូលរួមនៅក្នុងបទពិសោធន៍ជាច្រើនដងទាក់ទងនឹងបទចម្រៀង (ឧទាហរណ៍ការស្ដាប់នឹងផ្លាស់ប្ដូរទៅបទចម្រៀងដោយប្រើឧបករណ៍ភ្លេងអមជាមួយបទចម្រៀង)។ ចម្រៀងនិងចង្វាក់ភ្លេងក៏ជាវិធីធ្វើឱ្យសប្បាយរីករាយក្នុងការរៀនវាក្យសព្ទនិងការប្រើប្រាស់ភាសាថ្មីផងដែរ។
- ឧទាហរណ៍៖
- នៅពេលច្រៀងជាមួយកុមារសូមណែនាំពួកគេឱ្យលើកនិងបន្ទាបដៃទៅតាមចង្វាក់ភ្លេងនិងប្រើពាក្យ ដើម្បីពិពណ៌នាទិសដៅនៃសំឡេង (ឧទាហរណ៍៖ឡើងលើ ចុះក្រោម)
- ឱ្យកុមារជំនួសពាក្យនៅក្នុងបទចំរៀងចង្វាក់និងការស្រែក
- ដឹកនាំកុមារឱ្យចេះយោលយោគ តាមចង្វាក់ភ្លេងដូចពួកគេកំពុងច្រៀង កុមាររៀនអំពីផ្នែកផ្សេងៗនៃខ្លួន និងចលនា ដែលជាប់ទាក់ទងជាមួយពួកគេ។

### ៤.៥.៣. ការប្រើប្រាស់ចលនា និងលេងល្បែងជាមួយតន្ត្រី

ក្មេងៗចូលចិត្តផ្លាស់ទីរាំស្វែងយល់ និងច្នៃប្រឌិតជាមួយរាងកាយរបស់ពួកគេ។ លេងល្បែងជាមួយតន្ត្រី និងចម្រៀងសកម្មភាពផ្ដល់នូវឱកាសសម្រាប់កុមាររៀនគិតតាមរយៈតន្ត្រី និងចលនា។ ក្រៅពីការផ្លាស់ទី ល្បែងនិងចម្រៀងជាទូទៅមានសកម្មភាពចលនាពីរប្រភេទផ្សេងទៀតគឺ៖ ចលនាសេរីនិងចលនាមានរចនាសម្ព័ន្ធ។

ឧទាហរណ៍៖ ចលនាសេរី

- ការផ្លាស់ប្ដូរដោយសេរី ឬស្រមើស្រមៃទៅនឹងការដាស់តឿន អណ្ដែតដូចរោមសត្វ ដើរដូចទាហាន
- ការផ្លាស់ប្ដូរសេរីឆ្លើយតបទៅនឹងសក្ដានុពល និងចង្វាក់ភ្លេង
- ចលនា/សកម្មភាពធ្វើឡើង ដើម្បីអមដំណើរបទចម្រៀងចង្វាក់ភ្លេង ឬតាមឧបករណ៍ភ្លេងមួយចំនួន

ឧទាហរណ៍៖ ចលនាដែលមានរចនាសម្ព័ន្ធ

- ការផ្លាស់ប្ដូរទៅតាមបទចម្រៀងជាមួយនឹងទំនុកច្រៀងដែលកំណត់សកម្មភាពជាក់លាក់និងចលនា រាងកាយដូចជា"ក្បាល ស្មា ជង្គង់ ជើង"និង"រំលែងទៅមីល"
- រាំតាមលំដាប់លំដោយនៃជំហានដែលបានកំណត់ទុកជាមុនដូចជានៅក្នុងរបាំប្រជាប្រិយ

### ៤.៥.៤.ការប្រើប្រាស់រាងកាយនិងឧបករណ៍តន្ត្រី

ជាទូទៅកុមារត្រូវបានទាក់ទាញដោយសំឡេងឧបករណ៍ភ្លេងនិងចូលចិត្តលេងឧបករណ៍ភ្លេង ដូចជាស្គរកណ្ដឹងប្រដាប់គោះចង្វាក់។ នៅពេលប្រើតាមវិធីសមស្របឧបករណ៍តន្ត្រីអាចពង្រឹងគំនិតនិងជំនាញតន្ត្រីដល់ពួកគេបាន។

គ្រូបង្រៀនត្រូវការផ្ដល់ឱកាសដល់កុមារឱ្យចូលរួមក្នុងការបង្កើតតន្ត្រីយ៉ាងសកម្ម ដែលកុមារអាចស្វែងយល់ និងលេងឧបករណ៍នៅក្នុងបរិស្ថានសិស្សមជ្ឈមណ្ឌល ដើម្បីទទួលបានចំណេះដឹងនិងជំនាញតន្ត្រី។ ការទិញនិងផលិតឧបករណ៍តន្ត្រីនៅផ្ទះដើម្បីផ្ដល់ជូនកុមារសម្រាប់លេងនិងស្វែងរកបទពិសោធន៍លើការរុករកសម្លេងនិងការបង្កើតតន្ត្រីនៅបឋមវ័យ។

ការប្រើប្រាស់អវយវៈលើរាងកាយគឺជា ឧបករណ៍ភ្លេងដែលអាចផ្លាស់ប្តូរបានច្រើនបំផុតដោយសារតែមានភាពច្នៃប្រឌិតជាច្រើន នៃសំឡេងដែលអាចត្រូវបានបង្កើតឡើងជាមួយផ្នែកផ្សេងៗ នៃរាងកាយ។ នៅក្នុងវប្បធម៌ខ្លះវាអាចជាប្រភពចម្បង នៃសំឡេងតន្ត្រី។ គ្រូអាចផ្តល់ឱកាសដល់កុមារ ដើម្បីរកឱ្យឃើញវិធីផ្សេងគ្នានៃការបង្កើតសំឡេងនិងចង្វាក់ដោយដៃ បាតដៃម្រាមដៃកែងដៃជើងបបូរមាត់អណ្តាតជង្គង់និងភ្លៅរបស់ពួកគេ។

ការប្រើឧបករណ៍ភ្លេងលេង និងគោះប្រភេទផ្សេងៗគ្នាសម្រាប់ការបង្កើតតន្ត្រី នៅថ្នាក់រៀនអនុញ្ញាតឱ្យកុមារចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពតន្ត្រី និងចលនា។ នេះក៏ជួយសម្រួលការច្នៃប្រឌិតនិងការលូតលាស់ផ្នែកតន្ត្រីផ្ទាល់ខ្លួនរបស់កុមារផងដែរ។ គ្រូគួរតែផ្តល់ឧបករណ៍ភ្លេងដែលមិនគួរឱ្យចាប់អារម្មណ៍និងវត្ថុអាចវាយប៉ះអង្រួនដើម្បីផលិតសម្លេងផ្សេងៗគ្នា។ កុមារគួរតែត្រូវបានផ្តល់ឱកាសនិងពេលវេលាគ្រប់គ្រាន់ ដើម្បីស្វែងយល់ពីភាពខុសគ្នាគុណភាពសំឡេងដែលអាចត្រូវបានផលិតដោយឧបករណ៍តាមប្រភេទនីមួយៗមុនពេលណែនាំរបស់ថ្មី។

គ្រូអាចណែនាំឧបករណ៍ភ្លេងតាមរបៀបដូចខាងក្រោម៖

- ស្តាប់ប្រៀបធៀបនិងនិយាយអំពីគុណភាពសំឡេងរបស់ឧបករណ៍ពីរឬច្រើនកុមារអាចតំណាងឱ្យភាពខុសគ្នានៃគុណភាពសំឡេងតាមរយៈការធ្វើចលនាដោយសេរី
- ប្រើឧបករណ៍គោះដើម្បីភ្ជាប់រឿងឬចង្វាក់ភ្លេង កុមារអាចធ្វើបានជ្រើសរើសចង្វាក់ជាក់លាក់មួយ ដើម្បីតំណាងឱ្យតួអក្សរឬចលនានៅក្នុងរឿង/ចង្វាក់ភ្លេង និងលេងជាចង្វាក់ដូចដែលរឿងកំពុងត្រូវបានគេនិយាយឬដូចជាចង្វាក់ភ្លេងកំពុងត្រូវបានគេស្រែកឡើង។

### ៤.៥.៥. ការប្រើល្ពោនអាយ៉ង

គ្រូអាចធ្វើឱ្យបទពិសោធន៍តន្ត្រីមានភាពមើលឃើញសម្រាប់កុមារដោយប្រើអក្សរ ឬភាពខុសគ្នានៃល្ខោន។

ឧទាហរណ៍៖ តុក្កតាអាចត្រូវបានប្រើដើម្បីសម្តែងចង្វាក់ភ្លេងនិងចម្រៀងដូចដែលពួកគេត្រូវបានស្រែកនិងសម្តែង។

### ៤.៥.៦. ធ្វើឱ្យតន្ត្រីក្លាយជាផ្នែកសំខាន់មួយនៃទម្លាប់និងដំណើរផ្លាស់ប្តូរ

គ្រូគួរតែបង្កើតតន្ត្រីជាផ្នែកសំខាន់មួយ នៃការរៀនសូត្ររបស់កុមារលើសពីនេះទៅទៀតតន្ត្រីនិងសកម្មភាពចលនាដែលបានគ្រោងទុក ដោយច្រៀងជាមួយកុមារនៅពេលឆ្លងកាត់ពីបន្ទប់មួយទៅបន្ទប់មួយឬពីសកម្មភាពមួយទៅបន្ទប់មួយទៀត។ឧទាហរណ៍ខ្លះរួមមាន៖

- ច្រៀងចម្រៀងស្វាគមន៍
- ច្រៀងឬលេងភ្លេងដែលធ្លាប់ស្គាល់រាល់ពេល ដែលអ្នកចង់បញ្ចប់សកម្មភាពណាមួយបង្កើត "ចម្រៀងដើរ" សម្រាប់កុមារច្រៀងនៅពេលពួកគេផ្លាស់ពីបន្ទប់មួយទៅបន្ទប់មួយផ្សេងទៀត
- ច្រៀងចម្រៀងដើម្បីប្រមូលកុមារ សម្រាប់រឿងនិទាន ឬសម្រាប់ពេលធ្វើការងារក្រុម
- ច្រៀងចម្រៀង១បទ មុនពេលចេញទៅផ្ទះ

### ៤.៥.៧ យុទ្ធសាស្ត្រផ្សេងទៀតសម្រាប់សោភ័ណភាពនិងការបញ្ចេញមតិច្នៃប្រឌិត

គ្រូជ្រើសរើសសកម្មភាពឆ្លើយតបតាមតំបន់ដូចខាងក្រោម៖

- តំបន់ខ្លង់រាប ភ្នំ( សម្ភារៈតាមមូលដ្ឋាន សម្គាល់អត្តសញ្ញាណ )

- តំបន់មាត់សមុទ្រ (សំបក សំណាក គ្រឿងសមុទ្រ...)
- តំបន់ទំនាបកណ្តាល (ឬស្សី ស្រូវ ចំបើង សំណាកសត្វ ខ្ចៅ ខ្យង លៀស គ្រំ...)ការប្រើប្រាស់

ឧបករណ៍៖ ភ្លេងខ្មែរបុរាណ (ស្គរ ខ្លុយ ប៉ី រនាដ ទ្រ ឈើង...) និងឧបករណ៍ភ្លេងរបស់ជនជាតិដើមភាគតិច......។

សកម្មភាពផ្សាភ្ជាប់ជាមួយសហគមន៍ (រកអ្នកដែលមានបទពិសោធន៍លេងភ្លេងក្នុងសហគមន៍មកបង្ហាញ) រកឧទាហរណ៍តាមខ្លឹមសារនីមួយៗ(យកឬស្សីជាខ្លុយ រនាដ...) យកចំបើងមកធ្វើមនុស្សចំបើង ស្លឹកឈើរៀបចំជារូបផ្សេងៗ

**សង្ខេប**

តាមរយៈការបង្កើតបរិយាកាសរៀនសូត្រប្រកបដោយភាពទាក់ទាញ និងចក្ខុវិស័យគ្រូអាចជួយសម្រួលដល់អន្តរកម្មដែលមានគុណភាពក្នុងសិល្បៈតន្ត្រី និងចលនាសកម្មភាព។ គ្រូគួរតែបានរៀបចំនិងបង្ហាញឱ្យបានត្រឹមត្រូវនូវធនធានសិល្បៈ និងតន្ត្រី ព្រមទាំងលើកទឹកចិត្តឱ្យកុមារស្វែងយល់ពិសោធន៍និងច្នៃប្រឌិត និងរៀនសូត្របង្កើតនូវអ្វីដែរ។

# ជំពូក ៥

# ការពិនិត្យតាមដាន និងវាយតម្លៃ

# ជំពូក៥ ការពិនិត្យតាមដាន និងវាយតម្លៃ

## ៥.១- ចំពោះគ្រូ

ការវាយតម្លៃមានសារៈសំខាន់៖

១. ដើម្បីវាស់ស្ទង់សមត្ថភាពកុមារ

២. ជួយឱ្យគ្រូតាមដាននូវការយល់ដឹងកុមារលើបញ្ញត្តិ និងខ្លឹមសារមេរៀន

៣. ដើម្បីគ្រូតពិនិត្យតាមដានលទ្ធផល វាយតម្លៃការសិក្សាកុមារ និងការបង្រៀនរបស់គ្រូ

៤. រកឱ្យឃើញរាល់ចំណុចខ្វះខាតរបស់កុមារ រួចធ្វើផែនការដើម្បីជួយដល់ពួកគេឱ្យទាន់ពេលវេលា។

*ប្រភេទនៃការវាយតម្លៃសំខាន់ៗ*

*វិធីវាយតម្លៃមានពីរប្រភេទ៖*

### ៥.១.១. វាយតម្លៃក្នុងដំណើរការសិក្សា

ការវាយតម្លៃក្នុងដំណើរការសិក្សាមានគោលបំណង៖

- ពង្រឹងការសិក្សារបស់កុមារ

*ក.ផលសម្រេច*

- គ្រូតពិនិត្យការរបស់កុមារ
- កុមារទទួលមតិត្រឡប់បែបណាពីគ្រូ
- សម្របការបង្រៀនទៅតាមតម្រូវការរបស់កុមារ
- ការសិក្សារបស់កុមារកាន់ប្រសើរឡើង

*ខ .វិធីធ្វើ*

- ក្នុងពេលបង្រៀន និងរៀន
- ម្តងបន្តិចក្នុងម៉ោងសិក្សា
- ជាដំណើរដែលកើតឡើងបន្តរហូត។

### ៥.១.២. វាយតម្លៃសរុប

ការវាយតម្លៃសរុបមានគោលបំណង៖

- វាយតម្លៃភាពជោគជ័យរបស់កុមារ

*ក.ផលសម្រេច*

- គ្រូបានវាយតម្លៃការរបស់កុមារ
- កុមារម្នាក់ៗដឹងពីកម្រិតនៃលទ្ធផលរបស់ខ្លួន។

*ខ.វិធីធ្វើ*

- ក្រោយរៀនចប់
- ក្រោយពេលចប់រៀនឬជំពូកមួយ
- ជាលទ្ធផលសម្រេចចុងក្រោយ

*លក្ខណៈខុសគ្នានៃការវាយតម្លៃសំខាន់ៗ*

| ការវាយតម្លៃក្នុងដំណើរការបង្រៀន | វាយតម្លៃសរុប |
|---|---|
| **សង្ខេប** | **សង្ខេប** |
| ✓ មិនផ្លូវការ | ✓ ផ្លូវការ |
| ✓ កើតឡើងជាបន្តបន្ទាប់រហូត (អំឡុងពេលសិក្សា) | ✓ម្តងម្កាល (មានពេលវេលាជាក់លាក់) |
| ✓ ផ្តល់មតិត្រឡប់ដើម្បីពង្រឹងដល់ការសិក្សា | ✓ ផ្តល់មតិត្រឡប់ដើម្បីវាយតម្លៃការសិក្សា |
| ✓ វាយតម្លៃសម្រាប់ការសិក្សា | ✓ វាយតម្លៃពីការសិក្សា |
| ✓ នាំផ្លូវសម្រាប់ការបង្រៀន និងការធ្វើកិច្ចតែងការ | ✓ អាចប្រើជាការវាយតម្លៃដើម្បីរកចំណុចខ្វះខាត |
| ✓ មានផលវិជ្ជមានខ្ពស់ដល់ការសិក្សា | ✓ មានផលវិជ្ជមានតិចតួចដល់ការសិក្សា |

**រូបភាពនៃការវាយតម្លៃមាន៖**

- សំណួរផ្ទាល់មាត់
- សំណួរសេសេរ
- អនុវត្តដោយផ្ទាល់
- កិច្ចការក្រុម ឬដៃគូរ
- ល្បែងសិក្សា
- កិច្ចការផ្ទះ
- តេស្ត

ឧទាហរណ៍៖

គឺជាការវាយតម្លៃក្នុងដំណើរការបង្រៀន និងការវាយតម្លៃចប់១ម៉ោងសិក្សាដើម្បីធ្វើការឆ្លុះបញ្ចាំងប្រសិទ្ធភាពនៃការបង្រៀនរបស់គ្រូ និងជួយកុមាររៀនយឺតបានទាន់ពេលវេលា។

- **សកម្មភាពប្រចាំថ្ងៃ៖** នៅក្នុងសកម្មភាពនេះ គ្រូត្រូវសង្កេត តាមដាន សម្របសម្រួល កែលម្អ និងមានកំណត់ត្រានូវលក្ខណៈពិសេសរបស់កុមារ ដែលពុំសូវនិយាយស្តី មិនចូលរួមក្នុងការប្រើតារាងសកម្មភាពប្រចាំថ្ងៃ ដើម្បីចាត់វិធានការជួយកុមារទាំងនោះឱ្យបានទាន់ពេលវេលា។
- **ល្បែង៖** វាយតម្លៃតាមរយៈនៃការលេងពេលកំពុងលេង (ពិនិត្យលើទឹកមុខសកម្មភាពលេង) និងក្រោយពេលលេង
- **ចម្រៀង៖** ពិនិត្យសកម្មភាពកំពុងច្រៀងក្រោយពេលច្រៀងឡើងវិញល្បែងចម្រៀងបណ្តាក់ សលាកបត្រចម្រៀងតន្ត្រី (គោរពតាមការណែនាំលេងលក្ខខណ្ឌល្បែង) ឆ្លុះបញ្ចាំងនិងវាយតម្លៃសមត្ថភាពគ្រូលើការដឹកនាំកុមារលេង។

- **គំនូរនិងសកម្មភាពកសាង៖** ក្នុងពេលកំពុងអនុវត្តសកម្មភាពគ្រូត្រូវតាមដាន សម្រសម្រួលតាមជួយជំរុញលើកទឹកចិត្ត និងវាយតម្លៃនៅចុងម៉ោងសិក្សាអាចជាបុគ្គល និងជារួមចំពោះកិច្ចការតាមបែប សហការ៖
  - នាំកុមារផ្ទៀងផ្ទាត់លទ្ធផលស្នាដៃដែលលេចធ្លោ ទៅនឹងស្នាដៃដែលមានកម្រិតប្រហាក់ប្រហែលគ្នា
  - លើកសរសើរចំណុចលេចធ្លោ និងជំរុញលើកទឹកចិត្តកុមារឱ្យកែលម្អ ឬត្រូវបន្ថែមទៅលើស្នាដៃទាំង ២ប្រភេទនេះ
  - នាំកុមារដទៃទៀត បិទស្នាដៃតាមលំដាប់បន្តបន្ទាប់ពីស្នាដៃលេចធ្លោ លើតារាងស្នាដៃកុមារដោយនិយាយជាលក្ខណៈទូទៅថាស្នាដៃខ្វះខាតបន្តិចបន្តួចដូចគ្នា ថ្ងៃក្រោយ យើងនឹងខំគូរ ផាត់ ហែក... ឱ្យបានកាន់តែស្អាតជាងនេះ។
  - គ្រូមិនត្រូវប្រកាសឈ្មោះកុមារដែលអនុវត្តមិនល្អឬស្តីបន្ទោសឬបន្តុះបង្អាប់កុមារទាំងនោះឡើយ។ គ្រូសន្សំស្នាដៃកុមារចាប់ពីដើមឆ្នាំចងក្រងកិបជាសៀវភៅស្នាដៃកុមារឬបិទស្នាដៃទៅក្នុងសៀវភៅកិច្ចការកុមារទុកផ្ញើជូនទៅមាតាបិតានៅដំណាច់ឆមាស ឬដំណាច់ឆ្នាំសិក្សា។

## ៥.២- ចំពោះកុមារ

### ក. ការសង្កេត

ការសង្កេតពីសកម្មភាពទឹកមុខកាយវិការអារម្មណ៍ការយកចិត្តទុកដាក់ គឺការកត់ត្រានូវអ្វីដែលកុមារអាចធ្វើបាន និងការលំបាករបស់កុមារ។ ដើម្បីបញ្ជាក់ពីការអភិវឌ្ឍជំនាញ ផ្នែកទំនាក់ទំនង ការគ្រប់គ្រង សេចក្តីអំណត់ តស៊ូព្យាយាម ម្ចាស់ការ ការទទួលខុសត្រូវ ចេះធ្វើការរួមគ្នា ចេះផ្តល់ព័ត៌មាន ការគ្រប់គ្រងខ្លួនឯងមានសមត្ថភាពដោះស្រាយបញ្ហា តាមរបៀបនៃការគិតពិចារណាដោយការពេញចិត្ត មានភាពម្ចាស់ការកាន់តែមានភាពឯករាជ្យមានទម្លាប់ល្អក្នុងការរស់នៅប្រចាំថ្ងៃនិងរួមរស់នៅជាសមូហភាពប្រកបដោយភាពសុខដុម។

### ខ. ការវាយតម្លៃ

ត្រូវធ្វើឡើងដោយគ្រូបង្រៀនតាមសម្មភាពនីមួយៗ ក្នុងគោលបំណងវាយតម្លៃលទ្ធផលសិក្សារបស់កុមារម្នាក់ៗដោយផ្តោតលើវិជ្ជាសម្បទាបំណិនសម្បទាចរិយាសម្បទា និងការអនុវត្តសមត្ថភាពតាមសកម្មភាពនីមួយៗ។ក្នុងករណីកុមារអនុវត្តមិនទាន់បាននូវសកម្មភាពដែលគ្រូបានបង្រៀនគ្រូត្រូវជួយកុមារ ឱ្យសម្រេចបាននូវសកម្មភាពនោះដោយផ្តោតលើបំណិនជាក់លាក់មួយ។គ្រូបង្រៀនត្រូវការវាយតម្លៃការអនុវត្តរបស់កុមារ និងដឹងថាតើបំណិនចាំបាច់អ្វីខ្លះដែលត្រូវបន្ថែមទៀតដើម្បីជួយកុមារ។

### ៥.២.១ ការវាយតម្លៃលទ្ធផលសិក្សាប្រចាំថ្ងៃ

នៅពេលបង្រៀនមេរៀនចប់គ្រូត្រូវធ្វើការវាយតម្លៃ ដើម្បីវាស់ស្ទង់ នៃការអនុវត្តសកម្មភាពនីមួយៗ គ្រូត្រូវធ្វើជាប្រចាំ តាមរយៈសកម្មភាពបន្ទាប់ពីការអនុវត្ត។ ការវាយតម្លៃត្រូវសមស្របនឹងលទ្ធផលសិក្សាកម្រិតថ្នាក់ ។

### ៥.២.២ ការវាយតម្លៃលទ្ធផលសិក្សាប្រចាំត្រីមាស

ការវាយតម្លៃកម្រិតសមត្ថភាពសិក្សារបស់កុមារម្នាក់ៗតាមមេរៀន ដើម្បីរិះរកវិធានការជួយកុមាររៀនយឺត និងកុមារជួបការលំបាកជាបន្ទាន់ដោយមិនទុកឱ្យកុមារជួបការលំបាក និងអនុវត្តមិនបានទៅតាមកម្រិតស្តង់ដាលទ្ធផលសិក្សានៃសកម្មភាពនីមួយៗ។

### ៥.២.៣ ការវាយតម្លៃលទ្ធផលសិក្សាប្រចាំឆ្នាំ

ការវាយតម្លៃលទ្ធផលសិក្សាប្រចាំឆ្នាំ គ្រូប្រចាំថ្នាក់ផ្សព្វផ្សាយលទ្ធផលតេស្តលម្អិតសម្រាប់កុមារម្នាក់ៗដាក់ក្នុងតេស្តរួមនៅតាមថ្នាក់រៀន។ ក្រុមបច្ចេកទេសនិងនាយិកាសាលាបិទផ្សាយលទ្ធផលតេស្តសរុបកម្រិតថ្នាក់រៀន និងកម្រិតសាលារៀនគ្រប់មុខវិជ្ជានៅតាមភូមិ និងទីសាធារណៈ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១ ផ្នែកខ្លឹមសារអត្ថបទ

### ផ្នែកទី១

### ការអនុវត្តសកម្មភាពគោលដែលជំនួយដល់ដំណើរការបង្រៀន និងរៀន

ប្រធានបទ៖បំណិនទំនាក់ទំនង ដើម្បីកែញែកអំពើល្អ មិនល្អ

១-រឿងនិទាន « បាយ១ពំនូត »

នៅក្បែរជើងភ្នំស្រួចក្នុងខេត្តកំពង់ស្ពឺ មានកុមារា ២នាក់ បងប្អូនរស់នៅកំព្រាឪពុកម្ដាយ ខិតខំរកស៊ីចិញ្ចឹមខ្លួនផងតស៊ូទៅសាលារៀនដ៏សែនឆ្ងាយដោយវេចបាយលាយស៊ុតមាន់ម្នាក់ ១ពំនូត សម្រាប់ហូបថ្ងៃត្រង់ផង។ ព្រឹកថ្ងៃចន្ទនេះ កុមារ **ស៊ន** បានដឹកដៃ **សុខ** ជាប្អូនដើរផងរត់ផង ព្រោះខ្លាចពុំទាន់ម៉ោងចូលរៀន។ ស្រាប់តែកុមារទាំង ២ អាក់ដំណើរភ្លាមស្ទុះទៅគ្រាលោកតាម្នាក់ដែលបម្រុងនឹងដួល។ លោកតាឱបចៅទាំង២ រួចនិយាយថា៖

- តា វង្វេងផ្លូវ ២ថ្ងៃហើយ អត់មានអ្វីហូបឃ្លានណាស់។ កុមារ**ស៊ន**ហុចបាយ ១ពំនូត និងទឹក១ដបជូនលោកតាភ្លាម។ លោកតាទទួល ហើយពិសាបាយអស់ ១រំពេច។ ឃើញដូច្នេះ **សុខ** ជូនបាយ ១ពំនូតទៀតទៅលោកតាទំនងដូចជាស្ដាយប៉ុន្តែលោកតា រាដៃប្រកែក៖
- តាឆ្អែត និងមានកម្លាំងហើយ។ សូមចៅទាំង ២ ជួយជូនតាទៅរកថ្នល់ជាតិបាន ឬទេ? កុមារទាំង ២ គិត ១សន្ទុះ ក៏សម្រេចចិត្ត ជូនលោកតាទៅដល់ថ្នល់ជាតិ។ លោកតាបានសាកសួរចៅទាំង២ អំពីឈ្មោះ ថ្នាក់ និងសាលារៀនរួចក៏លាចៅទាំង ២ ឡើងឡានឈ្នួលចេញបាត់ទៅ។

កុមារទាំង ២ ត្រឡប់ក្រោយ ដឹកដៃគ្នារត់យ៉ាងលឿនសំដៅទៅសាលារៀន។ នៅពេលឃើញ **ស៊ន និងសុខ** មកដល់ថ្នាក់ អ្នកគ្រូប្រែទឹកមុខ លែងខឹង លែងភ័យ បែរជាសួរដោយរីករាយ អំពីមូលហេតុដែលមករៀនយឺត។

**ស៊ន និងសុខ** បានរៀបរាប់ជម្រាបអ្នកគ្រូតាមដំណើររឿង។ អ្នកគ្រូ និងមិត្តរួមថ្នាក់នាំគ្នាទះដៃសរសើរយ៉ាងខ្លាំង។

ដល់ម៉ោងសម្រាកថ្ងៃត្រង់ល្មមមិត្តរួមថ្នាក់បានបបួល **ស៊ន និងសុខ** ហូបបាយជាមួយគ្នាដោយរីករាយ។

ថ្ងៃស្អែកឡើង **ស៊ន និងសុខ** គ្រាន់តែឈានជើងចូលដល់ថ្នាក់ភ្លាម មានការភ្ញាក់ផ្អើលនឹងស្នូរទះដៃយ៉ាងខ្លាំង។ នៅខាងមុខមាននំចំណី សម្ភារសិក្សា និងសម្ភារល្បែងជាច្រើន និងនៅក្បែរនោះ មានលោកនាយកសាលា អ្នកគ្រូ និងលោកតា ដែលបានជួបពីម្សិលមិញ គាត់ស្ទុះមកចាប់ឱប **ស៊ន និងសុខ** យ៉ាងណែនដោយប្រកាសថា៖

ចៅៗថ្នាក់ទី ១ ទាំងអស់គ្នា បាយ១ពំនូតរបស់ **ស៊ន និងសុខ** បានធ្វើឱ្យលោកតារំភើបចិត្តណាស់ លោកតាសុំអនុញ្ញាតពីលោកនាយក អ្នកគ្រូ ប្រកាសថា សូមប្រគល់នំចំណី សម្ភារសិក្សា និងសម្ភារល្បែងជូនដល់ចៅៗទាំងអស់គ្នា និងចាប់ពីថ្ងៃនេះតទៅ **ស៊ន និងសុខ** គឺជាកូនរបស់ខ្ញុំ។ **ស៊ន និងសុខ** ត្រេកអរ

ពេក ព្រលែងដៃពីលោកតា ស្រក់ទឹកភ្នែក អង្គុយថ្វាយបង្គំ ៣ដង ហើយងើបឈរប្រកាសថា ខ្ញុំទាំង ២នាក់មានប៉ាដូចគេហើយ។ បរិយាកាសរីករាយទូទាំងថ្នាក់បានកើតឡើងសាជាថ្មីម្ដងទៀត។ **ស៊ន និងសុខ** បានជម្រាបលា លោកនាយក អ្នកគ្រូ និងមិត្តរួមថ្នាក់ចាកចេញទៅរៀននៅសាលាឯភ្នំពេញដោយក្ដីអាល័យ និងរស់នៅយ៉ាងសុខសាន្តជាមួយគ្រួសារកក់ក្ដៅ។

ប្រធានបទ៖ការលើកតម្កើងវប្បធម៌ការលើកតម្កើងវប្បធម៌របស់ខ្លួន

## ២- រឿងនិទាន ប្រវត្តិបុណ្យអុំទូក

នាល្ងាចថ្ងៃឈប់សម្រាកមួយ នារី និងបូណា អង្គុយលេងជាមួយលោកតានៅក្រោមម្លប់ស្វាយ។

**លោកតា** ៖ខ្យល់បក់ត្រសៀកៗ មេឃស្រឡះល្អ! នៅប៉ុន្មានថ្ងៃទៀតដល់ពេលប្រារព្ធពិធីបុណ្យអុំទូក សំពះព្រះខែ អកអំបុកហើយ។

**នារី** ៖ ពិតមែនហើយលោកតា! អ្នកគ្រូបានប្រាប់ចៅថា៖ នៅសប្ដាហ៍ក្រោយខាងមុខនេះ សិស្សទាំងអស់ត្រូវបានឈប់សម្រាកចំនួន៣ថ្ងៃ

**បូណា** ៖ លោកតា! ហេតុអ្វីចាំបាច់ប្រារព្ធពិធីបុណ្យអុំទូក?

**លោកតា** ៖ ពិធីបុណ្យអុំទូក ជាពិធីបុណ្យប្រពៃណីខ្មែរ ដែលធ្វើឡើងដើម្បីរំឭកថ្ងៃជ័យជំនះនៃកងទ័ពជើងទឹកដ៏ខ្លាំងពូកែនាសម័យអង្គរ។ នៅថ្ងៃទី១៤កើត ១៥កើត និងថ្ងៃ១រោច ខែកត្ដិក ពិធីអុំទូកចាប់ផ្ដើមប្រណាំងគ្នាតាមគូ ស្ថិតនៅទន្លេចតុមុខ ខាងមុខព្រះបរមរាជវាំង។

**នារី** ៖ លោកតា! ចៅឮអ្នកគ្រូប្រាប់ថា មានបណ្ដែតប្រទីបនៅពេលយប់ទៀត! តើមែនទេតា?

**លោកតា** ៖ ត្រូវហើយចៅ! បណ្ដែតប្រទីបនេះសប្បាយណាស់ចៅ គេធ្វើឡើងដើម្បីនឹកគុណដល់ព្រះគង្គារ និងព្រះធរណី ដែលបានផ្ដល់ជីវភាពរស់នៅយ៉ាងរុងរឿងដល់យើងគ្រប់គ្នាណាចៅ!

**បូណា** ៖ លោកតា! ចុះពិធីអកអំបុក និងសំពះព្រះខែវិញនោះ?

**លោកតា** ៖ ស្របពេលបណ្ដែតប្រទីប នាវេលាយប់ចន្ទពេញបូណ៌មី ត្រូវនឹងថ្ងៃ ១៥កើត អ្នកស្រុកក្មេងចាស់ប្រុសស្រីនាំគ្នាស្លៀកពាក់ស្អាតបាត មានទឹកមុខរីករាយនាំយកចេកទុំ ដូងខ្ចី ត្រាវស្ងោរ អំពៅ ស្លឹកអំបុក ធូប ទៀន បាយសី ផ្កាភ្ញី រៀបចំពិធីសំពះព្រះខែនៅខាងមុខផ្ទះ ឬទីធ្លាខាងមុខវត្ត។ ពេលខែរះពេញពន្លឺ អ្នកស្រុកនាំ គ្នាអុជទៀន ធូប សំពះបួងសួងថ្វាយរណ្ដាប់ដល់ព្រះចន្ទ។ បន្ទាប់មកគេធ្វើពិធីអកអំបុក ដោយលាយអំបុកជាមួយដូងខ្ចី ឬច្របាច់អំបុកលាយជាមួយចេកទុំ បង្អកគ្នាទៅវិញទៅមកយ៉ាងសប្បាយរីករាយ។

**លោកតា** ៖ ព្រលប់ចូលមកដល់ហើយចៅៗ តោះចូលទៅក្នុងផ្ទះខ្លាចមូសខ្លាខាំ។ នារី និងបូណា ដើរចូលក្នុងផ្ទះបណ្ដើរគិតបណ្ដើរថា សូមឱ្យថ្ងៃបុណ្យអុំទូកមកដល់ឆាប់ៗ។

ប្រធានបទ៖គំនូរ និងសកម្មភាពកសាងការយល់ដឹងពីភាពធ្លាស់នៃវត្ថុតាមចង្វាក់និងការគូរគំនូរ
(ការកាន់ខ្មៅដៃ)

## ៣- រឿងនិទាន ស្វាកាន់ខ្មៅដៃ

មានស្វាតូចៗពីរ មួយឈ្មោះ **សា** និងមួយទៀតឈ្មោះ **ដា**។ ស្វាទាំងពីរអង្គុយនៅលើដើមឈើមួយ ពួកវាមើលមកក្រោម បានឃើញក្មេងៗ កំពុងលេងនៅក្នុងទីធ្លាសាលារៀន។ ស្គរជួងបានបន្លឺឡើង ម៉ឹង ម៉ឹង ម៉ឹង ក្មេងៗ បាននាំគ្នាប្រញាប់ដើរចូលថ្នាក់រៀនវិញ។

**សា** ស្រែកថា ៖ អូ !មើលពួកក្មេងៗ ទុកអ្វីនៅលើដី ប្រហែលជានំហើយ។ សា អង្អែលពោះដូចជាឃ្លានខ្លាំង

**ដា** និយាយថា៖ តោះយើងទៅមើល។ ពួកវាសម្រូតចុះយ៉ាងលឿន ពីលើដើមឈើមកខាងក្រោមមានខ្មៅដៃមួយផ្តេកនៅលើដី។

**សា**និយាយថា៖ អូ ! មានស្អីគេហ្នឹងចង្អុលមករកខ្ញុំ។ សា មិនដឹងថានោះជាខ្មៅដៃទេ វាក៏លើកខ្មៅដៃនោះឡើងដោយប្រើមេដៃ និងចង្អុលដៃរបស់វា។ តើនេះជាអ្វី?

**ដា** ឆ្លើយថា ៖ វាជាខ្មៅដៃ ឯងកាន់ខ្មៅដៃដោយមេដៃ និងចង្អុលដៃរបស់ឯង ហើយប្រើដៃម្ខាងទៀតបង្វិលវាឱ្យមកនៅលើប្រអប់ដៃរបស់ឯង។ ដា បានធ្វើបង្ហាញ។

**សា**និយាយថា៖ អូ វាស្រួលកាន់ជាងមុន ប៉ុន្តែខ្ញុំចុកដៃ !។

**ដា** និយាយថ ៖ មិនអីទេដាក់ម្រាមដៃផ្សេងទៀតមកខាងក្រោមខ្មៅដៃរបស់ឯង ហើយដាក់ដៃឱ្យ ដល់ដីទៅ។

**សា** ដាក់ម្រាមដៃរបស់វានៅក្រោមខ្មៅដៃហើយនិយាយថា៖ វាស្រួលជាងមុនហើយ មើលនែ ! បើខ្ញុំកម្រើកត្រង់នៅលើដី ខ្ញុំអាចគូសគំនូសបាន ។

**ដា** សើចហើយនិយាយថា៖ ឯងក៏អាចរៀនគូសនិងសរសេរអ្វីផ្សេងៗ ទៀតដូចជាគំនូសផ្តេក គំនូសទេរទៅឆ្វេង ទេរទៅស្តាំ កោងផ្កាប់ កោងផ្ងារ រង្វង់ និងគំនូសអ្វីផ្សេងៗ ទៀតបាន មិនត្រឹមតែនៅលើដីទេ អាចសរសេរនៅលើក្រដាស ឬលើសៀវភៅបាន។

**សា** សួរ ៖ ពិតមែនឬ ? ឯងអាចជួយខ្ញុំបានទេ ?

**ដា**ឆ្លើយ ៖ ពិតជាបាន! ថាហើយ សា និង ដា បានញញឹមញញែមដាក់គ្នា ហើយក៏លាគ្នាទៅផ្ទះរៀងៗខ្លួន។

ប្រធានបទ ៖បំណិនទំនាក់ទំនង អត្តសញ្ញាណរបស់ខ្លួន

## ៤- រឿងនិទាន គ្រួសារខ្ញុំ

ព្រឹកថ្ងៃអាទិត្យនេះ ផានិតនៅចាំផ្ទះតែម្នាក់ឯង។ ផានិតកំពុងពិនិត្យមើលរូបភាពក្នុងសៀវភៅ និងដៃកាន់ខ្មៅដៃពណ៌ក្នុងគោលបំណងផាត់ពណ៌ក្នុងរូបភាពទាំងនោះនៅរានហាលខាងមុខផ្ទះ ស្រាប់តែមានលោក យាយមិនស្គាល់មុខម្នាក់បានស្រែកសួរ៖ ចៅតូច ចៅតូច! ពុកម៉ែនៅផ្ទះដែរឬទេ?

**ផានិត** ៖ មិននៅទេ! ពុកម៉ែគាត់ទៅស្រែតាំងពីព្រលឹមម្ល៉េះ។

**លោកយាយ** ៖ តើអាចឱ្យយាយសុំចូលអង្គុយលេងបានដែរឬទេ?

**ផានិត** ៖ បានលោកយាយ! សូមអញ្ជើញពិសាទឹក។

**លោកយាយ** ៖ អរគុណណាស់ចៅ! តើចៅឈ្មោះអ្វី? អាយុប៉ុន្មានឆ្នាំ? មានបងប្អូនប៉ុន្មាននាក់?

**ផានិត** ៖ ខ្ញុំឈ្មោះផានិត អាយុ ៥ឆ្នាំ មានបងប្អូន ៣នាក់។ ម៉ែហៅខ្ញុំថាអាពៅ។

**លោកយាយ** ៖ បងៗ របស់ចៅទៅណាអស់ហើយ?

**ផានិត** ៖ គាត់ទៅផ្សារជាមួយមីងពូរបស់ខ្ញុំ។

**លោកយាយ** ៖ ចុះពុកម៉ែចៅឈ្មោះអ្វី?

**ផានិត** ៖ ពុកឈ្មោះផាន់ ម៉ែឈ្មោះលីម។

**លោកយាយ** ៖ ចុះមាននរណាទៀតទេ ចៅផានិត?

**ផានិត** ៖ យាយតាគាត់ទៅវត្ត។

**លោកយាយ** ៖ ដូចនេះ គ្រួសាររបស់ចៅមានប៉ុន្មាននាក់? ផានិតរាប់ដៃស្ងាត់ៗ រួចឆ្លើយ៖ មានយាយតា ពុក ម៉ែ បងៗ និងខ្ញុំ អូលោកយាយ! គ្រួសារខ្ញុំមាន ៧នាក់ ។

**លោកយាយ** ៖ ចៅភ្លេច ២នាក់ ហើយ គឺមីងពូរបស់ចៅ។

**ផានិត** ៖ **គាត់**នៅផ្ទះផ្សេងទេ លោកយាយ!។ លោកយាយលាន់មាត់ថា ៖ អូ!

**ផានិត** ៖ នោះពុកម៉ែមកដល់ហើយ! ពុកម៉ែរបស់ផានិតគ្រាន់តែក្រឡេកឃើញភ្លាម ក៏ស្ទុះទៅឱបលោកយាយហើយប្រាប់ផានិតថា៖ ផានិត! កូនមកជម្រាបសួរលោកយាយភីម គាត់ជាប្អូនស្រីរបស់លោកតា និងជាមីងរបស់ពុកណា។ ផានិតឆ្លើយ៖ បាទ! ហើយដើរទៅជម្រាបសួរលោកយាយ រួចកាន់សៀវភៅរត់ចូលទៅក្នុងផ្ទះដើម្បីទុកពេលឱ្យចាស់ៗ បានជជែកគ្នាលេងដោយសប្បាយរីករាយ។

ប្រធានបទ៖បំណិនទំនាក់ទំនងការយល់ដឹងអំពីទង្វើ និងលទ្ធផល

## ៥-រឿងនិទាន ការអត់ឱន

កាលពីព្រេងនាយ មានកូនស្ដេចស្វាដ៏សែនពើសមួយឈ្មោះ**ពីនពីន**។ **ពីនពីន**មិនចេះនៅស្ងៀម តែងតែរត់លេងហក់លោតចុះឡើងពីដើមឈើមួយទៅដើមឈើមួយ។ **ពីនពីន**បានឃើញមិត្តភក្ដិកំពុងចែកផ្លែចាន់គ្នាហូបយ៉ាងឆ្ងាញ់ វាលេបទឹកមាត់ក្លឹកៗ ក៏ដាច់ចិត្តសុំមិត្តភក្ដិភ្លក្សមួយម៉ាត់។ ពិតជាឆ្ងាញ់មែន! តើវាមាននៅឯណា? **ពីនពីន**សួរ។ នៅក្នុងព្រៃខាងមុខឯនោះគ្រាន់តែស្ដាប់មិត្តភក្ដិនិយាយចប់ពុំទាន់ **ពីនពីន** រត់យ៉ាងលឿនចូលទៅក្នុងព្រៃ។ កំពុងតែធ្វើដំណើរ ស្រាប់តែមានកូនស្វាតូចមួយរត់មកបុក**ពីនពីន** ដួលទាំង២នាក់ **ពីនពីន** មិនប្រកាន់ឡើយស្ទុះងើបទៅជួយលើកកូនស្វាឱ្យងើបឈររួចបង្វិលខ្លួនមើល ដើម្បីឱ្យប្រាកដក្នុងចិត្តថាពុំមានរបួស ហើយវាក៏រត់ទៅមុខទៀតយ៉ាងលឿន បានទៅដល់ដើមចាន់។ **ពីនពីន** ឈោងដៃបេះផ្លែចាន់ ស្រាប់តែសំឡេងដើមចាន់ឃាត់ថា៖ ឯងត្រូវតែរកប្រស្នាឱ្យយើងចំនួន៣ អំពីការអត់ឱនមកប្ដូរផ្លែចាន់នេះទើបបាន។ **ពីនពីន** សំឡឹងផ្លែចាន់ដោយលេបទឹកមាត់ ហើយក៏អង្គុយសណ្ដូកជើងគិតបែបអស់សង្ឃឹមគិតចុះគិតឡើងនៅតែនឹកមិនឃើញ។ រំពេចនោះ មានពស់មួយវារកាត់លើជើង **ពីនពីន** ខឹងម៉ូម៉ៅលូកដៃចាប់កពស់បម្រុងនឹងបោក តែបែរជាអាណិតហើយក៏ព្រលែងពស់នោះវិញ។ យី!នរណាគប់មែកឈើត្រូវក្បាលខ្ញុំហ្នឹង? **ពីនពីន** អង្អែលក្បាលឈឺផងខឹងផងស្ទុះបម្រុងទៅវាយកូនស្វាដែលឈរគប់ផ្លែចាន់ពីក្រោយខ្នងកូនស្វាសំពះសុំអភ័យទោស **ពីនពីន**។ **ពីនពីន** រសាយកំហឹងហើយក៏ចាប់ដៃកូន

ស្វានោះឱ្យមកជួយគិតគ្នា រំពេចនោះស្រាប់តែផ្លែចាន់ពណ៌មាសមួយយ៉ាងធំបានធ្លាក់មកលើដៃ **ពីនពីន។** **ពីនពីន** ឆ្ងល់ណាស់ក៏សួរទៅដើមចាន់ថាៈ ខ្ញុំពុំទាន់បានដោះប្រស្នាឱ្យបង! តើហេតុអ្វីបានជាបងឱ្យចាន់ដ៏ក្រអូបឆ្ងាញ់នេះមកខ្ញុំ? ដើមចាន់តបៈ ចូរឯងគិតទៅមើល!ចាប់ពីពេលដែលឯងធ្វើដំណើររហូតដល់ពេលនេះ តើ**ពីនពីន** បានធ្វើអ្វីខ្លះ បានប៉ុន្មានដង? ដែលទាក់ទងនឹងប្រស្នាការអត់ឱននេះ? **ពីនពីន**គិតមួយសន្ទុះ ញញឹម និងនិយាយថាៈ ខ្ញុំយល់ហើយៗ! សូមអរគុណបងដើមចាន់ច្រើនណាស់! ជម្រាបលាបង!

ត្រឡប់ទៅវាំងវិញ នៅតាមផ្លូវ **ពីនពីន** ចែកផ្លែចាន់ឱ្យកូនស្វាញ៉ាំជាមួយដែរ ចំណែកខ្លួន **ពីនពីន** មានពណ៌មាសខុសពីធម្មតា។ មកដល់វាំង **ពីនពីន** ភ្ញាក់ផ្អើលយ៉ាងខ្លាំង ឃើញមានការតុបតែងភ្លើផ្កា មានក្បួនឈរអមតាមផ្លូវខ្លះទះដៃ ខ្លះគ្រវីផ្កាអបអរសាទរ **ពីនពីន**បានពាក់មកុដអំពីមាស និងបានឡើងសោយរាជ្យ។

ប្រធានបទ៖បំណិនទំនាក់ទំនងបំណិនរស់នៅក្នុងសង្គមនិងទំនាក់ទំនងជាមួយមនុស្សជុំវិញ

### ៦-រឿងនិទាន កុមារីក្លាហាន

មានរឿងមួយតំណាលថា នៅក្នុងខ្ទមដ៏កំសត់មួយ មានកូនស្រីម្នាក់ឈ្មោះ**មេត្តា** និងម្តាយចាស់ជរាមានជំងឺប្រចាំកាយ។ ជារៀងរាល់ថ្ងៃ **នាងមេត្តា**តែងរៀបចំបាយ ទឹកនំចំណី និងថ្នាំព្យាបាលទុកឱ្យនៅជិតម្តាយ ទើបចេញដំណើរទៅរកថ្នាំព្យាបាល និងម្ហូបអាហារ សម្រាប់បន្តទៅថ្ងៃក្រោយទៀត។ **នាងមេត្តា**បានចេញដំណើរទៅក្នុងព្រៃជ្រៅ បានជួបនិងខ្លាធំមួយមានបបួសជើងម្ខាង នាងអាណិតបានជូតឈាម និងរុំរបួសឱ្យខ្លានោះ។ ខ្លាបានសងគុណវិញដោយឱ្យទៅ**នាងមេត្តា**នូវដុំឡូង ១បាវ និងគ្រាប់សណ្តែកខៀវ ១បាវ។ **នាងមេត្តា**ត្រេតអរណាស់តែយកពុំរួច ព្រោះធ្ងន់ និងមិនអាចយកទៅតាមខ្លួន ដើម្បីរកថ្នាំក្នុងព្រៃជ្រៅខាងមុខបន្តទៀត។ **នាងមេត្តា**បានដាំមើមដំឡូងនៅតាមចិញ្ចើមផ្លូវម្ខាង និងចិញ្ចើមផ្លូវម្ខាងទៀត នាងដាំសណ្តែកខៀវ។ **នាងមេត្តា** ដាំបែបនេះ រហូតទៅដល់កន្លែងមួយដែលមានថ្នាំ។ **នាងមេត្តា**កំពុងអង្គុយជីកថ្នាំបានឮសំឡេងថ្ងូរ និងស្រែកសុំឱ្យជួយនៅក្រោយខ្នងនាង។ **នាងមេត្តា**កាន់មើមថ្នាំរត់ទៅមើល ឃើញមនុស្សរូបអាក្រក់គួរឱ្យខ្លាចកំពុងឈឺញ័រញាក់ **នាងមេត្តា**ឈរគិត ហើយនិយាយតែម្នាក់ឯងថាៈ អូហ៎! នឹកឃើញហើយ យកមើមថ្នាំនេះព្យាបាលបុរសនេះសិនចុះ នៅមួយកន្លែងទៀត ដែលអាចជីកថ្នាំទៅព្យាបាលម្តាយបាន។ ពោលចប់ នាងបានបុកមើមថ្នាំពូតយកទឹកមកឱ្យបុរសនោះផឹក បុរសនោះបានធូរស្រាលក៏ចាប់នាងបិទភ្នែកចងនឹងកន្សែងលីទៅប្រាសាទ។ នៅតាមផ្លូវ នាងចំណាំដោយការបត់ឆ្វេង ២ដង បត់ស្តាំម្តងបត់ឆ្វេងម្តងដល់មុខប្រាសាទ។ បុរសរូបអាក្រក់នោះ បានស្រាយក្រណាត់ចេញពីភ្នែកនាង។ **នាងមេត្តា** ឃើញរូបចម្លាក់មុខអាក្រក់សំឡឹង និងគ្រហឹមដាក់នាងគួរឱ្យខ្លាច។ នាងគិតក្នុងចិត្តថា មិនខ្លាច នឹងធ្វើឱ្យរូបចម្លាក់ទាំងនេះ ស្រឡាញ់ទុកចិត្តនាងវិញ។ នាងសួរថា ៖ ពូរូបអាក្រក់! តើនៅជិតនេះ មានអណ្តូងទឹកស្អាតឬទេ? ខ្ញុំចង់ជូតខ្លួនឱ្យរូបចម្លាក់ទាំងនេះ មើលទៅខានមុជទឹកយូរឆ្នាំមកហើយ។ បុរសរូបអាក្រក់នោះ បានបង្ហាញអណ្តូងទឹកស្អាតនៅខាងក្រៅប្រាសាទ។ រាល់ពេលនាងទៅដងទឹកអណ្តូងមកជូតខ្លួនឱ្យរូបចម្លាក់ នាងតែងលួចគិត ចម្ងាយផ្លូវដែលនាងមកដល់ខ្លោងទ្វារប្រាសាទ និងផ្លូវបត់ឆ្វេង២ដង បត់ស្តាំម្តង បត់ឆ្វេងម្តង បើត្រឡប់ទៅវិញបត់ស្តាំម្តង បត់ឆ្វេងម្តង បត់ស្តាំ២ដង នាងគិតចុះគិតឡើងជឿជាក់ថាត្រូវហើយនាងសប្បាយចិត្តណាស់។ ក្នុងរយៈពេល ៣ថ្ងៃនេះ **នាងមេត្តា**បានគោរព និងបម្រើបុរសមុខ

អាក្រក់ប្រៀបដូចជាអ្នកមានគុណ និងជូតសម្អាតរូបចម្លាក់ថ្មមៗ ដោយប្រិតប្រៀង ធ្វើឱ្យប្រាសាទមានភាពរីករាយ និងមានក្ដីសង្ឃឹមឡើងវិញ។

ជាឱកាសដែលពួកគេកំពុងស្រឡាញ់ទុកចិត្តនាង នាងលួចរត់យ៉ាងលឿនតាមផ្លូវដែលនាងបានគិតទុក បត់ស្ដាំម្ដង បត់ឆ្វេងម្ដង បត់ស្ដាំ២ដង រហូតមកដល់ពំនូកដីដែលនាងទើបនឹងដាំដំឡូង និងសណ្ដែកខៀវថ្មីៗ នៅតាមដងផ្លូវទាំងសងខាង នាងប្រឹងរត់បន្តទៀត។ ស្រាប់តែឮសំឡេងខ្លាស្រែកថា៖ **នាងមេត្តា!** ឡើងជិះលើខ្នងខ្ញុំមក ផ្ទះនាងនៅឯណា ខ្ញុំជូនទៅ។ **នាងមេត្តា**ឡើងជិះលើខ្នងខ្លាបណ្ដើរនិយាយប្រាប់ខ្លាបណ្ដើរ៖ ផ្ទះខ្ញុំជាខ្ទម មានដើមពុទ្រា ២ដើម ក្បែរផ្ទះយាយភីម ស្ថិតនៅខាងចុងភូមិគូលែន។ ខ្លាស្ដាប់បានហើយក៏បោលតែមួយប៉ព្រិចភ្នែកបានដល់ផ្ទះដូចបំណង។ នាង សំពះលា និងអរគុណខ្លា។ នាងបានរៀបរាប់ដំណើររឿងប្រាប់ម្ដាយ។ ប៉ុន្មានខែក្រោយមកអ្នកភូមិបានមកបបួលនាងទៅជីកដំឡូង និងបេះសណ្ដែក ដែលទេវតាបានដាំទុកឱ្យ។ អ្នកភូមិមិនដឹងថានាងជាអ្នកដាំ គិតថាជាទេវតា នាងនឹងលួចទៅដាំឱ្យអ្នកភូមិសប្បាយចិត្តបន្តទៀត ហើយនាងក៏នឹកទៅដល់បុរសមុខអាក្រក់។ នាងសុំការអនុញ្ញាតិពីម្ដាយទៅលេងគាត់។ ខ្លាជូននាងទៅប្រាសាទតាមដែលនាងចង្អុលប្រាប់ផ្លូវ។ នាងបានទៅដល់ប្រាសាទឃើញរូបចម្លាក់ទាំងអស់យំ។ នាងរត់ឡើងទៅបើកទ្វារបន្ទប់ខាងលើប្រាសាទ ឃើញបុរសមុខអាក្រក់ស្លាប់ នាងសំពះឱនក្បាលយំដាក់លើទ្រូងបុរសនោះ រៀបរាប់សុំអភ័យទោស។ រំពេចនោះផ្ទៃប្រាសាទទាំងមូលមានពន្លឺចែងចាំង សំឡេងតន្ត្រីលាន់រងំ បុរសមុខអាក្រក់ប្រែក្លាយជាព្រះមហាក្សត្រដ៏ស្រស់សង្ហាស្ទុះមកឱបនាង និងរៀបរាប់ប្រាប់ថា៖ ទឹកភ្នែកដ៏ស្មោះត្រង់របស់នាង បានរំដោះនគរទេពឱ្យរួចពីបណ្ដាសារបស់អារក្សទឹក។ ព្រះមហាក្សត្រដ៏ស្រស់សង្ហាបានដឹកដៃនាងមកសាលប្រជុំ រូបចម្លាក់ទាំងឡាយបានក្លាយជាមនុស្ស។ ព្រះអង្គបានប្រកាសថា៖ សូមមហាសេនា នាហ្មឺននិងមន្ត្រីគ្រប់លំដាប់ថ្នាក់ទាំងអស់យកថ្នាំទិព្វនេះទៅជូនអ្នកម្ដាយរបស់ **ព្រះនាងមេត្តា** ហើយដង្ហែរទ្រង់ និងអញ្ជើញអ្នកភូមិទាំងអស់មកទទួលអំណោយ និងចូលរួមអបអរសាទរពិធីឡើងគ្រងរាជ្យរបស់**ព្រះនាងតូចមេត្តា**។ ចាប់ពីថ្ងៃនោះមកអ្នកភូមិគូលែនមានជីវភាពរុងរឿង រស់នៅសុខសាន្ត និងមានទំនាក់ទំនងល្អជាមួយព្រះនគរទេព។

ប្រធានបទ៖ការលើកតម្កើងវប្បធម៌ការលើកតម្កើងវប្បធម៌របស់ខ្លួន

## ៧-រឿងនិទាន ចូលឆ្នាំខ្មែរ

ព្រឹកថ្ងៃអាទិត្យនេះ **វណ្ណី**គេងលក់យ៉ាងស្កប់ស្កល់។ យី! អ្វីមកចាំងភ្នែកខ្ញុំម្ល៉េះ! អ៊ំ! ពន្លឺព្រះអាទិត្យចាំងចូលតាមបង្អួច ខ្ញុំសុំដំបន្តិចទៀតសិន។ គួរឱ្យរំខានមែន! ទ្រនិចនាឡិកាពេទិ៍ណីងណុងៗ ១ ណីងណុងៗ ២ ណីងណុងៗ ៣ ណីងណុងៗ ៤ ណីងណុងៗ ៥ ណីងណុងៗ ៦ ណីងណុងៗ ៧ ទ្រាំមិនបានទេម៉ោង ៧ហើយ ខ្ញុំត្រូវតែភ្ញាក់។ **វណ្ណី**ភ្ញាក់ពីដំណេកទាញបន្ទឹងកម្រាលពូក រៀបចំខ្នើយ បត់ភួយ ឃើញមានខោអាវថ្មី ២សម្រាប់នៅលើកៅអី។ **វណ្ណី**ញញឹម ដើរចេញទៅក្រៅបន្ទប់ឃើញទីធ្លាផ្ទះស្អាតខុសពីថ្ងៃធម្មតា។ នៅរានហាលខាងមុខផ្ទះ មានតុមួយរៀបចំយ៉ាងស្អាតក្រាលកម្រាលពណ៌ស ដែលមានទៀនធូប បាយសី ផ្លែឈើ២ថាស ផ្តិលទឹកអប់ផ្កាម្លិះ និងថូផ្កា១គូ មានក្លិនក្រអូបឈ្ងុយឈ្ងប់។ **វណ្ណី**រត់ទៅផ្ទះបាយឃើញម្ដាយ និងបងស្រីកំពុងរៀបចំម្ហូបដាក់ស្រាក់ ម្ដាយនិយាយថា៖ **វណ្ណី** ឆាប់ទៅមុជទឹក ស្លៀកពាក់ ទទួលទេវតាឆ្នាំថ្មី ដល់ម៉ោងឥឡូវហើយកូន។ **វណ្ណី**ឆ្លើយ ចាស ហើយរត់ទៅមុជទឹក ស្លៀកពាក់ខោអាវថ្មី តុបតែងខ្លួន

យ៉ាងស្អាត រួចចេញទៅអុចធូបជាមួយក្រុមគ្រួសារទទួលទេវតាឆ្នាំថ្មី។ បន្ទាប់មក**វណ្ណី**កាន់សាដក បងស្រីកាន់ស្រាក់ ម្ដាយទូលកញ្ជើដាក់អន្សម និងផ្លែឈើដើរទៅវត្តនៅចុងភូមិ។ ល្ងាចថ្ងៃទី១នេះ បងស្រីកាន់ដៃ**វណ្ណី**បណ្ដើរគ្នាទៅលេងល្បែងប្រជាប្រិយនៅឯវត្ត។ **វណ្ណី**និយាយទៅកាន់បងស្រីថា៖ បងមើលហ្ន៎! ពួកគេលេងល្បែងចោលឈូងក៏សប្បាយ បោះអង្គញ់ក៏សប្បាយ ចាប់កូនខ្លែងក៏សប្បាយ តើយើងលេងល្បែងមួយណា? ប្អូនមើលទៅខាងនោះវិញ មានក្មេងៗ ស្រករនឹងប្អូនកំពុងលេងល្បែងលាក់កន្សែង។ បងស្រីតបគ្រាន់តែក្រឡេកឃើញភ្លាម **វណ្ណី**ព្រលែងដៃបងស្រី ហើយរត់ទៅសុំមិត្តភក្ដិលេងជាមួយរហូតដល់ហត់នឿយត្រឡប់មកផ្ទះវិញ។ នៅពេលយប់កំពុងញ៉ាំអាហារជុំគ្នា ប៉ាបាននិយាយថា៖ ថ្ងៃស្អែកជាថ្ងៃទី២ កូនៗ ត្រូវភ្ញាក់ពីព្រលឹមជួយរៀបចំម្ហូបអាហារម៉ាក់ និងយករណ្ដាប់រួមទាំងលុយកាក់ ទៅជូនលោកតាលោកយាយរបស់កូននៅឯដើមភូមិណា! ខានស្អែកជាថ្ងៃទី៣ កូនៗត្រូវទៅវត្តជាមួយប៉ាម៉ាក់យកចង្ហាន់ប្រគេនព្រះសង្ឃ ពូនភ្នំខ្សាច់ ស្រង់ទឹកព្រះពុទ្ធរូបរួចទៅផ្ទះឯដើមភូមិស្រង់ទឹកជូនលោកតាលោកយាយ។ បងស្រីនិយាយថា៖ តើកូនទាំង២ អាចស្រង់ទឹកជូនប៉ាម៉ាក់ ព្រមពេលលោកយាយ លោកតាបានឬទេ? ប្រាកដជាបានណាកូន! ប៉ាម៉ាក់ ឆ្លើយព្រមគ្នា។ ប៉ាម៉ាក់! បន្ទាប់ពីស្រង់ទឹកអ្នកមានគុណហើយ តើប៉ាម៉ាក់អាចជូនកូនទៅលេងសមុទ្របានឬទេ? គ្រាន់តែ**វណ្ណី**សួរចប់ភ្លាម។ ក្រុមគ្រួសារនាំគ្នាទះដៃសើចយល់ព្រមតាមសំណើរបស់**វណ្ណី**។

ប្រធានបទ៖ ការយល់ដឹងពីតម្លៃមនុស្ស .ការយល់ដឹងពីតម្លៃមនុស្ស និងចរិតលក្ខណៈរបស់មនុស្ស

## ៨-រឿងនិទាន កូនបួននាក់មិនបម្រើឪពុក

ក្នុងកាលកន្លងទៅ មានបុរសពោះម៉ាយម្នាក់ គាត់មានកូនប្រុសបួននាក់ ដែលមានអាយុគ្រប់ការទាំងអស់។ ដោយមានការលំបាក ខ្វះស្ត្រីមេផ្ទះជាអ្នកចម្អិនអាហារ និងជួយថែទាំទ្រព្យសម្បត្តិ គាត់ក៏រៀបការប្រពន្ធឱ្យកូនប្រុសជាបន្តបន្ទាប់ ដោយចែកទ្រព្យសម្បត្តិអស់រលីងពីខ្លួន ទុកតែផ្ទះមួយខ្នងឱ្យកូននៅជុំគ្នា។ ឪពុកតែងតែគិតថា កូនទាំងបួន នឹងរកស៊ីចិញ្ចឹមគាត់វិញរហូតដល់ថ្ងៃស្លាប់។ ប៉ុន្តែការគិតនេះខុសស្រឡះ ព្រោះចាប់ពីមានប្រពន្ធមក កូនទាំងនោះបានបែកចិត្តគំនិតផ្សេងៗគ្នា រស់នៅជាមួយគ្នាពុំសូវបានសុខ ចេះតែស្តៀបមាស់បន្តិចទាស់នេះ បន្តិចទាស់នោះ ក៏នាំគ្នាចេញពីផ្ទះកំណើតទៅរកសង់ផ្ទះនៅទីទៃពីគ្នា ចោលតាជាឪពុកឱ្យនៅតែម្នាក់ឯង។ កាលកូនទាំងបួននាក់ទើបនឹងចុះពីឪពុកទៅថ្មីៗ នៅហុចបាយហុចចំណីជូនតាជាឪពុកបន្តិចបន្តួចរាល់ៗថ្ងៃ លុះមានកូនខ្ចីគ្រប់ៗគ្នា ជួនពេលប្តីរវល់ដើរទៅជួញស្រុកឆ្ងាយ ភរិយាម្នាក់ៗមើល បំណាំគ្នា ខ្លះគិតថាប្រហែលប្អូនគេយកទៅជូនហើយ ខ្លះគិតថាបងឯនោះយកបាយទៅជូនពុកហើយ។ យូរថ្ងៃទៅតាអត់បាយមួយពេលក៏មានពីរពេលក៏មាន។ ពេលប្តីមកវិញដឹងរឿងនេះ បានស្តីបន្ទោសប្រពន្ធ។ ប្រពន្ធ ទាំងនោះដោះសារថាកូនឈឺ ខ្លះថាជាប់រវល់ទៅជួយញាតិជិតខាង ស្រេចតែប្រពន្ធថា ប្តីតាមទាំងអស់។ ចំណែក តាពោះម៉ាយ ខ្លួនកាន់តែចាស់ ទ្រព្យក៏គ្មាន រកស៊ីអ្វីពុំកើតក៏ធ្លាក់ខ្លួនសុំទានគេ រងទុក្ខវេទនាពេកក្រៃ។

ថ្ងៃមួយមានបុរសម្នាក់មានចិត្តសប្បុរស ដើរមកឃើញក៏មានចិត្តអាណិតក៏សាកសួរតា។ លុះបានដឹងរឿងហើយចៅកម្លោះនិយាយថា៖ កូនចិត្តអាក្រក់ដល់ម្លឹងហ្ន៎! ខ្ញុំយកបាយទឹកជូនតា តែសូមតាធ្វើតាមខ្ញុំ គឺតាជុះអាចម៍ឱ្យពេញពាងមួយ រុំក្រណាត់បិទមាត់ឱ្យជិតកប់ក្នុងដីជិតសសរទ្រូងផ្ទះ រួចនិយាយឱ្យកូន

ណាដែលដឹងគុណ បើខ្ញុំរៀបស្លាប់ខ្ញុំនឹងប្រគល់ឱ្យកូននោះ។ តាឈប់សុំទាន ហើយធ្វើតាមចៅចិត្តសប្បុរស។ លុះបានប្រហែល៥ថ្ងៃ សម្ដីតានោះបានឮដល់កូន និងកូនប្រសាទាំង៨នាក់ ដែលមានចិត្តលោភលន់ចង់បានកំណប់តែរៀងខ្លួនក៏នាំគ្នាយកបាយទឹកម្ហូបចំណី ផ្លែឈើទុំ ខ្ទី គ្រប់មុខ និងខោអាវក្រមាមកផ្គាប់ផ្គន់ជូនឪពុករៀងរាល់ថ្ងៃ រហូតដល់តាចាស់បានជាសះស្បើយពោគមានកម្លាំងពលំ សុខសប្បាយចិត្ត។ លុះចំណេរយូរមក ភាពចាស់ជរាបានធ្វើឱ្យតាស្លាប់ហើយកូនក៏នាំគ្នាធ្វើបុណ្យអធិកអធមតាមទំនៀមទម្លាប់។ កូនទាំងអស់គិតនាំគ្នាគាស់ពាងកំណប់ ប៉ុន្តែក្រែងចែកមិនស្មើគ្នានាំឈ្លោះប្រកែកគ្នា ក៏ទៅអញ្ជើញគ្រូហ្ម ម្នាក់។ ហេតុតែចង់បានរបស់គេ គ្រូហ្ម នោះបានយកក្អមមួយធំមករុំជួតក្បាលធំទើងមើងធ្វើឱ្យខូងកណ្ដាលដូចគេទូលជើងផ្ទាំងផ្ទារ ក៏ តាំងអង្គុយពែនភ្នែនបែរមុខទៅទិសខាងកើត ធ្មេចភ្នែករាងសង្រួមស្ងឹងស្ងាធ ហើយប្រាប់កូនទាំងបួនឱ្យទៅគាស់យកកំណប់មក ប៉ុន្តែហាមមិនឱ្យបើកមាត់ពាងខ្លាចខុសត្រណម។ លុះយកពាងមកដល់ហើយ កូនប្រុសទាំងបួនធ្មេចភ្នែក យកដៃទាំងអស់គ្នាចាប់លើកពាងទ្រស្លូចលើក្បាល ហើយស្រាយចំណងមាត់ពាង នាំគ្នាផ្អៀងមាត់ពាងស្រោចកំណប់មកលើក្បាលគ្រូហ្ម បើកំណប់ធ្លាក់ទៅទិសណាប៉ុន្មាន គឺត្រូវបានទៅអ្នកឈរនៅទិសនោះ កំណប់ណានៅសល់ ទើរលើផ្នួតក្បាលត្រូវបានជាង្វាន់គ្រូហ្មទាំងអស់។ រីឯភរិយាទាំងបួនឈរកាន់កញ្ជើរៀងខ្លួនចាំកើបកំណប់ ចំណែកអ្នកស្រុកជិតខាងនាំគ្នាចាំឈរមើល ទឹកម៉ាត្រាំលាមកដ៏ច្រើនខួបជុំក្លិនស្អុយ បានហូរស្រោចលើក្បាលគ្រូហ្មពេញបន្ទុក ហើយបានខ្ទាតបាចសាចទៅគ្រប់ទិស ប្រឡាក់ពេញមុខ និងសំពត់អាវហូតដល់នាងប្រពន្ធអ្នកទាំងបួននាក់ទៀត។ គ្រូហ្មខ្មាស់អ្នកស្រុកក៏ស្រែកជេរថា៖ មេដែង អាដែងទាំងអស់គ្នា បានធ្វើបាបខ្មោចឪច្រើនណាស់មើលទៅបានជាកំណប់មាសប្រាក់អន្តរាយក្លាយទៅជាអាចម៍ដូច្នេះ។ គ្រូហ្មនិងសិស្សនាំគ្នារត់លោតទម្លាក់ខ្លួនទៅក្នុងទន្លេប្រូង ខំត្រាំទឹកលាងបាបអស់មួយម៉ោង រួចនាំគ្នាឡើងទៅលើផ្ទះរៀងៗខ្លួនដោយសេចក្ដីក្ដៅក្រហាយស្ដាយក្រោយ ខ្មាស់គេតកូនតចៅ។

ប្រធានបទ៖ ការយល់ដឹងអំពីខ្លួនឯង .សម្ដែងអារម្មណ៍និងចេះសង្កត់ចិត្តរបស់ខ្លួន

## ៩-រឿងនិទាន ហ្វូងដំរី

ថ្ងៃនេះមានដំរីមួយហ្វូងនៅក្នុងព្រៃ(កុមារទាំងអស់ធ្វើហ្វូងដំរី) វាចង់មកលេងនៅសាលារៀនយើង។ ហ្វូងដំរីនៅឆ្ងាយកំពុងធ្វើដំណើរមកហើយ( ឱ្យកុមារដើរទន្រ្ទាំជើងឮតិចៗ)។ ហ្វូងដំរីកំពុងតែធ្វើដំណើរមកកាន់តែជិតដល់សាលាយើងហើយ ( ឱ្យកុមារដើរទន្រ្ទាំជើងឮខ្លាំងៗ)។ អូ! នុះហ្វូងដំរីបានមកដល់សាលារៀនយើងហើយ ( ឱ្យកុមារដើរទន្រ្ទាំជើងឮកាន់តែខ្លាំងឡើងៗ)។ ឥឡូវនេះ ហ្វូងដំរីរៀបចំធ្វើដំណើរត្រឡប់ទៅវិញហើយ ( ឱ្យកុមារដើរទន្រ្ទាំជើងឮខ្លាំងៗ)។ ហ្វូងដំរីទៅកាន់តែឆ្ងាយទៅៗ ( ឱ្យកុមារដើរទន្រ្ទាំជើងឮកាន់តែតិចទៅៗ)។ ហ្វូងដំរីទៅដល់ព្រៃវិញហើយ( ឱ្យកុមារឈរស្ងៀមឈប់ទន្រ្ទាំជើងទាំងអស់គ្នា )។

**បញ្ជាក់ ៖** និទានបណ្ដើរ នាំកុមារធ្វើសកម្មភាពតាមខ្លឹមសាររឿងបណ្ដើរ។

ប្រធានបទ៖ បំណិនសង្គម ការយល់ដឹងអំពីបរិស្ថានធម្មជាតិ និងវិធីការពារ

## ១០-រឿងនិទាន ដើរលេងតាមសួន

នេះ គឺសុភាជាកូន នោះគឺសុផាជាម៉ែ ពួកគេដើរលេងតាមសួន។

សុភា! តើកូនឃើញដើមចំប៉ីឬទេ? សុភា ៖ ឃើញដើមចំប៉ី។ សុភារាប់ដើមចំប៉ីជាមួយម៉ែ ១ ២

សុភា! តើកូនឃើញចាបទេ ? សុភា៖ ឃើញចាប។ សុភារាប់ចាបជាមួយម៉ែ ១ ២ ៣
សុភា! តើកូនឃើញមេអំបៅទេ ? សុភា៖ ឃើញមេអំបៅ។ សុភារាប់មេអំបៅជាមួយម៉ែ ១ ២ ៣ ៤
សុភា! តើកូនឃើញថង់សំរាមទេ ?សុភា៖ ឃើញថង់សំរាម។ សុភារាប់ថង់សំរាមជាមួយម៉ែ ១ ២ ៣ ៤ ៥
សុភា! តើកូនឃើញធុងសំរាមទេ ? សុភា៖ ឃើញធុងសំរាម។ សុភារើសថង់សំរាមដាក់ទៅក្នុងធុងសំរាម។

ប្រធានបទ៖ គំនូរ និងសកម្មភាពកសាង .ការពេញចិត្តចំពោះលក្ខណៈផ្សេងគ្នារបស់បុគ្គល

## ១១-រឿងនិទាន កូនទារូបអាក្រក់

នេះជារដូវក្តៅ **ម្តាយ**ទាបានរកឃើញកន្លែងដ៏ល្អសម្រាប់ពងនៅក្រោមដើមឈើជិតស្រះមួយ។ នាងពងបាន៥ ភ្លាមនោះនាងក៏កត់សម្គាល់ថា ពងមួយមានរូបរាងខុសពីពងដទៃ។ នាងមានការព្រួយបារម្ភ រងចាំរហូតដល់ពងនោះ ញាស់។ ពេលព្រឹកមួយពងទាំងអស់ចាប់ផ្តើមញាស់ សល់តែពងមួយ ពួកវាស្រែកកេបៗ គ្រប់ពងចាប់ផ្តើមមានជីវិតក្លាយជាកូនទា។ កូនទាទាំងអស់នោះ បានរុញក្បាលវាចេញមកក្រៅដើម្បីបានឃើញពិភពលោកដ៏ធំធេង។ **ម្តាយ**ទានិយាយថា៖ កូនរបស់ខ្ញុំអីគួរឱ្យស្រឡាញ់ម្ល៉េះ! ខ្ញុំជា**ម្តាយ**អីក៏សំណាងម្ល៉េះ! តើមានរឿងអ្វីចំពោះពងទី៥នេះមិនទាន់ញាស់ នាងពិបាកចិត្តក៏ដើរទៅក្រាបលើពងនោះដើម្បីឱ្យមានកំដៅ ហើយនាងគិតថា ពងនេះប្រហែលជាកូនស្អាតជាងគេហើយបានជាក្រញាស់ អញ្ចឹងនោះ។ នាព្រឹកមួយពងក៏បានបែក មានកូនទាពណ៌ប្រផេះដ៏អាក្រក់ចេញមក កេបៗ កូនទានេះវាខុសពីបងៗរបស់វា វាធំជាងគេហើយអាក្រក់ជាងគេ។ ម៉ែទាបានភ្ញាក់ផ្អើលនៅពេលឃើញកូនអ៊ីចឹង តែនាងសង្ឃឹមថាថ្ងៃណាមួយវានឹងមានរូបរាងដូចបងៗវិញ។ តែច្រើនថ្ងៃកន្លងមកកូនទានៅតែអាក្រក់ដដែល បងៗ វាគេលេងយ៉ាងសប្បាយ តែគេមិនឱ្យវាលេងចូលទេ ហើយក៏មិនលេងជាមួយវាដែរ ថែមទាំងស្តីឱ្យនិងសើចចំអកឱ្យវាទៀត។ កូនទារូបអាក្រក់ពិបាកចិត្តក៏ដើរទៅបឹងមើលរូបរាងវានៅក្នុងទឹក កូនទានិយាយថា៖ គ្មានអ្នកណាដូចខ្ញុំទេ ខ្ញុំមានរូបអាក្រក់ណាស់។ កូនទាសម្រេចចិត្តចាកចេញពីគ្រួសារវាទៅឱ្យឆ្ងាយនៅក្នុងព្រៃ។ កូនទាដើរត្រាច់ចរម្នាក់ឯងនៅតាមផ្លូវ។ មិនយូរមិនឆាប់រដូវរងារមកដល់ មានព្រិលជាច្រើនធ្លាក់នៅទីនោះ កូនទាពិបាកចិត្តមិនអាចរស់នៅបាន ក៏វិលត្រឡប់ទៅគ្រួសារវិញ។ ពួកគេក៏នៅតែបដិសេធមិនទទួលស្គាល់។ វាក៏ដើរទៅផ្ទះមាន់ ប៉ុន្តែមាន់ទាំងនោះបានចឹកវា វាក៏រត់ទៅមុខក៏បានជួបនឹងឆ្កែមួយនៅតាមផ្លូវ ឆ្កែនោះក៏ដើរទៅផុតទៀត វាក៏ដើរទៅមុខទៀតបានជួបនឹងមនុស្សម្នាក់ គាត់ក៏យកកូនទានោះទៅផ្ទះឱ្យប្រពន្ធកូនគាត់។ នៅទីនោះក៏មានបញ្ហាជាមួយឆ្មាដែលរស់នៅទីនោះ វាក៏ចាកចេញពីទីនោះទៅ។ មិនយូរមិនឆាប់និទាឃរដូវក៏មកដល់ វាសប្បាយចិត្តណាស់ក៏ដើរទៅបឹងម្តងទៀត ហើយបានជួបនឹងក្ងានមួយដ៏ស្រស់ស្អាត វាក៏ចាប់ចិត្តស្រឡាញ់នាង។ វាក៏ទៅមើលមុខវាម្តងទៀត វាឃើញរូបវាប្លែកមិនអាក្រក់ទេ វាមិនមែនកូនទាទៀតទេ វាគឺជាក្ងាន។ វាសប្បាយចិត្តក៏រៀបការជាមួយនាងក្ងាន រស់នៅដោយមានសេចក្តីសុខតរៀងទៅ។

## ១២-រឿងនិទាន បុណ្យភ្ជុំបិណ្ឌ

**សុភី**ជាកូនស្រីឆ្លាតវាងវៃ និងឧស្សាហ៍ព្យាយាម។ ល្ងាចនេះ **សុភី**មិនរត់លេងទៅណាឆ្ងាយពីម្តាយទេ នាងនៅជួយហុចនេះ ហុចនោះ ឱ្យម្តាយធ្វើសម្លការីយកទៅវត្តនៅព្រឹកថ្ងៃស្អែក។ **សុភី**សួរម្តាយថា៖ ម៉ែហេតុអ្វីបានជាម៉ែស្លការីឆ្នាំងធំម្ល៉េះ? **ម្តាយ**៖ ថ្ងៃស្អែកនេះជាថ្ងៃទី១៣រោច បិណ្ឌទី១៣ ត្រូវជាវេនរបស់

គ្រួសារយើងធ្វើចង្ហាន់យកទៅប្រគេន ព្រះសង្ឃនៅឯវត្តណាកូន។ **សុភី** ៖ យប់មិញកូនយល់សប្តិឃើញមនុស្សស្គមខ្ពស់ទល់មេឃយំស្រែកថា ឃ្លានណាស់ៗៗ។ **ម្តាយ៖** មនុស្សនោះមានបាប គឺជាប្រេតដែលស្តេចយមរាជដោះលែងឱ្យមកទទួលផលបុណ្យកុសលពីញាតិសន្តានឧទ្ទិសឱ្យ ហើយប្រេតនោះដើរគ្រប់៧វត្ត បើមិនឃើញកូនចៅបងប្អូនណាធ្វើបុណ្យឧទ្ទិសកុសលឱ្យទេ គាត់នឹងដាក់បណ្តាសា។ **សុភី** ៖ ម៉ែ ! កូនឃើញម៉ែធ្វើបុណ្យភ្ជុំបិណ្ឌយូរថ្ងៃម្ល៉េះ? **ម្តាយ៖** ថ្ងៃទី១រោច រហូតដល់ថ្ងៃទី១៤រោច គឺជាពិធីបុណ្យកាន់បិណ្ឌ។ លុះដល់ថ្ងៃ១៥រោច ខែភទ្របទ គេហៅថាពិធីបុណ្យភ្ជុំបិណ្ឌ។ ថ្ងៃនោះហើយដែលយើងគ្រប់គ្នាទោះបីជានៅទណាក៏ដោយ ក៏ត្រូវទៅជួបជុំញាតិសន្តានចាស់ទុំតាមភូមិឋានរៀងៗខ្លួន ដើម្បីនាំយកចង្ហាន់និងទេយ្យទានទៅប្រគេនព្រះសង្ឃឆ្លងបុណ្យនៅឯវត្ត។ ឮដូច្នេះ **សុភី**សប្បាយចិត្តណាស់ គិតថាថ្ងៃស្អែកនេះត្រឡប់មកពីវត្តវិញ ពុកម៉ែនឹងនាំកូនទៅលេងផ្ទះលោកតាលោកយាយ ដើម្បីបានជួបជុំជាមួយបងប្អូនជីដូនមួយជាច្រើននាក់។



## ១៣-រឿងនិទាន ពិធីបុណ្យវិសាខបូជា

បុណ្យវិសាខបូជា ជាពិធីមួយដ៏ធំក្នុងព្រះពុទ្ធសាសនាដែលប្រទេសកម្ពុជាបានចាត់ទុកជាបុណ្យជាតិ។ បុណ្យនេះធ្វើឡើងដើម្បីរំឭកដល់ព្រះពុទ្ធ នៅថ្ងៃពេញបូណ៌មី ថ្ងៃ១៥កើត ខែវិសាខ អ្នកដែលកាន់សាសនាព្រះពុទ្ធ ទាំងព្រះសង្ឃ ទាំងប្រជាពលរដ្ឋ តែងធ្វើពិធីប្រារព្ធបូជាតាំងពីបូរាណកាលមក ដែលមានជំនឿថាជាមហាបុណ្យដ៏ប្រសើរ។ ការប្រារព្ធពិធីបុណ្យវិសាខបូជាគឺដើម្បីរំឭកដល់ព្រឹត្តិការណ៍ដ៏ពិសេសចំនួនបីដែលព្រះពុទ្ធនៃយើង ទ្រង់បានប្រសូត្រ(ចាប់កំណើត) ត្រាស់ដឹង(ត្រាស់ជាព្រះពុទ្ធ) និងចូលបរិនិព្វាន (មរណៈភាព/ស្លាប់) សុទ្ធតែនៅក្នុងថ្ងៃពេញបូណ៌មី ខែវិសាខ ទាំងអស់ខុសប្លែកគ្នាតែឆ្នាំប៉ុណ្ណោះ ។

ជារៀងរាល់ឆ្នាំនៅថ្ងៃ១៥កើត ខែវិសាខ ប្រជាពលរដ្ឋគ្រប់រូបតែងតែប្រារព្ធពិធីបុណ្យវិសាខបូជានៅតាមវត្តអារាមយ៉ាងច្រើនកុះករ ដើម្បីរួមគ្នាបំពេញកុសលផលបុណ្យតាមសទ្ធាជ្រះថ្លានិងសប្បាយរីករាយ។ មហាជនចាស់ ក្មេង ប្រុស ស្រី ប្រជុំគ្នាអ៊ូអរព្រមទាំងនាំមកជាមួយនូវគ្រឿងសក្ការបូជាមានទៀន ធូប ផ្កាភ្ញី ប្រទីបតូច ធំ អុជបំភ្លឺព្រោងព្រាតនៅក្នុងគ្រប់វត្តអារាម ។ ប្រការសំខាន់បំផុតនោះអង្គការសហប្រជាជាតិបានចាត់ទុកពិធីបុណ្យវិសាខបូជា ជាពិធីបុណ្យអន្តរជាតិមួយដែលត្រូវប្រារព្ធឡើងដោយកំណត់កាល

បរិច្ឆេទដូចប្រទេសកម្ពុជាដែរ ។



រូបភាពទី 13៖ ពិធីបុណ្យវិសាខបូជា

## ១៤.ទិវាកុមារអន្តរជាតិ ១មិថុនា

ទិវាកុមារអន្តរជាតិ គេតែងប្រារព្ធធ្វើឡើងនៅថ្ងៃទី១ ខែមិថុនា នៅទូទាំងពិភពលោក ។ គេបង្កើតទិវានេះ ដើម្បីឱ្យកុមារដឹងពីសិទ្ធិសេរីភាពដែលមនុស្សជាតិលើសកលលោក ចងចាំឥតភ្លេចនៅឧក្រិដ្ឋកម្មព្រៃផ្សៃយង់ឃ្នងទៅលើស្ត្រីនិងកុមារនៅក្នុងប្រទេសមួយចំនួនធំ ក្នុងនោះប្រទេសកម្ពុជាក៏បានឆ្លងកាត់មហាវិនាសកម្មប្រល័យពូជសាសន៍ប៉ុលពត ដែលបានកាប់សម្លាប់និងបំផ្លាញអ្វីៗទាំងអស់ខ្ទេចខ្ទីរគ្មានសល់ ក្នុងនោះកុមារជាច្រើនលាននាក់ត្រូវបានស្លាប់ដោយ ការកាប់សម្លាប់ វាយធ្វើបាប បង្អត់អាហារ និងបង្ខំឱ្យធ្វើការហួសកម្លាំង រស់នៅដោយក្តីលំបាកវេទនា ព្រាត់ប្រាស់ឪពុកម្តាយ និងបន្សល់ទុកឱ្យកុមារស្ថិតក្នុងស្ថាភាពដ៏សែនលំបាកយ៉ាងធ្ងន់ធ្ងរ។ វិនាសកម្មទាំងនេះហើយធ្វើឱ្យកងកម្លាំងស្នេហាសន្តិភាព និងមិត្តភាពរវាងប្រជាជាតិ និងមនុស្សគ្រប់ពណ៌សម្បុររួបរួមគ្នាក្រោកឈរឡើងហើយធ្វើការអំពាវនាវ ដើម្បីប្រឆាំងរាល់ទង្វើដែលនាំឱ្យអន្តរាយដល់អាយុជីវិតមនុស្សជាតិ ជាពិសេសគឺដើម្បីការពារជីវិត សន្តិសុខ និងគាំពារដល់កុមារនៅលើផែនដី ហើយបានមូលមតិគ្នាសម្រេចយកថ្ងៃទី១ ខែមិថុនាជារៀងរាល់ឆ្នាំប្រារព្ធពីធី«ទិវាកុមារអន្តរជាតិ»។

ប្រទេសកម្ពុជាយើងក៏ត្រូវបានរាជរដ្ឋាភិបាលអនុញ្ញាតឱ្យគ្រប់ស្ថាប័ន អង្គភាពពាក់ព័ន្ធទាំងអស់រៀបចំប្រារព្ធពិធីទិវាកុមារអន្តរជាតិជារៀងរាល់ឆ្នាំនៅថ្ងៃទី១ ខែមិថុនា ក្នុងគោលបំណងចូលរួមលើកកម្ពស់សិទ្ធទាំងបួនរបស់កុមារគឺ៖ សិទ្ធិរស់រានមានជីវិត សិទ្ធិអភិវឌ្ឍន៍ សិទ្ធិទទួលការការពារ និងសិទ្ធិក្នុងការ

ចូលរួម ជាពិសេសនៅតាមសាលារៀនភាគច្រើនត្រូវបានរៀបចំ ចូលរួម គាំទ្រយ៉ាងច្រើនកុះករពីសំណាក់អាជ្ញាធរដែនដី សហគមន៍ អង្គការពាក់ព័ន្ធ មាតាបិតាឬអ្នកអាណាព្យាបាលរបស់កុមារ ក្នុងនោះមានការរៀបចំកម្មវិធីលេងកំសាន្ត និងផ្តល់រង្វាន់ជាច្រើន ដើម្បីលើកទឹកចិត្តកុមារទាំងអស់ដែលបានចូលរួមសហការលេងសប្បាយរីករាយជាមួយគ្នា ដូចជាការសម្តែងសិល្បៈ ល្បែងប្រឡងប្រណាំងជាដើម៕






រូបភាពទី 14៖ ទិវាកុមារអន្តរជាតិ ១មិថុនា

## ១៥.ពិធីបុណ្យឯករាជ្យជាតិ

ប្រទេសកម្ពុជាយើងបាទទួលឯករាជ្យពេញបរិបូរណ៍ណ៌ ពីការគ្រប់គ្រងរបស់ប្រទេសបារាំងនៅថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ ក្រោមការដឹកនាំតស៊ូ ទាមទារដ៏ស្វិតស្វាញរបស់ សម្តេចព្រះនរោត្តម សីហនុ ដែលជាសម្តេចតា/តាទួតរបស់យើង។ នៅពេលបានទទួលឯករាជ្យ សម្តេចតា/តាទួតបានសរសេរលិខិតផ្លូវការទៅរដ្ឋាភិបាលប្រទេសបារាំងដោយអះអាងថា៖ចាប់ពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ តទៅ កម្ពុជាជាប្រទេសឯករាជ្យមួយមិនស្ថិតនៅក្រោមការដឹកនាំរបស់ប្រទេសណាមួយនោះទៀតឡើយ ហើយប្រទេសកម្ពុជានឹងរាប់អានប្រទេសបារាំងក្នុងឋានៈជាប្រទេសឯករាជ្យដូចគ្នា។

ហេតុនេះហើយនៅថ្ងៃទី០៩ ខែវិច្ឆិកាជារៀងរាល់ឆ្នាំ គ្រប់ខេត្ត-ក្រុងជាពិសេសនៅស្តូបវិមានឯករាជ្យក្នុងរាជធានីភ្នំពេញ បានប្រារព្ធពិធីបុណ្យឯករាជ្យជាផ្លូវការក្រោមព្រះរាជ្យធិបតីភាពរបស់ព្រះមហាក្សត្រនៃប្រទេសកម្ពុជា ថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រីជាច្រើននៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងព្រះសង្ឃ មហាជនគ្រប់លំដាប់ថ្នាក់ បានមកជួបជុំគ្នាយ៉ាងច្រើនកុះករប្រកបដោយទឹកមុខរីករាយ និងមានមោទកភាពក្រៃលែង។

មុនពិធីប្រារព្ធទិវាបុណ្យឯករាជ្យជាតិ មានការរៀបចំតុបតែងលម្អវិមានឯករាជ្យដោយដាក់ភ្លើងចម្រុះពណ៌បំភ្លឺនៅពេលយប់ រីឯសួនច្បារនានាមានការតុបតែងលម្អអគ្គិសនី កម្រងផ្កាភ្ញី...។ នៅពេលព្រឹកថ្ងៃទីមួយព្រះមហាក្សត្រនៃប្រទេសកម្ពុជារបស់យើង បានយាងដុតទៀនជ័យ និងពេលក្រោយប្រារព្ធពិធីចប់មានការបង្ហោះប៉េងប៉ោងចម្រុះពណ៌ លែងសត្វព្រាប និងមានការដុតកាំជ្រួចអបអរសាទរនៅពេលយប់ៗផងដែរ។ ការរក្សាតម្កល់ទុកភ្លើងទៀនជ័យនេះមានរយៈពេលបីថ្ងៃ។ នៅថ្ងៃបញ្ចប់ប្រារព្ធពិធីចុងក្រោយ មានការជួបជុំថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រីជាច្រើន នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងព្រះសង្ឃមហាជនគ្រប់លំដាប់ថ្នាក់យ៉ាងច្រើនកុះករម្តងទៀត ដើម្បីរៀបចំពិធីពន្លត់ភ្លើងទៀនជ័យដោយព្រះមហាក្សត្រនៃប្រទេសកម្ពុជាយើង។



រូបភាពទី 15៖ ពិធីបុណ្យឯករាជ្យជាតិ

## ១៦.សង្កេត « ទង់ជាតិកម្ពុជា »



រូបភាពទី 16៖ ទងជាតិកម្ពុជា

- **អត្ថសញ្ញាណនៃទង់ជាតិកម្ពុជា**( គប្បីសង្ខេបខ្លី ងាយយល់ សម្រាប់ការពន្យល់កុមារ )

  - *ផ្នែកខាងលើ និងខាងក្រោម៖* ពណ៌ខៀវតំណាងសាមគ្គីភាព ភាតរភាព មេត្តា ករុណា សន្តិភាព អហិង្សាស្ថិតនៅក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះមហាក្សត្រ តំណាងឱ្យធម្មជាតិត្រជាក់ត្រជុំស្រប់ព្រង

  - *ផ្នែកកណ្តាល៖* ពណ៌ក្រហមតំណាងឱ្យស្មារតីអង់អាច ក្លាហានពុះពារគ្រប់ឧបសគ្គ ពលិកម្មសព្វបែបបែបយ៉ាងដើម្បីទឹកដី

  - *រូបប្រាសាទអង្គរវត្ត៖* ពណ៌ស តំណាងធរិយធម៌ខ្មែររុងរឿង នាសម័យមហានគរ និងតំណាងសាសនា សីលធម៌ ចរិយាធម៌

## ១៧.សន្ទនា « ឧបករណ៍តន្ត្រីខ្មែរ »




រូបភាពទី 17៖ ឧបករណ៍តន្ត្រីខ្មែរ

## ១៨.ល្បែងជម្រាបសួរ



## ១៩.កំណាព្យ

### អូនវង្វេងផ្លូវតែក្លាហាន

(លំនាំបទកាកគតិ)

អូនវង្វេងផ្លូវ តែអូនមិនត្រូវ ស្រែកយំភិតភ័យ
តាំងចិត្តឈ្លាសវៃ រិះគិតលកលៃ រកអ្នកប្រពៃ
ជូនអូនទៅផ្ទះ ។

ខ្លួនអូនតូចពិត តែមានគំនិត លើកដៃសំពះ
ប្រាប់ឈ្មោះហូរហែរ ពុកម៉ែជាព្រះ ទូរស័ព្ទលេខផ្ទះ
អូនបានចងចាំ។

## ២០.ចម្រៀង

### សម្លៀកបំពាក់សមសួន

(លំនាំបទយីកេ)

កូនប្រុសស្រីស្លៀកពាក់ឱ្យសមសួន
ទៅរៀនស្លៀកខៀវអើយសប្រពៃ
ឈុតហូលផាមួងស្រស់ឆើតបវរ
កូនស្លៀកពាក់អើយត្រូវក្បួនតម្រា

អើៗអ៊ើងអើយទើបកូននឹមនួនអើយមានសិរី
ស្លៀកពាក់ល្អក្រៃសមជាសិស្សល្អ។
អើៗអ៊ើងអើយជាកេរតំណអើយពីដូនតា
កូនបានរក្សាប្រពៃណីខ្មែរ។
អើៗៗៗអ៊ើងអើយ។



## ផ្នែកទី២
## ការអនុវត្តសកម្មភាពគោលសម្រាប់ដំណើរការបង្រៀន និងរៀនពេញមួយម៉ោងសិក្សា

### ១.តារាងសកម្មភាពប្រចាំថ្ងៃ

ឧទាហរណ៍១.តារាងវត្តមានកុមារ

១.១.អត្ថបទ

| តារាងវត្តមានកុមារ | | |
|---|---|---|
| ក្រុមទី១ | ក្រុមទី២ | ក្រុមទី៣ |
| រូបថត គឹម មុន្នីលាភ | រូបថត ចន្ទ លីនីត | រូបថត លី យសវឌ្ឍ |
| រូបថត លី មាន | រូបថត ឃុន រ៉ាឌីន | រូបថត ហ៊ាប លី |
| | | |
| | | |
| | | |
| រូបថត បូណា វិជ្ជា |  ស៊ី រ៉េត ០១២ ១១១ ១០២ |  ស៊ីន វ៉េនី ០១១ ១២៩ ១០៩ |

បណ្ណផ្នែកខាងមុខ

| |
|---|
| រូបថត ប៊ូ រ៉ាវី |

បណ្ណផ្នែកខាងខ្នង

| |
|---|
|  ប៊ូ រ៉ាវី ០១២ ២២២ ២១៥ |

- តារាងវត្តមានកុមារនេះ គ្រូអាចផលិតដោយបន្ទះប្លាស្ទិច និងក្រដាសកាតុង ឬកំណាត់ ដើម្បីប្រើការបានយូរដែលមានថតបែបជាហោប៉ៅស៊ើកបណ្ណឈ្មោះកុមារ។គ្រូអាចច្នៃប្រឌិតតារាងវត្តមានកុមារនេះឱ្យមានលក្ខណៈទាក់ទាញឱ្យកុមារងាយយល់ ងាយប្រើប្រាស់ឱ្យទៅជាទម្លាប់ និងជាប្រយោជន៍ដល់គ្រូក្នុងការត្រួតពិនិត្យវត្តមានកុមារផងដែរ។
- បណ្ណផ្នែកខាងមុខមានរូបថតកុមារ និងឈ្មោះ ឯបណ្ណផ្នែកខាងខ្នងមានរូបភាពដែលកុមារជ្រើសរើសដោយខ្លួនឯងងាយស្រួលចំណាំ មានឈ្មោះ និងលេខទូរស័ព្ទសម្រាប់ទំនាក់ទំនងនៅពេលកុមារមានបញ្ហា។

### ១.២.ដំណើរការអនុវត្តតារាង

- បំផុសកុមារឱ្យត្រឡប់បណ្ណផ្នែកខាងខ្នងមកបណ្ណផ្នែកខាងមុខវិញ។ គ្រូទម្លាប់កុមារឱ្យអនុវត្តនៅពេលមកដល់ថ្នាក់ភ្លាមមុនពេលចូលរៀន និងទុកដាក់សម្ភារៈតាមកន្លែងផ្ទាល់ខ្លួន ដែលមានសញ្ញាសម្គាល់ដូចក្នុងបណ្ណផ្នែកខាងខ្នង
- កុមាររាយការណ៍ពីអវត្តមានក្នុងក្រុមតាមបណ្ណឈ្មោះផ្នែកខាងខ្នង

- ណែនាំអប់រំកុមារអំពីការសុំអនុញ្ញាតច្បាប់ឈប់ ពីទម្លាប់ត្រឡប់ប្តូរបណ្ណឈ្មោះពីផ្នែកខាងមុខ មកផ្នែកខាងខ្នងវិញពេលត្រៀមរៀបចំទៅផ្ទះ
- សម្រង់អវត្តមានពីបណ្ណឈ្មោះផ្នែកខាងខ្នងដាក់ក្នុងបញ្ជីហៅឈ្មោះកុមារ។

**ឧទាហរណ៍២.តារាងថ្ងៃប្រចាំសប្តាហ៍**




រូបភាពទី 18៖ តារាងថ្ងៃប្រចាំសប្តាហ៍

**២.១.អត្ថបទ**

- ប្រអប់នៅលើក្បាលរទេះភ្លើងសម្រាប់ដាក់បណ្ណអាកាសធាតុ
- ប្រអប់នៅលើទូរទេះភ្លើងថ្ងៃអាទិត្យសម្រាប់ដាក់បណ្ណរូបផ្ទះ និងបណ្ណអានសៀវភៅសម្រាប់សម្គាល់ថ្ងៃរៀន
- ទូរទេះភ្លើងនីមួយៗដាក់តាមពណ៌សម្លៀកបំពាក់នៃក្បួនតម្រាជូនតាតាមថ្ងៃចន្ទគតិ និងមាន២ថត គឺថតលើសម្រាប់ដាក់បណ្ណអាកាសធាតុ និងថតក្រោមសម្រាប់ដាក់បណ្ណទៅរៀន ឬបណ្ណសម្រាកនៅផ្ទះ។

**២ដំណើរការបង្រៀន.២.**

- បំផុសកុមារឱ្យរាប់ឈ្មោះថ្ងៃក្នុង១សប្តាហ៍
- កុមារប្រាប់ឈ្មោះថ្ងៃដែលត្រូវមករៀន និងថ្ងៃឈប់សម្រាកជាប្រចាំ
- កុមារស្មគ្រចិត្តម្នាក់ប្រាប់ឈ្មោះថ្ងៃនេះ និងយកបណ្ណសម្គាល់ថ្ងៃរៀនមកដាក់នៅក្នុងថតទូរទេះភ្លើង
- កុមារម្នាក់ទៀតយកបណ្ណអាកាសធាតុមកដាក់នៅផ្នែកខាងលើនៃទូរទេះភ្លើង
- កុមាររៀបរាប់សកម្មភាពនៅថ្ងៃម្សិលមិញ ថ្ងៃនេះ ថ្ងៃស្អែក និងប៉ាន់ស្មានអាកាសធាតុសម្រាប់ថ្ងៃស្អែក។ ប្រសិនបើ
- ថ្ងៃស្អែកចំលើថ្ងៃឈប់សម្រាក គ្រូនាំកុមារដាក់បណ្ណរូបផ្ទះជាមុន ឬដាក់នៅថ្ងៃចូលរៀនវិញ អាស្រ័យតាមសិល្បវិធី
- បូកសរុប និងវាយតម្លៃ។

## ឧទាហរណ៍៣.តារាងប្រតិទិនប្រចាំខែ

### ៣.១.អត្ថបទ

| តារាងប្រតិទិនប្រចាំខែ | | | | | | |
|---|---|---|---|---|---|---|
| | មករា | | | | ២០២១ | |
| ចន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ | សៅរ៍ | អាទិត្យ |
| | | | | ១ | ២ | ៣ |
| ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ |
| ១១ | | | | | | |
| | | | | | | |
| | | | | | | ៣១ |

| បណ្ណលេខផ្នែកខាងមុខ | បណ្ណលេខផ្នែកខាងខ្នង |
|---|---|
| ១១ | ១១ |

- តារាងប្រតិទិនប្រចាំខែ ឬប្រតិទិនសិក្សានេះ អាចផលិតដោយប្លាស្ទិចស និងក្រដាសកាតុង ឬកំណាត់
- ថតនីមួយៗ គឺជាហោប៉ៅសម្រាប់កុមារស៊កបណ្ណលេខជារៀងរាល់ថ្ងៃ
- បណ្ណលេខនីមួយៗមាន២ផ្នែក គឺផ្នែកខាងមុខពណ៌ស បញ្ជាក់ថាជាថ្ងៃរៀន និងផ្នែកខាងខ្នងពណ៌ក្រហម បញ្ជាក់
- ថាជាថ្ងៃឈប់សម្រាក។ហោប៉ៅចុងក្រោយដែលមានបណ្ណលេខក្រហម សម្រាប់ដាក់បណ្ណលេខទាំងអស់
- នាំកុមារអានកាលបរិច្ឆេទដោយចាប់ផ្តើមពីថ្ងៃ ខែ ឆ្នាំ )ឧទាហរណ៍៖ថ្ងៃចន្ទ ទី១១ ខែមករា ឆ្នាំ២០២១(

### ៣.២.ដំណើរការបង្រៀន

- បំផុសកុមារឱ្យយកបណ្ណលេខសម្រាប់ថ្ងៃនេះ មកដាក់ក្នុងហោប៉ៅជួរថ្ងៃចន្ទ
- កុមារប្រាប់ឈ្មោះបណ្ណលេខថ្ងៃម្សិលមិញ និងថ្ងៃនេះ
- កុមារអានកាលបរិច្ឆេទថ្ងៃនេះ ថ្ងៃ ចន្ទ ទី១១ ខែ មករា ឆ្នាំ ២០២១ ។

## ២.ការអនុវត្តល្បែងសិក្សា

ក្នុងជំហានទី២ នៃកិច្ចតែងការបង្រៀន (ត្រួតពិនិត្យមេរៀនចាស់) គ្រូមត្តេយ្យសិក្សាអាចចោទជាសំណួរព្រំវ៉ូក ឬដាក់លំហាត់ឱ្យកុមារធ្វើតាមរយៈល្បែងច្នៃប្រឌិតខ្លីៗមានរយៈពេល២ទៅ៣នាទី។

ឧទាហរណ៍១៖ ល្បែង « រៀបចំសម្លៀកបំពាក់ឱ្យត្រូវកម្មវិធី » រំឭកការលើកតម្កើងវប្បធម៌

ឱ្យកុមារស្ម័គ្រចិត្ត៤នាក់ ដោយម្នាក់ៗជ្រើសរើសសម្លៀកបំពាក់១ឈុតឱ្យត្រូវគ្នាមកបិទលើក្តារខៀន រួចប្រាប់ថា៖ សម្លៀកបំពាក់នេះ ស្លៀកពាក់សម្រាប់កម្មវិធីបុណ្យ ឬទៅសាលារៀន ហាត់កីឡា ឬដើរកំសាន្ត។

ឧទាហរណ៍២៖ ល្បែង រំឭក « ចំណាំឈ្មោះខ្ញុំ »អត្តសញ្ញាណរបស់ខ្លួន

ឧទាហរណ៍៣៖ ល្បែងរំឭក « សកម្មភាពប្រចាំថ្ងៃរបស់ខ្ញុំ »បំណិនរស់នៅក្នុងសង្គមនិងទំនាក់ទំនងវិជ្ជមានជាមួយមនុស្សជុំវិញ។

**ល្បែង ណែនាំខ្លួន**

- របៀបលេង
- ឱ្យកុមារចាប់ដៃគូ២នាក់ៗ
- ឱ្យកុមារប្រាប់ឈ្មោះនិងពត៌មានផ្ទាល់ខ្លួនដល់គ្នាទៅវិញទៅមក
- ឱ្យកុមារអនុវត្តដូចខាងលើដោយផ្លាស់ប្តូរដៃគូ
- ឱ្យកុមារនិយាយប្រាប់ពីពត៌មានរបស់មិត្តភក្តិដែលបាននិយាយជាមួយគ្នាអាស្រ័យទៅតាមពេលវេលា។

**ល្បែងចំណាំឈ្មោះខ្លួនឯង**

- របៀបលេង
- ឱ្យកុមារអង្គុយជារាងពាក់កណ្តាលរង្វង់
- ឱ្យកុមារប្រាប់ឈ្មោះរបស់ខ្លួនម្តងម្នាក់ៗ
- កុមារដទៃត្រូវចំណាំឈ្មោះមិត្តភក្តិ
- ហៅកុមារម្នាក់ក្រោកឈរ ហើយនិយាយថា ៖ ខ្ញុំឈ្មោះអ្វី?
- កុមារដទៃទៀតប្រាប់ឈ្មោះ(ប្រាប់ជាបុគ្គលឬក្រុមធំ)
- នាំកុមារលេងរបៀបនេះឱ្យបានច្រើននាក់ អាស្រ័យតាមពេលវេលាជាក់ស្តែង

**ល្បែង ការងារប្រចាំថ្ងៃ**

- របៀបលេង
- ឱ្យកុមារចាប់ដៃគូ២នាក់ៗ
- ឱ្យកុមារប្រាប់ឈ្មោះនិងការងារផ្ទាល់ខ្លួនដល់គ្នាទៅវិញទៅមក
- ឱ្យកុមារអនុវត្តដូចខាងលើដោយផ្លាស់ប្តូរដៃគូ
- ឱ្យកុមារនិយាយប្រាប់ពីពត៌មានរបស់មិត្តភក្តិដែលបាននិយាយជាមួយគ្នា អាស្រ័យទៅតាមពេលវេលា
- ការងារផ្ទាល់ខ្លួនមានដូចជា ការឱ្យចំណីសត្វ ស្រោចដំណាំ បោសសំអាត ការងារផ្ទះបាយ ជាដើម។

**ល្បែង « ទាយអារម្មណ៍របស់ខ្ញុំ »**

- របៀបលេង
- ចែកកុមារក្នុងថ្នាក់ជា២ក្រុម ដោយមានការផ្លាស់ប្តូរវេនគ្នាម្តង១ក្រុមសម្តែង ម្តង១ក្រុមទាយ
- តំណាងក្រុមទាំងមករើសយកបណ្ណម្នាក់១
- ក្រុមនីមួយៗពិនិត្យបណ្ណ រួចពិភាក្សាក្នុងក្រុម រិះរកសកម្មភាពទឹកមុខសម្តែងអារម្មណ៍តាមបណ្ណនោះ ដើម្បីឱ្យក្រុមម្ខាងទៀតទាយ
- តំណាងក្រុមម្នាក់សម្តែងទឹកមុខឱ្យក្រុមម្ខាងទៀតទាយ រួចផ្ទៀងផ្ទាត់ចម្លើយជាមួយនឹងបណ្ណ ទឹកមុខ។ អនុវត្តបែបនេះ ដោយការផ្លាស់ប្តូរវេនគ្នា ។ ក្រុមណាសម្តែងទឹកមុខខុសពីបណ្ណ ឬទាយខុសត្រូវដកសមាជិកម្នាក់មកខាងក្រុមទាយត្រូវ។ បន្តការលេងរបៀបនេះរហូតដល់អស់បណ្ណអារម្មណ៍
- ក្រុមណាមានសមាជិកច្រើនជាង គឺក្រុមនោះឈ្នះច្រៀងឱ្យក្រុមចាញ់រាំ។

| | | | |
|---|---|---|---|
|  |  |  |  |
| សើច | ញញឹម | ខឹង | ភ័យខ្លាច |
|  |  |  |  |
| យំ | ព្រួយចិត្ត | ភ្ញាក់ផ្អើល | ឆ្ងល់កំពុងគិតអ្វីមួយ |

រូបភាពទី 19៖ ល្បែង ទាយអារម្មណ៍របស់ខ្ញុំ

## យើងចេះគួរសម

➢ **របៀបលេង ៖**

- ឱ្យកុមារច្រៀង និងដើរជារង្វង់
- និយាយថា៖ រត់រកដៃគូ។ កុមារត្រូវរត់រកដៃគូណាម្នាក់ដែលខ្លួនចូលចិត្ត
- និយាយថា៖ពេលជួបគ្នា។ ឱ្យកុមារលើកដៃសំពះគ្នាទៅវិញទៅមកដោយនិយាយថា៖ជម្រាបសួរ
- និយាយថា៖ពេលបែកគ្នា។ ឱ្យកុមារលើកដៃសំពះគ្នាទៅវិញទៅមកដោយនិយាយថា៖ ជម្រាបលា។ ពេលដើរចេញពីគ្នាកុមារត្រូវរត់រកចាប់ដៃគូផ្សេងទៀត
- និយាយថា៖ពេលជួបគ្នា។ ឱ្យកុមារសួរសុខទុក្ខគ្នាទៅវិញទៅមកដោយសួរសំណួរ៖
    - អ្នកទី១ សួរ ៖ តើអ្នកសុខសប្បាយជាទេ ?
    - អ្នកទី២ ឆ្លើយ ៖ ខ្ញុំសុខសប្បាយជាទេ។ អរគុណ!
    - អ្នកទី២ សួរ ៖ ចុះអ្នកវិញ តើសុខសប្បាយជាទេ ?
    - អ្នកទី១ ឆ្លើយ ៖ ខ្ញុំក៏សុខសប្បាយដូចអ្នកដែរ។ អរគុណ!
- នាំកុមារលេងរបៀបទាំងពីរនេះសាជាថ្មីអាស្រ័យតាមពេលវេលា។

## បកជំឡូងក្ដៅបង្ហាញពីអារម្មណ៍

➢ **របៀបលេង ៖**

- គូររូបមុខមនុស្ស ឬបិទរូបមុខមនុស្សបញ្ជាក់ពីអារម្មណ៍លើក្រដាស ១អារម្មណ៍ ១សន្លឹក

- ខ្ទប់សន្លឹកក្រដាសដែលបញ្ជាក់ពីអារម្មណ៍ម្តងមួយៗ ត្រួតពីលើគ្នា បង្កើតឱ្យបានជាដុំក្រដាសមួយមានច្រើនស្រទាប់ ដែលគេហៅថា ដំឡូងក្តៅ
- ឱ្យកុមារទាំងអស់ឈរជារង្វង់
- ហុចដំឡូងក្តៅទៅកុមារម្នាក់ រួចឱ្យហុចបន្តគ្នាពីម្នាក់ទៅម្នាក់ និងច្រៀងបណ្តើរ
- ពេលគ្រូឱ្យសញ្ញាបញ្ឈប់ កុមារឈប់ហុច អ្នកដែលមានដំឡូងក្តៅកាន់នៅដៃ ត្រូវបកស្រទាប់ក្រដាសដែលនៅពីលើគេយកមកមើល ឃើញរូបអ្វីត្រូវធ្វើកាយវិការ ទឹកមុខ តាមរូបដែលបានឃើញនោះ ហើយកុមារដទៃទៀតសង្កេតរួចប្រាប់ពីអារម្មណ៍ដែលមិត្តភក្តិបានបង្ហាញ
- កុមារលេងរបៀបនេះរហូតដល់សន្លឹកស្រទាប់ចុងក្រោយ។
- **បញ្ជាក់ ៖** ក្នុងពេលកំពុងលេង គ្រូត្រូវបញ្ឈប់មិនឱ្យចំអ្នកដែលបកសំបកដំឡូងក្តៅរួចហើយនោះទេ។ ល្បែងដំឡូងក្តៅនេះ អាចលេងជាមួយខ្លឹមសារផ្សេងៗទៀតបាន។

## ទាយពីអារម្មណ៍របស់ខ្ញុំ

- **របៀបលេង ៖**
- ចែកកុមារក្នុងថ្នាក់ជា ២ក្រុម (១ក្រុមសម្តែង ១ក្រុមទាយ)
- ណែនាំកុមារពីរបៀបលេង៖ តំណាងក្រុមសម្តែងម្នាក់ ត្រូវឡើងមកចាប់យកប័ណ្ណអារម្មណ៍មួយមើលរួចលាក់ទុក បន្ទាប់មកពិភាក្សាក្នុងក្រុមរកសកម្មភាពសម្តែងអារម្មណ៍តាមប័ណ្ណនោះសម្រាប់ក្រុមម្ខាង ទៀតទាយ។
- តំណាងក្រុមចាប់ផ្តើមអនុវត្តសកម្មភាពសម្តែងអារម្មណ៍ឱ្យក្រុមម្ខាងទៀតទាយ
- អ្នកសម្តែងអារម្មណ៍ប្រាប់ចម្លើយត្រឹមត្រូវ ដោយលើកបង្ហាញប័ណ្ណអារម្មណ៍ដែលខ្លួនបានលាក់ទុកនោះ
- បន្តការលេងដោយប្តូរវេនឱ្យតំណាងក្រុមផ្សេងទៀតធ្វើសកម្មភាពដូចខាងលើ។

## មុខគួរឱ្យចង់សើច

- **របៀបលេង ៖**
- ឱ្យកុមារ ២នាក់ ក្នុង១ក្រុម មកឈរទល់មុខគ្នាពីមុខមិត្តភក្តិទាំងអស់(៣ក្រុម ស្មើនឹង ៦នាក់)
- ណែនាំពីរបៀបលេង ៖
    - ឱ្យកុមារឈរទល់មុខគ្នាជាមួយដៃគូ
    - ប្រាប់កុមារម្នាក់ឱ្យសម្តែងទឹកមុខបង្ហាញពីអារម្មណ៍អ្វីមួយ (សប្បាយ ខឹង យំ...)
    - ឱ្យដៃគូម្ខាងទៀតប្រាប់ពីទឹកមុខនោះ
    - កុមារទាំង ២នាក់ សម្តែងទឹកមុខដោយផ្លាស់វេនគ្នា
    - នាំកុមារទាំងអស់ច្រៀងទល់មុខគ្នានូវចម្រៀង «អូ ឡា ឡា ឆ្លុះកញ្ចក់ រ៉ូមរ៉ាក់អឺ!»
- ហៅកុមារ ២នាក់ ឱ្យនិយាយពីអារម្មណ៍ដែលបានសម្តែងម្នាក់ម្តង។
- បញ្ជាក់ ៖ បើមានពេលត្រូវផ្លាស់ប្តូរក្រុមធ្វើយ៉ាងណាឱ្យកុមារបានលេងគ្រប់ៗគ្នា។

## ទាយអារម្មណ៍តាមរូបភាព

- **របៀបលេង ៖**
- កុមារអង្គុយជារាងពាក់កណ្តាលរង្វង់

- ដាក់ផ្កាប់ប័ណ្ណរូបភាពអារម្មណ៍នៅលើតុពីមុខកុមារ
- ហៅកុមារម្នាក់ឡើងមកបើកប័ណ្ណរូបភាពអារម្មណ៍ ១សន្លឹកមើល រួចសម្តែងអារម្មណ៍តាមរូបភាពនៅក្នុងប័ណ្ណ
- កុមារដទៃទៀតសង្កេត រួចប្រាប់ពីឈ្មោះអារម្មណ៍
- កុមារដែលសម្តែងលើកប័ណ្ណអារម្មណ៍បង្ហាញ ហើយកុមារដទៃទៀតផ្ទៀងផ្ទាត់
- បន្ទាប់មកកុមារដែលបានសម្តែងត្រូវហៅកុមារណាម្នាក់ទៀតតាមការពេញចិត្តរបស់ខ្លួនឡើងមកសម្តែងអារម្មណ៍ឱ្យកុមារដទៃទៀតទាយវិញម្តង
- អនុវត្តរបៀបនេះរហូតដល់អស់ប័ណ្ណអារម្មណ៍។

## ស្វាមើលឃើញ ស្វាធ្វើតាម

➢ **របៀបលេង ៖**

- ឱ្យកុមារចាប់ដៃគូ និងអង្គុយទល់មុខគ្នាដោយម្នាក់ធ្វើជាមេដឹកនាំ និងម្នាក់ទៀតធ្វើជាស្វា។ ស្វាត្រូវត្រាប់តាមមេដឹកនាំ រួចប្តូរតួនាទីដោយឆ្លាស់វេនគ្នា។
- ឱ្យមេដឹកនាំធ្វើចលនារាងកាយតាមចំណង់ចំណូលចិត្តនិងប្រាប់អ្នកដែលធ្វើស្វាឱ្យសង្កេតមើលដោយប្រុងប្រយ័ត្ន ហើយព្យាយាមធ្វើតាមចលនារបស់មេដឹកនាំឱ្យដូចបេះបិទ
- កុមារអនុវត្តបាន ២នាទី ទៅ៣នាទី គ្រូឱ្យកុមារផ្លាស់ប្តូរតួនាទីដោយអ្នកដែលធ្វើជាមេដឹកនាំមកធ្វើជាស្វាវិញ និងអ្នកដែលធ្វើជាស្វាមកធ្វើជាមេដឹកនាំវិញម្តង។

## ស្គាល់ធម្មជាតិរបស់អ្នក

➢ **របៀបលេង៖**

- បំផុសកុមារឱ្យចាប់អារម្មណ៍ពីធម្មជាតិ
- អប់រំណែនាំអំពីសុវត្ថិភាព វិន័យ និងសណ្តាប់ធ្នាប់នៅពេលធ្វើដំណើរ
- ប្រាប់ពីកិច្ចការដែលកុមារត្រូវធ្វើ ដូចជារើសវត្ថុដែលពេញចិត្ត និងស្អាតដាក់ចូលក្នុងថង់
- នាំកុមារដើរមើលក្នុងធម្មជាតិនៅបរិវេណក្នុង ឬក្រៅសាលា ឬសួនធម្មជាតិ ឬក្នុងសហគមន៍ ឬតាមសមុទ្រ...
- នៅពេលធ្វើដំណើរ និងពេលទៅដល់កន្លែងមានម្លប់ឱ្យកុមារសម្រាក និងនាំកុមារ ៖
    - ស្តាប់សូរសំឡេងដែលកើតឡើងពីធម្មជាតិ រួចឱ្យកុមារប្រាប់ឈ្មោះសំឡេងនោះ
    - ពិសោធជាមួយធម្មជាតិដោយការដកដង្ហើមស្រូបយកខ្យល់ធម្មជាតិ ការប៉ះ ស្ទាប ហិត រួចឱ្យកុមារបញ្ជាក់មកវិញនូវភាពរលោង គគ្រាតគគ្រើម ក្រអូប...
    - សង្កេតស្តាប់សូរសំឡេងដែលកើតឡើងពីធម្មជាតិ រួចឱ្យកុមារប្រាប់ឈ្មោះសំឡេងនោះ
    - ពិសោធជាមួយធម្មជាតិដោយការដកដង្ហើមស្រូបយកខ្យល់ធម្មជាតិ ការប៉ះ ស្ទាប ហិត រួចឱ្យកុមារបញ្ជាក់មកវិញនូវភាពរលោង គគ្រាតគគ្រើម ក្រអូប...
- នៅពេលត្រឡប់វិញគ្រូឱ្យកុមារបង្ហាញអំពីសម្ភារៈដែលរើសបាន រួចឱ្យកុមាររៀបសម្ភារៈទាំងនោះដាក់តាមក្រុម បន្ទាប់មកឱ្យកុមារចាប់ដៃគូការងារផ្គុំសម្ភារៈទាំងនោះជារាងផ្សេងៗ តាមគំនិតច្នៃប្រឌិត
- ឱ្យកុមារបង្ហាញ និងរៀបរាប់អំពីស្នាដៃរបស់ក្រុម។

## ស្តេចចង់

➢ **របៀបលេង ៖**

- បែកកុមារជា ២ក្រុម ដែលមានចំនួនកុមារស្មើគ្នា
- ឱ្យកុមារទាំង ២ក្រុម ឈរជាជួរបណ្តោយទល់មុខគ្នា ដែលមានចម្ងាយ ៥ម៉ែត្រ
- ចាត់កុមារ ១នាក់ អង្គុយចំកណ្តាលទីធ្វើជាស្តេច
- ស្តេចឱ្យសមាជិកក្រុមទី១ ម្នាក់ឡើងមកខ្សឹប ដោយនិយាយថា៖ ខ្ញុំចូលចិត្ត/ស្រឡាញ់...(ឈ្មោះអ្នកណាម្នាក់នៅក្នុងក្រុមទី២ រួចត្រឡប់មកកន្លែងដើមវិញ)
- ហៅកុមារក្នុងក្រុមទី២ ណាម្នាក់ឡើងមកខ្សឹបវិញម្តង ដោយនិយាយថា៖ ខ្ញុំចូលចិត្ត/ស្រឡាញ់... (ឈ្មោះអ្នកណាម្នាក់នៅក្នុងក្រុមទី១) រួចឱ្យត្រឡប់ទៅកន្លែងដើមវិញ
- ប្រសិនបើក្រុមណាមួយឡើងមកខ្សឹបប្រាប់ស្តេចថាស្រឡាញ់ និងចូលចិត្តអ្នកណាម្នាក់ក្នុងក្រុមម្ខាងទៀត ហើយអ្នកដែលចំឈ្មោះនៅក្នុងក្រុមម្ខាងទៀតនោះឡើងទៅជួបស្តេចក្រុមនោះត្រូវចាញ់។ អ្នកចាញ់ត្រូវមកនៅក្នុងក្រុមអ្នកឈ្នះ
- លេងរបៀបនេះរហូតដល់ក្រុមណាមួយអស់កុមារពីក្នុងក្រុម។

## ព្រះអាទិត្យរះលើ

➢ **របៀបលេង ៖**

- ឱ្យកុមារអង្គុយជារង្វង់ធំបែរមុខចូលគ្នា និងមានកុមារម្នាក់ឈរចំកណ្តាលរង្វង់
- កុមារនៅកណ្តាលរង្វង់សម្គាល់លក្ខណៈនៃសម្លៀកបំពាក់ ស្បែកជើង និងរូបរាងរបស់ខ្លួន ដើម្បីស្រែករកអ្នកដែលមានលក្ខណៈដូចខ្លួន
- កុមារនៅកណ្តាលរង្វង់ស្រែកថា ៖ ព្រះអាទិត្យរះលើអ្នកពាក់អាវដៃខ្លី
- កុមារទាំងឡាយណាដែលពាក់អាវដៃខ្លីងើបឈរឡើង ហើយប្តូរកន្លែងគ្នារួចអង្គុយចុះ ឯអ្នកនៅកណ្តាលក៏រត់ទៅដណ្តើមកន្លែងមួយដែលគេកំពុងរត់ចេញ
- ក្រោយការប្តូរកន្លែងនឹងនៅសល់កុមារម្នាក់ដែលនឹងត្រូវឈរចំកណ្តាលរង្វង់
- កុមារនៅកណ្តាលស្រែកថា៖ ព្រះអាទិត្យរះលើអ្នកស្លៀកខោវែង /ដែលមានសក់ខ្លី...(ដូចលក្ខណៈឬអ្វីៗ ដែលខ្លួនមាន)
- សកម្មភាពខាងលើអនុវត្តសារជាថ្មី។

**របៀបលេង៖**

កុមារនៅក្នុងក្រុមនីមួយៗឈរបន្តគ្នាជាជួរ នៅពេលគ្រូឱ្យសញ្ញា កុមារដែលកាន់បាល់ឈរនៅមុខគេ និងហុចបាល់បន្តឱ្យទៅកុមារនៅពីក្រោយបន្ទាប់នោះ ដោយយោលទៅតាមការដាក់លក្ខខ័ណ្ឌចំពោះក្រុមទាំងបីនេះ អាចហុចពីលើក្បាលឬពីក្រោមចន្លោះជើងទាំង២ឬហុចចំហៀងខាងស្តាំ ខាងឆ្វេង បាល់មិនត្រូវឱ្យប៉ះដីឡើយ ហើយត្រូវហុចបន្តពីដៃកុមារម្នាក់ទៅកុមារម្នាក់ទៀតយ៉ាងរហ័ស។

❖ ធ្វើរបៀបនេះរហូតដល់ក្រុមដែលបានហុចចប់មុនគេគឺជាអ្នកឈ្នះ។

**ល្បែង៖ ក្រពើដេញចាប់**

ការរៀបចំលេង៖ គូសខ្សែគំនូសពីរស្របគ្នា(ចម្ងាយពី៤ឬ៥ម៉ែត្រ) កំណត់បានជាស្ទឹងមួយដែលកុមារទាំងឡាយត្រូវឆ្លងកាត់ ហើយដែលជាកន្លែងសម្រាប់អ្នកធ្វើក្រពើត្រូវនៅ។

**របៀបលេង៖** ឱ្យកុមារប៉ាវ កុមារណាចាញ់គេត្រូវធ្វើជាក្រពើ។ ឱ្យកុមារឈរសងខាងត្រើយនៃស្ទឹង កុមារទាំងឡាយរត់ឆ្លងស្ទឹង ទៅវិញទៅមកទៅតាមចំណង់«ដំបូងកុមារម្នាក់គត់ធ្វើក្រពើ» នៅរាល់លើកក្រពើចាប់បានកុមារណាម្នាក់នោះត្រូវចាប់ដៃជាមួយក្រពើហើយក្លាយជាក្រពើដោយកាន់ដៃក្រពើទី១ ឱ្យជាប់បើសិនរបូតដៃចេញពីគ្នា មិនអាចចេញចាប់កុមារនោះបានឡើយត្រូវឱ្យកុមារនោះរួចខ្លួន។

❖ បញ្ជាក់៖ នៅពេលដែលក្រពើមានគ្នា៣នាក់រួចទៅហើយអ្នកចាប់បានក្រោយៗមកទៀតបង្កើតបានជាក្រពើមួយទៀតពីម្នាក់ ពីរនាក់ឬបីនាក់។ ពីពេលនោះមកបង្កើតបានជាក្រពើទីបី មួយទៀត។

## ល្បែង៖ ជិះសេះបោះបាល់

**ការរៀបចំលេង៖** បាល់លេងនៅខាងក្រៅថ្នាក់ កុមារពាក់កណ្ដាលឈរជារង្វង់មូលធ្វើជាសេះ និងពាក់កណ្ដាលទៀតធ្វើជាអ្នកជិះសេះ សេះនីមួយៗត្រូវអៀវអ្នកជិះម្នាក់(អ្នកជិះត្រូវជិះពីលើខ្នងសេះ)។

**របៀបលេង៖**

អ្នកជិះសេះបោះបាល់ទៅវិញទៅមក ពេលបាល់ធ្លាក់ អ្នកជិះលោតចុះដីហើយរត់គេច។ អ្នកធ្វើសេះម្នាក់រត់ទៅរើសបាល់ ព្យាយាមគប់ឱ្យចំអ្នកជិះណាម្នាក់(អ្នកជិះសេះទាំងអស់ត្រូវធ្វើសេះឱ្យគេជិះម្ដង)។ ប្រសិនគប់ខុសវិញអ្នកជិះសេះនៅជិះដដែលហើយគេចាប់ផ្ដើមលេងសារថ្មីទៀត។

ល្បែង៖ លេងអ៊ូ

ការរៀបចំលេង៖ នៅក្រៅថ្នាក់គ្រូគូសខ្សែគំនូសពីរដើម្បីបែងចែកទីធ្លាសម្រាប់ក្រុម «ក»និងក្រុម«ខ»

របៀបលេង៖

ក្រុមទាំងពីរប៉ាវ។ ក្រុមណាប៉ាវចាញ់ត្រូវចូលអ៊ូមុន ។ឧទាហរណ៍៖ កុមារម្នាក់នៅក្រុម «ក»រត់ទៅទីធ្លាខាង ក្រុម«ខ» ដោយបញ្ចេញសំឡេងអ៊ូតែមួយដង្ហើមគត់ ក្រុម«ខ» ព្យាយាមចាប់កុមារនោះ។ ចំណែកកុមារនោះវិញព្យាយាមត្រឡប់មកក្នុងទីធ្លាខ្លួនវិញ។ ប្រសិនបើគេចាប់បានកុមារនោះហើយសម្រេក អ៊ូមិនទាន់ដាច់នៅឡើយ កុមារនោះខំរំដោះខ្លួនក្នុងករណីសម្រេកអ៊ូរបស់ខ្លួននៅបន្តទៀតបាន។ ប្រសិនបើកុមារនោះដាច់ដង្ហើមពេលនោះគឺត្រូវចាញ់ហើយត្រូវបញ្ជូនទៅក្រុម«ខ» វិញ។ កុមារចាប់ផ្ដើមលេងឡើងវិញប៉ុន្តែលើកនេះកុមារក្រុម«ខ» ត្រូវរត់ចូលមកក្រុម «ក» វិញម្ដង។

## ល្បែង៖ អ្វីៗគ្រប់យ៉ាងអំពីខ្ញុំ

**ការរៀបចំលេង៖** ដៃគូ និងក្រុមធំ

**របៀបលេង៖**

- កុមារអង្គុយឬឈរជាមួយដៃគូរបស់ខ្លួនរួចនិយាយរៀបរាប់អំពីខ្លួនឯងប្រាប់ទៅដៃគូ
- គ្រូពន្យល់ដោយបំផុសសំណួរជាបន្តបន្ទាប់ដើម្បីឱ្យកុមារងាយស្រួលនិយាយប្រាប់ទៅដៃគូ
- ឧទាហរណ៍៖ ...........ឈ្មោះខ្ញុំមានន័យថា .....ខ្ញុំឈ្មោះ
  ខ្ញុំចូលចិត្តខ្ញុំមិនចូលចិត្ត.... ថ្ងៃនេះខ្ញុំ......
- កុមារប្ដូរវេនគ្នាដើម្បីបង្កឱកាសឱ្យមានការនិយាយប្រាប់គ្នាទៅវិញទៅមក
- កុមារតំណាងដៃគូងាកនិយាយប្រាប់ក្រុមធំពីអ្វីដែលមិត្តភក្ដិបានប្រាប់

## ល្បែង៖ គូររូបបង្ហាញពីអារម្មណ៍របស់អ្នក

**ការរៀបចំលេង៖** ដៃគូ និងក្រុមធំទាំងមូល

**របៀបលេង៖**

- កុមាររកនឹកឡើងវិញអំពីអ្វីដែលពួកគេបានជួយដល់អ្នកដទៃ សប្បាយរីករាយ ឬយំ ភ័យខ្លាចមានអារម្មណ៍កក់ក្ដៅក្នុងចិត្ត
- កុមារគូររូបភាពដែលបង្ហាញពីអារម្មណ៍របស់ពួកគេ
- កុមារបែរមុខទៅរកដៃគូរបស់ខ្លួននិងចាប់ផ្ដើមនិយាយអំពីគំនូរដែលខ្លួនបានគូរដោយគ្រូជាអ្នកចោទសួរ៖
    - តើនៅពេលនោះកូនមានអារម្មណ៍យ៉ាងដូចម្ដេចនៅក្នុងខ្លួនរបស់កូន ?
    - តើកូនបានធ្វើអ្វីខ្លះ នៅពេលដែលកូនមានអារម្មណ៍បែបនោះ ?
- កុមារឡើងបង្ហាញចម្លើយរបស់ខ្លួនទៅកាន់ក្រុមធំ

បញ្ជាក់៖ កុំបញ្ចប់សកម្មភាពនេះជាមួយនឹងអារម្មណ៍អវិជ្ជមានដូចជា សោកសៅ ភ័យខ្លាចជាដើម។

## ល្បែង៖ ម្រាមដៃនៅឯណា ?

**ការរៀបចំលេង៖** ក្រុមធំទាំងមូល

**របៀបលេង៖**

- គ្រូសួរសំណួរកុមារអំពីឈ្មោះម្រាមដៃទាំង៥ ចំណែកកុមារជាអ្នកឆ្លើយ៖
- ចម្លើយរំពឹងទុក( ១៖មេដៃ ២៖ចង្អុលដៃ ៣៖ដៃកណ្ដាល ៤៖នាងដៃ ៥៖កូនដៃ )
- គ្រូនាំកុមារថាតាមពាក្យ មេដៃ ចង្អុលដៃ ដៃកណ្ដាល នាងដៃ កូនដៃ
- គ្រូច្រៀងចម្រៀងជាគំរូ១ៗព្រមទាំងធ្វើកាយវិការឱ្យកុមារស្ដាប់និងសង្កេត៖

១. មេដៃនៅឯណាៗ ( យកម្រាមមេដៃលាក់នៅក្រោយខ្នង )
នៅឯណេះៗ( លើកម្រាមមេដៃស្ដាំដាក់ទៅមុខបន្ទាប់មកម្រាមមេដៃឆ្វេង )
សុខសប្បាយជាទេៗ ( ម្រាមមេដៃទាំង២ រេចុះរេឡើងៗ )
សុខសប្បាយទាំងកាយចិត្ត ( ម្រាមមេដៃទាំង២ ដាក់ជាប់គ្នាចំដើមទ្រូង រេចុះរេឡើងៗ)
ជម្រាបសួរៗ ( ផ្ដុំម្រាមមេដៃទាំង២ រួចជម្រាបសួរ២ដង )។

២. ចង្អុលដៃនៅឯណាៗ ( យកចង្អុលដៃលាក់នៅក្រោយខ្នង )
នៅឯណេះៗ( លើកចង្អុលដៃស្ដាំដាក់ទៅមុខបន្ទាប់មកម្រាមមេដៃឆ្វេង )
សុខសប្បាយជាទេៗ ( ម្រាមចង្អុលដៃទាំង២ រេចុះរេឡើងៗ )
សុខសប្បាយទាំងកាយចិត្ត( ម្រាមចង្អុលដៃទាំង២ ដាក់ជាប់គ្នាចំដើមទ្រូង រេចុះរេឡើងៗ )
ជម្រាបសួរៗ ( ផ្ដុំម្រាមចង្អុលដៃទាំង២ រួចជម្រាបសួរ២ដង )។

៣. ម្រាមដៃកណ្ដាលនៅឯណាៗ ( យកដៃកណ្ដាល លាក់នៅក្រោយខ្នង )
នៅឯណេះៗ( លើកដៃកណ្ដាល ស្ដាំដាក់ទៅមុខបន្ទាប់មកម្រាមមេដៃឆ្វេង )
សុខសប្បាយជាទេៗ( ម្រាមដៃកណ្ដាលទាំង២ រេចុះរេឡើងៗ)
សុខសប្បាយទាំងកាយចិត្ត( ម្រាមដៃកណ្ដាល ទាំង២ ដាក់ជាប់គ្នាចំដើមទ្រូង រេចុះរេឡើងៗ )
ជម្រាបសួរៗ ( ផ្ដុំម្រាមដៃកណ្ដាល ទាំង២ រួចជម្រាបសួរ២ដង )។

៤. នាងដៃនៅឯណាៗ ( យកនាងដៃលាក់នៅក្រោយខ្នង )

នៅឯណោះៗ(លើកនាងដៃស្តាំដាក់ទៅមុខបន្ទាប់មកម្រាមមេដៃឆ្វេង)
សុខសប្បាយជាទេៗ (ម្រាមនាងដៃទាំង២ រេចុះរេឡើងៗ)
សុខសប្បាយទាំងកាយចិត្ត(ម្រាមនាងដៃទាំង២ ដាក់ជាប់គ្នាចំដើមទ្រូង រេចុះរេឡើងៗ)
ជម្រាបសួរៗ (ផ្គុំម្រាមនាងដៃទាំង២ រួចជម្រាបសួរ២ដង)។

៥. កូនដៃនៅឯណាៗ (យកកូនដៃលាក់នៅក្រោយខ្នង)
នៅឯណោះៗ(លើកកូនដៃស្តាំដាក់ទៅមុខបន្ទាប់មកម្រាមមេដៃឆ្វេង)
សុខសប្បាយជាទេៗ (ម្រាមកូនដៃទាំង២ រេចុះរេឡើងៗ)
សុខសប្បាយទាំងកាយចិត្ត(ម្រាមកូនដៃទាំង២ ដាក់ជាប់គ្នាចំដើមទ្រូង រេចុះរេឡើងៗ)
ជម្រាបសួរៗ (ផ្គុំម្រាមកូនដៃទាំង២ រួចជម្រាបសួរ២ដង)។

៦. ម្រាមប្រាំនៅឯណាៗ (យកម្រាមដៃទាំងពីរ លាក់នៅក្រោយខ្នង)
នៅឯណោះៗ(លើកម្រាមប្រាំស្តាំដាក់ទៅមុខបន្ទាប់មកម្រាមមេដៃឆ្វេង)
សុខសប្បាយជាទេៗ (ម្រាមដៃប្រាំទាំង២ រេចុះរេឡើងៗ)
សុខសប្បាយទាំងកាយចិត្ត(ម្រាមដៃប្រាំទាំង២ ដាក់ជាប់គ្នាចំដើមទ្រូង រេចុះរេឡើងៗ)
ជម្រាបសួរៗ (ផ្គុំម្រាមប្រាំទាំង២ រួចជម្រាបសួរ២ដង)។

គ្រូនាំកុមារច្រៀងជាមួយគ្នាម្តងមួយវគ្គៗរហូតដល់ចប់ (២ដងឬ៣ដង)។

## ល្បែង៖ ខ្ញុំអាចស្តាប់បាន

**ការរៀបចំលេង៖** ចាប់ដៃគូឬក្រុមធំទាំងមូល

**របៀបលេង៖**

- កុមារចាប់ដៃគូ ម្នាក់ជាអ្នកគូររូប និងម្នាក់ទៀតជាអ្នកត្រូវបានគេគូរ។ អ្នកគូររូបត្រូវស្តាប់ សង្កេត និងគូរ ឥរិយាបថដៃគូរបស់ខ្លួន។ ចំណែកម្នាក់ទៀតសន្ទនាជាមួយគ្រូឬមិត្តភក្តិដើម្បីឱ្យដៃគូរ គូឥរិយាបថរបស់ខ្លួន។
- សំណួរជាបន្តបន្ទាប់ទៅកាន់កុមារថា៖
  - តើកូនប្រើអ្វីដើម្បីស្តាប់?
  - នៅពេលស្តាប់តើកូនធ្វើកាយវិការយ៉ាងដូចម្តេច? (អាចបំផុសសំណួរផ្សេងៗទៀតក្រៅពីត្រចៀក)
- កុមារគូររូបឥរិយាបថដៃគូរបស់ខ្លួនដែលកំពុងស្តាប់និងសន្ទនា(ត្រចៀកស្តាប់ ភ្នែកសំឡឹង អ្នកនិយាយមាត់បិទ មិននិយាយគ្នាខួរក្បាលគិតផ្ចង់អារម្មណ៍ដៃជើងនិងដងខ្លួននៅស្ងៀម)។
- កុមារពិភាក្សាជាមួយដៃគូ តើត្រូវបន្ថែមផ្នែកណាខ្លះទៀតនៃរាងកាយដែលបានប្រើប្រាស់ក្នុងពេលស្តាប់។
- កុមារពន្យល់ពីអ្វីដែលបានគូរជាមួយដៃគូ ដូចជាភ្នែកសម្រាប់មើលជាដើម ...
- កុមារឡើងទៅនិយាយឆ្លាស់វេនគ្នាជាមួយដៃគូ នៅពីមុខក្រុមធំដោយឆ្លើយនិងសំណួររបស់គ្រូ៖
  - តើកូនចូលចិត្តនិយាយឱ្យអ្នកណាស្តាប់?
  - តើកូននិយាយប្រាប់គេអំពីអ្វីខ្លះ?
  - បើកូននិយាយទៅតែគេមិនស្តាប់ តើកូនមានអារម្មណ៍យ៉ាងដូចម្តេច?

- ចុះបើគេដល់វេន គេនិយាយវិញ តើកូនស្តាប់គេឬទេ?
- តើកូនធ្វើកាយវិការយ៉ាងណាខ្លះ ដើម្បីឱ្យគេដឹងថាកូនកំពុងស្តាប់គេ?
- បើគេដឹងថាកូនកំពុងតែស្តាប់គេនិយាយ តើគេសប្បាយចិត្តដែរឬទេ?
- ដូច្នេះការចេះស្តាប់គ្នាទៅវិញទៅមកជារឿងសំខាន់ដែរឬទេ?
- តើកូនចង់និយាយរឿងអ្វីខ្លះទៀតប្រាប់មិត្តភក្តិ?

- កុមារដោះស្រាយបញ្ហា។ តើកូនត្រូវធ្វើយ៉ាងណានៅពេលដែលមានអ្នកណាម្នាក់មិនស្តាប់កូននិយាយ។

## ល្បែង៖ ទាយឈ្មោះសកម្មភាព

**ការរៀបចំលេង៖** កុមារអង្គុយជារាងអក្សរ U

**របៀបលេង៖**

- កុមារអង្គុយជារាងអក្សរ U
- គ្រូណែនាំពីរបៀបលេងល្បែង ដោយគ្រូធ្វើកាយវិការ កុមារទាយ
- គ្រូសម្តែងកាយវិការដូចជា ដំណើរសត្វដំរី ដំណើរសត្វទា ដុសធ្មេញ សិតសក់
- កុមារទាយសកម្មភាពរបស់គ្រូម្តងមួយៗ
- កុមារអនុវត្តការលេងដោយខ្លួនឯង និងប្តូរវេនគ្នាសម្តែងវិញម្តង។

## ល្បែង៖ឆ្លុះកញ្ចក់

**ការរៀបចំលេង៖** កុមារអង្គុយជារាងអក្សរ U ឬរង្វង់

**របៀបលេង៖**

- កុមារអង្គុយជារាងរង្វង់ឬអក្សរ U រួចគ្រូហុចកញ្ចក់ឱ្យកុមារឆ្លុះមើលមុខរបស់ខ្លួនម្តងម្នាក់ៗបន្តគ្នា
- កុមាររៀបរាប់ម្តងម្នាក់ៗអំពីអ្វីដែលបានមើលឃើញក្នុងកញ្ចក់នោះ
- កុមារគិតពីពេលណាមួយដែលខ្លួនសប្បាយចិត្ត ខឹងសោកសៅឬភ្ញាក់ផ្អើល។ល។
- កុមារនិយាយប្រាប់គ្នាទៅវិញទៅមកអំពីអ្វីដែលធ្វើឱ្យពួកគេមានអារម្មណ៍បែបនេះ (សប្បាយចិត្ត ខឹង សោកសៅ ឬភ្ញាក់ផ្អើល និងនៅពេលដែលពួកគេមានអារម្មណ៍បែបនេះ (សប្បាយចិត្ត ខឹង សោកសៅ ឬភ្ញាក់ផ្អើល) តើកូនធ្វើអ្វីខ្លះ?
- កុមារធ្វើមុខធ្វើមាត់ដែលបង្ហាញពីអារម្មណ៍នោះ ដាក់កញ្ចក់ម្តងទៀតដើម្បីពិនិត្យមើលការសំដែងទឹកមុខរបស់ខ្លួន។

## ល្បែង៖ ឈូក ឆាក់ៗ

**ការរៀបចំលេង៖** រៀបកុមារឈរជារង្វង់

**របៀបលេង៖**

- គ្រូអនុវត្តឱ្យកុមារមើលមួយដងឬពីរដង

១ដាក់ដៃស្តាំចូលក្នុង (ដៃឆ្វេងច្រត់ចង្កេះ ដៃស្តាំដាក់ទៅមុខរលាស់ដៃ)
ដាក់ដៃស្តាំចេញក្រៅ (ដៃឆ្វេងច្រត់ចង្កេះ ដៃស្តាំដាក់ទៅក្រោយរលាស់ដៃ)
២ដាក់ដៃឆ្វេងចូលក្នុង (ដៃស្តាំច្រត់ចង្កេះ ដៃឆ្វេងដាក់ទៅមុខរលាស់ដៃ)
ដាក់ដៃឆ្វេងចេញក្រៅ (ដៃស្តាំច្រត់ចង្កេះ ដៃឆ្វេងដាក់ទៅក្រោយរលាស់ដៃ)
បន្ទរថា ឈូក ឆាក់ៗ (២ដង)

៣ដាក់ជើងស្តាំចូលក្នុង (ដៃទាំងពីរច្រត់ចង្កេះ ជើងស្តាំដាក់ទៅមុខ)
ដាក់ជើងស្តាំចេញក្រៅ (ដៃទាំងពីរច្រត់ចង្កេះ ជើងស្តាំដាក់ទៅក្រោយ)
៤.ដាក់ជើងឆ្វេងចូលក្នុង(ដៃទាំងពីរច្រត់ចង្កេះ ជើងឆ្វេងដាក់ទៅមុខ)
ដាក់ជើងឆ្វេងចេញក្រៅ (ដៃទាំងពីរច្រត់ចង្កេះ ជើងឆ្វេងដាក់ទៅក្រោយ)
បន្ទរថា ឈូក ឆាក់ៗ (២ដង)។

- កុមារច្រៀង និងធ្វើកាយវិការព្រមគ្នា។

បញ្ជាក់៖ នៅពេលបន្ទរថាឈូក ឆាក់ៗ (២ដង)កុមារទាំងអស់កាន់ដៃគ្នារេទៅឆ្វេង រេទៅស្តាំឬ សទះដៃរេខ្លួនទៅឆ្វេងទៅស្តាំ ឬកាយវិការផ្សេងៗឱ្យត្រូវតាមចង្វាក់។

## ល្បែង៖ ការធ្វើសមាធិតាមការណែនាំ

**ការរៀបចំលេង៖** រៀបកុមារលេងជាក្រុមតូច

**សម្ភារៈ ៖**

- វត្ថុទន់ដូចជា ខ្នើយ តុក្កតា បាល់ទន់ៗ ដបទឹកសុទ្ធ សម្រាប់ថ្នាក់ទាបនិងមធ្យម
- ថ្នាក់ខ្ពស់ គ្មាន

**របៀបលេង៖**

- បង្ហាញសម្ភារៈឱ្យកុមារប្រាប់ឈ្មោះ
- គ្រូនាំកុមារអនុវត្ត៖
  - កុមារអង្គុយពែនភ្នែន លើកម្រាលដោយដាក់បាតដៃផ្ទារត្រួតពីលើគ្នានិងបិទភ្នែកទាំង២
  - ប្រាប់កុមារឱ្យដកដង្ហើមចូលយឺតៗតាមច្រមុះនៅពេលគ្រូរាប់ថ្នមៗពី១ដល់៤
  - កុមារដកដង្ហើមចេញតាមមាត់យឺតៗនៅពេលគ្រូរាប់ថ្នមៗពៅ១ដល់៤
  - ចុងក្រោយឱ្យកុមារដកដង្ហើមតាមធម្មតាវិញ៥វិនាទីរួចឱ្យកុមារបើកភ្នែកយឺតៗ។

## ល្បែង៖ ការសម្តែងពីការដឹងគុណអ្នកដទៃ

**ការរៀបចំលេង៖** ក្រុមធំ

**សម្ភារៈ ៖**

- រូបភាពដើមឈើគ្មានស្លឹកដែលផលិតពីក្រដាសឬមែកឈើពិត កន្ត្រក ស្លឹកឈើធ្វើពីក្រដាសពណ៌

**របៀបលេង៖**

- បង្ហាញរូបភាពដើមឈើគ្មានស្លឹកដែលផលិតពីក្រដាសឬមែកឈើពិត និងកន្ត្រកស្លឹកឈើធ្វើពីក្រដាសពណ៌
- បំផុសកុមារឱ្យចាប់អារម្មណ៍ពីមនុស្សណាម្នាក់ដែលធ្លាប់មានគុណលើខ្លួនទុកឱកាសឱ្យកុមារគិត
- ប្រាប់ពីកិច្ចការដែលកុមារត្រូវធ្វើ៖
  - កុមារនិយាយម្នាក់ម្តងៗអំពីការដឹងគុណរបស់មាតាបិតា លោកយាយ លោកតា លោកគ្រូ អ្នកគ្រូ៖ អរគុណម៉ាក់ដែលពីថ្ងៃមុនបានទិញតុក្កតាឱ្យកូន...
  - កុមារឈរពីរៗនាក់ ហើយនិយាយម្នាក់ម្តងៗអំពីការដឹងគុណចំពោះមិត្តភក្តិដូចជា៖ អរគុណណាស់ ដែលពីថ្ងៃមុនឯងបានចែកបាល់ឬវត្ថុនោះឱ្យខ្ញុំខ្ចីលេង និងលេងជាមួយ...

- នេះជាដើមឈើមួយដើមគ្មានស្លឹកទេ ដូចនេះយើងត្រូវធ្វើឱ្យដើមឈើមានភាពស្រស់បំព្រង
- កុមារគូរលើស្លឹកឈើដែលស្តែងចេញពីការដឹងគុណហើយប្រាប់គ្រូ
- គ្រូសរសេរពាក្យពេចន៍ដែលកុមារបានប្រាប់ដាក់លើស្លឹកឈើ រួចឱ្យកុមារយកទៅបិទភ្ជាប់ដើមឈើ
- តើកូនមានអារម្មណ៍យ៉ាងណា នៅពេលកូនដឹងគុណអ្នកណាម្នាក់?

## ៣. គំនូសមូលដ្ឋាន

**គំនូស « តំណក់ទឹកភ្លៀង »**

ក្នុងពេលកំពុងភ្លៀង ខ្យល់បក់យ៉ាងខ្លាំងមកពីខាងឆ្វេង ដំណក់ទឹកភ្លៀងធ្លាក់ចុះទ្រេតពីឆ្វេង និទានបណ្តើរ គូសឱ្យកុមារសង្កេតបណ្តើរ ពេលភ្លៀង ខ្យល់បក់យ៉ាងខ្លាំងមកពីខាងស្តាំ ដំណក់ទឹកភ្លៀងធ្លាក់ចុះទ្រេតពីស្តាំទៅឆ្វេង។




រូបភាពទី 20៖ គំនូស តំណក់ទឹកភ្លៀង

- ➢ **គ្រូអាចដំណើរការបង្រៀនដូចឧទាហរណ៍ទី១ និងទី២ ឬអនុវត្តវិធីផ្សេងទៀតបាន**

រូបភាពសម្រាប់នាំកុមារគូសគំនូស កោងឆ្វេង,កោងស្តាំ កោងផ្កាប់ កោងផ្ងារ (ពិនិត្យរូបភាព)




រូបភាពទី 21៖ គំនូសកោង

➢ **គំនូសៈ**ខ្សែកោងលើក្អម




រូបភាពទី 22៖ គំនូស ខ្សែកោងលើក្អម

➢ **គំនូសៈ** ខ្សែកោងលើបាល់




រូបភាពទី 23៖ គំនូស ខ្សែកោងលើបាល់

➢ គំនូស « កាំជណ្ដើរ »

គ្រូអាចរៀបចំខ្លឹមសារមេរៀនគំនូស« កាំជណ្ដើរ» នេះ ទៅតាមការច្នៃប្រឌិតសមស្របនឹងវ័យរបស់កុមារ។

**គំនូស** « កាំជណ្ដើរ »

គ្រូមានឈើត្រង់ល្អចំនួន២ដើម ចង់ធ្វើជាជណ្ដើរ១អាចប្រើការច្រើនយ៉ាងសម្រាប់ឡើងចុះដើមឈើ ឬជូតជញ្ជាំងឬផ្លាស់ប្ដូរអំពូលភ្លើង...។ តើយើងត្រូវធ្វើដូចម្ដេច? ចម្លើយៈគូសកាំជណ្ដើរ។




រូបភាពទី 24៖ គំនូស កាំជណ្ដើរ

## ៤.ការបត់

➢ **ការបត់ធ្វើផ្សិត**



រូបភាពទី 25៖ ការបត់ធ្វើផ្សិត

➢ **បត់ធ្វើយន្តហោះ**



រូបភាពទី 26៖ បត់ធ្វើយន្តហោះ

➢ **បត់ធ្វើបង្កង**



រូបភាពទី 27៖ បត់ធ្វើបង្កង

➢ បត់ធ្វើសត្វឆ្កែ



រូបភាពទី 28៖ បត់ធ្វើសត្វឆ្កែ

➢ បត់ធ្វើ**ដើម**ស្រស់



រូបភាពទី 29៖ បត់ធ្វើដើមស្រស់

➢ បត់ធ្វើសត្វកណ្តូប




រូបភាពទី 30៖ បត់ធ្វើសត្វកណ្តូប

## ៥.ការសូន្យ

➢ សូន្យដីធ្វើខ្យង



រូបភាពទី 31៖ សូន្យដីធ្វើខ្យង

- ➢ **សូនដីធ្វើក្តាម**




រូបភាពទី 32៖ សូនដីធ្វើក្តាម

## ៦.ការតំរៀបស្លឹកឈើ ជារូបសត្វ

- ផ្គុំស្លឹងឈើ ធ្វើជាទន្សាយ




រូបភាពទី 33៖ ផ្គុំស្លឹងឈើ ធ្វើជាទន្សាយ

- តម្រៀបគ្រាប់សណ្តែក អង្ករ ជារូបត្រី



រូបភាពទី 34៖ តម្រៀបគ្រាប់សណ្តែក អង្ករ ជារូបត្រី

## ៦.ចម្រៀង នៅមត្តេយ្យសិក្សា

**សកម្មភាពគោល ចម្រៀង៖** ខ្ញុំជាសត្វអ្វី? ( លំនាំបទ ស្អាតជានិច្ច )

១.ផ្លែធំធ្លាក់ ផ្លែតូចធ្លាក់ យើងពីរនាក់ នាំគ្នារត់លេង
ស្លឹកតូចធំ រត់ប្រទ្បែង មែកស្រែកថា ខ្ញុំសុំលេងផង។
២.កេបៗ គ្មានចំពុះ ខ្ញុំគ្មានឈ្មោះ សូមជួយដាក់ផង
កេបៗ សូមបងៗ ទាយថាខ្ញុំ គឺជាសត្វអ្វី?

### ពេលភ្លៀងធ្លាក់រួច

ពេលភ្លៀងធ្លាក់រួចអើយ ទឹកដក់ពេញថ្លុក កង្កែបប្រងុកអើយ សម្លឹងមើលហ៊ីង
កំពុងតែហែលអើយ ពោះឡើងកំពឹងៗ ខំស្រែកហៅហ៊ីង មកលេងរាំវង់
បងហ៊ីងកំប៉ោងអើយ មើលចុះមើលឡើង លើកដៃ លើកជើងអើយ រាំតាមចង្វាក់ភ្លេង
ឯកូនកង្កែបអើយ ដែលវានៅក្មេង មិនបានរាំលេង លបលួចមើលគេ។

ពេល  ធ្លាក់រួចអើយ ទឹកដក់ពេញ   ប្រងុកអើយ សម្លឹងមើល

 កំពុងតែ  អើយ ពោះឡើងកំពឹងៗ ខំស្រែកហៅ  មកលេងរាំវង់

បង  កំប៉ោងអើយ មើលចុះមើលឡើង លើកដៃលើកជើងអើយ រាំតាចង្វាក់ 

ឯកូន  អើយ ដែលវានៅក្មេង មិនបានរាំលេង លបលួចមើលគេ។

## ជម្រាបលោកអ្នក ខ្ញុំមិនភទេ

មួកតាខ្ញុំ  ត្បិតតែវាធំ តែវាស្រួលពាក់ កំពុងតែក្តៅ ពាក់ទៅត្រជាក់ ជម្រាបលោកអ្នក ខ្ញុំមិនមែនភទេ
អាវតាខ្ញុំ  ត្បិតតែវាធំ តែវាស្រួលពាក់ កំពុងតែក្តៅ ពាក់ទៅត្រជាក់ ជម្រាបលោកអ្នក ខ្ញុំមិនមែនភទេ
ខោតាខ្ញុំ  ត្បិតតែវាធំ តែវាស្រួលពាក់ កំពុងតែក្តៅ ពាក់ទៅត្រជាក់ ជម្រាបលោកអ្នក ខ្ញុំមិនមែនភទេ
ស្បែកជើងតាខ្ញុំ  ត្បិតតែវាធំ តែវាស្រួលពាក់ កំពុងតែក្តៅ ពាក់ទៅត្រជាក់ ជម្រាបលោកអ្នកខ្ញុំមិនមែនភទេៗ។

## ជម្រាបលោកអ្នក ខ្ញុំមិនភទេ

  ខ្ញុំ ត្បិតតែវាធំ តែវាស្រួលពាក់ កំពុងតែក្តៅ ពាក់ទៅត្រជាក់ ជម្រាបលោកអ្នក ខ្ញុំមិនមែនភទេ

  ខ្ញុំ ត្បិតតែវាធំ តែវាស្រួលពាក់ កំពុងតែក្តៅ ពាក់ទៅត្រជាក់ ជម្រាបលោកអ្នក ខ្ញុំមិនមែនភទេ

  ខ្ញុំ  ត្បិតតែវាធំ តែវាស្រួលស្លៀក កំពុងតែក្តៅ ស្លៀកទៅត្រជាក់ ជម្រាបលោកអ្នក ខ្ញុំមិនមែនភទេ

  ខ្ញុំ ត្បិតតែវាធំ តែវាស្រួលពាក់ កំពុងតែក្តៅ ពាក់ទៅត្រជាក់ ជម្រាបលោកអ្នកខ្ញុំមិនមែនភទេៗ។

## ផ្កាក្រដាស

ផ្កាអើយ  អើយផ្កាក្រដាស  សប្បាយចិត្តណាស់  ខ្ញុំរៀនចេះចាំ  រៀនលេខពី១ដល់៥ ខ្ញុំរៀនចេះចាំអក្សរ ក ខ ៗ។

 **ផ្កាក្រដាស**

ផ្កាអើយ អើយ សប្បាយចិត្តណាស់ រៀនចេះចាំ

រៀនលេខពី១ដល់៥ រៀនចេះចាំអក្សរ ក ខ រៀនចេះចាំអក្សរ ក ខ។

## កង្កែបចេញពីសាលា

កង្កែបៗចេញពីសាលាអ៊ើងអើយ កង្កែបៗចេញពីសាលា ទៅជួបយាយឆ្មាពាក់វ៉ែនតាធំៗ

កង្កែបតូចតូចពិត តែចេះគួរសមអ៊ើងអើយ កង្កែបតូចពិតតែចេះគួរសម

លោកយាយឆ្មាសុំ ស្គាល់ឈ្មោះសាលាៗ ។

កង្កែបឆ្លើយភ្លាម មិននៅយូរការអ៊ើងអើយ កង្កែបឆ្លើយភ្លាមមិននៅយូរការ

រៀននៅសាលាមត្តេយ្យសិក្សាធនធានក្រុងៗ ។



## ចេញពីសាលា

ចេញពីសាលាអ៊ើងអើយ ចេញពីសាលា

ទៅជួបយាយ  ពាក់វ៉ែនតាធំៗ ទៅជួបយាយ  ពាក់វ៉ែនតាធំៗ ។

តូចពិត តែចេះគួរសមអ៊ើងអើយ តូចពិតតែចេះគួរសម

លោកយាយ  សុំស្គាល់ឈ្មោះសាលា លោកយាយ  សុំស្គាល់ឈ្មោះសាលា។

ឆ្លើយភ្លាម មិននៅយូរការអ៊ើងអើយ ឆ្លើយភ្លាម មិននៅយូរការ

រៀននៅសាលាមត្តេយ្យសិក្សាធនធានក្រុងៗ ។

## កង្កែបពាក់មួក

កង្កែបពាក់មួក　　គីង្គក់ពាក់អាវអ៊ើងអើយ　　កង្កែបពាក់មួក　　គីង្គក់ពាក់អាវ
កញ្ចាញ់ចេកលាបម្សៅ　　បងហ៊ឹងអ៊ុតសក់ ៗ។



## កង្កែបពាក់មួក

 ពាក់មួក  ពាក់  អ៊ើងអើយ  ពាក់មួក  ពាក់ 

 លាបម្សៅ បង  អ៊ុតសក់  លាបម្សៅ បង  អ៊ុតសក់។

## អូនឈ្មោះតុក្កតា

អូនឈ្មោះតុក្កតា　　៣ឆ្នាំកាលណា　　អូនបានចូលរៀន
ពេលខ្លះកូនខ្មាស់　　ពេលខ្លះកូនអៀន　　ពេលខ្លះកូនឃ្លាននំចំណីផងៗ ។
កូនហៀរសំបោរ　　កូននោមដាក់ខោ　　អ្នកគ្រូទាន់ម្តងៗ
អ្នកគ្រូណែនាំ　　ពិរោះកន្លងៗ　　តុក្កតាចាំចងបណ្តាំអ្នកគ្រូៗ។

## អូនឈ្មោះ 

អូនឈ្មោះ  ៣ឆ្នាំកាលណា　អូនបានចូលរៀន ពេលខ្លះកូនខ្មាស់ ពេលខ្លះកូនអៀន

ពេលខ្លះកូនឃ្លាន  ចំណីផងៗ ។

កូនហៀរសំបោរ កូននោមដាក់   ទាន់ម្តង

កូនហៀរសំបោរ កូននោមដាក់   ទាន់ម្តង

 ណែនាំ ពិពោះកន្លង  ណែនាំ ពិពោះកន្លង

 ចាំចងបណ្តាំ   ចាំចងបណ្តាំ  ។

**ចំការយើង** (លំនាំបទគន់មើលកង្ហារត្រូវខ្យល់ )

ចំការយើងអើយស្រស់បំព្រង ត្រសក់ជំឡូង ឪឡឹកត្រឡាច ចេញផ្កាបោះផ្លែបាចសាច

ល្ពៅត្រឡាច វារគរលើគ្នា ល្អមែនៗៗ ល្អមែនៗ ។

**ចំការយើង** (លំនាំបទគន់មើលកង្ហារត្រូវខ្យល់)

  យើងស្រស់បំព្រង   

 ចេញ  បោះផ្លែបាចសាច  

វារគងលើគ្នា ល្អមែនៗៗ ល្អមែនៗ ។

**តារាងបង្ហាញពីសំណូមពរក្នុងដំណើរការបង្រៀន និងរៀនចម្រៀង**

| សំណូមពរ | ថ្នាក់ទាប | ថ្នាក់មធ្យម | ថ្នាក់ខ្ពស់ |
|---|---|---|---|
| - ធ្វើឱ្យកុមាររំភើបចិត្ត | - ស្តាប់ និងចូលរួមច្រៀងរហូតដល់ចប់រយៈពេល ១-២នាទី<br>- គ្រូប្រែប្រួលវិធីបង្រៀនឱ្យ មានលក្ខណៈទាក់ទាញ និងបំផុសសំណួរប្រដេញឱ្យកុមារយល់អត្ថន័យបទចម្រៀង | - ស្តាប់និងចូលរួមច្រៀងរហូតដល់ចប់រយៈពេល ៣-៥នាទីនិងយល់អត្ថន័យខ្លះៗ<br>- គ្រូប្រែប្រួលវិធីបង្រៀនឱ្យមានលក្ខណៈទាក់ទាញ និងបំផុសសំណួរប្រដេញឱ្យកុមារយល់អត្ថន័យបទចម្រៀង | - កុមារស្តាប់ដោយប្រុងប្រយ័ត្នបង្ហាញនូវឥរិយាបថជំនក់ចិត្ត និងចូលរួមច្រៀងរហូតដល់ចប់រយៈពេល៥នាទី និងយល់អត្ថន័យបទចម្រៀង អាចឆ្លើយតបសំណួរគ្រូបានច្រើននាក់ |

| | | | |
|---|---|---|---|
| | | | - គ្រូប្រែប្រួលវិធីបង្រៀនឱ្យមានលក្ខណៈទាក់ទាញ និងបំផុសសំណួរសរុប |
| - ជួយកុមារឱ្យអភិវឌ្ឍប្រត្យក្សារម្មណ៍ | - ស្តាប់ចម្រៀងកុមារប្រាប់ចំណងជើងចម្រៀងបានចំពោះចម្រៀងដែលធ្លាប់ស្តាប់និងបានហាត់ច្រៀង | - ស្តាប់ចម្រៀង កុមារប្រាប់ចំណងជើងចម្រៀងនិងលំនាំបទបានចំពោះម្រៀងដែលធ្លាប់ស្តាប់និងបានហាត់ច្រៀង | - ដូចសកម្មភាពថ្នាក់មធ្យម<br>- ស្តាប់បទភ្លេង កុមារប្រាប់ចំណងជើងចម្រៀង និងលំនាំបទបានចំពោះចម្រៀងថ្មីដែលមានសាច់ភ្លេងដូចគ្នា |
| - ជួយកុមារឱ្យបង្ហាញពីចំណូលចិត្តបទចម្រៀង | - ប្រាប់ពីចំណងជើងបទចម្រៀងនិងច្រៀងធ្វើកាយវិការបាន១ឬ២បទ | - ដូចថ្នាក់ទាប និងប្រាប់បានខ្លះៗពីហេតុផលចូលចិត្តបទចម្រៀងនោះ | - ដូចថ្នាក់មធ្យម |
| - ជួយកុមារឱ្យយល់ដឹងពីសញ្ញាតាង | - ចំណាំបានពីសញ្ញាតាងនិងកាយវិការដែលបញ្ជាក់ពីចំនួនព្យាង្គក្នុងពាក្យ | - ដូចថ្នាក់ទាបនិងអនុវត្តលំហាត់កាន់តែលំបាក<br>- ប្រាប់ពីសញ្ញាបញ្ជាភ្លេងរបស់គ្រូដូចជាសំឡេងស្មើ ឡើងចុះ លឿន យឺតជាដើម | - ដូចថ្នាក់មធ្យម<br>- ហ្វឹកហាត់ជាអ្នកបញ្ជាភ្លេង |

**ចម្រៀងសម្រាប់កុមារមត្តេយ្យសិក្សាថ្នាក់កម្រិតទាប**

**១- ឆ្មាមួយ**

ឆ្មា១ព្រួយចិន្តា ដើរឯការកអាហារធី។

**២- គោ១ (លំនាំបទឆ្មាមួយ)**

គោ១ព្រួយចិន្តា ដើរឯការកអាហារធី ស្រាប់តែទៅជួបស្មៅខ្ចី អរពេកក្រៃធីជាអាហារ (២ដង)។

**៣- យើងរាប់លេខ**

លេខ១ លេខ២ កុមារសំភីទើបរៀនពូកែ

**៤. អូនមើលស្រូវទុំ**

១.២.៣.៤ ខ្មែរមាំមួនទៅច្រូតស្រូវទុំ អាអូនកុំយំ មើលស្រូវទុំ ក្រហមពេញស្រែ ហេ!ហេ!ហេ!។

**៥. កុក១ កុក២ កុក៣**

កុក១ កុក២ កុក៣ ទៅចាប់ត្រីបបួលកុក៤ កុក៥មិនសូវស្រួលខ្លួន បបួលកុក៤ហៅកុក៦។

**៦. កង្កែប ហ៊ីង គីង្គក់ (លំនាំបទ កុក១ កុក២)**

កង្កែបមានជើងវែងៗ ចំណែកហ៊ីងមានជើងខ្លីៗ គីង្គក់មានរូបអប្រិយ សត្វទាំង៣រូបស្រដៀងគ្នា។

**៧. យើងសម្អាតធ្មេញ**

បើចង់ឱ្យធ្មេញល្អ កុំបៀមស្ករទុកនៅក្នុងមាត់

ក្រោកពីគេងត្រូវដុសឱ្យស្អាត យើងសម្អាតទើបធ្មេញមិនឈឺ។

**៨. លំអងជីស**

លំអងជីស មិនមែនល្អ បើប្រឡាក់ដៃ វាជាមេរោគ ស្មោគគ្រោក អាក្រក់ចង្រៃ

យើងត្រូវលាងដៃៗ កុំទុកនៅយូរ។

**៩. ឆ្វេង ស្តាំ (លំនាំបទ ប្រជុំគ្នា)**

ឆ្វេងស្តាំចាំឱ្យស្ទាត់១ ២ ពួកយើងប្រយ័ត្នដើរឱ្យត្រូវជើង១ ២

ឆ្វេងស្តាំត្រូវចាំពួកយើង១ ២ ដើរឱ្យត្រូវជើងកុំឱ្យច្រឡំ១ ២។

**១០. ពេលដើរត្រូវប្រកាន់ស្តាំ**

ពេលដើរទៅសាលា ហៃអស់កុមារ ចូរអ្នកចងចាំ

ដើរអែបៗខាងស្តាំ លើចិញ្ចើមថ្នល់ ទើបបានល្អ( ២ដង)។

**១១.កូនកំប្រុក**

ផ្លោតៗផ្លោះទៅលើចុងត្នោត ក្រោកៗ ក្រោក បក់កន្ទុយតែកតោក

កកេរផ្លែក្រេកក្រោក ហើយធ្វើក្បាលងីងើៗ។

**១២.កូនទា**

ពេលកូនទាវាដើរទៅ ដំណើរវាមិនល្អឡើយ

ចាំទុកណាពួកម៉ាកអើយ កុំឱ្យដើរដូចកូនទា។

**១៣.កូនមាន់តឿ (ចង្វាក់រាំក្បាច់)**

កូនមាន់តឿ កន្ទុយរីក ហាមាត់ស្រែក សំឡេងពិរោះណាស់

កាច់របាំក៏ល្អ ស្លាបក៏ល្អ ជើងដៃក៏ស ល្អទាំងប្រាណ។

ណយៗ ណយៗ ណយៗ ណយៗ ណយៗ ណយៗ ណយៗ។

**១៤. យើងសម្អាតដៃ**

ដៃយើងៗកខ្វក់ កុំដំអក់ទុកឱ្យនៅយូរ ទឹកមួយចានដុសលាងនឹងសាប៊ូ(២ដង)
កុំទុកយូរនាំកើតមេរោគ។

**១៥. កន្សែងដៃ**

កន្សែងដៃម៉ែដេរឱ្យកូន លើមែកផ្កាម៉ែចាក់កូនចាប
កូនរីករាយមានកន្សែងល្អស្អាត ជូតម្រាមដៃកូនបានស្អាតរាល់ថ្ងៃ។

**១៦. ដើរ ឬដេក**

ដើរ ឬដេកដងខ្លួនឱ្យត្រង់ ត្រូវតម្រង់ទាន់ខ្លួននៅក្មេង
ទោះអង្គុយ ឬមួយឈរលេង យើងក្មេងៗឈរឱ្យត្រង់ខ្លួន។

**១៧. ក្រចកត្រូវកាត់ឱ្យខ្លី**

ក្រចកត្រូវកាត់ឱ្យខ្លី កុំលេងដីខ្លាចវាឆ្លងជំងឺ
ភ្នែកជាក្លាយជាឈឺ គេដឹងឮគេមិនឱ្យលេងចូល។

**១៨. ឆាប់គេង (លំនាំបទ ពេលដើរទៅសាលា)**

ពេលយប់ត្រូវឆាប់គេង កុំនៅលេងវាមិនល្អ ព្រឹកព្រាងក្រោកមុនគេ
ហើយគ្នាន់គ្នេររៀបចំទៅរៀន(២ដង)។

**១៩. មេអំបៅទៅសាលា**

អើយមើលមេអំបៅ ហិចហើរសំដៅ ទៅរកក្រេបផ្កា
ពណ៌លឿងក្រហម បែតងស្រស់អស្ចារ្យ អូនទៅសាលាជាមួយបងទេ(២ដង)។

**២០. ស្អាតជានិច្ច**

ស្អាតជានិច្ចៗ យើងកុំភ្លេច ត្រូវសម្អាតកាយ
ទាំងពេលគេង ពេលញ៉ាំបាយ សម្អាតកាយមុនទៅសាលា។

**២១. កំពូលប្រាសាទ**

មិត្តអើយមើលហ្ន៎ អង្គរវត្តស្អាតអើងអើយ (២ដង)
កំពូលប្រាសាទ មិត្តអើយត្រូវចាំមានប្រាំ(២ដង)។

**២២. សួនច្បារ (លំនាំឡាំលាវ)**

មិត្តអើយមើលហ្ន៎ មើលសួនច្បារយើង(២ដង)
សិរមាន់ស្បៃរឿង មិត្តអើយពណ៌លឿងក្រហម(២ដង)។

**២៣. រថភ្លើង**

រទេះភ្លើងកូនក្មេងបរទៅ បរសំដៅទៅសាលារៀន មកមិត្តអើយប្រញាប់រួសរាន់
មកឱ្យទាន់រទេះភ្លើងចេញហើយ ទីន ទីន ទីន ឈុក ឈុក ឈុក។

**២៤. សារិកាកែវពត់ប្រាណ**

សារិកាកែវអើយ ស៊ីអីកងកងៗ កុមារត្រសងនាំគ្នាពត់ប្រាណ
អើយកែវៗអើយ(២ដង)
យើងខំលើកដៃ លើកជើងឱ្យបាន ខំពត់ទាំងប្រាណទើបសុខភាពល្អ

អើយកែវៗអើយ(២ដង)។

**២៥. ផ្កាវីកក្នុងបឹង (លំនាំបទ ផ្កាយលើមេឃ)**

តាក់ទឹងកណឹងណឹង មិត្តមើលក្នុងបឹង ផ្កាវីករហង់ គឺផ្កាព្រលឹត
និងផ្កាវិចង់ លឿងក្រហមយង់គួរឱ្យចង់បេះ(២ដង) ។ តាក់ទឹងកណឹងៗ។

**២៦. កុំលេងឈើគូស**

កុំលេងឈើគូស ខ្លាចវាជ្រុះ រលាកដៃជើង
ចូរកុំលេងភ្លើង ខ្លាចវាប៉ើង ឆេះផ្ទះខាននៅ។

**២៧. សត្វទីទុយ**

មានសត្វទីទុយ មួយភ្នែកធំ ស្រែកយំពីលើចុងជ្រៃ
ឮសូរសម្រែក សត្វមៀមព្រៃ ឃ្មាតខ្មីវាយំឆ្លើយឆ្លង
ទីទុយ ទីទុយ ទីទុយ ទីទុយ ។

**២៨. មត្តេយ្យសាលា(លំនាំបទ ឱផ្កាល្អុង)**

មត្តេយ្យសាលា មត្តេយ្យសាលា យើងបើកទ្វារហើយ
ឱមិត្តយើងអើយ កុំកន្តើយ ត្រូវទៅសិក្សា ( ២ដង )។

**២៩.អាគីឆ្កែខ្ញុំ**

អាគីឆ្កែខ្ញុំ វានៅចាំផ្ទះ វាចេះសំពះ ចេះដើរជើងពីរ
បើចង់ប្រើវា ទាល់តែឱ្យនំស៊ី ទើបវាដើរជើងពីរ បក់កន្ទុយឱ្យមើល។

**៣០. ចំការយើង (លំនាំ គន់មើលកង្ហារត្រូវខ្យល់)**

ចំការយើងស្រស់បំព្រង ត្រសក់ដំឡូង ឪឡឹកត្រឡាច ចេញផ្កាបោះផ្លែបាចសាច(២ដង)
ល្ពៅត្រឡាច វារគរលើគ្នា ល្អមែន ល្អមែន ល្អមែន ល្អមែន ល្អមែន ល្អមែន ។

**៣១. ជម្រាបសួរ**

ជម្រាបសួរថ្ងៃនេះជួបគ្នា សប្បាយចិត្តពេលបានឃើញគ្នា
អូឡា ឡា ឡា ឡា ឡា ឡា អូឡា ឡា ឡា ឡា ឡា ឡា ។
ជម្រាបសួរថ្ងៃនេះជួបគ្នា សប្បាយចិត្តពេលបានស្គាល់គ្នា
អូឡា ឡា ឡា ឡា ឡា ឡា អូឡា ឡា ឡា ឡា ឡា ឡា ។

**៣២. កង្កែបពាក់មួក**

កង្កែបពាក់មួក គីង្គក់ពាក់អាវអ៊ើងអើយ កង្កែបពាក់មួក
គីង្គក់ពាក់អាវ កញ្ចាញ់ចេកលាបម្សៅ បងហ៊ឹងអ៊ុតសក់ (២ដង)។

**៣៣. អូនឈ្មោះតុក្កតា**

អូនឈ្មោះតុក្កតា ៣ឆ្នាំកាលណា អូនបានចូលរៀន
ពេលខ្លះកូនខ្មាស់ ពេលខ្លះកូនអៀន ពេលខ្លះកូនឃ្លាននំចំណីផងៗ ។
កូនហៀរសំបោរ កូននោមដាក់ខោ អ្នកគ្រូទាន់មួង (២ដង)
អ្នកគ្រូណែនាំ ពិរោះកន្លង (២ដង)
តុក្កតាចាំចងបណ្តាំអ្នកគ្រូ (២ដង)។

## ចម្រៀងសម្រាប់កុមារមត្តេយ្យសិក្សាថ្នាក់កម្រិតមធ្យម

**១. ខ្ញុំអាយុបួនឆ្នាំ (លំនាំបទ មេឃក្រហមឆ្អៅ)**

ខ្ញុំអាយុទើបតែ៤ឆ្នាំ ខ្ញុំរៀនចេះចាំលេខ ១លេខ ២
ហាត់ពត់វាចាភាសាសំភី លេខ៦ ៧ ខ្ញុំរាប់បានដែរ។

**២. កុំប្រឡែងគ្នាលេង(លំនាំបទអុំទូក)**

អើយយើងនាំគ្នាទៅ ឱណានាងណា ទៅជិះទូកលេង(២ដង)
យើងមិនៗប្រឡែង ឱណានាងណា ខ្លាចទូកយើងលិច(២ដង)។

**៣. ក្នុងឆ្លាចិញ្ចឹមសត្វ**

អ៊ីកអ៊ូក កាបកាប កុកកុក អ្នកស្រុកភ្ញាក់ផ្អើលគ្រប់គ្នា ទាំងជ្រូកទាំងមាន់ទាំងទា
ដេងគ្នាប្រកែកឡូឡា អ៊ីយ៉ា អ៊ីយ៉ា បងជ្រូក អ៊ីកអ៊ូកឈ្នះគេ។

**៤. យើងទៅរៀន**

នែពួកម៉ាក យើងកុំនៅស្ងៀម ចូរយើងទៅរៀនទាន់នៅក្មេង
យើងរីករាយ ខំរៀនផងនិងលេង វិជ្ជាផ្សេងៗនៅមត្តេយ្យសាលា។

**៥. ការងារកសិករ (បទយីកេ)**

គន់មើលវាលស្រែ ស្រូវទុំល្ហឹងល្ហើយ អើ អើ អើងអើយ កសិករយើងអើយនាំគ្នាច្រូតកាត់
ខ្លះដឹកខ្លះរែកបោកបែនប្រយ័ត្ន មិនឱ្យខ្ជាយខ្ជាត់បាត់បង់ស្រូវយើង
ណាយៗៗៗៗៗៗ ណាយៗៗ ណាយៗៗៗៗៗៗៗ។

**៦. ព្រះច័ន្ទ និងផ្កាយ(លំនាំបទ ឱផ្កាយលើមេឃ)**

ព្រះច័ន្ទ និងផ្កាយ ស្ថិតនៅសែនឆ្ងាយពីភពផែនដី ផ្កាយរះព្រិចៗ គួរឱ្យបេតី
ច័ន្ទពេញបូរមីរះមូលក្រឡង់(២ដង) បន្ទរះ ព្រះច័ន្ទនិងផ្កាយ។

**៧. ទន្លេសាប**

មិត្តអើយដឹងទេ ទន្លេមានត្រី ហើយច្រើនជាងគេ ខ្ញុំដឹងមែនៗ ចិត្តខ្ញុំគ្នាន់គ្នេរ ត្រីច្រើនជាងគេ
គឺទន្លេសាប។ បន្ទរះ មែនមែនទន្លេសាបសំបូរត្រី។(២ដង)

**៨. ពូកម្មករ**

ពោលះ អ្នកណាសង់ផ្ទះ? ពូកម្មករអ្នកណាលីសែង? ពូកម្មករ
ឱពូកម្មករៗ ញើសហូរសស្រាក់ ចិត្តគ្មានថ្នាំងថ្នាក់ លីសែងអីវ៉ាន់
មិត្តអើយមើលហ្ន ស្មាលីដៃកាន់ ជញ្ជូនអីវ៉ាន់ ផ្គត់ផ្គង់ដល់យើង
ឡាឡាឡាឡាឡា ពូកម្មករ(២ដង)។

**៩. កន្ទុបមែមួយ**

កន្ទុបៗម៉ែមួយ ម៉ែឱ្យៗចាំចាប(២ដង)
រវល់ៗតែស្ងាប អឺ អឺ អឺង អើយ ឱ្យចាបស៊ីស្រូវ(២ដង)
រំពាត់ៗម៉ែមួយ ម៉ែវាយៗឥឡូវអ៊ូយ!
ឱ្យចាបៗស៊ីស្រូវ អឺ អឺ អឺង អើយ រវល់ទៅណា(២ដង)។
បន្ទរះសូមម៉ែមេត្តាដល់តុប ព្រោះតុបនាងនៅក្មេងខ្ចី(២ដង)
មិនទាន់ៗដឹងក្ដី អឺ អឺ អឺង អើយ ប្រណីតុបម្ដង(២ដង)។

**១០. ចំការបន្លែ(លំនាំបទ មេឃពណ៌ក្រហមឆ្អៅ)**

គន់មើលចំការបន្លែ យើងដាំហើយថែ ឱ្យវាល្អពិត
ផ្លែអើយ អើយផ្លែប្រណិត ស្រឡាញ់ពេញចិត្ត ព្រោះស្លទៅឆ្ងាញ់។ (២ដង)
ត្រកួនសាលាដខាត់ណា ព្រមទាំងស្ពៃផ្កា ត្រឡាចប៉េងបោះ
បន្លែគ្រប់មុខល្អឥតខ្ចោះ ញ៉ាំទៅគ្មានទាស់ ស្រស់ហើយថ្មីផង។ (២ដង)

**១១. ប្រាសាទអង្គរ(លំនាំឡាំលាវ)**

មិត្តអើយមើលហ្ន៎ អង្គរវត្តស្អាត(២ដង)
កំពូលប្រាសាទ មិត្តអើយត្រូវចាំមានប្រាំ(២ដង)។
លានដល់ដំរី ប្រាសាទបន្ទាយស្រី(២ដង)
តាព្រហ្មប្រឹមប្រីយ៍ មិត្តអើយញញឹមជានិច្ច(២ដង)។

**១២. បូតសណ្តែក**

បូតសណ្តែក អើងអើយបូតសណ្តែក យើងនាំគ្នារែកបូតដាក់ក្នុងល្អី
មិត្តខ្លះទូល ខិតខំឃ្មាតខ្មី មិត្តខ្លះកាប់ដីបន្តទុកដាំ។
បន្ទរះ មែនហើយ មែនពិត ដេញចង្រិតចូលរន្ធ
ដេញមាន់ស្រែកខ្វក ដេញចចករត់លឿន រត់អើយរត់លឿន
រត់លឿនហុយដី អើងអើយបូតសណ្តែក។

**១៣. ភូមិស្អាត(លំនាំបទ ឱផ្កាយលើមេឃ)**

ឱ!កុមារអើយ យើងកុំកន្តើយ ត្រូវសម្អាតខ្លួន
ទាំងផ្ទះសំបែង ទាំងសាលារៀន យើងកុំខ្ជាសអៀនត្រូវតែក្លាហាន(២ដង)។
បន្ទរះ ឱកុមារអើយ ។

**១៤.ជូនពរ (លំនាំបទ អបអរសាទរ)**

យើងខ្ញុំកុមារ ជូនពរយាយតា ឱ្យបានជោគជ័យ(២ដង)
មានប្រាជ្ញាវាងវៃ សិរិសួស្តី សុភមង្គល។

**១៥. យើងដាំបន្លែ(លំនាំបទ សារិកាកែវ)**

យើងដាំបន្លែនៅខាងក្រោយផ្ទះ ផ្កាផ្លែច្រើនណាស់ទាំងគូទាំងគូ អើយទាំងគូទាំងគូ
យើងបេះស្លហូបព្រមទាំងលក់ដូរ បានផលហែហូរចិញ្ចឹមជីវិត អើយចិញ្ចឹមជីវិត។

**១៦. សាលាមត្តេយ្យ(លំនាំបទ ឱផ្កាយលើមេឃ)**

នៅក្នុងសាលា កូនធ្វើចលនា ដោយមិនខ្មាសអៀន
ចេះសូត្រកំណាព្យ ទាំងរឿងនិទាន កែច្នៃប្រិតប្រៀងដោយក្តីក្លាហាន(២ដង)។
បន្ទរះ សាលាមត្តេយ្យ។

**១៧. កុមារថ្មី**

ឱស្វាយចន្ទី យើងត្រូវសំភី ខិតខំសិក្សា
បណ្តុះប្រាជ្ញា ទឹកចិត្តហានក្លា ជាកុមារថ្មី។

**១៨. សូមទះដៃ**

| | | |
|---|---|---|
| សូមទះដៃ | មួយពីរបី | សូមដេក |
| សូមទះដៃ | មួយពីរបី | សូមងើប |
| សូមទះដៃ | មួយពីរបី | សូមសើច |
| សូមទះដៃ | មួយពីរបី | សូមយំ |
| សូមទះដៃ | មួយពីរបី | សូមហ៊ោ។ |

**១៩. កុមារចេះគួរសម(លំនាំបទ កង្ហារត្រូវខ្យល់)**

មុនពេលខ្ញុំមកសាលា ខ្ញុំលាម៉ាក់ប៉ា លើកដៃសំពះ
ដល់ពេលខ្ញុំចេញទៅផ្ទះ លើកដៃសំពះ ជម្រាបលាគ្រូ យើងរៀនៗៗ។(២ដង)

**២០. អូនមើលស្រូវ**

១ ២ ៣ ៤ ខ្មែរមាំមួនទៅច្រូតស្រូវទុំ
អាអូនកុំយំ មើលស្រូវទុំក្រហមពេញស្រែ។ (ហេ ហេ ហេ)

**២១. ចំនួនម្រាមដៃ**

ដៃឆ្វេងមានម្រាម៥ ដៃស្តាំក៏មាន៥ដែរ ឆ្វេងក៏៥ ស្តាំក៏៥
៥ និង៥ត្រូវជា១០(២ដង)។

**២២. ស្អាតជានិច្ច**

ស្អាតជានិច្ចៗ យើងកុំភ្លេចត្រូវសម្អាតកាយ ទាំងពេលគេងពេលញុំាបាយ
សម្អាតកាយមុនទៅសាលា។
សូនរូបដីៗ ហើយឃ្នាតខ្ចីរូតរះម្ទីម្ចា លាងដៃស្អាតគ្រប់វេលា
ទើបឈ្មោះថាកុមារគំរូ។

**២៣. រូបខ្ញុំ (លំនាំបទ លើកដៃឡើងរាំ)**

រូបខ្ញុំស្រស់ស្អាត ខ្ញុំខំសង្វាតដុះលាងរាល់ថ្ងៃ ភ្នែកខ្ញុំភ្លឺច្បាស់ល្អល្អះប្រពៃ
ត្រចៀកវាងវៃក្នុងការស្តាប់សួរ (២ដង)។

**២៤. ត្រូវសម្អាតខ្លួនប្រាណ (លំនាំបទ យីកេ)**

កូនប្រុសកូនស្រីថៃខ្លួនប្រាណ រក្សាឱ្យបានអើយកុំទុកយូរ
យើងត្រូវដុះលាងអើយនឹងសាប៊ូ កុំឱ្យក្លិនជូរស្អាតជានិច្ច។

**២៥.បង្ការគ្រោះថ្នាក់ (លំនាំបទដែនដីខ្មែរ)**

កុំលេងភ្លើងឬលេងកាំបិត ១ ២ នាំឱ្យមិត្តរលាកមុតផ្សា ១ ២
កុំលេងទឹកកខ្វក់រមាស់កាយា ១ ២ កុំឡើងព្រឹក្សាក្រែងគ្រោះថ្នាក់ដល់ប្រាណ។

**២៦.ក្តាមអើយ**

ក្តាមអើយ ក្តាមអើយ នាំកូនវារទៅណាដែរ ទៅស្រែ ទៅស្រែ នៅឯជើងភ្នំនោះហ្ន
ទឹកច្រើនសម្បូរហូរហៀរសប្បាយ។
ទាំងហ្វូង ទាំងហ្វូង តូចៗទៅណាស្រីមុំ ម៉ែខ្ញុំម៉ែខ្ញុំ គាត់នាំដើរលេងកម្សាន្ត
ពេលឃ្លានខ្ញុំមានចំណីទុកធី។

**២៧.ជម្រាបលោកអ្នក ខ្ញុំមិនមែនភទេ**

ម្នួកតាខ្ញុំ ត្បិតតែវាធំ តែវាស្រួលពាក់ កំពុងតែក្តៅ ពាក់ទៅត្រជាក់ ជម្រាបលោកអ្នក ខ្ញុំមិនមែនភទេ
អាវតាខ្ញុំ ត្បិតតែវាធំ តែវាស្រួលពាក់ កំពុងតែក្តៅ ពាក់ទៅត្រជាក់ ជម្រាបលោកអ្នក ខ្ញុំមិនមែនភទេ
ខោតាខ្ញុំ ត្បិតតែវាធំ តែវាស្រួលពាក់ កំពុងតែក្តៅ ពាក់ទៅត្រជាក់ ជម្រាបលោកអ្នក ខ្ញុំមិនមែនភទេ
ស្បែកជើងតាខ្ញុំ ត្បិតតែវាធំ តែវាស្រួលពាក់ កំពុងតែក្តៅ ពាក់ទៅត្រជាក់ ជម្រាបលោកអ្នកខ្ញុំមិនមែនភទេៗ។

## ចម្រៀងសម្រាប់កុមារមត្តេយ្យសិក្សាថ្នាក់កម្រិតខ្ពស់

**១.សម្រស់សួនច្បារ( លំនាំបទយីកេ )**

កូនប្រុសកូនស្រីមើលសួនច្បារ  អើអើអើងអើយ  ផ្ការីកត្រៀបត្រាអើយគួរបេតី
កុលាបសិរមាន់អើយរីកថ្មីៗ  ឯណោះក្លិនល្បីគឺចន្ទ។
រីកចម្រុះពណ៌គួរចេតនា  អើអើអើងអើយ  បើចោលនេត្រាអើយនឹងបានធូរសាយ
ទុក្ខអំពល់អើយដែលកើតយូរ  ច្នេះគួរគិតគួររកផ្កាដាំ។

**២.សិប្បកម្មទូ( លំនាំបទ ឱផ្ទៃស្រុកខ្មែរ )**

ឱផ្ទៃស្រុកខ្មែរៗ  យប់ខែភ្លឺថ្លា( ២ដង )  អ្នកស្រុកធ្វើការ  លោកអើយអ្នកអើយ
អ្នកស្រុកធ្វើការ  អឺអឺងអើយ  ធ្វើការញាប់ដៃ។
មានជាងឈូសឈើៗ  ធ្វើតុកៅអី( ២ដង )  គ្រែទូសម័យ  លោកអើយអ្នកអើយ
គ្រែទូសម័យ  អឺអឺងអើយ  ម៉ូតថ្មីល្អណាស់។

**៣.យើងរាំលេងក្រោមខែភ្លឺថ្លា ( លំនាំបទ ឱផ្ទៃស្រុកខ្មែរ )**

ឱផ្ទៃស្រុកខ្មែរៗ  យប់ខែភ្លឺថ្លា( ២ដង )  ពួកយើងកុមារ  ឱណាមិត្តអើយ
ពួកយើងកុមារ  អឺអឺងអើយ  នាំគ្នារាំលេង។
យើងលេងបិទពួនៗ  លេងចាប់កូនខ្លែង( ២ដង ) យើងរត់ប្រទ្បែង  ឱណាមិត្តអើយ
យើងរត់ប្រទ្បែង  អឺអឺងអើយ  ក្រោមខែភ្លឺថ្លា។

**៤.សិប្បកម្មឡឥដ្ឋ( លំនាំបទ ឱផ្កាយលើមេឃ )**

មិត្តអើយមើលហ្ន  មើលពូកម្មករខំប្រឹងជាន់ដី បញ្ចូលក្នុងឡទាំងប្រុសទាំងស្រី
ក្រោមកំដៅថ្ងៃខំប្រឹងធ្វើការ( ២ដង )។
មិត្តអើយមើលហ្ន  មើលពូកម្មករកំពុងរៀបឥដ្ឋ ឥដ្ឋតាន់ប្រហោងក្បឿងល្អប្រណិត
ផ្តល់ផលវិចិត្រធ្វើលំនៅឋាន( ២ដង )។

**៥.រីករាយបុណ្យ១មិថុនា ( លំនាំបទ ឱផ្កាយលើមេឃ )**

ថ្ងៃ១មិថុនា  យើងខ្ញុំកុមារសោទរពេកក្រៃ  កុមារានិងកុមារី
កិត្តិយសប្រពៃថ្លៃថ្លារុងរឿង ( ២ដង )។
កុមារអន្តរជាតិ  រីកស្រស់ឥតឃ្លាតច្បាប់និងវិន័យ  ពុកម៉ែជូនតាបងនិងពូយាយ
ជូនពរកូនថ្លៃបានសុខក្សេមក្សាន្ត ( ២ដង )។

**៦. យើងក្មេងៗនាំគ្នារាំ**

យើងក្មេងៗនាំគ្នារាំ  រាំសប្បាយៗលំហែកាយា  មកមិត្តអើយយើងនាំគ្នារាំៗ
រាំលេងសប្បាយ។  កាន់ដៃគ្នាៗ ជារង្វង់  រាល់ថ្ងៃឈប់ៗឈប់សម្រាករៀន
មិត្តអើយយើងនាំគ្នារាំៗ  រាំលេងសប្បាយ  ណាយៗៗៗៗៗៗៗៗៗៗ។

**៧. ខ្ញុំស្រឡាញ់មាតុភូមិ( លំនាំបទ ឱផ្កាយលើមេឃ )**

កម្ពុជាអើយ  ចិត្តខ្ញុំគ្មានស្បើយសែនស្រឡាញ់អ្នក  វាលភ្នំទន្លេព្រឹក្សាល្អជាក់
ខ្ញុំស្រមៃអ្នករាល់ពេលវេលា( ២ដង )។
ខ្ញុំប្តេជ្ញាថា  ធំឡើងកាលណា ខ្ញុំធ្វើយោធា  ប្តេជ្ញាកសាងហើយនិងការពារ
ដែនកម្ពុជាឱ្យគង់វង្សអើយ ( ២ដង )។

៨. ល្បែងលេងនានា(លំនាំបទឱផ្កាយលើមេឃ)

ល្បែងតុក្កតា រូបមាន់រូបឆ្មាគោសេះដំរី កូនក្រមុំជ័រទន្សាយទាត្រី
មិត្តយើងប្រុសស្រីត្រូវថែរក្សា(២ដង)។
ឡានរទេះភ្លើង ល្បែងឡុកឡាក់យើងក៏ត្រូវការពារ កុំឱ្យបែកបាក់រហែកឡើយណា
ទើបបានឈ្មោះថាកុមារសុភាព (២ដង)។

៩. យើងសាមគ្គីគ្នា(លំនាំបទឱផ្កាយលើមេឃ)

កុមារមត្តេយ្យ ទាំងប្រុសទាំងស្រីត្រូវស្រឡាញ់គ្នា
ពេលរៀនពេលលេងចិត្តយើងសាមគ្គី ជួយធុរៈគ្នាកុំខ្លាចនឿយហត់ (២ដង)។
យើងជួយស្រោចផ្កា ជួយបោសសាលាឱ្យបានមាំមួន
យើងរៀនធ្វើការឱ្យបានហ្មត់ចត់ ពេលភ័យកុំរត់ចោលមិត្តភក្តិយើង (២ដង )។

១០. វត្តភ្នំ (លំនាំបទ វិញ្ញាណទាំង៥)

ឱវត្តភ្នំរំយំរវើយ យំឆ្លងឆ្លើយស្រែកហៅគ្នីគ្នា
ឱ្យក្រោកឡើងប្រកបការងារ ចិញ្ចឹមអាត្មារួចផុតទុក្ខភ័យ
មែនហើយរួចផុតទុក្ខភ័យ។
ចំណែកខ្ញុំជាក្រុមកុមារ រីករាយអស្ចារ្យទៅសាលាមត្តេយ្យ
ក្រោកពីព្រលឹមមករៀនរាល់ថ្ងៃ គោរពវិន័យតាមច្បាប់សាលា
មែនហើយតាមច្បាប់សាលា។

១១. បណ្តាំរបស់អ្នកគ្រូ(លំនាំបទ អក្ខរាដែលបងសរសេរទៅ)

បណ្តាំដែលអ្នកគ្រូផ្តាំទៅ ថាឱ្យកូនពៅជម្រាបសួរចាស់ៗ
ម្តេចឡើយក៏ពៅមិនចាំច្បាស់(២ដង) ភ្លេចអស់សំពះភ្លេចថាអរគុណ។
ក្រោយៗសំពះចាស់ៗមុន(២ដង) រួចថាអរគុណមុនទទួលអ្វីៗ។
បន្ទរះស្តាយណាស់អ្នកគ្រូខានចែកចំណី(២ដង) ព្រោះតែថ្លាថ្លៃភ្លេចបណ្តាំអ្នកគ្រូ(២ដង)។

១២. យើងចូលរៀនសាលាមត្តេយ្យ

មត្តេយ្យសាលា ចាប់បើកទ្វារហើយអើងអើយ
មិត្តកុំកន្តើយ មិត្តអើយយើងទៅសាលា(២ដង)។
រៀនលេខហាត់គូរ គំនូរភាសាអើងអើយ
ហាត់ធ្វើចលនា មិត្តអើយបំប៉នសុខភាព(២ដង)។

១៣.កុមាររីករាយនឹងចូលរៀន(លំនាំបទ ប្រជុំគ្នារីករាយ)

កុមារជុំគ្នា រីករាយសប្បាយចិត្ត នាំគ្នាមូលមិត្ត
ចូលរៀនមត្តេយ្យសាលា ខិតខំត្រងត្រាប់ កែច្នៃគំនិតប្រាជ្ញា
ឱ្យសមកុមារ ថ្លៃថ្លាផ្ទរផង់(សិក្សា)
បន្ទរះមត្តេយ្យសាលា ឡាឡាមត្តេយ្យសាលា(២ដង) មត្តេយ្យសាលាៗសិក្សា។

១៤. ខ្ញុំលាសំឡាញ់ទៅផ្ទះ (លំនាំបទ មុនពេលយើងបែកគ្នា)

មិត្តអើយខ្ញុំសូមលាទៅ ខ្ញុំសូមលាទៅផ្ទះវិញហើយណា យើងទៅសម្រាកកាយា
ដល់ម៉ោងសិក្សាយើងជួបគ្នាវិញ ( ២ដង )។

## ១៥. ពេលភ្លៀងធ្លាក់រួច

ពេលភ្លៀងធ្លាក់រួចអើយ ទឹកដក់ពេញថ្លុក កង្កែបច្រងុកអើយ
សម្លឹងមើលហ៊ីង កំពុងតែហែលអើយ ពោះឡើងកំពឹងៗ
ខំស្រែកហៅហ៊ីង មកលេងរាំវង់ បងហ៊ីងកំប៉ោងអើយ
មើលចុះមើលឡើង លើកដៃ លើកជើងអើយ រាំតាមចង្វាក់ភ្លេង
ឯកូនកង្កែបអើយ ដែលវានៅក្មេង មិនបានរាំលេង
លបលួចមើលគេ។

## ១៦. កង្កែបចេញពីសាលា

កង្កែបៗចេញពីសាលាអ៊ើងអើយ កង្កែបៗចេញពីសាលា ទៅជួបយាយឆ្មាពាក់វ៉ែនតាធំៗ
កង្កែបតូចតូចពិត តែចេះគួរសមអ៊ើងអើយ កង្កែបតូចពិតតែចេះគួរសម
លោកយាយឆ្មាសុំ ស្គាល់ឈ្មោះសាលាៗ ។
កង្កែបឆ្លើយភ្លាម មិននៅយូរការអ៊ើងអើយ កង្កែបឆ្លើយភ្លាមមិននៅយូរការ
រៀននៅសាលា មត្តេយ្យសិក្សាធនជានក្រុងៗ ។

## ១៧. ផ្កាក្រដាស

ផ្កាអើយ អើយផ្កាក្រដាស សប្បាយចិត្តណាស់ ខ្ញុំរៀនចេះចាំ
រៀនលេខពី១ដល់៥ ខ្ញុំរៀនចេះចាំអក្សរ ក ខ ៗ។

## ១៨. ជម្រាបសួរ

ជម្រាបសួរថ្ងៃនេះជួបគ្នា សប្បាយចិត្តពេលបានឃើញគ្នា
អូឡាឡាឡាឡាឡាឡា អូឡាឡា ឡាឡាឡាឡា។
ជម្រាបសួរថ្ងៃនេះជួបគ្នា សប្បាយចិត្តពេលបានស្គាល់គ្នា
អូឡាឡា ឡាឡាឡាឡា អូឡាឡា ឡាឡាឡាឡា។

## ១៩.មេអំបៅទៅសាលា

អើយមើលមេអំបៅ ហិចហើរសំដៅទៅរកក្រេបផ្កា
ពណ៌លឿង ក្រហមបៃតងស្រស់អស្ចារ្យ អូនទៅសាលាជាមួយបងទេ(២ដង)។

## ២០. ស្អាតជានិច្ច

ស្អាតជានិច្ចៗ យើងកុំភ្លេច ត្រូវសម្អាតកាយ
ទាំងពេលគេង ពេលញ៉ាំបាយ សម្អាតកាយមុនទៅសាលា។
សូនរូបដីៗ ហើយឃ្នាតខ្មី រូតរះម្នីម្នា
លាងដៃស្អាត គ្រប់វេលា ទើបឈ្មោះថាកុមារគំរូ។

## ២១.ចំការបន្លែ (លំនាំបទមេឃពណ៌ក្រហមឆ្អៅ)

គន់មើលចំការបន្លែ យើងដាំហើយថែឱ្យវាល្អពិត
ផ្លែអើយៗ ផ្លែល្អប្រណិត ស្រឡាញ់ពេញចិត្តព្រោះស្លទៅឆ្ងាញ់(២ដង)។
ត្រកួនសាលាដខាត់ណា ព្រមទាំងស្ពៃផ្កាត្រឡាចប៉េងប៉ោះ
បន្លែគ្រប់មុខល្អឥតខ្ចោះ ញ៉ាំទៅគ្មានទាស់ ស្រស់ហើយថ្មីផង(២ដង)។

**២២. បណ្ដាំអ្នកគ្រូ**( លំនាំបទ អក្ខរាដែលបងសរសេរទៅ )

បណ្ដាំដែលអ្នកគ្រូផ្ដាំទៅ ថាឱ្យកូនពៅជម្រាបសួរចាស់ៗ
ម្ដេចឡើយក៏ពៅមិនចាំច្បាស់( ២ដង ) ភ្លេចអស់សំពះភ្លេចថាអរគុណ
ក្រោយៗ សំពះចាស់ៗ មុន( ២ដង ) រួចថាអរគុណមុនទទួលអ្វីៗ
បន្ទរៈស្ដាយណាស់អ្នកគ្រូខំចែកចំណី( ២ដង ) ព្រោះតែថ្លាថ្លៃភ្លេចបណ្ដាំអ្នកគ្រូ( ២ដង )។

**២៣. នគររាជ**

សូមពួកទេព្ដា រក្សាមហាក្សត្រយើង ឱ្យបានរុងរឿង
ដោយជ័យមង្គលសិរីសួស្ដី យើងខ្ញុំព្រះអង្គ សូមជ្រកក្រោមម្លប់ព្រះបារមី
នៃព្រះនរបតីវង្សក្សត្រា ដែលសាងប្រាសាទថ្ម គ្រប់គ្រងដែនខ្មែរបុរាណថ្កើងថ្កាន ។
ប្រាសាទសីលា កំបាំងកណ្ដាលព្រៃ គួរឱ្យស្រមៃនឹកដល់យសសក្តិ
មហានគរ ជាតិខ្មែរដូចថ្ម គង់វង្សនៅល្អរឹងប៉ឹងជំហរ
យើងសង្ឃឹមពរ ភ័ព្វព្រេងសំណាងរបស់កម្ពុជា មហារដ្ឋកើតមានយូរអង្វែងហើយ។
គ្រប់វត្តអារាម ឮតែសូរសព្ទធម៌ សូត្រដោយអំណរ
រំឭកគុណពុទ្ធសាសនា ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រតាមបែបដូនតា
គង់តែទេវតា នឹងជួយជ្រោមជ្រែងផ្គត់ផ្គង់ប្រយោជន៍ឱ្យ
ដល់ប្រទេសខ្មែរជាមហានគរ។

**២៤. ដើមល្ហុង**( លំនាំបទ ឱ! ផ្កាល្ហុង )

ឱដើមល្ហុងៗ តាខ្ញុំគាត់ដាំ ផ្លែខ្ចីស្លញ៉ាំ តាខ្ញុំដាំខ្ញុំជួយស្រោចទឹក( ២ដង ) ។
នៅពេលផ្លែវាធំពណ៌វាលឿងទុំ គួរឱ្យចង់ធី ហូបនៅថ្មីៗ
មានរសជាតិក្រៃ ផ្អែមឆ្ងាញ់អស្ចារ្យ( ២ដង )។

**២៥. សត្វទីទុយ**

មានសត្វទីទុយមួយភ្នែកធំ ស្រែកយំពីលើចុងជ្រៃ ឮសូរសម្រែកសត្វមៀមព្រៃ
ឃ្មាតខ្មីវាយំឆ្លើយឆ្លង ទីទុយ ទីទុយ ទីទុយ ទីទុយ។

**២៦. ជីតាខ្ញុំ**

ជីតាខ្ញុំគាត់នៅឯស្រែ អ៊ីយ៉ាអ៊ីយ៉ាយ៉ូ នៅឯស្រែគាត់ចិញ្ចឹមមាន់ អ៊ីយ៉ាអ៊ីយ៉ាយូ
យំឮតត តតឯណេះ យំឮតត តតឯណោះ ឯណេះក៏តតឯណាៗ ក៏តត តត។
ជីតាខ្ញុំគាត់នៅឯស្រែ អ៊ីយ៉ាអ៊ីយ៉ាយ៉ូ នៅឯស្រែគាត់ចិញ្ចឹមទា អ៊ីយ៉ាអ៊ីយ៉ាយូ
យំឮកាបកាបឯណេះ យំឮកាបកាបឯណោះ ឯណេះក៏កាប ឯណាៗ ក៏កាប កាប។
ជីតាខ្ញុំគាត់នៅឯស្រែ អ៊ីយ៉ាអ៊ីយ៉ាយ៉ូ នៅឯស្រែគាត់ចិញ្ចឹមគោ អ៊ីយ៉ាអ៊ីយ៉ាយូ
យំឮម៉ម៉ឯណេះ យំឮម៉ម៉ឯណោះ ឯណេះក៏ម៉ ឯណាៗ ក៏ម៉ម៉។
ជីតាខ្ញុំគាត់នៅឯស្រែ អ៊ីយ៉ាអ៊ីយ៉ាយ៉ូ នៅឯស្រែគាត់ចិញ្ចឹមជ្រូក អ៊ីយ៉ាអ៊ីយ៉ាយូ
យំឮអ៊ូកអ៊ូកឯណេះ យំឮអ៊ូកអ៊ូកឯណោះ ឯណេះក៏អ៊ូក ឯណាៗ ក៏អ៊ូក អ៊ូក។

**២៧. កូនមាន់តឿ**

កូនមាន់តឿ កន្ទុយរីក ហាមាត់ស្រែក សំឡេងពិរោះណាស់
កាច់របាំល្អ ស្លាបក៏ល្អ ជើងដៃក៏ស ល្អទាំងខ្លួន។ ណយ ៗ ៗ ៗ ៗ ។

**២៨. មុខរបរភូមិខ្ញុំ**( ឱ! ផ្ទៃស្រុកខ្មែរ )

| | | |
|---|---|---|
| នៅក្នុងភូមិខ្ញុំៗ | មានជាងឈូសឈើ | មានស្រីជំទើរលោកអើយអ្នកអើយ |
| មានស្រីជំទើរ | អើអឹងអើយ | អង្គុយត្បាញហូល។ |
| មានអ្នកលក់ដូរៗ | មានអ្នករកត្រី | ជនប្រុស ជនស្រី លោកអើយអ្នកអើយ |
| ជនប្រុស ជនស្រី | អើអឹងអើយ | មិនភ័យអត់ឃ្លាន។ |

**២៩. កុំប្រទ្បែងគ្នាលេង** (លំនាំបទ អុំទូក )

| | | |
|---|---|---|
| អើយយើងនាំគ្នាទៅ | ឱណានាងណា | ទៅជិះទូកលេង( ២ដង ) |
| យើងមិនៗ ប្រលែង | ឱណានាងណា | ខ្លាចទូកយើងលិច( ២ដង )។ |

**៣០. ពេលសប្បាយ**

| | | |
|---|---|---|
| ពេលសប្បាយ | ពេលយើងរីករាយ | យើងត្រូវទះដៃ( ទះដៃ២ដង ) |
| យើងទះដៃ | មិត្តរាល់គ្នាបើមិនសប្បាយក៏ត្រូវទះដៃ( ទះដៃ២ដង )។ | |
| ពេលសប្បាយ | ពេលយើងរីករាយ | យើងត្រូវទះស្មា( ទះស្មា២ដង ) |
| យើងទះស្មា | មិត្តរាល់គ្នាបើមិនសប្បាយក៏ត្រូវទះស្មា ( ទះស្មា២ដង )។ | |
| ពេលសប្បាយ | ពេលយើងរីករាយ | យើងត្រូវទះក្បាល( ទះក្បាល២ដង |
| យើងទះក្បាល | មិត្តរាល់គ្នាបើមិនសប្បាយក៏ត្រូវទះក្បាល( ទះក្បាល២ដង )។ | |
| ពេលសប្បាយ | ពេលយើងរីករាយ | យើងត្រូវគោះជើង( គោះជើង២ដង ) |
| យើងគោះជើង | មិត្តរាល់គ្នាបើមិនសប្បាយក៏ត្រូវគោះជើង ( គោះជើង២ដង )។ | |

**៣១. អក្ខរក្រម**( លំនាំបទ តាចាស់ចង់បានប្រពន្ធក្មេង )

| | |
|---|---|
| ក ខ ខិតខំសំភី | គ គា គិ គី គឺកូនគីង្គក់ |
| ឃ ឃា កុំដេកទ្រមក់ | ង ងើបកុំងក់ ក ខ គ ឃ ង។ |
| ច ចា រាបសារម្សេទម | ឆ ឆី សមរម្យ ជ ជួបសំពះ |
| ឈ ឈប់ ឆាឆៅចាស់ៗ | ញញឹមកុំខ្មាស់ ច ឆ ជ ឈ ញ។ |
| ដ ឋ ឌ ឍ និង ណ | រីករាយត្រេកអរ ទៅសាលារៀន |
| ត តាតាមដំបូន្មាន | សង្វាតសូត្ររៀន ត ថ ទ ធ ន។ |
| ប ផ ព ភ និង ម | រីករាយសាទរមិនទាស់ទែងគ្នា |
| យ រ ល វ សាមគ្គា | ស ហ ឡ អ ជាសាមសិបបីតួ។ |

ឧបសម្ព័ន្ធទី ២

# គរុកោសល្យរៀន និងបង្រៀន

# ដើម្បីឆ្លើយតបសមភាពយេនឌ័ររវាងកុមារី និងកុមារានៅមត្តេយ្យសិក្សា



សម្រាប់ជំនួយដល់គ្រូមត្តេយ្យសិក្សាដឹកនាំ
សកម្មភាពរៀន និងបង្រៀន

## ១-សេចក្តីផ្តើម

សមភាពយេនឌ័រ មិនមែនគ្រាន់តែជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការកសាងនិងរក្សាសន្តិភាព ភាពរុងរឿង និងស្ថិរភាពក្នុងសង្គមលើពិភពលោកផងដែរ។ ការផ្តល់ឱ្យស្ត្រី និងកុមារីនូវភាពស្មើគ្នាក្នុងការទទួលបាននូវការអប់រំ ការថែទាំសុខភាព ការងារដ៏ត្រឹមត្រូវ និងការត្រៀមជាស្រេចក្នុងការចូលរួមក្នុងដំណើរការសម្រេចចិត្តផ្សេងៗ ក្នុងសង្គមមួយដែលមានសមភាព និងស្ថិរភាព។

## ២-ស្ថានភាពទូទៅ

ផ្អែកលើស្ថានភាពជាក់ស្តែងក្នុងសង្គមកម្ពុជា ជារឿយៗឪពុកម្តាយនិងអ្នកថែកុមារមិនបានដឹងថាពួកគាត់បានបន្តបង្ហាញនូវផ្នត់គំនិតលម្អៀងជំនឿអំពីតួនាទីខុសគ្នារវាងបុរសនិងស្ត្រីនោះទេ។ កុមារីមួយចំនួនត្រូវបានទទួលការថែទាំនិងចិញ្ចឹមបីបាច់ខុសគ្នាពីកុមារា ជាទូទៅកុមារីត្រូវបានរៀបចំឱ្យស្លៀកពាក់ទៅតាមពណ៌ ដូចជាពណ៌ផ្កាឈូក ពណ៌ក្រហម ពណ៌ស្វាយជាដើម ហើយប្រដាប់លេងទៀតសោត គឺកូនក្រមុំ តុក្កតា និងប្រដាប់ប្រដាជាំស្ល គឺសម្រាប់កុមារីលេង រីឯបាល់ និងកូនឡាន សម្រាប់កុមារាលេង។ កូនស្រីត្រូវបានបង្រៀនឱ្យស្តាប់បង្គាប់និងសុភាពរាបសា រីឯកុមារាត្រូវបានបង្រៀនឱ្យក្លាហាន និងរឹងមាំ ជួនកាលកុមារីត្រូវបានការពារម៉ត់ចត់ជាងកុមារា ទន្ទឹមនឹងនេះកុមារាត្រូវបានបង្រៀនមិនឱ្យយំព្រោះជាសញ្ញាបង្ហាញថាទន់ខ្សោយ ។

នៅតាមសាលារៀន យើងសង្កេតឃើញថាការរៀបចំសកម្មភាពរៀននិងបង្រៀននៅកម្រិតមត្តេយ្យសិក្សាមួយចំនួន មិនទាន់ទទួលបាននូវបរិយាកាសរៀនសូត្រដែលមានលក្ខណៈសមភាពយេនឌ័ររវាងកុមារីនិងកុមារានៅឡើយទេ។ កត្តាទាំងអស់នោះ គឺដោយសារតែចំណេះដឹង និងការអនុវត្តរបស់គ្រូផ្អែកលើផ្នត់គំនិតអវិជ្ជមានដែលបន្សល់ទុកតាំងពីដើមមក នឹងផ្អែកទៅលើកម្រិតចំណេះដឹងរបស់គ្រូជាពិសេសគ្រូមត្តេយ្យសិក្សាសហគមន៍ដែលមានការបណ្តុះបណ្តាលមិនទាន់គ្រប់គ្រាន់នៅឡើយ។ បញ្ហាដែលបានបន្សល់ទុកទាំងនោះមានដូចជា កុមារីឆាប់ភ័យខ្លាចនៅពេលកុមារាស្រែកសម្លុតមិនសូវមានទំនុកចិត្តក្នុងការដឹកនាំក្រុម មិនហ៊ានហក់លោតខ្លាំងដូចកុមារា (ឡើងទីខ្ពស់ ឬលេងបាល់ទាត់។ល។) មិនហ៊ានជ្រើសរើសពណ៌ដែលខ្លួនចូលចិត្ត ត្រូវបានមនុស្សចាស់បង្ហាក់មិនឱ្យហក់លោតច្រើនពេកទេ ព្រោះខ្លួនជាកូនស្រី មិនសូវក្លាហានក្នុងការនិយាយខ្លាចខុស ហើយត្រូវបានគ្រូឱ្យធ្វើតែការងារណាដែលកុមារីធ្លាប់ធ្វើទៅតាមទម្លាប់ពីដើមមក ដូចជាការរៀបចំថ្នាក់ ជូត ឬទុកដាក់សម្ភារៈ(មិនប្រើកុមារា)។ល។ចំណែកកុមារាមួយចំនួនក៏នៅមិនទាន់មានសមភាពដែរ ដូចជាកុមារា មានសកម្មភាពរពិស និងចូលចិត្តស្រែកសម្លុតដាក់កុមារី និងកុមារាខ្លះដណ្តើមល្បែងលេងពីកុមារី និងមិនអាចរើសយកអ្វីដែលជារបស់ចំណូលចិត្តរបស់កុមារី ពេលខ្លះកុមារាមិនអាចលេងល្បែងដែលកុមារីមានទម្លាប់លេង។

បើយើងគិតឱ្យបានល្អិតល្អន់ យើងឃើញថា ទាំងនេះគឺជាកត្តាសំខាន់ដែលយើងមិនត្រូវមើលរំលងឡើយ ព្រោះទម្លាប់នៃភាពមិនមានសមភាពនេះហើយដែលធ្វើឱ្យជះឥទ្ធិពលអវិជ្ជមានដល់សង្គមនៅពេលដែលកុមារទាំងនោះបានក្លាយទៅជាមនុស្សពេញវ័យ

## ៣. គរុកោសល្យនៃសកម្មភាពបង្រៀននិងរៀនឆ្លើយតបសមភាពយេនឌ័ររវាងកុមារា និងកុមារី

គរុកោសល្យនៃសកម្មភាពរៀននិងបង្រៀន ឆ្លើយតបទៅនឹងសមភាពយេនឌ័រ សំដៅទៅលើសកម្មភាពដែលផ្តោតសំខាន់ទៅលើតម្រូវការនៃការសិក្សាជាក់លាក់របស់កុមារី និងកុមារា។ ទាំងនេះតម្រូវឱ្យគ្រូនិងគណៈគ្រប់គ្រងសាលារៀន គឺជាអ្នកដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រនៅក្នុងដំណើរការនៃសកម្មភាពរៀននិងបង្រៀន។

គរុកោសល្យនៃសកម្មភាពបង្រៀនដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ នឹងត្រូវបានលើកកម្ពស់ឱ្យមានការឆ្លុះបញ្ចាំងអំពីជំនឿរបស់ពួកគាត់ផ្ទាល់ទៅលើតួនាទីយេនឌ័រ ដែលមានតាំងពីយូរណាស់មកហើយ។ ការអនុវត្តបន្តិចម្តងៗជាបន្តបន្ទាប់ វានឹងជួយគ្រូក្នុងការផ្តល់ឱកាសស្មើគ្នារវាងកុមារី និងកុមារាក្នុងការចូលរួមសកម្មភាពរៀនសូត្រនិងលេងល្បែងនៅមត្តេយ្យសិក្សាមិនចំពោះតែកុមារី ឬកុមារានោះទេ។ បន្ថែមពីលើនេះទៅទៀត គរុកោសល្យនៃសកម្មភាពរៀននិងបង្រៀនឱ្យឆ្លើយតបទៅនឹងសមភាពយេនឌ័រនឹងបង្ហាញផ្លូវគ្រូក្នុងការជួយឱ្យសកម្មភាពដោយស្មើភាពគ្នារវាងកុមារី និងកុមារា។

*ហេតុអ្វីបានជាត្រូវមានគរុកោសល្យនៃការអប់រំរបស់គ្រូ ឱ្យឆ្លើយតបទៅនឹងសមភាពយេនឌ័ររវាងកុមារានិងកុមារី?*

គរុកោសល្យនៃការអប់រំកុមារដែលតម្រូវឱ្យមានការឆ្លើយតបទៅនឹងសមភាពរវាងកុមារា និងកុមារី គឺត្រូវតែមានទំនាក់ទំនងនៅក្នុងដំណើរការរៀននិងបង្រៀន សកម្មភាពក្នុងនិងក្រៅថ្នាក់រៀនដែលមានតួនាទីសំខាន់ ដើម្បីកំណត់ឱ្យកុមារទទួលបាននូវការបន្តចូលរួមនិងការអនុវត្តសមត្ថភាពរៀននៅក្នុងថ្នាក់រៀន។ ក្នុងនាមជាគ្រូមត្តេយ្យសិក្សា អ្នកអាចជួយកុមារឱ្យមានទំនាក់ទំនងដោយសមភាពរវាងកុមារានិងកុមារី ក្នុងលក្ខណៈជាវិជ្ជមានដោយទទួលបាននូវឱកាសរៀនសូត្រ និងអភិវឌ្ឍន៍ស្មើគ្នា។

## ៤- គោលបំណងនៃឯកសារ

ឯកសារនេះ រៀបចំឡើងដើម្បីជាជំនួយបន្ថែមដល់គ្រូមត្តេយ្យសិក្សា ធ្វើឱ្យកាន់តែប្រសើរឡើងនូវ៖

(១). ការរៀបចំផែនការបង្រៀន

(២). ការបង្រៀន និងបរិស្ថានសិក្សា

(៣). ការរៀបចំកន្លែងអង្គុយ ក្នុងពេលរៀន

(៤). ការលេងក្នុងនិងក្រៅថ្នាក់

(៥). ការប្រើភាសាក្នុងការប្រាស្រ័យទាក់ទងជាមួយកុមារពេលដឹកនាំសកម្មភាពរៀននិងបង្រៀន

(៦).ការធ្វើការទំនាក់ទំនងជាមួយឪពុកម្តាយ ឬអ្នកអាណាព្យាបាល។

## ៥. ខ្លឹមសារសំខាន់ៗ

**ខ្លឹមសារសំខាន់ៗដែលត្រូវយកចិត្តទុកដាក់**




### ក. ការរៀបចំផែនការបង្រៀន

គ្រូត្រូវមានផែនការបង្រៀនដែលបានរៀបចំជាស្រេចនូវសម្ភារៈបង្រៀន សម្រាប់មេរៀននីមួយៗ ឆ្លើយតបទៅនឹងតម្រូវការនិងលទ្ធផលសិក្សារបស់កុមារ។ គ្រូគួរត្រៀមនិងគិតទៅដល់ចំណុចមួយចំនួនដូចខាងក្រោម៖

- តើត្រូវបង្រៀនដូចម្តេច ដើម្បីតម្រូវទៅនឹងចំនួនកុមារដែលមាននៅក្នុងថ្នាក់?
- រៀបចំបរិស្ថានថ្នាក់រៀន គិតបញ្ចូលរបៀបអង្គុយរបស់កុមារ
- តើកុមារត្រូវការប្រើសម្ភារៈអ្វីខ្លះ?

- តើត្រូវនិយាយយ៉ាងដូចម្ដេច ដើម្បីធ្វើការទំនាក់ទំនងជាមួយកុមារ ឱ្យមានលក្ខណៈរីករាយ និងស្មើភាព?
- តើត្រូវធ្វើអ្វីខ្លះដើម្បីឱ្យមានការទំនាក់ទំនងជាមួយឪពុកម្ដាយឬអាណាព្យាបាលកុមារក្នុងការជួយយកចិត្តទុកដាក់ជាមួយកូនស្មើៗគ្នានៅផ្ទះបន្ថែមទៀត?

**គន្លឹះសំខាន់ៗក្នុងពេលរៀបចំផែនការ បង្រៀន**

- *ធានាថាកុមាររីករាយ និងចូលចិត្តសកម្មភាពដែលអ្នករៀបចំ ចៀសវាងការ ផ្ដោតតែទៅលើកុមារី ឬកុមារា។*
- *គ្រូអាចនិយាយចែករំលែក នូវបទពិសោធន៍ជាក់ស្ដែងរបស់អ្នក ដែលកំពុងតែ ប្រឈមនឹងទទួល ខុសត្រូវ ឧទាហរណ៍ពេលខ្លះប្ដីរបស់អ្នកគ្រូ ដាំស្ល) បោកគក់ខោអាវ លាងចាន។ល។*
- *នៅក្នុងមេរៀនអំពីមុខរបរ គ្រូគួរនិយាយពិភាក្សាអំពីការទទួលខុសត្រូវរបស់ មុខជំនាញនីមួយៗដែល បុរស និងស្ត្រីក៏អាចធ្វើបានដូចគ្នា រួមទាំង។*
- *ចៀសវាងការសន្និដ្ឋានក្នុងកំឡុងការសន្ទនាដូចជាឪពុកដែល មិនចេះដាំស្លគឺ ជាឪពុកមិនល្អ ជាដើម។*
- *នៅពេលដែលអ្នកធ្វើផែនការចូរអ្នកចាំថាអ្នកចង់ឱ្យកុមារទទួលស្គាល់និងយល់អំពីកុមារីនិងកុមារា ស្ត្រីនិងបុរស។*

**ខ-ការបង្រៀន និងបរិយាកាសសិក្សា**

- **ការបង្រៀន៖** នៅក្នុងមេរៀនមួយ គ្រូបង្កឱកាសសម្រាប់កុមារដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយមិត្តរបស់ពួកគេពីម្នាក់ទៅម្នាក់ទៀត ប្រើប្រាស់វិធីសាស្ត្រធ្វើការងារជាក្រុមដែលអាចលើកទឹកចិត្តកុមារទាំងអស់ឱ្យមានឱកាសបានការចូលរួមមតិយោបល់ ការសហការគ្នាក្នុងការធ្វើការងារ ហើយនៅពេលដែលកុមារបានធ្វើការងារជាមួយដៃគូពួកគេ នឹងបានអភិវឌ្ឍន៍បំណិនក្នុងការនិយាយប្រាស្រ័យទាក់ទងគ្នាយ៉ាងមានប្រសិទ្ធភាព ធ្វើឱ្យពួកគេមានទំនុកចិត្តចំពោះខ្លួនគេផ្ទាល់ និងមានភាពស្និទ្ធស្នាលជាមួយកុមារផ្ទុយភេទក្នុងការប្រាស្រ័យទាក់ទងទៀតផង។ បំណិនសង្គមទាំងនោះគឺយើងពិតជាត្រូវការប្រើប្រាស់ក្នុងជីវិតនៅពេលដែលពួកគេក្លាយជាមនុស្សធំ នៅពេលដែលពួកគេនឹងត្រូវធ្វើការទំនាក់ទំនងគ្នាក្នុងការងារដែលមានបុរស និងស្រីធ្វើការជាមួយគ្នា។
- **បរិយាកាសសិក្សា៖** សកម្មភាពនៃការបង្រៀននិងការរៀនអាចធ្វើឡើងនៅក្នុងនិងក្រៅថ្នាក់។ ការឆ្លើយតបបែបសមភាពរវាងកុមារីនិងកុមារាក្នុងសកម្មភាពរៀននិងបង្រៀនអាចកំណត់បាន តាមរយៈការរៀបចំកន្លែងធ្វើសកម្មភាពឬកន្លែងអង្គុយរៀនរបស់កុមារ ការរៀបចំគ្រប់គ្រងថ្នាក់រៀន ការរៀបចំការងារជាក្រុមរបស់កុមារ ការរៀបចំសកម្មភាពរៀនក្នុងនិងក្រៅថ្នាក់ដោយរៀបចំសកម្មភាពរៀនតាមរយៈការលេងរបស់កុមារ (Learning Through Play)។



## គ. ការរៀបចំកន្លែងអង្គុយ ក្នុងពេលធ្វើសកម្មភាពរៀន

- បែងចែកកុមារជាក្រុមការងារ ដែលក្នុងក្រុមនីមួយៗ មានកុមារី និងកុមារា លាយគ្នាដើម្បីឱ្យពួកគេបានចូលរួមធ្វើការងារ ឬលេងជាក្រុមដែលមានចម្រុះភេទ។
- ផ្លាស់ប្តូរក្រុមជាប្រចាំ ដើម្បីឱ្យកុមារបានចូលរួម និងបានផ្សារភ្ជាប់ទំនាក់ទំនងរវាងគ្នានិងគ្នាជាមួយមិត្ត និងទំនាក់ទំនងបន្តពីម្នាក់ទៅម្នាក់ទៀតនៅក្នុងថ្នាក់រៀន។
- រៀបកុមារឱ្យអង្គុយជារាងរង្វង់ ដោយឆ្លាស់គ្នារវាងកុមារីនិងកុមារាដើម្បីឱ្យពួកគាត់បានធ្វើការរួមគ្នាចូលរួមបានគ្រប់គ្នា ស្មើភាពគ្នា និងមានការទំនាក់ទំនងគ្នារវាងភេទផ្សេងគ្នា។



## ឃ. ការលេងក្នុង និងក្រៅថ្នាក់

ការរៀនតាមរយៈការលេង(Learning Through Play) គឺជាមធ្យោបាយដ៏សំខាន់ណាស់ និងមានប្រសិទ្ធភាពបំផុតជាពិសេសគឺចំពោះកុមារវ័យមត្តេយ្យសិក្សា។ សម្ភារៈល្បែង និងការប្រាស្រ័យទាក់ទងគ្នាក្នុងការលេងជាមួយដៃគូ នឹងជួយឱ្យកុមារបានលេងទាំងអស់គ្នា និងដោះស្រាយបញ្ហាក្នុងការលេង

រួមគ្នា។  ការលេងគឺនាំឱ្យកុមារបានរៀនហើយកុមារអាចលេងជាមួយកុមារដ៏ទៃដែលមានក្រុមអាយុចម្រុះ និងភេទផ្សេងគ្នា។ យ៉ាងណាក៏ដោយក៏កុមារានិងកុមារីច្រើនតែចូលចិត្តលេងអ្វីផ្សេងពីគ្នា  ដែលជាហេតុផលធ្វើឱ្យពួកគាត់យល់ថាកុមារីនិងកុមារា គឺមានភាពខុសគ្នាឆ្ងាយមិនអាចធ្វើអ្វីដូចគ្នាបានទេ។ កុមារាចូលចិត្តលេងអ្វីដែលរពឹសជាង ប្រទាឹមជាង រហ័សរហួនជាង ត្រូវការទីកន្លែងទូលាយ ដូចជា កុមារាចូលចិត្តលេងបាល់ទាត់ នៅពេលដែលកុមារីចូលចិត្តលេងល្បែងដែលងាយៗយឺតៗ ដូចជា លេងផ្ទឹះគ្រាប់គ្រួសជាដើម។ កំណត់សម្គាល់ទាំងអស់ខាងលើនេះ នឹងមានការជះឥទ្ធិពលដល់ការគិត និងលទ្ធផលរបស់កុមារ។





- អ្នកត្រូវចងចាំថាកុមារី និងកុមារាមានរាងកាយមាំមួន និងត្រូវការធ្វើចលនាដូចគ្នារហូតដល់ពេលដែលពួកគេពេញវ័យ ប៉ុន្តែកុមារី ច្រើនតែអាចបង្ហាញពីអត្តចរិតទំនាក់ទំនងសង្គមបានប្រសើរជាង។
- លើកទឹកចិត្តកុមារលេងល្បែងជាក្រុម ដែលមានសមាសភាពកុមារីលាយចម្រុះជាមួយកុមារា ក្នុងការលេង ឬធ្វើការងារជាក្រុម។
- ល្បែងមួយចំនួនមានការលេង ដោយកុមារា ឬក៏កុមារី តែប៉ុណ្ណោះ ពួកគាត់មិនដែលលេងចូលគ្នាទេ ឧទាហរណ៍ បាល់ លេងកូនក្រមុំ លេងល្បែងសំណង់ និងលេងលោតអន្ទាក់។ល។ ដូច្នេះគ្រូត្រូវលើកទឹកចិត្តនិងរៀបចំសកម្មភាពបង្រៀនអំពីរបៀបលេងដល់កុមារ ឱ្យពួកគាត់អាចលេងជាមួយគ្នាបាន។
- លើកសរសើរ កុមារី កុមារាដែលមានការផ្លាស់ប្តូរបាននូវទម្លាប់លេងជាមួយគ្នា និងចេះផ្តល់តម្លៃឱ្យគ្នាទៅវិញទៅមក។





### ខ. ការប្រាស្រ័យទាក់ទង និងការប្រើប្រាស់ការនិយាយជាមួយកុមារ

ការប្រាស្រ័យទាក់ទងរវាងគ្រូ និងសិស្ស គឺជាកត្តាដ៏សំខាន់បំផុតដែលត្រូវប្រើជាមួយកុមារក្នុងថ្នាក់រៀន ព្រោះវាត្រូវតែជាភាសាដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ ។ ការនិយាយស្តី ដែលមានលក្ខណៈឆ្លើយតបទៅនឹងសមភាពយេនឌ័រដែលវាអាចធ្វើឱ្យកុមារមានអារម្មណ៍ថា ត្រូវទទួលបានការគោរព និងឱ្យតម្លៃ ដូចជាការលើកទឹកចិត្តកុមារដែលនឹងធ្វើឱ្យការរៀនសូត្របានប្រសើរឡើង បន្ថែមពីនេះទៀតបានបង្ករបរិយាកាសល្អក្នុងការសិក្សាដែលកុមារអាចបញ្ចេញគំនិតខ្លួនឯងដោយសេរី ក្រោមការសម្របសម្រួលពីសំណាក់គ្រូមត្តេយ្យសិក្សា។

ការរៀនដែលមានការផ្តល់តម្លៃឱ្យកុមារ ធ្វើឱ្យកុមារមានទំនុកចិត្ត មានសេចក្តីក្លាហាន និងមានអារម្មណ៍ត្រូវបានលើកទឹកចិត្ត មានការយកចិត្តទុកដាក់ ដែលនាំឱ្យលទ្ធផលនៃការសិក្សារបស់ពួកគេកាន់តែប្រសើរឡើង។ ផ្ទុយទៅវិញ ការនិយាយឬប្រើភាសាមិនល្អ និងកាយវិការដែលមិនសមរម្យ ដូចជាកាយវិការ ទឹកមុខ ប្រើភ្នែកសម្លក់ បែបគំរាមកំហែង ទៅលើកុមារីឬកុមារា អាចធ្វើឱ្យកុមារចម្លងតាមនូវទស្សនៈអវិជ្ជមានចំពោះសមភាពយេនឌ័រ និងជាសារដែលកុមារនឹងរៀនតាមរយៈការប្រាស្រ័យទាក់ទងពីមនុស្សម្នាក់ទៅម្នាក់ទៀតផងដែរ។

### ច. ការប្រាស្រ័យទាក់ទងរវាងគ្រូ និងឪពុកម្តាយ

ជារឿយៗ ឪពុកម្តាយនិងអ្នកមើលថែកុមារ មិនបានដឹងថាពួកគាត់ បន្តការបង្ហាញនូវអត្តចរិត និងជំនឿអំពីតួនាទីខុសគ្នារវាងបុរសនិងស្ត្រីនោះទេ ហើយកុមារាភាគច្រើនថែទាំនិងចិញ្ចឹមខុសគ្នាពីកុមារី។ ជាទូទៅកុមារីត្រូវបានរៀបចំឱ្យស្លៀកពាក់ទៅតាមពណ៌ដូចជាពណ៌ផ្កាឈូកពណ៌ស្វាយ ហើយសម្ភារៈលេងទៀតសោតមានដុចជា កូនក្រមុំ តុក្កតា គឺសម្រាប់កុមារីលេង រីឯបាល់ ឬកូនឡាន សម្រាប់តែកុមារាលេង។ កូនស្រីត្រូវបានបង្រៀនឱ្យស្តាប់បង្គាប់សុភាពរាបសា កុមារាត្រូវបានបង្រៀនឱ្យក្លាហានរឹងមាំជួនកាលកុមារី ត្រូវបានការពារម៉ត់ចត់ជាងកុមារា។ ទន្ទឹមនឹងនេះដែរ កុមារាត្រូវបានបង្រៀនមិនឱ្យយំព្រោះជាសញ្ញាបង្ហាញថា ទន់ខ្សោយ។ ឪពុកម្តាយ ក៏បានបង្ហាញនូវទស្សនៈលម្អៀងមួយចំនួន ដូចជា ស្ត្រីត្រូវធ្វើការងារផ្ទះ ដូចជាបោសសម្អាតផ្ទះ បោកគក់ខោអាវ ធ្វើម្ហូបជាដើម។ ចំណែកបុរស ធ្វើការងារក្រៅ

ផ្ទះ។ ដើម្បីដោះស្រាយបញ្ហា ផ្ទត់គំនិតអវិជ្ជមាន អំពីសមភាពយេនឌ័រ នៅក្នុងគ្រួសារ និងសហគមន៍របស់កុមារ អ្នកត្រូវធ្វើការជិតស្និទ្ធជាមួយសហគមន៍ ។

**ចំណុចដែលត្រូវយកចិត្តទុកដាក់បន្ថែម ដើម្បីចូលរួមចំណែក លើកកម្ពស់សមភាព រវាងកុមារា និងកុមារី ចំពោះការប្រាស្រ័យទាក់ទង រវាងគ្រូ និងឪពុកម្ដាយ**

- *នៅពេលដែលកុមារបង្ហាញអំពីចរិតវិសេសអើង ត្រូវ ព្យាយាមទទួលព័ត៌មានបន្ថែមអំពីស្ថានភាព និងហេតុផលដែលនាំឱ្យកុមារមានចរិតបែបនេះ។*
- *ព្យាយាមរកពេលសន្ទនាជាលក្ខណៈឯកជន ជាមួយឪពុកម្ដាយ ឬអាណាព្យាបាលកុមារដើម្បី ពិភាក្សារកឱកាសចំណេញស្មើគ្នានិងគោរពការជួយរបស់ពួកគាត់។*
- *ត្រូវចងចាំថា ការគោរពគ្នាទៅវិញទៅមកគឺជា*



របស់កុមារនូវព័ត៌មានសំខាន់ៗ មួយចំនួន អំពីការរីកចម្រើនរបស់កុមារ។

- ព័ត៌មានសំខាន់ៗបានមកពីការវាយតម្លៃ ក៏ត្រូវបានប្រើប្រាស់ ផងដែរសម្រាប់ប្រសិទ្ធភាពនៃសកម្មភាពបង្រៀននិងរៀន ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សារបស់កុមារ។
- នៅពេលធ្វើការវាយតម្លៃ អ្នកនឹងត្រូវមានមោទនភាព ព្រោះអ្នកដឹងថា អ្វីដែលអ្នកកំពុងធ្វើគឺត្រឹមត្រូវដូចដែលមានគ្រោងទុក។
- ការសង្កេតរបស់អ្នកទៅលើកុមារី និងកុមារានឹងជួយអ្នកឱ្យវាយតម្លៃអំពី ការប្រាស្រ័យទាក់ទងក្នុងសមភាពយេនឌ័រ។
- ប្រើប្រាស់ព័ត៌មាន ដែលអ្នកបានប្រមូល ដើម្បីជួយកុមារឱ្យប្រសើរឡើងនូវ អត្តចរិត អាកប្បកិរិយា តម្លៃ និងការសិក្សារៀនសូត្រ។





### គន្លឹះសំខាន់ៗ

- វិធីដែលល្អបំផុតក្នុងការវាយតម្លៃកុមារគឺ "ការសង្កេត"។ តាមរយៈការសង្កេត អ្នកនឹងបានដឹងថាតើមានផ្នត់គំនិតអ្វីខ្លះដែលរារាំងនៅក្នុងថ្នាក់ដែលជាឧបសគ្គក្នុងការសិក្សារបស់កុមារ។
- លើកទឹកចិត្តកុមារ ឱ្យលេងល្បែងណាដែលជាធម្មតាលេងដោយភេទផ្ទុយបាន ដូចជា បាល់បាញ់កៅស៊ូកង លោតអន្ទាក់ កូនក្រមុំ។ល។
- អ្នកអាចសួរសំណួរទៅកុមារម្នាក់ៗ អ្នកនឹងបានដឹងអំពី ការយល់ដឹង ផ្នត់គំនិត និងការអនុវត្តរបស់កុមារជុំវិញ រឿងរ៉ាវនៃផ្នត់គំនិតយេនឌ័រ។
- នៅពេលអ្នកធ្វើការសង្កេត អ្នកគួរផ្តោតទៅលើ ការបញ្ចេញមតិ ការធ្វើកាយវិការ ការច្រៀង រាំ និងគូររូបរបស់កុមារ។ល។

## ឧទាហរណ៍មួយអំពីឧបករណ៍សម្រាប់ធ្វើការសង្កេត៖

*គំរូឧទាហរណ៍នេះ គឺមានប្រយោជន៍សម្រាប់ធ្វើការសង្កេត អាកប្បកិរិយារបស់កុមារ។*
*បញ្ជាក់៖ អ្នកអាចកែសម្រួលទៅតាមតម្រូវការជាក់ស្តែងនៃថ្នាក់រៀនរបស់អ្នក។*

| ឈ្មោះ របស់កុមារ | ចំណុចដែលធ្វើបាន | យោបល់បន្ថែម |
|---|---|---|
| *ការប្រាស្រ័យទាក់ទងជាមួយដៃគូ* | ✓ | *ជាមួយអ្នកណា ?* |
| *ការប្រាស្រ័យទាក់ទងជាមួយដៃគូដែលជាភេទ ផ្ទុយគ្នា* | ✓ | *ជាមួយអ្នកណា ?* |
| *មិនមានការខុសគ្នានៅពេលធ្វើការទំនាក់ទំនង ពេលនិយាយទៅកាន់ដៃគូជាភេទផ្ទុយគ្នា* | ✓ | *ធ្វើការអធិប្បាយ* |
| *លេងនៅក្បែរកុមារដែលមានភេទផ្ទុយ* | ✓ | *ជាមួយអ្នកណា ?* |
| *ចូលរួមលេងជាមួយដៃគូដែលជាភេទផ្ទុយ* | × | *លេងជាមួយអ្នកណា ?* |
| *ចូលរួមលេងជាមួយសម្ភារៈរៀន* | × | *សម្ភារៈអ្វីខ្លះ ?* |
| *ចូលរួមលេងជាមួយសម្ភារៈ ដែលមិនមានផ្នត់គំនិត យេនឌ័រ* | ✓ | *លេងដូចម្តេច ?* |
| *រូបដែលកុមារបានគូរ រួចមាន រូបកុមារា និងរូបកុមារី* | ✓ | *ធ្វើការអធិប្បាយ* |
| *បាននិទានរឿងប្រាប់អំពី សាច់រឿងដែលមានតួអង្គទាំងពីរភេទ* | ✓ | *ធ្វើការអធិប្បាយ* |

## យេនឌ័រ និងសិក្សាសង្គម

ដើម្បីឆ្លើយតបសមភាពយេនឌ័រសម្រាប់មុខវិជ្ជាសិក្សាសង្គម គ្រូមត្តេយ្យសិក្សាត្រូវយកចិត្តទុកដាក់ចំណុចសំខាន់ៗមួយចំនួនដូចជា៖

- ✓ នៅមុនពេលធ្វើសកម្មភាពនីមួយៗ ត្រូវរៀបចំ សម្ភារៈ ឱ្យបានគ្រប់គ្រាន់ដើម្បីជានាថា កុមារានិងកុមារីចូលចិត្ត និងអាចធ្វើបាន។
- ✓ ករណីមានការងារជាក្រុម ត្រូវរៀបចំបែងចែកជាក្រុមដោយលើកទឹកចិត្តកុមារឱ្យចេះចូលរួមធ្វើសកម្មភាពជាមួយភេទផ្ទុយគ្នា ដោយណែនាំឱ្យកុមារចេះគោរព និងផ្តល់តម្លៃឱ្យគ្នាទៅវិញទៅមកក្នុងការងារឬការលេងជាក្រុម។
- ✓ លើកសរសើរកុមារណាដែលមានទម្លាប់ធ្វើកិច្ចការរួមគ្នាដែលមានសមាសភាពចំរុះរវាងកុមារី និងកុមារា។
- ✓ ត្រូវលើកទឹកចិត្តកុមារា ឱ្យអាចធ្វើកិច្ចការដែលកុមារីធ្វើបានហើយកុមារាមិនធ្លាប់ធ្វើបានកន្លងមក ដូចជាកុមារាអាចអាចរាំត្រូវចង្វាក់ដូចកុមារីដែរ កុមារីក៏អាចគោះស្គរពិរោះ ដូចដែលកុមារាធ្វើបានដែរ។ល។
- ✓ លើកទឹកចិត្តឱ្យកុមារាបានចូលរួមធ្វើសកម្មភាព តុបតែងលម្អផ្សេងៗ ជាមួយកុមារី ហើយបង្ហាត់បង្រៀនកុមារា ឱ្យមានទំនុកចិត្តក្នុងការតុបតែងលម្អដូចកុមារីដែរ។
- ✓ លើកទឹកចិត្តកុមារឱ្យចេះជួយគ្នាទៅវិញទៅមកដោយមិនប្រកាន់ថា កុមារីឬកុមារានោះទេ។
- ✓ ឧស្សាហ៍សង្កេតមើលទង្វើ និងការនិយាយស្តីរវាងកុមារីជាមួយកុមារា ហើយប្រសិនបើមានការរើសអើងមិនគោរពគ្នាទៅវិញទៅមក គ្រូត្រូវពន្យល់បន្ថែមដើម្បីកែលម្អកុមារ។
- ✓ លើកទឹកចិត្ត កុមារនៅពេលដែលកុមារអាចលេងនិងធ្វើសកម្មភាពជាមួយគ្នាដោយមិនមានភាពរើសអើង។

**ឯកសារពិគ្រោះ**


១-. រាជរដ្ឋាភិបាលកម្ពុជា « យុទ្ធសាស្ត្រចតុកោណ » រាជធានីភ្នំពេញ ខែកញ្ញា ឆ្នាំ២០១៨

២-. សិក្សាចិត្តសាស្ត្រសង្គមនៅមត្តេយ្យសិក្សា ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានអប់រំកុមារតូចឆ្នាំ២០២០

៣-. សៀវភៅសិក្សាសង្គមជាភាសាអង់គ្លេស ប្រទេសសឹង្ហបុរី

៤-. កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានអប់រំកុមារតូចឆ្នាំ២០១៨

៥-. តន្ត្រី និងចំរៀងផ្នែកមត្តេយ្យសិក្សាសម្រាប់គ្រូមត្តេយ្យ ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំសិក្សា១៩៩៨-៩៩

៦-. ល្បែងសិក្សាសម្រាប់កុមារ ក្រសួងអប់រំ យុវជន និងកីឡា នាយកបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០០៩

៧-. គំនូរ-ហត្ថកម្ម ក្រសួងអប់រំ យុវជន និងកីឡា នាយកបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំសិក្សា២០០៣

៨-. កសាងសម្ភារសម្រាប់បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា ក្រសួងអប់រំ យុវជន និងកីឡា នាយកបណ្តុះបណ្តាល និងវិក្រឹតការឆ្នាំសិក្សា២០១៣

៩-. ផ្នែកទី១តន្ត្រីឯកសារសម្រាប់បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា ក្រសួងអប់រំ យុវជន និងកីឡា នាយកបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំសិក្សា២០១៣)

១០-. ឯកសារធនធានអភិវឌ្ឍកុមារតូច ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានអប់រំកុមារតូច ខែកុម្ភៈ ឆ្នាំ២០១០

ឧបត្ថម្ភការបោះពុម្ព

PLAN INTERNATIONAL